# វិញ្ញាណទស្សនៈ

ដោយ

ភិក្ខុធម្មបាល ខៀវ-ជុំ

ចម្លងដោយ

ផ្ទះលេខ១៣៦អ៊ិ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

គ.ស.១៩៦៧ ព.ស. ២៥១០



ភិក្ខុ ធម្មបាលោ ខៀវ ជុំ វត្តលង្កា

# បណ្ណាកម្មឧទ្ទិស

សូមឧទ្ទិសនូវកុសលកម្មដ៏ពេញចិត្តនេះ ប្រគេនព្រះវិញ្ញាណនៃព្រះសពសម្តេចព្រះធម្មលិខិត ល្វី ឯម ជាអតីតចៅអធិការវត្តលង្កា ព្រះអង្គជាព្រះឧបជ្ឈាយ៍របស់ខ្ញុំសូមសម្តេច ទទួលនូវកុសល អំពីកូនសិស្សកម្សត់នេះ ហើយសូមសម្តេចមានភពថ្មីក្នុងបច្ចុប្បន្ននេះប្រកបដោយសេចក្តីសុខចម្រើនអស់កាលជានិរន្តរ៍ ៕

ខៀវ ជុំ

# អារម្ភកថា

ដោយខ្ញុំយល់ឃើញថា វិញ្ញាណជាធម្មជាតិសម្រាប់ទាក់ទងមួយ បុណ្យបាបជាប្រធាននៃបុណ្យបាប ជាអង្គធាតុធ្វើឱ្យបុណ្យនិងបាបមានគុណភាព និងទោសភាពខុស ប្រក្រតីជាពិសេសនាមធាតុសម្រេចឱ្យកើតជាបុណ្យជាបាបមានភាពលក្ខណៈប្លែកៗ គ្នា។ ហើយក្នុងទីបំផុតវិញ្ញាណនេះ ក៏ត្រូវបានទទួលឈ្មោះថា **"វិញ្ញាណអនិទស្សនៈ"** ក្នុងព្រះនិព្វានក្នុងបច្ឆិមជាតិ។ ដូចនេះ ទើបខ្ញុំសរសេរសៀវភៅនេះក្នុងបំណងចង់ឱ្យអ្នកគិតគូរអំពីរឿងវិញ្ញាណ ដែលជាធាតុសំខាន់ដើរតួក្នុងរឿងបុណ្យបាប និងក្នុងរឿងនិព្វានបានស្គាល់វិញ្ញាណតាមសេចក្ដីពិតប្រាកដ ។

ក្នុងកាលណាមនុស្សយើង បានស្គាល់វិញ្ញាណច្បាស់លាស់ហើយក្នុងកាលនោះ កិច្ចការដែលខ្លួនត្រូវធ្វើក៏កាន់តែល្អប្រសើរឡើង ។ ចំណែកខាងបរលោកឬអនាគតជាតិឬ និព្វានដែលមនុស្សទាំងឡាយខ្លះ បានបោះបង់ចោលលែងនឹកនាទៅហើយនោះ គេទាំងឡាយក៏មុខជាមិនខានវិលមកគិតគូរជាថ្មីវិញទៀតឡើយ។ ខ្ញុំសូមរំលឹកអ្នកអានថា សៀវភៅនេះមានសេចក្ដីជ្រាលជ្រៅបន្តិចហើយ ក្នុងពេលលើកសៀវភៅនេះអានម្ដងៗ សូមអានឱ្យបានគ្រប់ពាក្យ សង្កេតរឿងក្នុងអត្ថបទមួយៗ ឱ្យបានល្អិតស្អន់ ចាំរឿងទាំងអស់ឱ្យបានល្អទើបអាចយល់បាន ។

សៀវភៅនេះខ្ញុំឱ្យឈ្មោះថា **"វិញ្ញាណទស្សនៈ"** ដែលកាលអំពីមុននោះ (**កាលបោះពុម្ពនិព្វានទស្សនៈ**) ខ្ញុំបានឱ្យដំណឹងក្នុងអារម្ភបទថានឹងបោះពុម្ពសៀវភៅនោះម្ដងទៀតជាលើកទី២ ដោយមានបន្ថែមអត្ថបទទាំងឡាយមកទៀត ឬនឹងបោះពុម្ពនិព្វានទស្សនៈភាគទី២ ឥឡូវនេះហេតុដូចម្ដេចបានជាខ្ញុំមិនឱ្យសៀវភៅនេះឈ្មោះនិព្វានទស្សនៈ ភាគទី២ ឬនិព្វានទស្សនៈពិស្ដារ? ព្រោះខ្ញុំមានយោបល់ថា អត្ថបទក្នុងសៀវភៅនេះ មាននិយាយអំពីរឿងនិព្វានត្រឹមបន្តិចបន្តួច តែមាននិយាយអំពីរឿងវិញ្ញាណ ដែលដើរតួជាសំខាន់ក្នុងការងារសម្រាប់លោកិយនិងការងារសម្រាប់លោកុត្តរជាច្រើន ទើបខ្ញុំឱ្យឈ្មោះថា **"វិញ្ញាណទស្សនៈ"** វិញ ។

អ្នកអានទាំងឡាយ សូមកត់សំគាល់នូវសៀវភៅទាំងពីរ គឺនិព្វានទស្សនៈ និង

វិញ្ញាណទស្សនៈនេះថាជាសៀវភៅតែមួយ ត្រូវរៀន ត្រូវអានជាមួយគ្នា ឬថាជាសៀវភៅមានរឿងដូចគ្នា តែមានឈ្មោះពីរដើម្បីគ្រាន់ជាកិច្ចទាញអារម្មណ៍ ឬផ្លាស់អារម្មណ៍របស់អ្នកអានក្នុងពេលបានឃើញឈ្មោះប៉ុណ្ណោះ ។

ក្នុងទីបំផុតនេះ ខ្ញុំសូមឧទ្ទិសនិពន្ធកុសលដែលកើតឡើងដោយចេតនាបរិសុទ្ធនេះ ជូនចំពោះពុទ្ធបរិស័ទទាំងអស់ សូមទទួលយកនូវចំណែកបុណ្យនេះ ហើយសូមឱ្យបានសម្រេចនូវសេចក្ដីសុខ ចម្រើនតាម សេចក្ដីប្រាថ្នារៀងៗខ្លួន ។ ជាពិសេសសូមឧទ្ទិសថ្វាយចំពោះសម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះប្រមុខរដ្ឋ សូមកម្លាំងនៃកុសលនេះជួយទ្រទ្រង់ព្រះអង្គឱ្យបានសម្រេចនូវសេចក្ដីបរមសុខ មានព្រះទីឃាយុយឺនយូរអស់រយនៃវស្សា ដើម្បីបានជាទីជម្រកនៃប្រជាជាតិអស់កាលយូរអង្វែងទៅ ។

សូមអ្នកអានជាមិត្តនិងជាអមិត្តទាំងឡាយរបស់ខ្ញុំ បានសម្រេចនូវជ័យជំនះលើសេចក្ដីងងឹត លើកិលេសតណ្ហា ទាំងអស់កុំបីអាក់ខានឡើយ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែមករា

ព.ស. ២៥០៩

គ.ស. ១៩៦៧

ភិក្ខុធម្មបាលោ

**ខៀវ-ជុំ**

វត្តលង្កា

សង្កាត់លេខ ៦

★ ★ ★

# វិញ្ញាណគឺជាអ្វី?

ដើម្បីដឹងថាអ្វីជាវិញ្ញាណ យើងត្រូវសិក្សាអំពីបដិច្ចសមុប្បាទ ។ ប៉ុន្តែការសិក្សាអំពីបដិច្ចសមុប្បាទ តាមលំដាប់នៃមេសូត្រមុនសិក្សាអំពីវិញ្ញាណ ជាការនាំឱ្យលំបាកចូលចិត្តណាស់។ ដូច្នេះយើងត្រូវសិក្សាអំពីរឿងវិញ្ញាណជាមុន ហើយទើបសិក្សាអំពីបដិច្ចសមុប្បាទតាមលំដាប់នៃមេសូត្រជាក្រោយ ព្រោះវិញ្ញាណដើរជាតួឯកក្នុងបដិ-ច្ចសមុប្បាទ។ តែការសិក្សាអំពីរឿងវិញ្ញាណឱ្យបានចូលចិត្តងាយតាមសេចក្តីដៅនៃពុទ្ធសាសនានោះ ការចាំបាច់ត្រូវសិក្សាអំពីសេចក្តីដៅនៃពាក្យថា ធម្មជាតិនិងរឿងនៃព្រះអាទិទេពផង ព្រោះរឿងទាំងពីរនេះមានលក្ខណៈស្រដៀងៗគ្នា នឹងរឿងវិញ្ញាណក្នុងពុទ្ធសាសនា កាលណាបានចូលចិត្តរឿងទាំងពីរនេះក៏និងបានចូលចិត្តរឿងវិញ្ញាណក្នុងពុទ្ធសាសនាយ៉ាងជ្រៅជ្រះ ហើយងាយបំផុតផង ។

កាលណានិយាយដល់វិញ្ញាណ ជនទូទៅច្រើនឹកឃើញដល់ភាពនៃខ្មោចបីសាចដែលអាចមកសម្តែងខ្លួនឱ្យមនុស្សឃើញបាន ដូចជាគេធ្លាប់និយាយថា ព្រលឹង(វិញ្ញាណ) របស់បុគ្គលស្លាប់ទៅ មកសម្តែងរូបឱ្យកូនចៅរបស់ខ្លួនឃើញ ឬវិញ្ញាណរបស់អ្នកស្លាប់មកដើរក្នុងផ្ទះ បានឮសូរដូចមនុស្សដើរ ខ្លះក៏និយាយថា មកធ្វើសំឡេងប្លែកៗឱ្យកូនចៅឮ ឬជួនកាលក៏មកបញ្ជូលចិត្តកូនចៅ ដែលកំពុងដេកលក់ឱ្យយល់សប្តិឃើញរឿងផ្សេងៗ ដូច្នេះជាដើម។ តែតាមសេចក្តីពិតបើខ្មោចដែលយើងបានឃើញរូបឬដែលបានឮសំឡេងនោះមានមែននោះក៏មិនមែនជាវិញ្ញាណទេ តែជាជីវិតប្រភេទមួយផ្សេងទៀត នៅក្នុងពួកឧបបាតិកកំណើត ដែលជាជីវិតកើតស្រេចហើយ ពោលគឺមនុស្សនោះស្លាប់ហើយទៅកើតជាខ្មោច រូបរាងរបស់ខ្មោចនោះ ជាវត្ថុធាតុដែលកើតឡើងចាកការបណ្តាលនៃវិញ្ញាណរបស់មនុស្សស្លាប់ ចំណែកវិញ្ញាណសុទ្ធៗ មែនៗ នោះយើងមើលពុំឃើញឡើយ ។

វិញ្ញាណតាមសេចក្តីដៅរបស់ពុទ្ធសាសនា ទោះជាដោយកលវិធីណាៗក៏ដោយវិញ្ញាណនឹងមកប្រាកដឱ្យយើងឃើញដោយភ្នែកពុំបានទេ។ តាមមតិពុទ្ធសាសនា វិញ្ញាណគឺជាថាមពល ឬជាអំណាចមួយបែបដែលមាននៅក្នុងជីវិតគ្រប់ប្រភេទ។ ពុទ្ធសាសនាបាននិយាយថា ជីវិតរបស់មនុស្សយើងប្រកបដោយធាតុ៦គឺ ដី ទឹក ភ្លើង

ខ្យល់ អាកាសនិង វិញ្ញាណ។ វិញ្ញាណជាធាតុមួយបែបទៀតក្រៅអំពីធាតុទាំង៤និង អាកាសធាតុ។ វិញ្ញាណជានាមធម៌ មេត្តាគិតឱ្យចូលចិត្តពាក្យថា "**ធាតុ**" ធាតុពុទ្ធសាសនាដៅដល់ថាមពលផងដែរ។ ចូរសង្កេតថា កំដៅទូទៅក្នុងពិភពលោកក៏ហៅថាធាតុ។ អាកាសគឺទីវាលទទេក៏ហៅថាធាតុ។ ពាក្យថា "**ធាតុ**" ពុទ្ធសាសនាដៅដល់របស់ដែលមាននៅដោយធម្មតា ដោយមិនមានអ្នកណាសាង មិនមានអ្នកណាជាម្ចាស់ ទោះជាវត្ថុឬជាថាមពលក៏ហៅថាធាតុដូចគ្នា ពាក្យថា "**នាមធម៌**" សំដៅយករបស់ដែលមិនអាចនឹងសម្ផស្ស (**ចាប់ពាល់**) បានដោយប្រាសាទទាំង៥ នាមធម៌គឺវិញ្ញាណនេះមាននៅរាល់ៗកោសិកាជីវិត ជាបច្ច័យសំខាន់ក្នុងការធ្វើឱ្យកើតព្រឹត្តិកម្មផ្សេងៗរបស់កោសិកា (**ឆ្អែងជីវិត**) សឹងមានន័យមានរបៀបគ្រប់គ្រង ធ្វើឱ្យកិច្ចការនៃកោសិកា មានដំណើរប្រព្រឹត្តទៅយ៉ាងមានរបៀបរៀបរយ ធ្វើឱ្យកោសិកាទ្រទ្រង់នូវជីវិតបាន ចម្រើនធំធាត់បានធម្មធាតុនេះហើយដែលពុទ្ធាសាសនាហៅថា "**វិញ្ញាណ**"។

ដើម្បីឱ្យអ្នកអានបានចូលចិត្តកាន់តែច្បាស់អំពីរឿងវិញ្ញាណ ក្នុងពុទ្ធសាសនា ខ្ញុំសូមឱ្យអ្នកអានសិក្សារឿងនេះ ចាកសេចក្តីពិតដូចតទៅនេះ ÷

កាលណាយើងសម្លឹងមើលជីវិតរបស់យើង របស់បុគ្គលដទៃៗរហូតដល់របស់សត្វ និងរបស់ពីជៈ[1] ទាំងឡាយយើងនឹងបានជួប្រទះនូវសេចក្តីពិតមួយថាចំណែកផ្សេងៗ ដែលបានរួមគ្នាជាអង្គាវយវៈនៃជីវិតនោះៗ របស់មួយៗ ក៏បានកើតមកដោយមានន័យ មានសេចក្តីដៅទាំងអស់។ សក់កើតមកសម្រាប់ធ្វើអ្វី? រោមកើតមកសម្រាប់ធ្វើអ្វី? ក្រចកកើតមកសម្រាប់ធ្វើអ្វី? ។ល។ សំនួរនេះអ្នកសរីរសាស្ត្រអាចឆ្លើយបានយ៉ាងច្បាស់លាស់ជាមិនខាន។ បើសរុបសេចក្តីទៅ ក៏អាចឱ្យឃើញបានថារបស់មួយៗកើតមកដើម្បីប្រយោជន៍អ្វីមួយ ហើយមិនចំពោះតែជីវិតរបស់មនុស្សប៉ុណ្ណោះទេ ចំណែកផ្សេងៗនៃសត្វនៃពូជក៏កើតឡើង ក្នុងមានបំណង មានន័យមួយៗដូចគ្នា ។ ទីបំផុតសូម្បីតែចំណែកប្រកបចូលក្នុងកោសិកាក៏កើតឡើងមានន័យ មានសេចក្តីដៅទាំងអស់គឺកាលណាបើយើងបានសរុបសេចក្តីពិតនេះហើយធ្វើ ការស្រាវជ្រាវ វែកញែកជាថ្មីទៀតនោះយើងក៏អាចបញ្ជាក់ដោយ សេចក្តីក្លាហានបានថាជីវិតទាំងឡាយកើតឡើងយ៉ាងមានន័យជាប្រាកដ ។

[1] ពីជៈ ធ្លាប់ប្រើមកជាពូជ បានដល់រុក្ខជាតិគ្រប់ប្រភេទ ។

កាលណាយើងដឹងថា ជីវិតកើតឡើងយ៉ាងមានន័យដូចនេះ យើងក៏អាចដឹងបានទៀតថា អំណាចដែលសាងជីវិតនេះ ត្រូវជាអំណាចមួយដែលមានចេតនា ហើយត្រូវ ជាអំណាចដែលមានរបៀបរៀបរយជាទីបំផុតព្រោះចំណែកផ្សេងៗរបស់រូបកាយដែលកើតឡើងរួមគ្នាជាជីវិតមួយៗនោះមានច្បាប់ឃុំគ្រងរក្សាយ៉ាងល្អឥតខ្ចោះ ប្រកបដោយរបៀបយ៉ាងប្រសើរមិនងាយអ្នកណានឹងធ្វើតាមកើត។ ពិតជាងនេះទៅទៀតនោះ គឺជីវិតថ្លៃថ្នូរ ដូចយ៉ាងជីវិតមនុស្ស ជីវិតនេះមានសេចក្តីប្រណិតជាទីបំផុត មានអាថ៌កំបាំងយ៉ាងច្រើនបំផុត ។ យើងក៏រៀនដឹងទៀតថា អំណាចដែលសាងជីវិតនោះត្រូវជាអំណាចមានសេចក្តីប្រណីតជាទីបំផុត មានបញ្ញាអាថ៌កំបាំងយ៉ាងច្រើនបំផុតទើបសាងជីវិតនេះបាន ដូចជាជាងសំណង់ដែលមានថ្វីដៃយ៉ាងប្រណីត មានបច្ចេកទេសយ៉ាងល្អ បានធ្វើឱ្យសំណង់របស់ខ្លួនបានល្អដូច្នោះដែរ ។

ព្រោះហេតុថាជីវិតមានការប្រែប្រួលរាល់ខណៈ តែការប្រែប្រួលនោះក៏ជាការប្រែប្រួលដើម្បីរក្សាទុកនូវបែបបទរបស់ជីវិត គឺរក្សាទុកឱ្យបានគង់ទ្រង់ឬឱ្យបានមាំមួនដូចរូបកាយមនុស្សយើង មានការប្រែប្រួលរាល់ខណៈចាប់អំពីផ្តើមកើតរហូតដល់ស្លាប់។ បើយើងសង្កេតមើលឱ្យជ្រៅដល់ការប្រែប្រួលខាងក្នុងរបស់កោសិកា យើងនឹងដឹងថា អំណាចមួយដែលឃុំគ្រងការប្រែប្រួលនោះ ជាអំណាចមានសេចក្តីខ្លាំងពូកែពិតៗ ព្រោះវាព្យាយាមរក្សាទុកនូវបែបបទរបស់ជីវិតឱ្យនៅក្នុងលក្ខណៈនោះៗបានមាំមួនបំផុត ដូចជាមនុស្សយើង សូម្បីរូបកាយប្រែប្រួលរហូតដល់ទៅចាំមិនបានស្គាល់មិនជាក់ តែរូបជាលក្ខណៈនៃភាពជាមនុស្ស ត្រូវគង់នៅជាមនុស្សដូចដើមជាដរាបមិនក្លាយជាសត្វឬទៅជាអ្វីដទៃបានទេ ។ ដូច្នេះទើបយើងដឹងថា អំណាចដែលសាងជីវិតនេះ ត្រូវជាអំណាចមួយដែលខ្លាំងពូកែហើយរឹងប៊ឹងជាទីបំផុត ។

សេចក្តីពិតរបស់ជីវិតមានមកយ៉ាងនេះឯង ដោយអាស្រ័យសេចក្តីពិតនេះ ធ្វើឱ្យយើងរឹតតែចូលចិត្តថា អំណាចដែលសាងជីវិតនោះមានប្រាកដ អ្នកណានឹងបដិសេធថា អំណាចនេះមិនមានពុំបានជាដាច់ខាត ហើយយើងអាចបញ្ជាក់ទៀតថាអំណាចនេះត្រូវជានាមធម៌ ព្រោះយើងមើលនឹងភ្នែកពុំឃើញចាប់ដោយដៃពុំបានឡើយ។ អំណាចនេះជនក្នុងលទ្ធិខ្លះដៅទៅលើ "**ធម្មជាតិ**" ជនក្នុងលទ្ធិខ្លះថាទៅលើ "**អាទិទេព**" តែខាងពុទ្ធសាសនាថាទៅលើ "**វិញ្ញាណ**" ។ តទៅយើងនឹងវិនិច្ឆ័យថាតើ

មតិទាំងអស់នេះ មតិណាខុសមតិណាត្រូវ? ឬជាសេចក្តីដៅចំពោះអំណាចនោះនៃពុទ្ធសាសនាទៅលើវិញ្ញាណជាសេចក្តីដៅត្រូវពិតឬមិនពិត ?

បឋមកំណើតនៃមនុស្សគឺជាចំណុចតូចមួយ សម្លឹងមើលដោយភ្នែកទទេស្ទើរតែពុំឃើញ ចំណុចតូចនេះ ខាងពេទ្យហៅថា "**ហ្សីគុត៍**" (zygote) ឬ "**ហ្វេទីលើហ្សេដ៍អេគគ៍**" (fortilized egg) គឺជាដំណក់ពពុះដែលផ្សំលាយ ដោយអសុចិនៃបុរស ហើយកំពុងរីកចម្រើនទៅជារូបមនុស្សតាមលំដាប់។ ចំណែកពុទ្ធសាសនាហៅថា "**កលលៈ**" កលលគឺជារូបធាតុដែលមានជីវិតរីកចម្រើនឡើង ដោយអាហារដែលម្តាយបរិភោគ ។ អាហារក្នុងទីនេះសំដៅយកលោហិតរបស់ម្តាយដូចគ្នានឹង ដើមឈើដែលដុះចេញអំពីគ្រាប់ ហើយរីកចម្រើនឡើងដោយអាហារដែលវាស្រូបចូលទៅតាមឫសរបស់វានោះដែរ។ មានបញ្ហាចោទឡើងថា ខាងពុទ្ធសាសនា ព្រមទទួលស្គាល់ថានៅខាងក្នុងកលលៈនេះ មានវិញ្ញាណមកចាប់បដិសន្ធិហើយឬនៅឡើយទេ? បញ្ហានេះជាបញ្ហាសំខាន់បំផុត បើយើងចូលចិត្តបញ្ហានេះ យើងក៏អាចនឹងចូលចិត្តសេចក្តីដៅនៃវិញ្ញាណ តាមល័ខពុទ្ធសាសនាយ៉ាងជ្រៅជ្រះ នឹងយ៉ាងត្រឹមត្រូវតាមសេចក្តីពិត រហូតដល់រឿងអាថ៌កំបាំងផ្សេងៗ ដែលជាប់ទាក់ទងជាមួយវិញ្ញាណក៏អាចចូលចិត្តបានពុំខានឡើយ ។

★ ★ ★

# វិញ្ញាណក្នុងបឋមបដិសន្ធិ

ជីវិតកាលទើបនឹងកើតថ្មីៗ សឹងនៅជាកលលៈនោះមានវិញ្ញាណមកបដិសន្ធិហើយឬនៅ? ចំពោះបញ្ហានេះព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងជាមួយអានន្ទថា?

អានន្ទ! យើងបាននិយាយហើយថា :

**"វិញ្ញាណជាបច្ច័យឱ្យកើតនាមរូប"** សេចក្តីនេះអ្នកយល់យ៉ាងណា?

អានន្ទ! ប្រសិនណាបើវិញ្ញាណ មិនចូលកាន់ផ្ទៃម្តាយ ទារកនឹងកើតក្នុងផ្ទៃបានឬទេ ? សូមសង្កេតថា តាមពុទ្ធភាសិតនេះសម្តែងថា វិញ្ញាណដែលធ្វើឱ្យទារកកើតនោះ មិនបានបែកចេញមកអំពីវិញ្ញាណរបស់មាតាបិតាតាមផ្លូវនៃអវយវៈផ្សំពន្ធ័នឹងដំណក់ស៊ុត ដែលពេទ្យហៅថា (geem cell ទេ) **"មិនបានទេ ព្រះករុណាម្ចាស់ខ្ញុំ"** (ព្រះអានន្ទទូលតប) បើវិញ្ញាណចូលកាន់ផ្ទៃម្តាយហើយ ត្រឡប់ចេញទៅវិញ តើនាមរូបកើតបានឬទេ ?

(បើវិញ្ញាណមកបដិសន្ធិក្នុងផ្ទៃម្តាយហើយ ត្រឡប់ចុតិទៅវិញតើទារកនឹងកើតក្នុងផ្ទៃម្តាយបានឬទេ ?)

**"មិនបានទេ ព្រះករុណាម្ចាសខ្ញុំ"** (ព្រះអានន្ទទូលតប)

អានន្ទ! បើវិញ្ញាណចុតិទៅវិញ ក្នុងរវាងដែលទារកស្ត្រីឬបុរសនៅតូចៗ តើនាមរូបនឹងរីកចម្រើនបានឬទេ? (គឺទៅជាមនុស្សមានវ័យចាស់បានឬទេ ?)

**"មិនបានទេ ព្រះករុណាម្ចាស់ខ្ញុំ"** (ព្រះអានន្ទទូលតប)

**"អានន្ទ! ព្រោះហេតុនេះឯង វិញ្ញាណទើបបានឈ្មោះថាជាហេតុ, ជានិទាន, ជាសមុទ័យ, ជាបច្ច័យរបស់នាមរូប"**

**មហានិទានសូត្រ ទី.មហា-**

សេចក្តីក្នុងព្រះសូត្រនេះ ខ្ញុំបានព្យាយាមប្រែឱ្យត្រូវតាមសេចក្តីដៅដើមនៃគម្ពីរផងនៃពាក្យអធិប្បាយក្នុងអត្ថកថាដែលបានបកប្រែតៗ គ្នាមកផង មើលពាក្យប្រែរបស់សាស្ត្រាចារ្យ **រិសដេវិដស៍** ដែលគេនិយាយថាជាបុគ្គលម្នាក់ ចេះប្រែបាលីទៅជាភាសាអង់គ្លេសបានល្អផង ព្រោះពាក្យក្នុងឃ្លានេះមានសេចក្តីសំខាន់ ក្នុងការបញ្ជាក់ឱ្យឃើញនូវសេចក្តីដៅឬនូវន័យរបស់វិញ្ញាណបានយ៉ាងល្អបំផុត ។

# វិញ្ញាណជាបច្ច័យឱ្យកើតនាមរូប

ក្នុងបឋមជីវិត មានវិញ្ញាណមកបដិសន្ធិហើយឬនៅ? យើងអាចរកពាក្យតប យ៉ាងល្អចាកព្រះសូត្រនេះ តែដើម្បីឱ្យចូលចិត្តរឿងនេះរិតតែល្អឡើង យើងគួរសិក្សា ដោយចំណុចថា "**វិញ្ញាណជាបច្ច័យឱ្យកើតនាមរូប**" នោះម្តងទៀត ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា :

"ភិក្ខុទាំងឡាយ! ក្នុងចំណុចថាវិញ្ញាណជាបច្ច័យឱ្យកើតនាមរូបនោះ វិញ្ញាណ ក្នុងទីនេះដៅយកអ្វី? នាមដៅដល់អ្វី? រូបដៅទៅលើអ្វី?

ភិក្ខុទាំងឡាយ! វិញ្ញាណ៦នេះគឺ : ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណនឹងមនោវិញ្ញាណ វិញ្ញាណ៦នេះឯង ភិក្ខុទាំងឡាយ! យើង ពោលថាជាបច្ច័យឱ្យកើតនាមរូប ។

វេទនា សញ្ញាណ ចេតនា ផស្ស មនសិការៈ ធម្មជាតុប៉ុណ្ណេះជាដើមហៅថា "**នាម**" ។

មហាភូតរូប៤ នឹងឧបាទាយរូប គឺរូបដែលកើតឡើងព្រោះអាស្រ័យមហាភូតរូប ៤ ទាំងអស់នេះហៅថា "**រូប**" ។

នាមនឹងរូបទាំងអស់នេះ ភិក្ខុទាំងឡាយ! យើងពោលថាកើតឡើងព្រោះ វិញ្ញាណ មានវិញ្ញាណជាបច្ច័យ បើវិញ្ញាណមិនមាន នាមនឹងរូបទាំងអស់នេះរមែងមាន ពុំបានឡើយ" ។

"**វិញ្ញាណ**" ដោយន័យប្រែថា "**សេចក្តីដឹងទូទៅ**" ឬ "**ធម្មជាតិសម្រាប់ទទួល ដំណឹងផ្សេងៗ**" ។ ដោយកំណើតស័ព្ទមកអំពីពាក្យថា "**វិ**" ប្រែថា វិសេស ច្បាស់ ផ្សេងៗ "**ញាណ**" ប្រែថាសេចក្តីដឹង (វិ + ញាញ តម្រួតញ សម្រេចរូបជាវិញ្ញាណ)។

វិញ្ញាណធាតុប្រែថា ធាតុដឹង (ធាតុសម្រាប់ទទួលដំណឹង) ធាតុនេះបានឈ្មោះ ថា ធាតុវិញ្ញាណ ក៏ព្រោះជាធាតុដែលអាចដឹងអ្វីៗ បានយ៉ាងវិសេសមានប្រាកដ ការណ៍ជាសេចក្តីដឹងបានច្រើនទ្វារច្រើនផ្លូវ គឺដឹងតាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយនឹងតាមខួរក្បាល។ វិញ្ញាណដែលចែកចេញជា ៦ នោះគឺ លោកចែកទៅតាមអាយតនៈខាងក្នុង ៦ នុ៎ះឯង "**អាយតនៈ**" ប្រែថាទីកើតឬទីតភ្ជាប់

ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយនឹងខួរក្បាល ឈ្មោះថាអាយតនៈ ក៏ព្រោះជាទីកើតនៃវិញ្ញាណ ជាទីធ្វើឱ្យវិញ្ញាណធាតុមានប្រាកដការណ៍ចេញមក ជាការឃើញ ការបានឮ ការស្គាល់ក្លិន ការដឹងរស ការដឹងសម្ផស្ស និងធ្វើឱ្យមានប្រាកដការណ៍ចេញមកជាសេចក្ដីនឹកគិត ហើយជាពិសេសគឺជាទីសម្រាប់ជាមួយរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ។

ពាក្យថា "**នាម**" តាមកំណើតស័ព្ទ ប្រែថាធម្មជាតិ ឱនទៅតាមអារម្មណ៍ មានវិគ្រោះសព្ទដូចនេះ ÷

នមតីតិ = នាមំ ប្រែថាធម្មជាតិណាវមែងឱនទៅ គឺងាករេទៅ (តាមអារម្មណ៍) ធម្មជាតិនោះឈ្មោះថា "**នាម**" មកអំពីមនៈធាតុ ក្នុងអត្ថថាឱនទៅ ។

មេត្តាសង្កេតថា ពាក្យថា "**នាម**" ក្នុងទីនេះមិនត្រូវប្រែថា "**ឈ្មោះ**" ដូចមាននិយាយក្នុងវេយ្យាករណ៍ទេ គឺត្រូវប្រែថា ឱនទៅឬរេទៅតាមអារម្មណ៍។ ព្រះសម្មាសម្ពុទ្ធបានឱ្យតួយ៉ាង ៥ គឺ : វេទនា សញ្ញា ចេតនា ផស្សៈ នឹងមនសិការៈ ដើម្បីឱ្យយើងបានស្គាល់នាមយ៉ាងសង្ខេបល្មមធ្វើជាមេគំនិតបណ្ដោះអាសន្នសិនប៉ុណ្ណោះ ការពិតធម្មធាតុដែលជានាម សឹងកើតចាកវិញ្ញាណជាបច្ច័យនោះមានច្រើនណាស់ដែលខ្ញុំនឹងនិយាយខ្លះទៀតទៅក្នុងខាងមុខ ។

មហាភូតរូប ប្រែថា រូបដែលប្រាកដឡើងក្នុងលក្ខណៈផ្សេងៗបានច្រើនបែបមកអំពីពាក្យថា មហា+ភូត+រូប "មហា" ប្រែថា "ធំ" ឬ "ច្រើន" "ភូត" ប្រែថា "កើតឬប្រាកដ" "រូប" ប្រែថា "រូប" មហាភូតរូបទើបត្រូវប្រែថា រូបដែលប្រាកដជាអ្វីៗ បានច្រើនយ៉ាង ។

"**មហាភូតរូប**" បានដល់ធាតុទាំងបួនគឺ : ដី ទឹក ភ្លើង ខ្យល់ ។ យើងដឹងហើយថា រូបធាតុផ្សេងៗក្នុងលោក ទោះមានជីវិតឬមិនមានជីវិតក៏ដោយ សុទ្ធតែកើតមកចាកធាតុទាំង ៤ ។ ធាតុ៤ បានឱ្យកំណើតមនុស្សសត្វ ដើមឈើនឹងវត្ថុផ្សេងៗ ដោយអាស្រ័យពឹងផ្អែកលើវិញ្ញាណធាតុ ហើយអំណាចនៃវិញ្ញាណធាតុនេះក៏បានធ្វើឱ្យវត្ថុធាតុមានជីវិតកើតតៗ មកមិនមានទីបំផុត ។

យើងគួរសិក្សាអំពីរឿង "**ធាតុ**" ក្នុងពុទ្ធសាសនាឱ្យបានចូលចិត្តល្អព្រោះតាមប្រក្រតី កាលណានិយាយដល់ពាក្យថាធាតុ អ្នកដែលធ្លាប់រៀនវិទ្យាសាស្ត្រ រមែងចូល

ចិត្តថាធាតុនេះដៅដល់ រូបធាតុដែលមានអណ្ហូដូចគ្នាឬសុទ្ធតែមានអណ្ហូនៅរួមគ្នាយ៉ាងច្រើនៗ រូបកាយរបស់មនុស្សយើង បើតាមមតិពុទ្ធសាសនាក៏មិនមែនមានត្រឹមតែធាតុ ៤ តែមានទាំងអស់ចំនួន ១៨ធាតុដែលពុទ្ធសាសនានិយាយដល់ ដី ទឹក ភ្លើង ខ្យល់ ថាជាធាតុនោះ ការពិតរបស់អស់ទាំងនេះ មិនមែនជាធាតុសុទ្ធៗ មួយមុខៗទេ ដីមានចំណែកប្រកបដោយធាតុច្រើនយ៉ាងទឹកនឹងខ្យល់ក៏ដូចគ្នា សុទ្ធតែមានចំណែកប្រកបដោយធាតុច្រើនៗ យ៉ាង។ ចំណែកខាងភ្លើងមិនមែនជាធាតុទេ គឺជាថាមពលមួយបែបតែពុទ្ធសាសនាបានសង្គ្រោះចូលក្នុងធាតុដែរ ។

សេចក្តីពិត ពាក្យថាធាតុដែលមាននិយាយក្នុងគម្ពីរពុទ្ធសាសនានឹងតម្រាវិទ្យាសាស្ត្រខាងគីមីនោះ មានសេចក្តីដៅមិនដូចគ្នាទេ ធាតុតាមសេចក្តីដៅរបស់ពុទ្ធសាសនា សំដៅយករបស់ដែលកើតឡើងតាមធម្មតា មាននៅដោយធម្មតា មិនមានអ្នកណាសាង គឺមិនមានទាក់ទងជាមួយព្រះអាទិទេព មិនមានអ្នកណាជាម្ចាស់ មិនមានខ្លួនប្រាណ ដូចទឹកដីជាដើម។ ក្នុងគ្រិស្តសាសនា គេចូលចិត្តថា ធាតុទាំងឡាយពីដំបូងឡើងមិនមានទេ តែព្រះអាទិទេពបានសាងឡើង ទើបមានជាខាងក្រោយ។ ចំណែកពុទ្ធសាសនាបានទុកដាក់ថា ធាតុទាំងឡាយជារបស់មាននៅដោយធម្មតា។ ពិតមែនតែវត្ថុទាំងឡាយ សុទ្ធតែកើតអំពីហេតុតែមូលហេតុដែលធ្វើឱ្យកើតដីឬទឹកជាដើមនោះមានច្រើនយ៉ាង ហេតុទាំងអស់នេះក្នុងហេតុមួយៗ បានទាក់ទងជាប់តគ្នារដឹកដូចកាំច្រវាក់ដែលយើងគួររៀនឱ្យដឹងថា វាមានមកយ៉ាងម៉េច? វាកើតមកយ៉ាងណា? វាទាក់ទងគ្នាដូចម្តេច? ចំពោះចំណោទនេះ គ្រិស្តសាសនិកគេឆ្លើយថា វត្ថុធាតុទាំងអស់ កើតមកអំពីព្រះអាទិទេព មានព្រះអាទិទេពជាដើមហេតុ គឺហេតុទាំងឡាយបានចប់ត្រឹមអាទិទេពនុ៎ះឯង ។ ចំណែកពុទ្ធសាសនា បានទទួលដឹងថា ហេតុទាំងឡាយមិនមានទីបំផុតទេ ព្រោះហេតុចេះតែមានជាប់តៗ គ្នាមិនមានដាច់ ជំនឿថាអាទិទេពជាដើមហេតុនោះ ជាជំនឿនៅក្នុងដំណើរមានការប្រែប្រួល មិនទាន់ដល់ទីបំផុតទេ ព្រោះជំនឿនេះ មិនអាចនឹងធ្វើឱ្យបាត់នូវសំនួរថា តើព្រះអាទិទេពកើតមកអំពីណា? តែយ៉ាងណាក៏ដោយចុះ រឿងធាតុនេះកាលណាយើងពិចារណាដេកដោលគ្នាឱ្យដល់ទីបំផុតទៅ ក៏មិនឃើញមានអ្វីក្រៅពីទទេ គឺជារបស់កើតឡើងហើយរលត់ទៅ រលត់ទៅហើយកើតឡើងតាមកាលតាមសម័យរបស់មួយៗ ពុំអាចតាំងនៅបាន

ដោយមិនមានពឹងអាស្រ័យលើបច្ច័យដទៃៗបានឡើយ ដី ទឹក ភ្លើង ខ្យល់ ក៏នៅក្នុងលក្ខណៈនេះដូចគ្នាទាំងអស់។ ដូច្នេះទើបហៅថាធាតុ ។ រាល់តែដងដែលទ្រង់សម្ដែងអំពីធាតុ ព្រះសម្មាសម្ពុទ្ធទ្រង់មិនដែលភ្លេចឱ្យយើងនឹកដល់ភាព មិនមែនជាខ្លួនប្រាណ មិនជាសភាពទៀងទាត់ ។ ឱ្យយើងដឹងថា របស់នោះៗត្រឹមតែធាតុមិនមែនជាខ្លួនរបស់យើង និងមិនមែនជាខ្លួនវាជាធាតុទាំងឡាយនោះឡើយ នេះជាសេចក្ដីកំណត់សំគាល់នៃធាតុក្នុងពុទ្ធាសាសនា ដូច្នេះទើបមានការកំណត់ព្រំដែននៃសេចក្ដីដៅមិនដូចធាតុក្នុងវិទ្យាសាស្ត្រ ។

ការណ៍ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានកំណត់ធាតុដែលជា ចំណែកវត្ថុឬទាក់ទងដោយវត្ថុត្រឹមតែ ៤ ក៏ដើម្បីឱ្យមនុស្សធម្មតាចូលចិត្តបានងាយៗ ប្រសិនណាបើព្រះអង្គទ្រង់កំណត់ឱ្យមានច្រើនឬទ្រង់ចែកដោយល្អិតជ្រាលជ្រៅដូចគ្នា នឹងវិទ្យាសាស្ត្រនោះជនធម្មតាមិនអាចនឹងរាប់អានពុទ្ធសាសនាបានទេ ។ ការនិយាយថាខ្លួនមនុស្សយើងម្នាក់ៗប្រកបដោយធាតុ ដី ទឹក ភ្លើង និងខ្យល់ ស្ដាប់ចូលចិត្តងាយ អ្នកណាល្ងង់ដល់ថ្នាក់ណាក៏គង់មើលឃើញបាន ។ ម្យ៉ាងទៀតខាងព្រះពុទ្ធសាសនាថ្នាក់ខ្ពស់ទៅទៀតមានការរៀនអំពីរឿងធាតុ ដើម្បីឱ្យស្គាល់ធាតុក្នុងបំណងដើម្បីដោះខ្លួនអំពីធាតុមិនឱ្យធ្លាក់ខ្លួនទៅជាធាតុ[2] នៃវត្ថុ។ ចំណែកខាងវិទ្យាសាស្ត្រមានការរៀនអំពីរឿងធាតុ ដើម្បីស្គាល់ធាតុហើយធ្វើខ្លួនឱ្យធ្លាក់ចុះទៅជាធាតុនៃវត្ថុ ដូចយើងបានឃើញគ្រប់គ្នាសព្វថ្ងៃនេះ ។

★ ★ ★

[2] ធាតុនៃវត្ថុ ពាក្យថាធាតុនៃវត្ថុ ត្រូវនឹងពាក្យមួយទៀតថា ទាសៈនៃវត្ថុ គឺមនុស្សជាតិ ជាខ្ញុំរបស់ធាតុទាំងឡាយ ។

# វិញ្ញាណជាបច្ច័យឱ្យកើតមហាភូតរូបគឺធាតុ៤

**គួរដឹងធាតុ៤ដោយកអ្វីខ្លះ? គម្ពីរអភិធម្មបានឱ្យឮយ៉ាងដូចនេះ ÷**

ធាតុដីបានដល់ សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ ឆ្អឹង សរសៃ សួត បេះដូង ។ល។

ធាតុទឹកបានដល់ប្រមាត់ស្លេស្ម ខ្ទុះ ឈាម ខ្លាញ់ មូត្រ ញើស សំបោ ។ល។

ធាតុភ្លើងបានដល់កំដៅដែលញ៉ាំងរូបកាយឱ្យចម្រើន កំដៅដែលញ៉ាំងរូបកាយឱ្យទ្រុឌទ្រោម ។ល។

ធាតុខ្យល់បានដល់ ខ្យល់ដែលបក់ពីខាងក្រោមឡើងទៅខាងលើ ខ្យល់ដែលបក់ពីខាងលើចុះទៅខាងក្រោម ខ្យល់ក្នុងក្រពះ ខ្យល់ក្នុងពោះវៀន ។ល។

វិញ្ញាណជាបច្ច័យឱ្យកើតមហាភូតរូប ៤ ក៏គឺជាបច្ច័យឱ្យកើតសក់ រោម ក្រចក ។ល។ សូមពិចារណាដោយល្អិតគ្រប់ពាក្យទើបចូលចិត្តសេចក្ដីដៅនៃពុទ្ធភាសិតនេះយ៉ាងជ្រៅជ្រះបាន ។

វិញ្ញាណជាបច្ច័យឱ្យកើតសក់ បើវិញ្ញាណមិនមាន សក់ក៏មិនមាន វិញ្ញាណជាបច្ច័យឱ្យកើតរោម បើវិញ្ញាណមិនមាន រោមក៏មិនមាន។ល។ វិញ្ញាណជាបច្ច័យឱ្យកើតខ្យល់ដកដង្ហើមចេញចូល បើវិញ្ញាណមិន មានខ្យល់ដកដង្ហើមចេញចូលក៏មិនមាន។ ពិចារណាដូច្នេះរឿយៗទៅគង់យល់បាន ប្រសិនបើយើងបានចេះដឹងខាងជីវសាស្ត្រជ្រៅជ្រះនឹងឱ្យនាំយើងកាន់តែឆាប់យល់នូវសេចក្ដីដៅនៃវិញ្ញាណ យ៉ាងប្រសើរពុំខានឡើយ ហើយកុំភ្លេចនឹកត្រឡប់ទៅខាងដើមវិញថា វិញ្ញាណនេះហើយដែលជាបច្ច័យតាក់តែងឱ្យកើតរូបកាយតាំងពីបឋមបដិសន្ធិ សូមតាំងសំនួរខ្លួនឯងថាអំណាចអ្វីដែលធ្វើឱ្យវត្ថុធាតុគីមីក្លាយទៅជាសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ ។ល។ តែដើម្បីឱ្យបានចូលចិត្តសេចក្ដីដៅនៃវិញ្ញាណរឹតតែជ្រៅហើយច្បាស់លាស់ជាងនេះទៅ ទៀតនោះ យើងត្រូវសិក្សាអំពីឧបាទាយរូបផង ។ "**ឧបាទាយរូប**" ប្រែថា រូបដែលកើតឡើងព្រោះអាស្រ័យមហាភូតរូប ៤ មកអំពីពាក្យថា ឧបាទាយ+រូប ឧបាទាយ ប្រែថា "**អាស្រ័យ**" ឧបាទាយរូប ប្រែថា "**រូបដែលអាស្រ័យ**" សំដៅយករូបដែលអាស្រ័យមហាភូតរូបហើយកើត ។ ក្នុងទីនេះពាក្យដែលគួរឱ្យយើងយកចិត្តទុកដាក់ជាពិសេសគឺ

ពាក្យថារូប ព្រោះពាក្យនេះជាគោលនៃវិជ្ជាផង ជាពាក្យមានន័យយ៉ាងទូលំទូលាយផង ។

**"រូប"** តាមកំណើតសព្ទ ប្រែថា **"របស់ដែលរលាយស្លាយទៅ"** លោកបានវិគ្រោះសព្ទថា **រុប្បតីតិ រូបំ សីតុណ្ហាទីវិរោធិបច្ចយេហិ វិការមាបជ្ជតិ** ប្រែថា ធម្មជាតិឯណារមែងរលាយស្លាយទៅពេលគឺដល់នូវសេចក្ដីពិការ ដោយបច្ច័យជាសត្រូវទាំងឡាយមានសេចក្ដីក្ដៅនិងសេចក្ដីត្រជាក់ជាដើម ធម្មជាតិនោះ **"ហៅថារូប"** ។

## -អភិធម្មត្ថវិភាវិនី-

សូមសង្កេតថា កំដៅដែលអ្នកវិទ្យាសាស្ត្រ សង្គ្រោះចូលក្នុងថាមពលនោះព្រះពុទ្ធបរមគ្រូក៏បានចាត់កំដៅនេះថាជារូបធម៌ ក៏ព្រះអង្គ[3] ទ្រង់ត្រាស់ហៅថារូប ។ កាលណាយើងបានពិចារណាមើលតួយ៉ាង ឧបាទាយរូប យើងនឹងឃើញបាននូវសេចក្ដីទូលំទូលាយរបស់រូបជាតួយ៉ាងខ្លះជាមិនខាន ។

**"ឧបាទាយរូប"** គម្ពីរ អភិធម្មឱ្យតួយ៉ាងទុកមកដូចនេះ ÷

ប្រសាទខាងភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយនឹងខួរក្បាល ។ ជីវិតរបស់រូបនឹងលក្ខណៈនៃពេសស្ត្រីពេស[4] បុរស ទាំងអស់នេះហៅថា ឧបាទាយរូបជារូបដែលកើតឡើងព្រោះអាស្រ័យមហាភូតរូប៤ ហើយមានវិញ្ញាណជាបច្ច័យ ។

សម្បុរ សំឡេង ក្លិន និងរស ទាំងអស់នេះលោកហៅថារូបជារូបដែលកើតឡើងព្រោះអាស្រ័យមហាភូត ៤ ហើយមានវិញ្ញាណជាបច្ច័យ ។

ចលនានៃកាយ ចលនានៃវាចា ទាំងអស់នេះក៏ហៅថារូប ជារូបកើតឡើងព្រោះអាស្រ័យមហាភូតរូប៤ ហើយមានវិញ្ញាណជាបច្ច័យ ។

សេចក្ដីស្រាលឬសេចក្ដីរហ័សនៃកាយ សេចក្ដីទន់ភ្លន់ សេចក្ដីស្ទាត់ជំនាញនៃកាយទាំងអស់នេះ ក៏លោកហៅថារូប ជារូបដែលកើតឡើងព្រោះអាស្រ័យមហាភូតរូប៤ ហើយមានវិញ្ញាណជាបច្ច័យ ។

3 (gnze) ពាក្យនេះមានន័យស្រដៀងនឹងពាក្យឧស្ម័នដែរ ។

4 (ពេស) ពាក្យនេះតាមទម្លាប់មកប្រើជាភេទ ។

ការរីកចម្រើន ការតភ្ជាប់ សេចក្ដីចាស់ សេចក្ដីបែកធ្លាយទាំងអស់នេះក៏លោកហៅថារូប ជារូបដែលកើតឡើងព្រោះអាស្រ័យមហាភូតរូប៤ ហើយមានវិញ្ញាណជាបច្ច័យ ។

អាហារសម្រាប់ចិញ្ចឹមរាងកាយ ក៏លោកហៅថារូប ជារូបដែលកើតឡើងដោយអាស្រ័យមហាភូតរូប៤ ហើយមានវិញ្ញាណជាបច្ច័យ ។

-ធម្មសង្គណី-

ការបែងចែកឧបាទាយរូប ក្នុងគម្ពីរធម្មសង្គណី មិនមាននិយាយដល់ហទយវត្ថុទេ ចំណែកខាងគម្ពីរវិសុទ្ធិមគ្គនឹងអភិធម្មត្ថសង្គហមាននិយាយដល់ ។

ក្នុងអភិធម្មសង្គហៈ មាននិយាយដល់ផោដ្ឋព្វៈ ចំណែកវិសុទ្ធិមគ្គនឹងធម្មសង្គណី ពុំបាននិយាយដល់ទេ។ ចាកល័ខឋានទាំងអស់នេះ សម្ដែងឱ្យឃើញថាសូម្បីតែគម្ពីរក៏លោកបែងចែកប្រភេទនៃឧបាទាយរូប មិនដូចគ្នា។ អ្នកអានប្រសិនណាបើបានដឹងប៉ុណ្ណោះហើយនៅពុំទាន់អស់ចិត្ត គប្បីស្វែងរកសេចក្ដីដឹងក្នុងទីដទៃទៀតផងចុះ ។

ការពិតបើយើងពិចារណាមើលពុទ្ធតម្រាស់ត្រង់ចំណុចថា ÷

**"វិញ្ញាណជាបច្ច័យឱ្យកើតមហាភូតរូប ៤ នឹងរូបដែលអាស្រ័យមហាភូតរូប៤"** យើងនឹងឃើញថា ពាក្យអធិប្បាយរបស់ព្រះពុទ្ធអង្គស្ដាប់ងាយចូលចិត្ត ព្រះតម្រាស់របស់ព្រះអង្គខ្លី តែស៊ីសេចក្ដីជ្រៅទូលាយ ។ តាមពាក្យអធិប្បាយនេះ សំដៅសេចក្ដីថា វិញ្ញាណមិនត្រឹមតែជាបច្ច័យឱ្យកើតធាតុទាំង ៤ ប៉ុណ្ណោះទេ គឺជាបច្ច័យឱ្យកើតវត្ថុគ្រប់យ៉ាងដែលទាក់ទងជាមួយធាតុទាំង៤ ផង ។ រាងកាយរបស់យើងប្រកបដោយធាតុទាំង៤ អ្វីៗទាំងអស់ដែលជាប់ទាក់ទងជាមួយធាតុទាំង៤ ជាព្រឹត្តិកម្មនៃធាតុទាំង ៤ រួមទាំងអស់ហៅថា ឧបាទាយរូប ។

ន័យមួយទៀត តាមសេចក្ដីអធិប្បាយខ្លី របស់ព្រះអរហន្តសម្ពុទ្ធនោះ យើងអាចនឹង បកប្រែសេចក្ដីដៅហើយសានិយាយជាថ្មីតាមល័ខកាយវិភាគនឹងសិរីរសាស្រ្តទៅវិញថា វិញ្ញាណជាបច្ច័យឱ្យកើតមហាភូតរូប នឹងឧបាទាយរូបនោះ ក៏គឺវិញ្ញាណជា

បច្ច័យឱ្យកើតរាងកាយនឹងព្រឹត្តិកម្ម[4] នៃរាងកាយនោះឯង ។

**"រាងកាយ"** សំដៅយកវត្ថុផ្សេងៗ ដែលរួមគ្នា កើតបានជារបបនៃកោសិកា ចាករបបនៃកោសិកាក៏ទៅជារបបនៃអវយវៈ ចាករបបនៃអវយវៈ ក៏កើតបានជារបបរាងកាយ ។

**"មហាភូតរូប"** សំដៅយករូបធាតុនឹងថាមពល ដែលជាចំណែកប្រកបនៃកោសិកាឬរបបនៃអវយវៈ ។

**"ឧបាទាយរូប"** សំដៅយកដំណើរប្រព្រឹត្តទៅ សេចក្តីទាក់ទងរវាងរបបផ្សេងៗ នឹងនាទី (មុខងារនៃរាងកាយ) តែពាក្យអធិប្បាយនេះយល់បានងាយសម្រាប់តែមនុស្សដែលធ្លាប់បានរៀនឬធ្លាប់បានគិតអំពីជីវសាស្រ្តជាច្រើនមកហើយ ។

កាលណាយើងបានចូលចិត្តពាក្យអធិប្បាយនេះហើយ យើងនិងឃើញថា តួយ៉ាង ទាំងប៉ុន្មានដែលលោកបានឱ្យមកអំពីឧបាទាយរូបនោះត្រឹមតែជាតួយ៉ាងខ្លីៗប៉ុណ្ណោះ ហើយយើងអាចនឹងរកតួយ៉ាងបានច្រើនជាងនេះទៅទៀត។ ព្រះពុទ្ធឃោសាចារ្យ លោកបានលើកយកពាក្យអត្ថកថាមកនិយាយថា **"សម្ភវរូប"** គឺទឹកកាមដែលញុំាងសត្វឱ្យកើតក៏លោកថាជាឧបាទាយរូប **"ពលរូប"** រូបគឺកម្លាំង ក៏លោកចាត់ថាជាឧបាទាយរូប ។

តួយ៉ាងនៃឧបាទាយរូប ដែលលោកបានអាងមកនេះ បង្ហាញឱ្យឃើញថា ពាក្យថារូបនោះ ពុំមែនដៅយកចំពោះតែអវយវៈផ្សេងៗ ទៅតែដៅយករហូតដល់នាទី (មុខងារ) នឹងព្រឹត្តិកម្មនានាឬដំណើរប្រព្រឹត្តិទៅផ្សេងៗ នៃរាងកាយផង ។ ដូច្នេះមុខងាររបស់សួត របស់បេះដូង របស់ក្រពះ របស់ពោះវៀន ។ល។ ក៏ហៅថារូប ។ សេចក្តីធំធាត់ សេចក្តីតភ្ជាប់ សេចក្តីជរា សេចក្តីបែកធ្លាយ ក៏ហៅថារូប។ សេចក្តីស្រាល សេចក្តីរហ័ស សេចក្តីទន់ភ្លន់ នៃអវយវៈ ក៏ហៅថារូប ។ បើតាមន័យនេះ ការស៊ី ការរំលាយ ការដុតកំដៅ ការបន្ទោរបង់ទាំងអស់នេះ សូម្បីក្នុងគម្ពីរមិនបានសង្គ្រោះចូលក្នុងពួករូប ក៏យើងអាចហៅថារូបបានដែរ។ នាទីនឹងព្រឹត្តិកម្មនានារបស់រាងកាយដែលហៅថារូបក៏ព្រោះវាជារឿងរបស់រូបធម៌ ទាក់ទងជាមួយរូបធម៌ ។

[4] ព្រឹត្តិកម្មនៃរាងកាយ ពាក្យថាព្រឹត្តិកម្មនៃរាងកាយ បានដល់ចលនាដែលកើតឡើង ដោយស្វ័យប្រវត្តិ ដូចជាការពព្រិចភ្នែក ការប៉ោងផតតែបេះដូង ការលំអិតអាហារនៃក្រពះនឹងពោះវៀន ។ល។

វិញ្ញាណជាបច្ច័យឱ្យកើតរូបដៅសេចក្ដីថាវិញ្ញាណជាបច្ច័យឱ្យកើតនាទីនិង ព្រឹត្តិកម្មនានារបស់រាងកាយផង។ បើវិញ្ញាណមិនមានអវយវៈផ្សេងៗ នឹងប្រតិបត្តិការតាមនាទីរបស់ខ្លួនក៏មិនបាន ហើយព្រឹត្តិកម្មផ្សេងៗ របស់រាងកាយក៏មិនមានដែរ ។ កាលណាវិញ្ញាណរលត់ អវយវៈផ្សេងៗ ក៏ឈប់ប្រតិបត្តិនាទីភ្លាម ព្រឹត្តិកម្មទាំងអស់ក៏ឈប់លែងធ្វើការភ្លាមព្រមៗ គ្នាក្នុងខណៈតែមួយនោះឯង។ សូមនឹកដល់ល័ខចិត្តសាស្ត្រដែលស្ដីថាប្រសាទមានមុខងារបង្គាប់អវយវៈផ្សេងៗ ឱ្យធ្វើការ តែវត្ថុធាតុដែលបង្គាប់ពិតៗនោះមិនមែនសរសៃប្រសាទទេ គឺជាក្រសែប្រសាទដែលរត់ទៅមកក្នុងសរសៃប្រសាទហើយសរសៃប្រសាទនេះ បើនិយាយតាមព្រះពុទ្ធសាសនាក៏គឺក្រសែវិញ្ញាណនុ៎ះឯង ។

ក្នុងបឋមជីវិត ពុទ្ធសាសនាបានសម្រេចថាមានវិញ្ញាណមកបដិសន្ធិហើយឬនៅឡើយទេ ?

សំនួរនេះយើងអាចឆ្លើយបានមិនលំបាកទេ កាលណាបើយើងនឹកដល់ល័ខដែលថា ការរីកចម្រើនដុះដាល ការតភ្ជាប់របស់រូប ជីវិតរបស់រូប របស់ទាំងអស់នេះមានវិញ្ញាណជាបច្ច័យ បើវិញ្ញាណមិនមានរូបនឹងរីកចម្រើនក៏មិនបានជីវិតរបស់រូបក៏មិនអាចរស់នៅបាន ការតភ្ជាប់របស់រូបក៏មិនអាចប្រព្រឹត្តទៅកើត ប៉ុណ្ណេះក៏យើងអាចយល់បានហើយ ថាតាមល័ខនៃពុទ្ធសាសនាលោកសម្រេចថាវិញ្ញាណបានមានហើយជាស្រេចតាំងអំពីមានបឋមជីវិតមកម្ល៉េះ ។

ក្នុងបឋមជីវិតនេះនៅមិនទាន់មានភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយនឹងខួរក្បាលទេ។ គេអាចសង្កេតឃើញហើយស្គាល់ច្បាស់ដោយគ្រឿងឆ្លុះដល់ពេទ្យ តែទោះជាដូច្នោះក៏ពុទ្ធសាសនានិយាយថា បានមានវិញ្ញាណមកនៅក្នុងបឋមជីវិតជាស្រេចហើយ ។

សូមគិតឱ្យជ្រៅ ហើយធ្មេចភ្នែកធ្វើមនោគតិទៅក្នុងភាពនៃជីវិតដំបូងគឺជីវិតដែលទើបនឹងកើតថ្មីៗ សឹងនៅតូចជាទីបំផុតហើយក្នុងជីវិតនេះបានមានព្រឹត្តិកម្មផ្សេងៗ ដូចជាការស៊ី ការរំលាយអាហារ ការដុតកំដៅ ការបន្ទោរបង់ ការរីកចម្រើន ។ របស់ទាំងអស់នេះសឹងកើតចាកវិញ្ញាណ មានវិញ្ញាណជាបច្ច័យ។ កាលណាល័ខពុទ្ធសាសនាមានមកយ៉ាងនេះ យើងក៏អាចរៀបចំជាទ្រឹស្ដីបានថា :

*“វិញ្ញាណគឺជាថាមពល ឬជាអំណាចមួយបែបដែលជានាមធម៌ មាននៅក្នុងជីវិតរាល់កោសិកា ជាបច្ច័យឱ្យកើតព្រឹត្តិកម្មរបស់ជីវិត ជាអំណាចឃុំគ្រងការរីកចម្រើនរបស់ជីវិតឱ្យប្រព្រឹត្តទៅក្នុងបែបណាមួយតាមកម្លាំងនៃកម្មព័ន្ធ”* ។

របៀបគិតយ៉ាងងាយបំផុត ដើម្បីឱ្យស្គាល់វិញ្ញាណ តាមសេចក្ដីដៅនៃពុទ្ធសាសនានោះ ជាដំបូងឱ្យនឹកដល់ចរិតសត្វក្នុងកោសិកាមួយៗ ហើយជាបន្ទាប់ឱ្យចែកជីវិតចេញទៅជាពីរចំណែក មួយចំណែកជារូបធម៌ មួយចំណែកទៀតជានាមធម៌ ។ នៅចុងក្រោយបង្អស់ឱ្យនឹកដល់ល័ខគោលត្រង់ថា **“វិញ្ញាណជាបច្ច័យឱ្យកើតរូប”** គឺជាបច្ច័យឱ្យកើតរបបនៃកោសិកានឹងព្រឹត្តកម្មនៃកោសិកាហើយនឹកតទៅទៀតថា វត្ថុធាតុផ្សេងៗ ដែលមិនមានជីវិតដែលមករួមគ្នាកើតបានជារបបនៃកោសិកា ហើយមានជីវិតមានព្រឹត្តិកម្មឆ្លែកៗកើតឡើងព្រោះអំណាចអ្វីហ្ន៎! អំណាចនោះហើយដែលពុទ្ធសាសនា ហៅថាវិញ្ញាណ ហើយត្រូវចាំកុំភ្លេចថា វិញ្ញាណជាធាតុមួយបែបក្រៅអំពីធាតុទាំង ៤ (ដី ទឹក ភ្លើង ខ្យល់) នឹងអាកាសធាតុ វិញ្ញាណជាធាតុនាមធម៌ ។

ជីវិតរាល់ជីវិត មិនថាជីវិតសត្វឬជីវិតពីជៈ (ពូជ) ធំបំផុតឬតូចបំផុតទេ រាល់ៗតែជីវិតរមែងមានប្រតិកិរិយាតបតចំពោះវត្ថុជុំវិញដែលបានសង្កត់មកលើ មានការស្ទុះការរុល ការរួញ ការពត់ ការរេ ។ល។ ក្នុងមានបំណង ដើម្បីរស់ ឬដើម្បីដឹកនាំជីវិតឱ្យរួចាកគ្រោះថ្នាក់ ដូចជាឆ្កែវាស្ទុះចេញ ឬ ស្ទុះចូលក្នុងពេលដែលគេត្រូវប្រហារ សត្វតូចៗ វារុលចូលទៅក្នុងគុម្ពឈើ ក្នុងពេលដែលត្រូវគេដេញចាប់ ស្លឹកឈើខ្លះវារួញចូលមកនៅក្រោមមែកក្នុងពេលដែលត្រូវគេបេះ មនុស្សនិងសត្វខ្លះចេះពត់ខ្លួន ក្នុងពេលដែលត្រូវធាតុអាកាសប្រែប្រួល ឈើខ្លះចេះចេញពីកន្លែងដើមរបស់វា ក្នុងពេលត្រូវឈើដទៃគ្របសង្កត់ ។ អ្នកជីវសាស្ត្រមិនបានដឹងថា ចលនានៃវត្ថុធាតុអស់ទាំងនេះ កើតមកអំពីអ្វីទេ ។ កាលណាបើមានសំនួរក្នុងរឿងនេះ អ្នកជីវាសាស្ត្រមិនឮនិយាយពន្យល់ថាម្ដេចក្រៅអំពីឆ្លើយថា កុំឆ្ងល់អ្វីច្រើនពេក រឿងរបស់ធម្មជាតិវាតែងតែដូច្នេះឯង។ ចំណែកខាងពុទ្ធសាសនាអាចអធិប្បាយរឿងនេះឱ្យគេចូលចិត្តបានយ៉ាងច្រើន តែរឿងនេះមានសេចក្ដីល្អិតជ្រាលជ្រៅណាស់ យើងត្រូវវែកញែកហើយស្រាវជ្រាវដោយឡែកៗ អំពីគ្នាទើបអាចចូលចិត្តបាន ។ នឹងនិយាយរឿងនេះឱ្យអ្នកអានយល់ខ្លះក្នុងខាងមុខ ។ ឥឡូវនេះសូមឱ្យអ្នកអានត្រឡប់មកសិក្សាក្នុងចំណុចថា

**"វិញ្ញាណជាបច្ច័យឱ្យកើតនាមជាថ្មីទៀត"** ដើម្បីឱ្យបានស្គាល់នូវវិញ្ញាណតាមសេចក្ដីដៅនៃពុទ្ធសាសនាឱ្យបានកាន់តែល្អឡើងជាងមុន ។

វិញ្ញាណជាបច្ច័យឱ្យកើតនាមគឺជាបច្ច័យឱ្យកើត វេទនា សញ្ញា ចេតនា ផស្សៈ នឹងមនសិការៈ ។ ហើយក្នុងពាក្យទាំងអស់នេះ គួរសិក្សាពាក្យថា ផស្សៈ ជាមុន ហើយសិមសិក្សាពាក្យដទៃៗតទៅ ។

**"ផស្សៈ"** តាមសព្ទប្រែថា ការសម្ផស្ស ការស្ទាប ការចាប់កាន់ ការពាល់ត្រូវ ការប៉ះ ការខ្ទប់ ។ ជីវិតរាល់ប្រភេទ កាលណាត្រូវប៉ះពាល់ដោយរបស់អ្វីមួយ រមែងមានប្រតិកិរិយាចំពោះរបស់នោះ គឺការប៉ះពាល់គឺជាហេតុឱ្យកើតប្រតិកិរិយានេះហើយដែលពុទ្ធសាសនាហៅថា **ផស្សៈ** ។ ដុំថ្មនឹងដុំថ្មប៉ះគ្នា សូម្បីមានប្រតិកិរិយាចេញមកជាផ្កាភ្លើង ក៏លោកមិនហៅថាផស្សៈក្នុងទីនេះទេ ព្រោះផស្សៈរបស់ថ្មជាផស្សៈមិនមានន័យមិនមានសេចក្ដីដៅ ចំណែកផស្សៈរបស់វត្ថុដែលមានជីវិតនោះជាផស្សៈមានន័យ ។ សូមពិចារណាមើលឱ្យជ្រៅបន្តិច ដែលថាផស្សៈមានន័យនោះគឺផស្សៈដែលជាហេតុឱ្យកើតសុខទុក្ខ ឧបេក្ខា ផស្សៈនេះឯងហើយដែលព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ថា មានវិញ្ញាណជាបច្ច័យកើតមកអំពីវិញ្ញាណប្រសិនបើនៅក្នុងជីវិតនោះមិនមានវិញ្ញា-ណសូម្បីរបស់អ្វីមកប៉ះទង្គិច វាក៏មិនមានប្រតិកិរិយាដែលមានន័យមានសេចក្ដីដៅកើតឡើងទេ។ ជីវិតសត្វក្នុងកោសិកាមួយៗសុទ្ធតែមានប្រតិកិរិយាតបទៅនឹងវត្ថុជុំវិញ គឺវត្ថុដែលចូលមកប៉ះពាល់។ កាលណាយើងបានចូលចិត្តជ្រៅដល់ថ្នាក់ដូចបាននិយាយមកនេះ យើងក៏អាចនឹងមើលឃើញវិញ្ញាណក្នុងជីវិតទាំងពួងបាន ។

**"ចេតនា"** ប្រែថាចំណង់ឬបំណង ជីវិតរាល់ប្រភេទ សុទ្ធតែមានបំណង។ ចេតនានេះក៏កើតមកអំពីវិញ្ញាណ មានវិញ្ញាណជាបច្ច័យ បើវិញ្ញាណមិនមាន ចេតនារមែងកើតឡើងមិនបាន។ ចេតនានិងផស្សៈគេសង្កេតឃើញបាននៅក្នុងជីវិតរាល់ៗកោសិកា ។

**"វេទនា"** ប្រែថា សេចក្ដីដឹងគឺដឹងសេចក្ដីសុខទុក្ខនិងឧបេក្ខាជាដើម ជីវិតរាល់ៗប្រភេទ សុទ្ធតែមានវេទនា ។ វេទនានេះក៏កើតមកអំពីវិញ្ញាណ មានវិញ្ញាណជាបច្ច័យបើវិញ្ញាណមិនមាន វេទនាក៏រមែងមានមិនបាន ។

**"សញ្ញា"** ប្រែថា សេចក្ដីសំគាល់ ឬការកំណត់សំគាល់ ។ សញ្ញានេះក៏កើតឡើង

អំពីវិញ្ញាណ មានវិញ្ញាណជាបច្ច័យ បើវិញ្ញាណមិនមាន សញ្ញាក៏រមែងមានមិនបាន ។ ពាក្យថា សញ្ញានេះធ្លាប់ ប្រែមកថាសេចក្ដីចាំ។ ក្នុងទីនេះ បើប្រែថាសេចក្ដីចាំ ពុំសូវមានន័យទេព្រោះសេចក្ដីចាំជាមុខងាររបស់សតិ មិនមែនជាមុខងាររបស់សញ្ញាទេ ។ សញ្ញាជាហេតុឱ្យកើតសតិ បើសញ្ញាល្អ សតិក៏ល្អ មនុស្សដែលមានសញ្ញាមិនល្អ សតិក៏មិនល្អ គឺចាំអ្វីៗ ពុំសូវបាន។ សញ្ញាល្អឬមិនល្អមកពីខួរក្បាល ។ សត្វជាន់ទាបដែលមិនមានរបបប្រសាទ សតិរមែងមានមិនបានគឺចាំអ្វីៗ ពុំសូវបានឡើយ តែសញ្ញារមែងមានបាន សូម្បីមិនមានខួរក្បាលក៏ដោយព្រោះសញ្ញាក្នុងអភិធម្មលោកចាត់ចូលក្នុងសត្វសាធារណចេតសិក គឺជាចេតសិកដែលកើតព្រមជាមួយចិត្តគ្រប់ខណៈគ្រប់ប្រភេទ ។

**"មនសិការ"** ប្រែថាការធ្វើទុកក្នុងចិត្តឬការកំណត់ទុកក្នុងចិត្តគឺការប្រមូលរួមយកមកគិត ។ មនសិការនេះក៏កើតមកអំពីវិញ្ញាណ មានវិញ្ញាណជាបច្ច័យ បើវិញ្ញាណមិនមាន មនសិការក៏រមែងមានមិនបាន ។

នាមធម៌ទាំង៣នេះ យើងសង្កេតឃើញបានដោយក្រណាស់ នៅក្នុងជីវិតជាន់ទាប តែក្នុងជីវិតសត្វជាន់ខ្ពស់ដែលមានរបបប្រសាទចម្រើនហើយនោះ យើងសង្កេតឃើញបានងាយៗ ចំណែកខាងឧបេក្ខាវេទនានោះ យើងសង្កេតឃើញបានថា ជាវេទនាមានគ្រប់ជីវិតរាល់ៗប្រភេទ។ ដូចដើមឈើ យើងសង្កេតឃើញថា វានៅស្ងៀមព្រងើយគ្រប់ពេលដែលជីវិតដទៃៗ គេមានសេចក្ដីសប្បាយរីករាយឬមានសេចក្ដីទុក្ខព្រួយ ។

វេទនា សញ្ញា ចេតនា ផស្សៈ នឹងមនសិការៈ របស់ទាំងនេះជានាមធម៌ ជារឿងរបស់នាមធម៌ ព្រោះគេស្គាល់របស់ទាំងអស់នេះពិតៗដោយចិត្តប៉ុណ្ណោះ ហើយរបស់ទាំងឡាយនេះ កើតមកតែអំពីវិញ្ញាណដែលជានាមធម៌ដូចគ្នា ។ តែមានមនុស្សខ្លះចូលចិត្តថារបស់ទាំងអស់នេះកើតមកអំពីខួរក្បាលព្រោះគេសង្កេតឃើញថា មនុស្សដែលត្រូវគ្រូពេទ្យចាក់ថ្នាំបញ្ចូលក្នុងខ្លួនឱ្យសន្លប់ មនុស្សនេះទោះជាត្រូវគ្រូពេទ្យធ្វើការវះកាត់យ៉ាងណាក៏មិនដឹងឈឺ។ មនុស្សមានខួរក្បាលពិការ មនុស្សនេះចាំអ្វីក៏មិនបាន គិតអ្វីក៏ពុំយល់។ តួយ៉ាងនេះពិតណាស់ មិនមានអ្នកណាអាចបដិសេធបានទេ ។ ដូច្នេះទើបគួរឱ្យមានសេចក្ដីសង្ស័យថាសេចក្ដីដឹងឈឺ សេចក្ដីចាំនឹងសេចក្ដីគិតជាដើម

នេះ កើតមកអំពីប្រសាទច្រើនជាងខួរក្បាលឬកើតមកអំពីខួរក្បាលច្រើនជាងប្រសាទ ?

ការពិតយើងមិនត្រូវភ្លេចថា មិនថារបស់អ្វីទេរបស់មួយៗ សុទ្ធតែកើតឡើងដោយអាស្រ័យហេតុច្រើនយ៉ាងដូចជាដើមឈើ ត្រូវអាស្រ័យគ្រាប់ ដី ទឹក កំដៅនិងអាកាសជាដើម ហេតុមួយៗមានសេចក្តីសំខាន់ដូចៗគ្នា ប្រសិនបើខ្វះហេតុណាមួយដើមឈើក៏រមែងកើតឡើងមិនបាន ។ ហេតុទាំងអស់នេះ ហៅថាបច្ច័យ មនុស្សយើងកើតមកគ្រប់គ្នាមិនមែនមានន័យថា មានតែវិញ្ញាណមួយកើតបានជាមនុស្សទេ ដែលពិតនោះគឺមានមូលហេតុផ្សេងៗនៃការឧបត្តិរបស់ជីវិត។ តាមដែលគេចេះដឹងខាងជីវសាស្ត្រនោះខាងពុទ្ធសាសនាមិនបានបដិសេធទេ ព្រះសម្មាសម្ពុទ្ធរបស់យើងបានត្រាស់សម្តែងថា :

ភិក្ខុទាំងឡាយ! កាលណាប្រកបព្រមដោយបច្ច័យ៣ យ៉ាងនេះ សត្វទើបកើតក្នុងគភ៌បាន។ ភិក្ខុទាំងឡាយ! បច្ច័យទាំង៣ យ៉ាងនោះគឺ :

**១) មាតាបិតាបាននៅរួមគ្នា**

**២) មាតាបានមានរដូវ**

**៣) មានវិញ្ញាណមកបដិសន្ធិក្នុងគភ៌។**

សេចក្តីក្នុងព្រះសូត្រនេះ ត្រង់ចំណុចទី១ សម្តែងឱ្យឃើញជា ពុទ្ធសាសនាព្រមទទួលថា មនុស្សយើងកើតមកបានត្រូវអាស្រ័យការផ្សំព័ន្ធ ។ ត្រង់ចំណុចទី២ សម្តែងឱ្យឃើញថា មាតាមានបុត្របាន ត្រូវនៅក្នុងវ័យមានរដូវ វ័យក្មេងពេករដូវនៅពុំទាន់មាន ឬវ័យចាស់ហួសរដូវអស់ពុំអាចនឹងមានកូនបានឡើយ ។ ត្រង់ចំណុចទី ៣ សម្តែងឱ្យឃើញថាហេតុត្រឹម២ យ៉ាងប៉ុណ្ណោះ មិនល្មមឱ្យមនុស្សយើងកើតឡើងបានទេត្រូវអាស្រ័យវិញ្ញាណមកបដិសន្ធិទើបអាចកើតបាន ។

មានកន្លែងខ្លះ ព្រះអង្គទ្រង់ត្រាស់សម្តែងថា : **“មនុស្សនឹងកើតបាន ត្រូវអាស្រ័យធាតុ ៦គឺ ដី ទឹក ភ្លើង ខ្យល់ អាកាសនិងវិញ្ញាណ”** ហើយក្រៅពីនេះមានហេតុដទៃជាច្រើន ស្រេចហើយតែយើងនិយាយគ្នា ចង់និយាយវែង ឬខ្លី ឬចង់និយាយទៅក្នុងរបៀបណា។ ចំពោះកំណើតនេះ ពុទ្ធាសាសនាពុំបានបដិសេធហេតុផ្សេងៗ ដែលគេចេះដឹងតាមជីវសាស្ត្រទេ ។ តែអ្នកជីវសាស្ត្រច្រើនបដិសេធហេតុ

ផ្សេងៗរបស់ពុទ្ធសាសនាដូចបដិសេធរឿងវិញ្ញាណជាបច្ច័យឱ្យកើតនាមរូបជាដើម ។ សូមត្រឡប់មកសិក្សាអំពីពាក្យថា : **បច្ច័យ** ឱ្យបានច្បាស់លាស់បន្តិចទៀត ហើយជួនកាលការសិក្សានេះអាចនឹងធ្វើឱ្យយើងចូលចិត្តអំពីរឿងកំណើតនេះតែម្តងទៅ ក៏មានដែរ ។

★ ★ ★

# សូត្រក្នុងបដិច្ចសមុប្បាទមានថា

**អវិជ្ជា**[5] ជាបច្ច័យឱ្យកើតសង្ខារ បើ**អវិជ្ជា**មិនមាន **សង្ខារ**ក៏មិនមាន
**សង្ខារ** ជាបច្ច័យឱ្យកើត**វិញ្ញាណ** បើ**សង្ខារ**មិនមាន **វិញ្ញាណ**ក៏មិនមាន
**វិញ្ញាណ** ជាបច្ច័យឱ្យកើត **នាមរូប** បើ**វិញ្ញាណ**មិនមាន **នាមរូប**មិនមាន
**នាមរូប** ជាបច្ច័យឱ្យកើត **សឡាយតនៈ** បើ**នាមរូប**មិនមាន **សឡាយតនៈ**ក៏មិនមាន
**សឡាយតនៈ** ជាបច្ច័យឱ្យកើត **ផស្សៈ** បើ**សឡាយតនៈ**មិនមាន **ផស្សៈ**ក៏មិនមាន
**ផស្សៈ** ជាបច្ច័យឱ្យកើត **វេទនា** បើ**សផ្សៈ**មិនមាន **វេទនា**ក៏មិនមាន
**វេទនា** ជាបច្ច័យឱ្យកើត **តណ្ហា** បើ**វេទនា**មិនមាន **តណ្ហា**ក៏មិនមាន
**តណ្ហា** ជាបច្ច័យឱ្យកើត **ឧបាទាន** បើ**តណ្ហា**មិនមាន **ឧបាទាន**ក៏មិនមាន
**ឧបាទាន** ជាបច្ច័យឱ្យកើត **ភព** បើ**ឧបាទាន**មិនមាន **ភព**ក៏មិនមាន
**ភព** ជាបច្ច័យឱ្យកើត **ជាតិ** បើ**ភព**មិនមាន **ជាតិ**ក៏មិនមាន
**ជាតិ** ជាបច្ច័យឱ្យកើត **ជរាមរណ** បើ**ជាតិ**មិនមាន **ជរាមរណ**ក៏មិនមាន ។

មេត្តាល្បងពិចារណាត្រឹមតែពីរ - បីតួយ៉ាង គង់នឹងចូលចិត្តពាក្យថា បច្ច័យដោយច្បាស់លាស់ជាមិនខានហើយតួយ៉ាងដែលឆាប់ចូលចិត្តជាទីបំផុតគឺ តួយ៉ាងថា ***"បើជាតិមិនមាន ជរាមរណៈរមែងមិនមាន កាលណាជាតិមានជរាមរណរមែងមាន"*** ។

ដូចយើងបានដឹងមកហើយថា សេចក្តីចាស់នឹងសេចក្តីស្លាប់មានមូលហេតុច្រើនយ៉ាង មិនមែនមានត្រឹមតែជាតិសេចក្តីកើតប៉ុណ្ណោះទេ ហើយបើនិយាយតាមរបៀបរបស់ពេទ្យ គេក៏អាចដឹងថា សេចក្តីកើតមិនមែនជាមូលហេតុដោយត្រង់ៗ ឬចំៗរបស់សេចក្តីចាស់និងសេចក្តីស្លាប់ទេ តែទោះជាដូច្នោះក៏ដោយ បើមិនមានតែកើតមួយ សេចក្តីចាស់និងសេចក្តីស្លាប់រមែងមានមិនបានឡើយ ដរាបណានៅមានកើតដរាបនោះនៅមានចាស់ស្លាប់ ដែលនឹងឱ្យមានតែកើត ហើយមិនឱ្យមានចាស់ស្លាប់ ជារបស់ផុតវិស័យនៃមនុស្សនិងធម្មជាតិ គឺទាំងមនុស្សទាំងធម្មជាតិ ធ្វើពុំកើតប្រព្រឹត្តពុំបានទេ ។

---

[5] **អវិជ្ជា : ជានាមធម៌ បានដល់ភាពងងឹត ជារូបធម៌បានដល់ធាតុ ៤ គឺ ទឹក ដី ភ្លើង ខ្យល់។**

ក្នុងសេចក្ដីខាងលើនេះ មានចំណុចមួយទៀតថា សេចក្ដីកើតជាបច្ច័យនៃសេចក្ដីសោកសេចក្ដីខ្សឹបខ្សួលសេចក្ដីទុក្ខកាយសេចក្ដីទុក្ខចិត្ត(**ថ្នាំងថ្នាក់ចិត្ត**) សេចក្ដីតានតឹងចិត្ត។ កាលណាពិចារណាដល់សេចក្ដីទុក្ខអស់ទាំងនេះ យើងនឹងបានឃើញថា សេចក្ដីទុក្ខនៃចិត្តផ្សេងៗនោះមានមូលហេតុដោយត្រង់ទៅលើអវិជ្ជា តណ្ហា ឧបាទាន។ ដូច្នេះ បុគ្គលដែលផុតចាកកិលេសទាំងអស់នេះហើយ សូម្បីមានជីវិតនៅ(**រស់នៅមិនទាន់ស្លាប់**) សេចក្ដីទុក្ខខាងផ្លូវចិត្តក៏មិនមាន ដោយអាស្រ័យតួយ៉ាងនេះ យើងអាចបញ្ជាក់ឱ្យឃើញបានថា ពាក្យថា "**បច្ច័យ**" នោះ លោកដៅយកមូលហេតុមួយៗ តែជាមូលហេតុដែលមានសេចក្ដីសំខាន់ក្នុងរឿងតាក់តែងកំណើត ។

**សឡាយតន** សំដៅយកភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និងខួរក្បាល ។ កាលណាមានរបស់ទាំងអស់នេះហើយ របស់ទាំងនេះក៏នៅក្នុងលក្ខណៈល្អបរិបូណ៌នោះ។ យើងហាមមិនឱ្យមានផស្សៈក៏ពុំបានឡើយ ហើយកាលណាបើមានផស្សៈហើយ យើងនឹងហាមមិនឱ្យមានវេទនា ក៏ពុំបានទៀតដូចគ្នា។ ដូច្នេះ**សឡាយតន**ទើបបានឈ្មោះថាជាបច្ច័យឱ្យកើតផស្សៈ ផស្សៈជាបច្ច័យឱ្យកើតវេទនា ។

ដោយន័យនេះ ឃើញថារាងកាយកើតចាកមូលហេតុច្រើនយ៉ាង គឺត្រូវអាស្រ័យមាតាបិតា អាស្រ័យអាហារ អាស្រ័យកំដៅ នឹងមូលហេតុដទៃៗទៀត ។ តែទោះជាដូច្នោះក្ដី កំណើតនៃជីវិតទាំងអស់ ប្រសិនបើខ្វះតែវិញ្ញាណមួយក៏មិនអាចកើតឡើងបានឡើយ ។ វេទនានិងសញ្ញាធម្មធាតុពីរនេះមានសេចក្ដីទាក់ទងយ៉ាងជិតស្និទ្ធជាមួយសរសៃប្រសាទនិង ខួរក្បាល តែប្រសាទនិងខួរក្បាលពិការវេទនានិងសញ្ញានឹងកើតមានពុំបានទេ។ ប្រសាទនឹងខួរក្បាលនៅល្អតែបើមិនមានវិញ្ញាណ វេទនានិងសញ្ញាក៏មានមិនបានឡើយ។ ដោយហេតុនេះវិញ្ញាណទើបបានឈ្មោះថា ជាបច្ច័យឱ្យកើតនាមនិងរូប ។

ក្នុងចំណុចនៃបដិច្ចសមុប្បាទ យើងអាចបែងចែកបានជាពីរប្រភេទគឺជារូបធម៌មួយ ជានាមធម៌១ ពួកដែលជានាមធម៌បានដល់ អវិជ្ជា សង្ខារ នាម ផស្សៈ វេទនា តណ្ហានិងឧបាទាន។ មេត្តាចូលចិត្តថានាមធម៌អស់ទាំងនេះ ខាងពុទ្ធសាសនារួមគ្នាហៅថា ចេតសិក ឬសម្បយុត្តធម៌ ។

"**ចេតសិក**" ប្រែថា ធម្មធាតុកើតមកអំពីចិត្ត នៅជាមួយចិត្ត។ "**សម្បយុត្តធម៌**"

ប្រែថា ធម្មធាតុប្រកបព្រមដោយចិត្ត កើតរលត់ព្រមជាមួយចិត្តមានអារម្មណ៍មានវត្ថុជាមួយគ្នានិងចិត្ត ទៅណាមកណាក៏ទៅមកជាមួយគ្នានឹងចិត្ត ។

គួរចាំទុកថា រវាងនាមធម៌និងចិត្តឬនឹងវិញ្ញាណ ជាសម្បយុត្តធម៌មានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធក៏ពិត តែពុំបានរលាយចូលគ្នាជាសាច់មួយដូចចិត្តនឹងចេតសិកទេ។ ដូច្នេះត្រូវពិចារណាឱ្យល្អិតល្អន់ថា ***"វិញ្ញាណជាបច្ច័យឱ្យកើតរូប នឹងជាបច្ច័យឱ្យកើតនាមនោះ ដោយសេចក្តីជៅសឹងមានជម្រៅមិនដូចទេ"*** វិញ្ញាណជាបច្ច័យរបស់រូបនៅក្នុងលក្ខណៈមួយវិញ្ញាណជាបច្ច័យរបស់នាមនៅក្នុងលក្ខណៈមួយទៀត ។ មានពាក្យអធិប្បាយយ៉ាងល្អិតពិស្តារក្នុងរឿងបច្ច័យ ២៤ ក្នុងគម្ពីរបដ្ឋាន អ្នកអានប្រសិនបើចង់ដឹងរឿងរាយរងដែលខ្ញុំមិនបានសរសេរក្នុងសៀវភៅនេះគប្បីតាមទៅមើល ក្នុងទីនោះផងចុះ ព្រោះរឿងនេះមានសេចក្តីវែងហើយ ជារឿងមានសេចក្តីសេមសាមច្រើនផង ។ ខ្ញុំនឹកថា បើស្រង់យកមកសរសេរត្រឹមតែបន្តិចបន្តួចនឹងនាំឱ្យអ្នកពុំសូវយល់រឹតតែមានសេចក្តីឆ្ងល់ច្រើនឡើងទៀត ។

★ ★ ★

# សេចក្តីវិនិច្ឆ័យ

## អំពីវិញ្ញាណជាបច្ច័យឱ្យកើតនាមរូប

វិញ្ញាណជាបច្ច័យឱ្យកើតនាមរូប ។ ពាក្យថាវិញ្ញាណក្នុងទីនេះ ព្រះសម្មាសម្ពុទ្ធទ្រង់អធិប្បាយថា បានដល់វិញ្ញាណ ៦ គឺសេចក្តីដឹងព្រោះបានឃើញរូប សេចក្តីដឹងព្រោះបានឮសំឡេង សេចក្តីដឹងព្រោះបានបានថើបក្លិន សេចក្តីដឹងព្រោះបានបរិភោគរស សេចក្តីដឹងព្រោះបានសម្ផស្សកាយ នឹងសេចក្តីដឹងព្រោះបាននឹកធម្មធាតុ ។ សេចក្តីដឹងទាំងអស់នេះកើតឡើងបានដោយអាស្រ័យភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនិងខួរក្បាល ។ មនុស្សយើងកាលដែលទើបនឹងកើតថ្មីៗ នៅជាកលលៈរូបនៅឡើយនោះ អវយវៈអស់ទាំងនេះមិនមានទេ។ កាលបើអវយវៈមានភ្នែក ត្រចៀក ច្រមុះ ជាដើមមិនមាន វិញ្ញាណក៏រមែងមិនមានដែរ ។ ដូចនេះនឹងទុកដាក់ថា វិញ្ញាណបានមានមកតាំងអំពីបឋមកំណើត ហើយបានជាបច្ច័យរបស់នាមរូបមកតាំងអំពីបឋមបដិសន្ធិយ៉ាងម្តេចកើត? ព្រះពុទ្ធតម្រាស់ថា ***"បើវិញ្ញាណមិនចូលកាន់ផ្ទៃម្តាយ តើនាមរូបនិងតាំងនៅក្នុងផ្ទៃម្តាយបានឬទេ?"*** ពាក្យថា វិញ្ញាណក្នុងទីនេះ និងវិញ្ញាណ ៦ យ៉ាងនោះ ដូចគ្នាឬផ្សេងគ្នា ? កាលណាមានសំណួរដូចនេះកើតឡើងយើងគួរសិក្សារឿងវិញ្ញាណក្នុងពុទ្ធសាសនាឱ្យបានយល់ជ្រៅជ្រះជាងនេះទៅទៀត ទើបអាចបន្ទោរបង់នូវសេចក្តីសង្ស័យទាំងនេះបាន ។

តាមល័ខពុទ្ធសាសនាប្រកាន់ថាមនុស្សកាលណាស្លាប់ហើយ វិញ្ញាណរមែងចេញចាករូបកាយទៅកើតថ្មីទៀត ។ រឿងនេះព្រះអរហន្តសម្មាសម្ពុទ្ធបានទ្រង់ត្រាស់សម្តែងជាមួយ **"មហានាម"** ជាព្រះញាតិរបស់ព្រះអង្គថា វិញ្ញាណដែលរលត់ចុងក្រោយបង្អស់ ហើយឃ្លាតចេញរាងកាយទៅ ហៅថា ចុតិវិញ្ញាណ (ចាំមើលខាងមុខ) ។

ពាក្យថាវិញ្ញាណរលត់មានន័យថាអស់សេចក្តីដឹងអស់នាទី (**មុខងារ**) ដែលមានចំពោះរូបកាយ ។ តាមប្រក្រតីកាលណាជីវិតកំពុងរស់នៅ វិញ្ញាណក៏បានត្រូវរលត់ជាដរាបរាល់ៗ ខណៈ តែរលត់ហើយ ក៏ត្រូវបានកើតជាថ្មីជាប់តរឿយៗ មកមិនចេះដាច់

បើជីវិតនៃរាងកាយត្រូវបានរលត់ក្នុងកាលណា វិញ្ញាណក៏រលត់ភ្លឹបក្នុងកាលនោះ ហើយពុំបានតភ្ជាប់នៅក្នុងរាងកាយនោះទៀតទេ ។

ពាក្យថារលត់ជាគ្រាចុងក្រោយបង្អស់មានន័យដូច្នេះឯង ។ វិញ្ញាណដែលឃ្លាតចេញចាករាងកាយទៅហើយ មានភពថ្មីនៅក្នុងទីណាវិញ្ញាណនោះហើយដែលធ្វើនាទីតភ្ជាប់ជាមួយជីវិតថ្មីក្នុងទីនោះ លោកហៅ វិញ្ញាណនេះថា បដិសន្ធិវិញ្ញាណ ។

**"បដិសន្ធិវិញ្ញាណ"** តាមសព្ទប្រែថា វិញ្ញាណដែលត្រឡប់តទៀត មកអំពីពាក្យថា បដិ=ត្រឡប់+សន្ធិ=ត+វិញ្ញាណ សាស្ត្រាចារ្យ**វិសដេវិដស៍** ប្រែថា :

Reunion of vital principal with a body.

កាលណាវិញ្ញាណចូលទៅនៅក្នុងជីវិតណា ក៏ស្ថាបនាជីវិតនោះឱ្យរីកចម្រើន។ របៀបស្ថាបនាគឺធ្វើឱ្យជីវិតនោះមានឫសគល់ គឺជាបុគ្គលិកភាពនៃរាងកាយ នៃនិស្ស័-យ នៃសន្តាន នៃសមត្ថភាព នៃជោគវាសនា ។ ឫសគល់ឬគ្រឹសនៃជីវិតនឹងបានទៅជាល្អឬអាក្រក់យ៉ាងណាៗ ស្រេចហើយ តែវិញ្ញាណនោះមានសម្បយុត្តធម៌ជាគុណសម្បត្តិឬជាទោសសម្បត្តិពីដើមមក។ វិញ្ញាណធ្វើមុខងារចាក់ឫសឬរៀបគ្រឹសស្ថាបនារូបកាយលោកហៅថា **"ភវង្គវិញ្ញាណ"** ។

**"ភវង្គវិញ្ញាណ"** តាមសព្ទប្រែថាវិញ្ញាណដែលជាអង្គនៃភព មកអំពីពាក្យថា ភវៈភព+អង្គ=អង្គ+វិញ្ញាណ។ ភពក្នុងទីនេះ ដៅដល់នាមរូប អង្គ ដៅដល់បច្ច័យសំខាន់ឬចំណែកប្រកបសំខាន់ឫសគល់ឬខ្លួនប្រាណ។ ពាក្យថាភវង្គសាស្ត្រាចារ្យ **វិសដេវិដស៍** ប្រែថា Costituent of becoming function of being, functional state of subconscioness ។

ព្រះពុទ្ធទ្រង់ត្រាស់ថា វិញ្ញាណ ៦ ជាបច្ច័យឱ្យកើតនាមរូបនោះពាក្យថាវិញ្ញាណមានសេចក្តីដៅពីរយ៉ាងគឺ :

ក) ដៅដល់វិញ្ញាណដែលកើតមកហើយដឹងខ្លួនបាន សឹងបានដល់ការដឹងព្រោះសេចក្តីនឹកគិត ។ ខ) ដៅដល់វិញ្ញាណដែលធ្វើមុខងារដោយយើងពុំបានដឹងខ្លួនឡើយ។ វិញ្ញាណដែលមិនដឹងខ្លួនគឺចុតិវិញ្ញាណ បដិសន្ធិវិញ្ញាណ នឹងភវង្គវិញ្ញាណ **"បើវិញ្ញាណមិនចូលកាន់ផ្ទៃម្តាយ ។ល។"** វិញ្ញាណក្នុងទីនេះក៏គឺបដិសន្ធិវិញ្ញាណនុ៎ះឯង ។

សូមមេត្តាចូលចិត្តថា ក្នុងខណៈដែលសត្វស្លាប់នោះវិញ្ញាណបានធ្វើការរហ័សណាស់ រកអ្វីប្រៀបដូចឱ្យដូចពុំបានទេ គឺគ្រាន់តែវិញ្ញាណចុតិភ្លាម ក៏ចាប់បដិសន្ធិភ្លែត ហើយកាលដែលវិញ្ញាណធ្វើមុខងាររតភ្ជាប់ជាមួយជីវិតថ្មី ក៏រហ័សលែងនិយាយកើតគឺអស់ពេលត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ។ បន្ទាប់ពីនោះមក វិញ្ញាណក៏ធ្លាក់ចុះនៅក្នុងស្ថានភាពជាភវង្គរឿយៗទៅរហូតដល់ខណៈនៃចុតិដែលត្រូវមានជាថ្មីទៀត ។

★ ★ ★

# សេចក្ដីវិនិច្ឆ័យ

## អំពីវិថីវិញ្ញាណជាបច្ច័យឱ្យកើតរូប

វិញ្ញាណ ៦ ជាបច្ច័យឱ្យកើតរូប វិញ្ញាណមានពីរប្រភេទគឺ : វិថីវិញ្ញាណនិងភវង្គវិញ្ញាណ ភវង្គវិញ្ញាណជាបច្ច័យយ៉ាងម៉េច? បានអធិប្បាយមកហើយថា អំណាចដែលឃុំគ្រងរបបនៃកោសិការបបនៃអវយវៈផ្សេងៗនោះ គឺជាភវង្គវិញ្ញាណ។ កាលណាចូលចិត្តដូច្នេះហើយ ក៏មិនសូវមានបញ្ហាអ្វីចោទទៅទៀតទេ សម្រាប់ភវង្គវិញ្ញាណ។ តែចំណែកខាងវិថីវិញ្ញាណគឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ។ល។ និងមនោវិញ្ញាណដែលជាចំណែកនៃសេចក្ដីដឹងខាងនឹកគិតនោះ តើជាបច្ច័យឱ្យកើតរូបបានយ៉ាងម៉េច? អ្នកខ្លះមិនអាចចូលចិត្តបានឡើយ ។ ដូច្នេះសូមអធិប្បាយបន្តិចទៀតដូចតទៅនេះ ÷

ដូចបាននិយាយមកហើយថា ពាក្យថារូបសំដៅយករបស់គ្រប់យ៉ាង ដែលរួមចូលគ្នាជារាងកាយ ហើយសំដៅដល់មុខងារ សេចក្ដីប្រព្រឹត្តិទៅនៃរាងកាយព្រមទាំងរបស់គ្រប់បែបគ្រប់យ៉ាងដែលជារូបធម៌ ទាក់ទងនឹងរូបធម៌ ។ វិថីវិញ្ញាណ ជាបច្ច័យឱ្យកើតរូបបានយ៉ាងម៉េច។ សូមពិចារណាបញ្ហាតទៅគង់នឹងចូលចិត្តបាន ។

ប្រសិនបើយើងមើលអ្វីមិនឃើញ ស្ដាប់អ្វីមិនឮ មិនដឹងក្លិនអ្វី មិនដឹងរសអ្វី មិនដឹងសម្ផស្សអ្វី មិនមានសេចក្ដីគិតអ្វីៗសោះ។ តើសន្តិសុខនៃជីវិតរបស់យើងនឹងមានដែរឬទេ? អវយវៈផ្សេងៗធ្វើការបានឬទេ? ចលនាផ្សេងៗនៃជីវិតរបស់យើងនិងមានឬពុំមានទេ? យើងគង់ឃើញថាពុំមានទេ។ ដូច្នេះវិញ្ញាណ៦ ទើបបានឈ្មោះថាជាបច្ច័យឱ្យកើតរូបព្រោះថាបើសន្តិសុខនៃជីវិតមិនមានអវយវៈផ្សេងៗ មិនធ្វើការចលនាគ្រប់បែបយ៉ាងមិនមាននោះការរីកចម្រើននៃជីវិតក៏រមែងមានពុំបានឡើយ ។

គួរចូលចិត្តថា ភវង្គវិញ្ញាណនិងវិថីវិញ្ញាណ ទាំងពីរនេះជាវិញ្ញាណផងគ្នានុ៎ះឯងក្នុងខណៈភវង្គវិញ្ញាណមកប្រាកដខាងភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយឬខាងសម្បកខួរក្បាលក្នុងខណៈនោះហៅថាវិថីវិញ្ញាណ ។ វិថីវិញ្ញាណ ប្រែថាវិញ្ញាណកើតក្នុងវិថីឬកើតតាមវិថី។ វិថីប្រែថាផ្លូវឬទ្វារ។ ផ្លូវឬទ្វារក្នុងទីនេះ សំដៅយកភ្នែក ត្រចៀក ច្រមុះជាដើម ។ វិថីវិញ្ញាណក៏គឺវិញ្ញាណ ដែលកើតតាមចក្ខុវិថី ឬសោតវិថីជាដើម ។

ដូច្នេះភវង្គវិញ្ញាណនិងវិថីវិញ្ញាណ ទើបជាធម្មធាតុមានការទាក់ទងគ្នាទៅវិញទៅមកគ្រប់ៗ ខណៈដូចសេចក្ដីដឹង សេចក្ដីចូលចិត្ត ឬមនោសញ្ចេតនាផ្សេងៗ ក្នុងខណៈយើងមិនដឹងថា ធម្មធាតុនេះបានកើតឡើងក្នុងវិថីវិញ្ញាណទេ តែយើងក៏ដឹងថាបានមាននៅក្នុងភវង្គវិញ្ញាណ ។ អារម្មណ៍ផ្សេងៗ ដែលវិថីវិញ្ញាណបានទទួល អារម្មណ៍ទាំងអស់នោះ ត្រូវបានប្រាកដនៅក្នុងវិថីត្រឹមតែមួយខណៈ ហើយត្រឡប់ចូលកាន់ភវង្គជាប្រក្រតី ពេលណាវិញ្ញាណត្រូវការ ទើបរើយកអំពីភវង្គមកវិញ។ កាលណាយើងដើរជាន់លើសសត្វពស់ យើងត្រូវស្លុតចិត្តយ៉ាងខ្លាំង ហើយយ៉ាងរហ័សផងសេចក្ដីស្លុតចិត្តនេះបានប្រាកដឡើងក្នុងសេចក្ដីគិតរបស់យើងត្រឹមមួយខណៈ ។ ក្នុងពេលមួយភ្លែតនេះយើងដឹងថា បេះដូងរបស់យើងបានលោតយ៉ាងខ្លាំង ឬបានដើរយ៉ាងញាប់។ ការលោតនៃចេះដូងរបស់យើងក៏នៅក្នុងអំណាចនៃភវង្គ **(ខាងចិត្តសាស្ត្រប្រកាន់ថាបេះដូងលោត ព្រោះសរសៃប្រសាទបង្គាប់ តែយើងកុំភ្លេចថា ដែលចិត្តសាស្ត្រថាសរសៃប្រសាទនោះក៏គឺក្រសៃវិញ្ញាណ ដែលនិយាយដោយពុទ្ធសាសនានុ៎ះឯង)** ។ ដូច្នេះយើងត្រូវដឹងឱ្យច្បាស់ថា វិថីវិញ្ញាណនិងភវង្គវិញ្ញាណទាំងពីរនេះ ជាធម្មធាតុមានការទាក់ទងគ្នាគ្រប់ខណៈ ។ កាលណាយើងចូលចិត្តថា ដូចម្ដេចភវង្គវិញ្ញាណទើបជាបច្ច័យឱ្យកើតរូបបានតាំងអំពីបឋមកំណើត យើងក៏មិនលំបាកនឹងចូលចិត្តថា ដូចម្ដេចវិថីវិញ្ញាណទើបជាបច្ច័យឱ្យកើតរូបបានឬកាលណាយើងចូលចិត្តថាវិថីវិញ្ញាណជាបច្ច័យឱ្យកើតរូបយ៉ាងណា យើងក៏នឹងចូលចិត្តថា ភវង្គវិញ្ញាណក៏ជាបច្ច័យឱ្យកើតរូបបានយ៉ាងនោះដូចគ្នាដែរ ។

★ ★ ★

# សេចក្តីវិនិច្ឆ័យ

## អំពីបឋមជីវិតមានវិញ្ញាណមកបដិសន្ធិហើយឬនៅ?

ជីវិតកើតថ្មីៗ បានមានវិញ្ញាណមកនៅហើយឬនៅ? បញ្ហានេះបានអធិប្បាយមកហើយ ដោយបានលើកយកល័ខពុទ្ធភាសិតមកអាងគ្រប់កន្លែងហើយ។ តទៅនេះ សូមលើកយកពាក្យរបស់ព្រះអត្ថកថាចារ្យមកអធិប្បាយខ្លះទៀត ដើម្បីឱ្យអ្នកអាន បានចូលចិត្តអំពីរឿងវិញ្ញាណកាន់តែច្បាស់លាស់ឡើង។ អំពីរឿងវិញ្ញាណព្រះអត្ថក-ថាចារ្យ លោកបាននិយាយថា ÷

***"កម្មជ្ជរូប ៣០ រមែងកើតព្រមគ្នាជាមួយនឹងបដិសន្ធិវិញ្ញាណ"***

កម្មជ្ជរូបប្រែថា រូបកើតអំពីកម្ម (កម្ម=កម្ម+ជ=កើត+រូប) លោកអធិប្បាយថា រូបដែលកើតអំពីកម្ម គឺរូបដែលទាក់ទងជាមួយកម្ម យ៉ាងជិតស្និទ្ធបំផុតក្នុងអតីតកាល មាន ៩ ប្រភេទគឺចក្ខុ សោត ឃាន ជីវ្ហា កាយ ហទយវត្ថុ ជីវិត ឥត្ថិភាព បុរិសភាព។ សេកច្ដីអធិប្បាយរបស់លោកមានន័យថា មនុស្សយើងដែលមានភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ខួរក្បាល ។ល។ ល្អឬមិនល្អនោះ ស្រេចហើយតែអំពីកម្មដែលបានធ្វើមកពីអតីតជាតិ ។ បើធ្វើកម្មល្អ រូបទាំងអស់នេះក៏បានល្អ បើធ្វើកម្មមិនល្អ រូបទាំងអស់នេះក៏បានមិនល្អ។ តួយ៉ាងដូចរឿងព្រះចក្ខុបាលក្នុងគម្ពីរធម្មបទ ភ្នែករបស់លោកត្រូវងងឹតក៏ព្រោះផលនៃកម្មដែលលោកបានធ្វើឱ្យគេខ្វាក់ភ្នែកដោយចេតនា ។ ជនដែលកើតមកបានជាមនុស្សមានខួរក្បាលល្អ ក៏ព្រោះធ្លាប់សាងបញ្ញាបារមីមកច្រើន ជនដែលកើតមកមានបុគ្គលិកលក្ខណៈ ឬបុគ្គលិកភាពខាងអវយវៈ ជាស្នេហ៍នាំឱ្យគេស្រឡាញ់រាប់អានច្រើន ក៏ព្រោះគេធ្លាប់បានអប់រំមេត្តាបារមីធម៌ច្រើន ជនដែលមានអាយុវែងឬអាយុខ្លីក៏មកតែពីកម្មដែលខ្លួនបានធ្វើក្នុងអតីតដូចគ្នា ។ ក្នុងបុលកម្មវិភង្គសូត្រព្រះអង្គទ្រង់បានត្រាស់សម្ដែងជាមួយសុភមាណពថា ***"ជនដែលសម្លាប់សត្វជានិច្ច ស្លាប់ហើយរមែងទៅកើតក្នុងនរក បើមិនទៅកើតក្នុងនរក កើតមកជាមនុស្ស រមែងទៅជាមនុស្សមានអាយុខ្លី ចំណែកបុគ្គលដែលមិនធ្វើដូច្នេះ រមែងបានជាមនុស្សមានអាយុវែង"*** ដូច្នេះជាដើម ។ មនុស្សដែលត្រូវបានកើតមកជាបុរសឬស្ត្រីក៏មានសេចក្ដីទាក់ទងមកអំពីកម្មក្នុងអតីត ។ តាមធម្មតាមនុស្សដែលធ្លាប់បានកើតមកជា

បុរស ក៏ច្រើនតែបានកើតជាបុរសរឿយៗទៅ មនុស្សដែលធ្លាប់បានកើតជាស្ត្រីក៏ច្រើនតែបានកើតជាស្ត្រីរឿយៗទៅដូចគ្នា ព្រោះហេតុអ្វី? ព្រោះនិស្ស័យសន្តានបុរសនិងស្ត្រីមិនដូចគ្នាទាំងចេតនាឬបំណងដែលជាបុព្វហេតុនៃកម្មដែលខ្លួនបានធ្វើក៏ច្រើន តែខុសគ្នា។ ព្រោះហេតុដែលរូបទាំងអស់នេះ ជាវត្ថុធាតុទាក់ទងជាមួយកម្មក្នុងអតីតដូច្នេះទើបលោកចាត់រូបទាំងអស់នេះថាជាកម្មជរូប ។

កម្មជរូប ១០ ដែលកើតព្រមគ្នាជាមួយបដិសន្ធិវិញ្ញាណនោះ គឺពួកកាយប្រសាទ ១០ ពួកហទយវត្ថុ ១០ ពួកឥត្ថីភាព ឬបុរិសភាព ១០ ក្នុងពពួកនេះ ពួកមួយៗមាន ១០ ដែលលោកចាត់ដូចនេះ ព្រោះលោកយល់ថា វត្ថុធាតុដែលកើតជាកាយប្រសាទក្តី ជាហទយវត្ថុគឺខួរក្បាលក្តី ជាលក្ខណៈនៃពេសក្តី ក្នុងវត្ថុមួយៗ រមែងត្រូវប្រកបដោយចំណែកផ្សំ ១០ យ៉ាងគឺធាតុដី ១ ធាតុទឹក ១ ធាតុភ្លើង ១ សម្បុរ ១ ក្លិន ១ រស ១ ឱជា ១ ជីវិត ១ លក្ខណៈពិសេសដែលជាសញ្ញាល័ក្ខណ៍របស់កាយប្រសាទឬរបស់ខួរក្បាលឬរបស់លក្ខណៈនៃពេស ១ ។ លោកបានបញ្ជាក់ថា ចំណែកប្រកបផ្សំអស់ទាំងនេះនឹងញែកចេញពីគ្នាពុំបានទេ ជារបស់ត្រូវនៅរួមគ្នាជាដរាបទៅទើបចាត់ជាពួកៗ ហៅថា កាយទសកៈ ពួក១០ នៃភាវៈស្ត្រីឬភាវៈបុរស ។ រឿងនេះគួរសិក្សាឱ្យល្អិតបន្តិចទៅទៀត ព្រោះជារឿងមានប្រយោជន៍ច្រើន ដល់ការធ្វើឱ្យចូលចិត្តនូវសភាពរបស់វិញ្ញាណតាមផ្លូវនៃពុទ្ធសាសនា ។

ជីវិតក្នុង ៧ ថ្ងៃដំបូងខាងក្រោយអំពីវិញ្ញាណបានមកបដិសន្ធិហើយនោះ តាមបាលីហៅថា "**កលលៈ**" នៅខាងក្នុងកលលៈនោះ បានមានទសកៈទាំង ១០ គ្រប់បរិបូណ៌ហើយ ក៏កលលៈនេះមានលក្ខណៈដូចម្តេច? មានទំហំប៉ុនណា?

"**កលលៈ**" តាមសព្ទប្រែថា "**ភក់**" តែតាមន័យសំដៅយកដំណក់ទឹកយ៉ាងតូចមួយដែលកើតមានមុនគេ ក្នុងតួកំណើតនៃមនុស្សមានលក្ខណៈដូចដំណក់ទឹកលាងសាច់ ។ ទំហំនៃកលលៈ ព្រះពុទ្ធឃោសាចារ្យបានអធិប្បាយប្រាប់ថា ***"រូបនេះតូចប៉ុនដំណក់ប្រេងល្ងយ៉ាងថ្លាដែលជាប់នៅចុងនៃរោមចាមរី ហើយត្រូវគេរលាស់ចោលអស់វារៈ ៧ ដង"*** (ចាមរីជាសត្វមួយប្រភេទមានរូបរាងស្រដៀងគោមានរោមល្អិតណាស់ មានច្រើននៅប្រទេសឥណ្ឌាភាគខាងលើនិងប្រទេសចិនត្រង់ភូមិភាគជាប់ នឹងឥណ្ឌា អង់គ្លេសហៅថា Yak) ។

ពុទ្ធសាសនាប្រកាន់ថា កាលណាមានវិញ្ញាណមកបដិសន្ធិហើយជីវិតក៏ផ្ដើមកើតជាកលលៈ ទៅអំពីកលលៈ ដែលមានលក្ខណៈដូចទឹកលាងសាច់ ក៏កើតបានទៅជាដុំឈាមខាប់ៗ ទៅអំពីដុំឈាមខាប់ៗ ក៏កើតបានជាដុំសាច់ជ្រាយៗ ហើយសន្សឹមរឹងម្ដងបន្តិចៗ តាមលំដាប់។ មានរូបស្រដៀងដង្កូវក្នុងបង្គន់ ហើយក៏ចាប់កើតមានបញ្ចសាខាគឺពកដៃទាំងពីរ ជើងទាំងពីរនិងក្បាលមួយ ដែលគម្ពីរពុទ្ធសាសនាបាននិយាយថា ÷

*"សរីរៈនេះដំបូងឡើងជាកលលៈ បន្ទាប់កលលៈ ជាអព្ពុទៈ បន្ទាប់អព្ពុទៈ ជាបេសិ បន្ទាប់បេសិ ជាឃនៈ បន្ទាប់ឃនៈ ជាបញ្ចសាខា បន្ទាប់បញ្ចសាខា ក៏ដុះសក់រោមនឹងក្រចក ។ មាតានៃទារកនោះបរិភោគអាហារណា ជាបាយក្ដី ជាទឹកក្ដី ជាចំណីអ្វីៗក្ដី ទារកក្នុងគភ៌ក៏រស់នៅដោយអាហារនោះ"* ។

លំដាប់នៃការកើតនៃទារកក្នុងគភ៌ ក្នុងគម្ពីរពុទ្ធសាសនាបាននិយាយថាព្រះពុទ្ធអង្គបានត្រាស់សម្ដែងជាមួយយក្ខម្នាក់ឈ្មោះ ឥន្ទកៈ នាភ្នំឈ្មោះឥន្ទកូដ នៅក្នុងក្រុងរាជគ្រឹះ ។ ភ្នំនេះជាលំនៅរបស់ឥន្ទយក្ខ។ ព្រះតម្រាស់នេះ ត្រូវបានព្រះអត្ថកថាចារ្យយកមកអធិប្បាយថា ក្នុងសប្ដាហ៍ទី១ ជាកលលៈ គឺឈាមមានសម្បុរសព្រឿងៗ សប្ដាហ៍ទី២ ជាអព្ពុទៈ គឺដុំលោហិតខាប់ៗ សប្ដាហ៍ទី៣ ជាបេសិ គឺជាដុំសាច់ជ្រាយៗ សប្ដាហ៍ទី៤ ជាឃន គឺជាដុំសាច់ណែនៗ ហើយសន្សឹមរឹងបន្តិចម្ដងៗ មានទ្រង់ទ្រាយដូចជាសត្វដង្កូវនៅក្នុងបង្គន់ សប្ដាហ៍ទី៥ ជាបញ្ចសាខា គឺមានពក ៥ ជាក្បាល ១ ជាដៃ ២ ជាជើង ២ កើតឡើង ។ ចំណែកសក់ រោម ក្រចកនោះ លោកថាកើតក្នុងសប្ដាហ៍ទី ១២ ។

**"បឋមំ កលលំ ហោតិ សរីរំ សុខុមំ ឥនំ កិមីវ វច្ចកូបម្ហិ តិដ្ឋតេ មាតុកុច្ឆិយំ"**

"សរីរៈនេះជារបស់ល្អិត មានកលលៈជាដំបូងតាំងនៅក្នុងគភ៌ម្ដាយប្រៀបបានទៅនឹងសត្វដង្កូវនៅក្នុងបង្គន់" ។

**-ភាសិតលង្កា-**

ក្នុងចំណុចទាំងអស់ មានចំណុចមួយដែលគួរឱ្យសង្កេតគឺត្រង់ក្បាលតាមការពិសោធន៍របស់ពេទ្យបានសេចក្ដីថា ជីវិតដែលទើបនឹងកើតថ្មីៗនោះ ភាគត្រង់ក្បាលធំជាងភាគដទៃៗ ទាំងអស់ ។ សេចក្ដីពិសោធន៍នេះដូចជាចង់បង្ហាញឱ្យឃើញថា

ក្បាលពុំមែនកើតព្រមជាមួយដៃនឹងជើងទេ គឺក្បាលកើតមុន ។ ប្រសិនបើក្បាលកើតមុន នឹងមានបញ្ហាចោទឡើងថា ពាក្យថាពកក្បាលនោះសំដៅយកអ្វី? សូមសង្កេតថា ជីវិតក្នុងមួយខែដំបូង កើតបានជាឃនៈមានរាងដូចជារូបដង្កូវ ។ ក្នុងសប្តាហ៍ទី៥ មានដៃនិងជើងត្រឹមតែជាពក គឺទើបនឹងដុះចេញជាហេតុឬជាទម្រង់បន្តិចៗប៉ុណ្ណោះ ។ ពាក្យថាពកក្បាលក្នុងទីនេះ លោកសំដៅយកភាគខាងលើ(ភាគសីលៈ) ដែលសន្សឹមៗ កើតមានជារាងទំនងក្បាល ហើយសន្សឹមៗរីកចម្រើនទៅជាក្បាលពិតៗ ក្នុងខាងក្រោយ ។ ក៏បញ្ហាកើតមុនកើតក្រោយនៃអវយវៈ របស់ជីវិតនេះ លំបាកនឹងសម្រេចថា ម៉េចឱ្យបានត្រូវចិត្តអ្នកអានពន់ពេកណាស់ ព្រោះបញ្ហានេះ ទាំងខាងពុទ្ធសាស្ត្រ ទាំងខាងជីវសាស្ត្រមាននិយាយពុំសូវជាក់លាក់ ។ ក្នុងបញ្ហាដដែលនេះ ខាងគម្ពីរនៃពុទ្ធសាសនាបានចែកអវយវៈនៃជីវិតទៅជា ៣ ភាគ។ ភាគខាងក្រោមគិតពីត្រឹមផ្ចិតរហូតចុះទៅដល់ទីបំផុតនៃបាទជើងហៅថា **ហេដ្ឋិមខ័ណ្ឌ** (កំណត់ខាងក្រោម) ភាគកណ្តាលគិតពីត្រឹមផ្ចិតឡើងរហូតដល់ទីបំផុតនៃដើមកហៅថា **មជ្ឈិមខ័ណ្ឌ** (កំណាត់កណ្តាល) ភាគខាងលើគិតពីត្រឹមទីបំផុតនៃដើមករហូតឡើងដល់ទីបំផុត នៃលលាដ៏ក្បាល ឬទីបំផុតនៃចុងសក់ហៅថា**ឧបរិមខ័ណ្ឌ** (កំណាត់ខាងលើ) តែលោកពុំបានបញ្ជាក់អំពីការកើតមុនក្រោយនៃខ័ណ្ឌទាំងអស់នេះទេ តើលោកខំប្រឹងចែកមកដើម្បីប្រយោជន៍ដល់ការភាវនាធម៌របស់ខ្លួនខាងផ្នែករូបកាយតែប៉ុណ្ណោះ ។ នេះគឺជាឧត្តមគតិនៃពុទ្ធសាសនាទាំងមូល ដែលនិយមវែកញែកឱ្យឃើញដើម្បីពិចារណាភាវរកធម៌ ហើយមិននិយមវែកញែកឱ្យឃើញ ដើម្បីពិចារណាភាវរកកំណើតមុនក្រោយឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ការបែងចែកនៃអវយវៈរបស់ជីវិតបើមិនមានប្រយោជន៍ច្រើនក៏តិចដែរ ។ ដោយអាស្រ័យការបែងចែករបស់លោកដូចបាននិយាយមកហើយនោះ យើងគួរគិតថា ក្នុងកំណាត់ទាំងឡាយ ៣ នេះ កំណាត់ណាមានសេចក្តីសំខាន់ជាងគេ ។ កាលណាយើងរកសេចក្តីសំខាន់ឃើញហើយ យើងក៏នឹងរកឃើញនូវកំណើតមុនក្រោយនៃអវយវៈទាំងអស់នោះជាមិនខាន ។ ចំពោះបញ្ហានេះ ខ្ញុំយល់ឃើញថាអវយវៈនៃជីវិតទាំងអស់សុទ្ធតែមានសេចក្តីសំខាន់ដូចគ្នា តែយើងគួររកថា អវយវៈត្រង់ភាគណាដែលជាទីអាស្រ័យនៅរបស់វិញ្ញាណឬវិញ្ញាណចូលមក អាស្រ័យនៅក្នុងអវយវៈភាគណាមុនគេបង្អស់ អវយវៈភាគនោះហើយដែលជាបឋមាអវយវៈ

តើជាបេះដូងដែលនៅក្នុងកណ្តាលដើមទ្រូងត្រង់កំណាត់ភាគកណ្តាលឬ ជាខួរក្បាលដែលនៅក្នុងកណ្តាលលលាដ៏ក្បាលត្រង់កំណាត់ភាគខាងលើ? សេចក្តីនេះខ្ញុំសូមផ្ញើលើអ្នកអាននឹងសម្រេចយ៉ាងណាឬមិនអាចនឹងសម្រេច បានទេក៏ស្រេចហើយតែសេចក្តីយល់ឃើញរៀងៗខ្លួនចុះ។ ចំណែកខ្លួនខ្ញុំ ក្នុងអវយវៈទាំងពីរនេះ គឺបេះដូងនឹងខួរក្បាល ខ្ញុំយល់ថាបើមិនមួយណាក៏មួយណាហើយ ព្រោះបេះដូងជាលំនៅនៃអង្គភពរបស់វិញ្ញាណឯខួរក្បាលក៏ជាលំនៅនៃអង្គការគឺជាកន្លែងទទួលការឬ ជាកន្លែងធ្វើការរបស់វិញ្ញាណ។ កន្លែងទាំងពីរនេះ បេះដូងក៏ជាអវយវៈសំខាន់របស់ជីវិត ខួរក្បាលក៏ជាអវយវៈសំខាន់ដូចគ្នា ហើយជាទីបញ្ជាការរបស់វិញ្ញាណផង ។

ការរកអវយវៈដំបូងក្នុងបឋមជីវិត មិនមែនជាការងាយទេ ព្រោះដើមកំណើតនៃអវយវៈនេះតូចណាស់ ហើយកុំនិយាយដល់ទៅកំណើតមនុស្សសត្វដែលនៅក្នុងគភ៌ដែលយើងលំបាកនឹងមើលឃើញ ឬមើលឃើញដោយមិនច្បាស់ សូម្បីតែបឋមកំណើតនៃពីជ (ពូជរុក្ខជាតិ) ដែលយើងមើលឃើញវាដុះចេញអំពីគ្រាប់ហើយបើមានគេសួរយើងថានៅក្នុងពន្លកតូចរបស់វានោះ ត្រង់ណាជាដើម ជាសំបក ជាមែក ជាស្លឹក ជាផ្កា ។ល។ នោះយើងមិនដឹងឆ្លើយដូចម្តេចកើតទេ បើពូកែណាស់បានត្រឹមតែឆ្លើយថា គឺពន្លកនោះហើយដែលជាដើមរបស់វា ។ ឯសម្បក មែក ផ្កា ផ្លែ... របស់វាក៏មិនមែនកើតមកអំពីណាគឺកើតមកតែអំពីដើមរបស់វា ។ ចម្លើយនេះល្មមស្តាប់បានដែរតែបើមានសំណួរមួយទៀតថា នៅក្នុងពន្លករបស់វា គេមិនឃើញមានសម្បក ស្លឹក ផ្កា ផ្លែ... សោះ តើរបស់ទាំងនេះកើតមានមកយ៉ាងម៉េច? សំណួរថ្មីនេះ យើងលំបាកនឹងឆ្លើយ លំបាកនឹងអធិប្បាយឱ្យគេយល់ណាស់ប្រសិនបើ យើងមិនបានចេះដឹងជីវសាស្ត្រនិងរុក្ខសាស្ត្រផងទេ ។ សម្តេចព្រះធម្មលិខិត **ល្វី អែម** ឧត្តមប្រឹក្សាគណនមហានិកាយអតីតចៅអធិការវត្តលង្កាជាអ្នកប្រាជ្ញជើងឯកមួយខាងអភិធម្ម ហើយជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ កាលគង់ព្រះជន្មនៅឡើយ លោកបានមានថេរដីកាជាមួយខ្ញុំថារូបកាយរបស់មនុស្សទាំង ៣ កំណាត់នេះ មិនដឹងជាកំណាត់ណាកើតមុនទេ តែបើនិយាយអំពីសាច់ដែលបានកើតឡើងមុនគេនោះ ក៏មិនមានសាច់ឯណាដទៃក្រៅអំពីសាច់ដែលគម្ពីរហៅថា **“ហទយវត្ថុទេ”** ព្រោះសាច់នេះជាទីតាំងនៅនៃវិញ្ញាណ។ សម្តេចបានបញ្ជាក់ថា វិញ្ញាណនិងសាច់នេះត្រូវតែកើតព្រមគ្នា ព្រោះថាបើវិញ្ញាណ

បដិសន្ធិហើយមិនមានសាច់នេះវិញ្ញាណក៏នៅពុំបាន បើសាច់នេះកើតហើយមិនមានវិញ្ញាណមកអាស្រ័យនៅក៏រីកចម្រើនទៅពុំកើត គឺថាមិនអាចកើតទៅជាមនុស្សបានទេ ប្រាកដជានឹងរលាយបាត់ទៅវិញមិនខាន។ យោបល់របស់សម្តេចនេះ មានហេតុផលល្មមទុកជាមេរៀនមួយ ព្រោះយោបល់នេះបានធ្វើឱ្យយើងភ្លឺច្រើន ក្នុងការសិក្សាអំពីរឿងវិញ្ញាណនេះ ។ ហើយយោបល់នេះ នាំឱ្យយើងឃើញមួយបែបទៀតថា ជីវិតមនុស្សដែលនឹងប្រព្រឹត្តទៅបានត្រូវមានហទយវត្ថុនេះ ដរាបណាហទយវត្ថុមិនមានដរាបនោះចក្រយន្តនៃជីវិតក៏ដើរទៅពុំបាន ។ ដូចខ្ញុំបាននិយាយមកហើយថាគ្រូពេទ្យគេបានឃើញអវយវៈរបស់ជីវិតក្នុងបឋមកំណើត ហើយគេបានបញ្ជាក់ថាអវយវៈនេះប៉ែកខាងក្បាលធំជាង គេមិនបានសម្រេចអំពីការកើតមុនក្រោយនៃភាគណាមួយក្នុងអវយវៈទាំងអស់នោះទេ តែប្រសិនណា បើគេចង់និយាយឬគេនិយាយថា ក្បាលកើតមុនគេនោះសរីរយន្តនៃជីវិតនេះត្រូវកើតភាគខាងលើមុន ព្រោះក្បាលនៅក្នុងកំណាត់ខាងលើ។ ពាក្យឬយោបល់របស់គ្រូពេទ្យក៏បានជាមេរៀនរបស់យើងមួយដែរ ព្រោះអ្វី? ព្រោះថានៅក្នុងលលាដ៏ក្បាល មានវត្ថុធាតុមួយយ៉ាងចម្លែកហៅថា ខួរក្បាល វត្ថុធាតុ នេះមានសម្បុរសមានលក្ខណៈជាដុំសាច់ជ្រាយៗដូចដុំម្សៅដែលត្រូវគេផ្សើមទឹក តែពុំមែនជាដុំសាច់ជាប់គ្នាទាំងអស់ទេ គឺជាសាច់មានលក្ខណៈជាស្រាទាប់ៗគឺនៅក្នុងកន្លែងនេះហើយ ដែលគេទុកដាក់ថាទីស្ថិការរបស់វិញ្ញាណ ។

មានរឿងមួយទៀតដែលគួរឱ្យសង្កេតខ្លាំងឡើងទៀត គឺខាងពេទ្យថាជីវិតក្នុងខែដំបូងមានក្បាលធំជាងគេ ។ ចំណែកពុទ្ធសាសនាថាជីវិតក្នុងខែដំបូងៗគឺទើបនឹងកើតថ្មីៗ ជាកលលៈនោះ មានវត្ថុទសកៈបានកើតមានក្នុងខណៈដែលវិញ្ញាណមកបដិសន្ធិ បើវិញ្ញាណមិនបានមកបដិសន្ធិ វត្ថុទសកៈក៏មិនមាន ហើយវត្ថុទសកៈនេះអ្នកប្រាជ្ញខាងចិត្តសាស្ត្រសំដៅយកខួរក្បាល អ្នកប្រាជ្ញខាងពុទ្ធសាសនាសំដៅយកបេះដូង សេចក្តីនេះនៅក្នុងការដណ្តើមយកត្រូវទាំងសងខាង។ ដើម្បីឱ្យអ្នកអានបានធូរគំនិត ហើយបានចំណេញពេលផងនោះ ខ្ញុំសូមបំភ្លឺថាមិនមែនជាការខុសត្រូវគ្នាប៉ុន្មានទេ ចំពោះពាក្យថាបេះដូងនឹងពាក្យថាខួរក្បាល ព្រោះវត្ថុធាតុទាំងពីរនេះ ជាកន្លែងស្នាក់របស់វិញ្ញាណ ហើយយើងក៏មានពាក្យកណ្តាលមួយទៀតហៅថា “**កាលវិញ្ញាណ**” ពាក្យថាកាយវិញ្ញាណនេះ ជាពាក្យសម្រាប់បង្ខិតគំនិត អ្នកបេះដូងនឹងអ្នកខួរ

ក្បាលឱ្យចូលជិតគ្នាបាន ព្រោះអ្វី? ព្រោះពាក្យថា "**កាយ**" លោកដៅយកអាការៈទាំងអស់របស់ជីវិត ដែលនៅក្នុងនោះមានបេះដូងនិងខួរក្បាលផង។ ដូច្នេះពាក្យថា វត្ថុទសកៈ ឬហទយវត្ថុនោះ យើងចង់និយាយទៅលើបេះដូងក៏បាន ទៅលើខួរក្បាលក៏បាន ប្រសិនបើយើងបានយល់ន័យពាក្យថា "**កាយ**" ដូចខ្ញុំបាននិយាយមកហើយ ។

★ ★ ★

# ភវង្គចិត្តនៅត្រង់ខួរក្បាល ឬនៅត្រង់ហទយវត្ថុ?

ពាក្យថា "**ខួរក្បាល**" ក្នុងទីនេះ ប្រែមកអំពីពាក្យបាលីថា ហទ័យវត្ថុ ដែលធ្លាប់ប្រែមកថា វត្ថុគឺបេះដូង ។ ពាក្យថាហទយវត្ថុនេះបើប្រែទាំងអស់ត្រូវប្រែថា ទីតាំងរបស់ចិត្ត ឬលំនៅរបស់ចិត្ត ឬកន្លែងជាទីអាស្រ័យនៅនៃចិត្ត ។ ព្រះពុទ្ធឃោសាចារ្យលោកអធិប្បាយថា បេះដូងជាដុំសាច់មួយស្ថិតនៅក្នុងដើមទ្រូងប៉ែកខាងឆ្វេង ជាទីតាំងនៅនៃមនោវិញ្ញាណ ។ លោកបញ្ជាក់ថា ទឹករក្សាបេះដូងទឹកលោហិត លោកថាទឹកនេះមានសម្បុរផ្លាស់ប្តូរទៅតាមចរិតរបស់មនុស្ស ដូចជាមនុស្សមានចិត្តប្រកបដោយរាគចរិត ទឹកនេះមានសម្បុរក្រហម ទោសចរិតសម្បុរខ្មៅ មោហចរិតសម្បុរទឹកលាងសាច់ វិតក្កចរិត សម្បុរដូចទឹកស្ងោរសណ្តែកបាយ សទ្ធាចរិតសម្បុរដូចផ្កាកណ្ដិកា បញ្ញាចរិតមានសម្បុរសជ្រះ ។

ការពិតប្រសិនបើយើងចេះដឹងខាងកាយវិភាគនឹងសរីរសាស្ត្រ ស្គាល់របៀបទាក់ទងរវាងប្រសាទនានាជាមួយខួរក្បាល ស្គាល់មុខងាររបស់ខួរក្បាល។ យើងនឹងឃើញថា សេចក្តីចូលចិត្តរបស់ព្រះពុទ្ធឃោសាចារ្យ ជាសេចក្តីចូលចិត្តហួសសម័យ។ តែបើយើងអធិប្បាយថា បេះដូងជាទីតាំងនៃមនោវិញ្ញាណនោះជាអវយវៈសំខាន់បំផុតសម្រាប់ទ្រទ្រង់នូវវិញ្ញាណ បើកាលណាអវយវៈចំណែកនេះឈប់ធ្វើការត្រឹមតែមួយភ្លែតមនោវិញ្ញាណក៏រលត់ភ្លឺបក្នុងខណៈនោះភ្លាម សេចក្តីអធិប្បាយនេះសាមញ្ញជនទូទៅអាចស្តាប់បាន ហើយប្រហែលជាលោកចូលចិត្តដូចសេចក្តីអធិប្បាយនេះហើយមើលទៅបានជាលោកនិយាយថា បេះដូងជាទីតាំងនៅនៃមនោវិញ្ញាណ ។

លោហិតរបស់យើង ជាវត្ថុធាតុសំខាន់បំផុត ព្រោះវត្ថុធាតុនេះត្រូវជាអាហាររបស់កោសិកា កោសិកាត្រូវការលោហិតរាល់ៗ ខណៈ ។ សេចក្តីដឹងឬមនោសញ្ចេតនាក្នុងកោសិកា កើតបានជាបច្ច័យមួយបែបសម្រាប់ធ្វើឱ្យមានកំដៅក្នុងរបបរបស់កោសិកា ប្រសិនបើកោសិកាមិនបានទទួលលោហិត កោសិកានោះក៏ត្រូវស្លាប់ ត្រូវអស់សេចក្តីដឹងព្រមៗគ្នា ។ បេះដូងរបស់យើងមានមុខងាររសប់ឬបាញ់លោហិតឱ្យចូលទៅក្នុងកោសិកា ដើម្បីឱ្យកោសិកាទាំងអស់នោះបានរស់នៅជាប្រក្រតី។ ដូច្នេះហើយបានជាយើងនិយាយថា បេះដូងជាទីតាំងនៅនៃមនោវិញ្ញាណ តែយើងមិនត្រូវ

ភ្លេចថា បេះដូងនឹងប្រតិបត្តិការរបស់ខ្លួនបានក៏ព្រោះតែមានសេចក្តីបង្គាប់មកអំពីខួរក្បាលឬមានកម្លាំងមកអំពីខួរក្បាល ។ ជីវិតកាលទើបនឹងកើតថ្មីៗ ពេទ្យបានពិសោធឃើញថា ខួរក្បាលបានរីកចម្រើនមុនអវយវៈចំណែកណាៗ ទាំងអស់ដែលក្នុងខណៈនោះ គេពុំទាន់បានឃើញបេះដូងផងទេ។ កាយប្រសាទជាខ្មែងនៃអវយវៈបែកចេញទៅអំពីខួរក្បាលឬអំពីហទយវត្ថុ។ ពុទ្ធសាសនាបានបញ្ជាក់ថា *"កាយទសកៈគឺកាយប្រសាទនឹងវត្ថុទសកៈគឺហទយវត្ថុ ។ វត្ថុទាំងពីរបានកើតព្រមគ្នា តាំងអំពីវិញ្ញាណចូលមកចាប់បដិសន្ធិ"* បើតាមសេចក្តីបញ្ជាក់នេះ ហទយវត្ថុគឺជាខួរក្បាលនុ៎ះឯង ។

សេចក្តីពិត ហទយវត្ថុគួរប្រែថា វត្ថុជាទីតាំងនៃហឫទ័យពាក្យថា ហឫទ័យក្នុងទីនេះសំដៅយកវិញ្ញាណ ខួរក្បាលជាទីតាំងនៃវិញ្ញាណដៅដល់ទីតាំងនៃបដិសន្ធិវិញ្ញាណ ដែលក្រោយមកបានទៅជាភវង្គវិញ្ញាណព្រោះនាទីនៃបដិសន្ធិវិញ្ញាណ មានត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះទេ ។ សេចក្តីនេះនាំឱ្យយើងយល់ថា ការរីកចម្រើននៃរាងកាយរាល់ចំណែកកើតមកអំពីខួរក្បាល បើខួរក្បាលត្រង់ចំណែកដែលឱ្យបញ្ជាទៅលើអវយវៈចំណែកណាមិនមានសេចក្តីចម្រើន អវយវៈចំណែកនោះក៏ចម្រើនតទៅទៀតពុំបានឡើយ។ ចាកល័ខឋាននេះ សម្តែងឱ្យឃើញថា វិញ្ញាណដែលមកបដិសន្ធិនោះ តាំងនៅក្នុងហទយវត្ថុឬខួរក្បាល ទាក់ទងជាមួយខួរក្បាល ហើយបានសាងខួរក្បាលមុនអវយវៈចំណែកដទៃៗ ។ វិញ្ញាណជារបបនៃកងថាមពល មាននៅក្នុងរូបកាយរបស់មនុស្សម្នាក់ៗ អវយវៈផ្សេងៗនៃរាងកាយបានរួបរួមនៅក្នុងរបៀបរៀបរយមានការទាក់ទងគ្នាយ៉ាងល្អនោះ បានសម្តែងឱ្យឃើញនូវនាទីយ៉ាងញឹកល្អិតនិងសេចក្តីប៊ិនប្រសប់របស់វិញ្ញាណយ៉ាងចម្លែក ព្រោះរាងកាយជាវត្ថុធាតុសម្រាប់សម្តែងចេញនូវអំណាចនិងសេចក្តីខ្លាំងពូកែរបស់វិញ្ញាណខាងស្ថាបនា ជាប្រាកដការណ៍របស់វិញ្ញាណខាងផ្លូវវត្ថុ។ បើការិយាល័យកណ្តាលនៃវិញ្ញាណនៅត្រង់ហទយវត្ថុឬនៅត្រង់ខួរក្បាល អង្គភពកណ្តាលនៃវិញ្ញាណក៏នៅក្នុងទីនោះដែរ។ កុំភ្លេចថាវិញ្ញាណជាថាមពលនៃនាមធម៌ មាននៅរាល់ៗកោសិកានៃជីវិតវិញ្ញាណជាខន្ធ។ ខន្ធះប្រែថាបាច់ ដុំ, កង, ។ វិញ្ញាណមិនមែនតែមួយដួងទេគឺមានច្រើនដួង ។ តែវិញ្ញាណរបស់មនុស្សម្នាក់ៗ ជាធម្មធាតុនៅរួមគ្នាជាដុំៗដូចដុំនៃអណ្តាតភ្លើង សឹងប្រកបទៅដោយអណ្តូនៃ

អណ្តាតភ្លើងច្រើនលានកោដិ រហូតដល់រាប់មិនអស់។ វិញ្ញាណក្នុងរូបកាយរបស់យើង ទោះជាមានច្រើនដោយបរិមាណ ដោយលក្ខណៈនិងដោយប្រភេទ តែវិញ្ញាណជាធម្មតានៅរួមគ្នាតែមួយជុំ ហើយជាធម្មធាតុចេះប្រាស្រ័យទាក់ទងគ្នានៅក្នុងរបៀបយ៉ាងប្រសើរបំផុត។ ព្រោះតែវិញ្ញាណជាធម្មជាតិនេះរួមគ្នាជាកង ទើបពុទ្ធសាសនាហៅថាវិញ្ញាណក្ខន្ធ ។ ព្រោះតែកងនៃវិញ្ញាណមានរបៀបរៀបរយជាទីបំផុត ទើបមនុស្សយើងចូលចិត្តថា វិញ្ញាណត្រូវសាងឡើងដោយធម្មជាតិឬដោយព្រះអាទិទេព ។

★ ★ ★

# សេចក្ដីវិនិច្ឆ័យ

**វិញ្ញាណបដិសន្ធិបានចំពោះតែក្នុងវត្ថុធាតុមានជីវិត**

នៅសល់បញ្ហាមួយទៀតដែលពុំទាន់បាននិយាយដោយច្បាស់លាស់គឺ មុនដែលវិញ្ញាណនឹងមកបដិសន្ធិនោះខាងពុទ្ធសាសនាបានទទួលស្គាល់តាម របៀបនេះឬក៏មិនទទួលស្គាល់ទេ(១) ថាត្រូវមានវត្ថុធាតុសម្រាប់ផ្សំកំណើត(២) ជាវត្ថុធាតុនោះត្រូវនៅក្នុងរូបធាតុមានជីវិត(៣) ថារូបធាតុមានជីវិតនោះកំពុងមានសេចក្ដីរីកចម្រើន ហើយនៅក្នុងវត្ថុធាតុ (ផ្សំកំណើត) នោះមានវិញ្ញាណជាប់មកអំពីឪពុកម្ដាយផង។ វត្ថុផ្សំកំណើតណាមិនមានវិញ្ញាណមកបដិសន្ធិ វត្ថុផ្សំកំណើតនោះ ទោះជាមានសេចក្ដីរីកចម្រើនក៏ពុំបានកើតជាមនុស្ស ។ វិញ្ញាណដែលមកបដិសន្ធិបានចំពោះតែក្នុងវត្ថុធាតុមានជីវិតប៉ុណ្ណោះឬ? ចំពោះបញ្ហានេះ ពុទ្ធសាសនាបានទទួលដឹងតាមរបៀបនេះទាំងអស់ វៀរលែងតែត្រង់ចំណុចថា ត្រូវមានវិញ្ញាណចេញមកអំពីមាតាបិតាប៉ុណ្ណោះ ព្រោះល័ខពុទ្ធសាសនាបានថែងយ៉ាងច្បាស់ហើយថា ÷

**"កាលណាប្រកបដោយបច្ច័យ ទាំង ៣ នេះគឺ :**

**១) មាតាបិតានៅរួមគ្នា**

**២) មាតាមានរដូវ**

**៣) មានវិញ្ញាណមកបដិសន្ធិ ទើបសត្វកើតឡើងក្នុងគភ៌បាន"**

***"កម្មជរូប ៣០ កើតព្រមគ្នាជាមួយបដិសន្ធិវិញ្ញាណ"***

ចំណុចនេះ បានអធិប្បាយម្ដងមកហើយ ក្រៅអំពីនេះនៅមានចំណុចមួយទៀតដែលលោកបាននិយាយយ៉ាងច្បាស់លាស់ថា ÷

***"មានតែរូបប៉ុណ្ណោះទេ ដែលអាចញុំាងរូបឱ្យកើតបាន ចំណែកខាងអរូប នឹងញុំាងរូបឱ្យកើតពុំបានឡើយ"***

-សម្មោហវិនោទនី-

ក្នុងចំណុចនេះមានន័យថា រូបគឺរាងកាយរបស់មនុស្សសត្វដែលនឹងកើតឡើងបាន ត្រូវមានរូបមកអំពីដើមឬត្រូវមានរូបចាស់មុន ដូចមានវត្ថុធាតុផ្សំកំណើតហើយ បើមិនមានរូប សូម្បីវិញ្ញាណមាន ហើយវិញ្ញាណជាបច្ច័យឱ្យកើតរូបបានក៏ពិត តែ

វិញ្ញាណក៏មិនអាចនឹងសាងរូបចាកអាកាសធាតុបានឡើយ។ ដូចគ្នាប្រាជ្ញក្រិកម្នាក់បាននិយាយថា :

*"របស់ទាំងអស់កើតមកអំពីទទេពុំបានឡើយ"*

**-ប្រវត្តិទស្សនវិជ្ជា-**

ពុទ្ធសាសនាថា វិញ្ញាណជាបច្ច័យឱ្យកើតរូប ក៏ចំពោះកាលណាមានរូបហើយដែរ ហើយវិញ្ញាណនោះមានមុខងារត្រឹមតែជាបច្ច័យមួយធ្វើឱ្យរូបកើតឡើង បានសេចក្តីថាវិញ្ញាណមានអំណាចធ្វើឱ្យរូបកើតជារូបប៉ុណ្ណោះ វិញ្ញាណពុំអាចធ្វើគ្មានឱ្យកើតទៅជារូបបានទេ តែវិញ្ញាណជាបច្ច័យសំខាន់របស់រូប ដូចជាងឈើជាបច្ច័យសំខាន់របស់ផ្ទះ។ នាយជាងសាងផ្ទះអំពីឈើ បើឈើមិនមាន នាយជាងក៏សាងផ្ទះពុំកើត ។ រូបកាយមនុស្សយើងកើតមកអំពីធម្មជាតិផ្សំកំណើតដែលជារូប រីកចម្រើនធំធាត់ឡើងដោយអាហារដែលជារូប។ ដោយន័យនេះ ទើបព្រះអត្ថកថាចារ្យពោលថា **"រូបប៉ុណ្ណោះដែលញ៉ាំងរូបឱ្យកើត អរូបមិនអាចញ៉ាំងរូបឱ្យកើតបានទេ"** លោកបានពោលមួយកន្លែងទៀតថា :

*"ព្រោះហេតុអ្វី វិញ្ញាណដែលទៅកើតក្នុងអរូប ទើបមិនញ៉ាំងរូបឱ្យកើត? ព្រោះក្នុងអរូបនោះមិនមាន[6] រូប"*

**-សម្មោហវិនោទនី-**

រូបដែលនឹងរីកចម្រើនឡើងបាន ត្រូវកើតក្នុងវត្ថុធាតុមានជីវិត បើរូបនោះមិនមានជីវិតឬរូបនោះស្លាប់ (បែកធ្លាយ) វិញ្ញាណក៏ពុំអាចមកបដិសន្ធិក្នុងរូបរបៀបនេះបានទេ ។ សេចក្តីនេះមាននិយាយច្បាប់លាស់ក្នុងអភិធម្មបិដកដូចនេះ :

*"រូបជីវិតិន្ទ្រិយជាបច្ច័យនៃកម្មជរូប ដោយឥន្ទ្រិយបច្ច័យ"*

**-បដ្ឋាន-**

**"រូបជីវិតិន្ទ្រិយ"** ប្រែថា ឥន្ទ្រិយគឺជីវិតរបស់រូប **"ឥន្ទ្រិយ"** ប្រែថា **"ធំ"** ឬរបស់ដែលធំឬមានសេចក្តីសំខាន់ច្រើន ដូចភ្នែកជាធំក្នុងការឃើញ ត្រចៀកជាធំក្នុងការឮ ច្រមុះជាធំក្នុងការថើប ទើបបានឈ្មោះថាជាឥន្ទ្រីយមួយៗ ។ បាលី ហៅថា ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ។ ជីវិតរបស់រូបក៏រាប់ថាជាឥន្ទ្រិយមួយព្រោះថាបើរាងកាយមិន

---

6 "អរូប" ក្នុងទីនេះសំដៅយកវិញ្ញាណរបស់សត្វ ដែលទៅកើតក្នុងអរូបព្រហ្ម ។

មានជីវិត រាងកាយក៏គង់តាំងនៅជារាងកាយពុំបាន ។ ដូច្នេះជីវិតរបស់រូប ទើបលោកចាត់ជាឥន្ទ្រិយមួយ ហៅថា រូបជីវិតិន្ទ្រិយ ពាក្យនេះ**វិសេដវិដស៍** ប្រែថា faculty of life, vitaltty ។

កោសិកានៃកាយប្រសាទក្តី កោសិកានៃខួរក្បាលក្តី កោសិកានៃអវយវៈខាងពេសក្តី របស់ទាំងអស់នេះសុទ្ធតែមានជីវិត ចេះស្រូបយកអាហារថ្មីៗ រាល់ៗ ខណៈយកទៅប្រើ ជំនួសអាហារចាស់ដែលត្រូវរំលាយទៅ។ ខាងពុទ្ធសាសនាបាននិយាយថា រូបជីវិន្ទ្រិយ ជាបច្ច័យនៃកម្មជរូប ហើយកម្មជរូបក៏គឺកោសិកានៃជីវិតទាំងឡាយដូចបានពោលមកហើយ ។ សូមសង្កេតថា កម្មជរូប ជាវត្ថុធាតុកើតព្រមជាមួយបដិសន្ធិវិញ្ញាណដែលនៅក្នុងខណៈនោះ បឋមកំណើតនៅជាកលលៈ កលលៈរូបមានទំហំតូចប៉ុនដំណក់ប្រេងល្ងដែលជាប់នៅចុងនៃរោមចាមរី ដែលត្រូវគេរលាស់ចោលអស់៧ដង ។ បើពិចារណាឱ្យជ្រៅជ្រះតាមសេចក្តីនេះ យើងអាចឆ្លើយបញ្ហាផ្សេងៗដែលចោទឡើងថា តើពុទ្ធសាសនា និយាយថាម៉េច? មុនអំពីវិញ្ញាណមកបដិសន្ធិនោះមានវត្ថុធាតុផ្សំកំណើតមែនឬ ? ហើយវត្ថុផ្សំកំណើតនោះជាធម្មជាតិមានជីវិតមែនទេ? ។ល។

★ ★ ★

# ការខ្វែងយោបល់គ្នា

## អំពីរឿងវិញ្ញាណក្នុងពុទ្ធសាសនានិងព្រះអាទិទេព

ដើម្បីឱ្យអ្នកអានបានចូលចិត្ត សេចក្តីដៅនៃវិញ្ញាណក្នុងពុទ្ធសាសនានិងសេចក្តីដៅនៃវិញ្ញាណ ក្នុងគ្រឹស្តសាសនាដែលគេចង់ដឹង ថាតើមានសេចក្តីប្លែកគ្នាយ៉ាងណាខ្លះនោះ ខ្ញុំសូមលើកយកល័ខគ្រឹស្តសាសនានោះមកបៀបនឹងពុទ្ធសាសនាដូចមានតទៅនេះ :

*"អំពីដើម វាទៈនោះទៅជាមួយព្រះជាម្ចាស់ ហើយវាទៈនោះបានបង្កើតឡើងជាសាច់ជាស្បែក"*

-យ៉ូហាន់-

ពាក្យនេះមានន័យថា ព្រះជាម្ចាស់សឹងជាព្រះវិញ្ញាណមួយ អាចបណ្តាលឱ្យមនុស្សកើតមកចាកវាទៈរបស់ព្រះអង្គបាន ។

*"កាលពីដើម ព្រះជាម្ចាស់បាននិម្មិតឱ្យកើតជាមេឃនិងដី ដីនោះក៏នៅវាលទទេ មានតែភាពងងឹតនៅលើដីនោះ ព្រះជាម្ចាស់បានត្រាស់ឱ្យកើតភាពភ្លឺស្វាង ហើយភាពភ្លឺស្វាងក៏បានកើតឡើង"*

-យ៉េនេស៊ិស-

*"ព្រះជាម្ចាស់ត្រាស់ឱ្យមានដួងពន្លឺលើមេឃ អាកាស ជាទីបែងចែកថ្ងៃចេញអំពីយប់ ឱ្យដួងពន្លឺនោះកំណត់ រដូវ, ខែ, ឆ្នាំ, ថ្ងៃ ឱ្យនៅលើផ្ទៃអាកាស សម្រាប់ឱ្យភ្លឺមកលើផែនដី។ ដូច្នេះព្រះជាម្ចាស់ទើបបានសាងដួងពន្លឺធំពីរដួង ឱ្យដួងធំនោះគ្រងរក្សាថ្ងៃ ឱ្យដួងតូចនោះគ្រងរក្សាយប់ ហើយព្រះអង្គបង្កើតឱ្យមានដួងផ្កាយដទៃៗផង ។ ព្រះជាម្ចាស់ទ្រង់តាំងដួងពន្លឺអស់ទាំងនេះ ឱ្យនៅក្នុងផ្ទៃមេឃអាកាសឱ្យឆ្លុះបំភ្លឺមកលើផែនដី ឱ្យគ្រងរក្សាថ្ងៃនិងយប់ ហើយឱ្យបែងចែកភាពភ្លឺស្វាងចេញអំពីភាពងងឹត ។ ព្រះជាម្ចាស់ទ្រង់ឃើញថាល្អ មានវេលាត្រជាក់ក្តៅហើយនៅព្រឹកថ្ងៃទី៤ (ព្រះអង្គបានសាងហើយទាំងអស់)"*

-យ៉េនេស៊ិស-

*"ព្រះជាម្ចាស់ទ្រង់សាងមនុស្សឡើង តាមបែបឆាយារបស់ព្រះអង្គហើយតាមបែបឆាយារបស់ព្រះអង្គនោះ ព្រះជាម្ចាស់ទ្រង់បានសាងមនុស្សឡើង ហើយបានទ្រង់សាងឱ្យជាប្រុសនិងស្រី"*

**-យ៉េនេស៊ិស-**

*"ព្រះយ៉ះហូវ៉ាបានទ្រង់សាងមនុស្សដោយផង់ធូលីដី ទ្រង់ផ្លុំខ្យល់នៃជីវិតបញ្ចូលតាមច្រមុះ ឱ្យមានជីវិតដកដង្ហើមចេញចូល មនុស្សទើបកើតជាចិត្តវិញ្ញាណ មានជីវិតរស់នៅ"*

(And the lord god formed man of the dust of the ground and breathed into his nostrils the breath of life and man became A lireing sotil)

**-យ៉េនេស៊ិស-**

"តាមល័ខនៃគ្រឹស្តសាសនានេះ ឃើញថាព្រះជាម្ចាស់អាចសាងរបស់រាល់យ៉ាងឡើងចាកវាទៈរបស់ព្រះអង្គ ជាដំបូងផ្តើមសាងផែនដី ទឹក ផ្ទៃមេឃ ដួងអាទិត្យ ដួងច័ន្ទ តែដួងផ្កាយទាំងឡាយមិនទាន់មានទេ ហើយព្រះអង្គក៏ទ្រង់បង្កើតឱ្យមានឡើង។ ក្នុងទីបំផុតព្រះអង្គទ្រង់សាងមនុស្សអំពីផង់ធូលី ។ សូមសង្កេតថាព្រះជាម្ចាស់ពុំបានសាងមនុស្សអំពីភាពគ្មានទេ ព្រះអង្គទ្រង់សាងផែនដី និងវត្ថុផ្សេងៗ ដែលជាចាំបាច់សម្រាប់ជីវិតជាមុន ហើយទើបទ្រង់សាងមនុស្សអំពីដី ទ្រង់ផ្លុំបញ្ចូលខ្យល់ជីវិតតាមច្រមុះ ស្រេចហើយទើបរូបនោះក្លាយទៅជាមនុស្សមានជីវិត មានមនោសញ្ចេតនាចេះគិតចេះនឹកដល់ហេតុការណ៍ផ្សេងៗ។ សូមអានប្រយោគភាសាអង់គ្លេសនឹងនាំឱ្យចូលចិត្តសេចក្តីដៅឬន័យរបស់ពាក្យកាន់តែច្បាស់ឡើងទៀតជាច្រើន ។

ពុទ្ធសាសនានិងគ្រឹស្តសាសនា បាននិយាយត្រូវគ្នាត្រង់ចំណុចថា អ្នកសាងជីវិតនោះគឺវិញ្ញាណ តែវិញ្ញាណខាងពុទ្ធសាសនា មិនបានទុកដាក់ទៅលើព្រះជាម្ចាស់ ព្រោះវិញ្ញាណដែលសាងជីវិតនោះ តាមប្រក្រតីរមែងត្រូវប្រកបដោយ អវិជ្ជា តណ្ហា ឧបាទាននិងកម្ម ។ គុណសម្បត្តិទាំងអស់នេះ យើងសង្កេតបានចាកវត្ថុធាតុមានជីវិតគ្រប់ប្រភេទលើពិភពលោកនេះ គឺជីវិតទាំងអស់នេះកើតមក មិនមានជីវិតណាមួយមានសេចក្តីបរិសុទ្ធឬមានសេចក្តីរឹងប៉ឹងដល់ទីបំផុតទេ ។ ជីវិតមួយៗសុទ្ធតែបាននាំ

មកជាមួយនូវសេចក្តីល្ងង់តាំងអំពីបឋមកំណើតឬតាំងតែអំពីទើបនឹងកើតមក សឹងសម្តែងឱ្យឃើញថា វិញ្ញាណដែលជាធម្មជាតិសាងជីវិតនោះនៅមានអវិជ្ជា។ ជីវិតរាល់ប្រភេទ មានសេចក្តីស្មុះស្មារមានកំណាន់នៅក្នុងខ្លួនឯង សឹងបង្ហាញឱ្យឃើញថា វិញ្ញាណដែលជាធម្មជាតិសាងជីវិត នៅមានតណ្ហានិងឧបាទាន។ ជីវិតនានាកើតមកមិនដូចគ្នា មានសេចក្តីល្ងង់ខ្លៅ និងសេចក្តីចេះដឹងមិនស្មើគ្នា មានជោគវាសនាមិនដូចគ្នា ។ល។ សឹងសម្តែងឱ្យឃើញថា សភាពនៃវិញ្ញាណនោះមិនដូចគ្នា ព្រោះមានការកសាងកម្មមកផ្សេងៗគ្នា ។ ចំណែកខាងគ្រីស្តសាសនាជឿថា ព្រះជាម្ចាស់ទ្រង់មានវិញ្ញាណបរិសុទ្ធ ប្រាសចាកកិលេសជា សព្វញ្ញូ ជាអ្នកទ្រទ្រង់នូវសេចក្តីយុត្តិធម៌ ហើយជាព្រះមួយព្រះអង្គពោរពេញទៅដោយសេចក្តីមេត្តាករុណាយ៉ាងខ្ពស់បំផុត ។ តែទឹកព្រះហឫទ័យរបស់ព្រះអង្គក្នុងការរៀបចំវត្ថុធាតុផ្សេងៗ មានមិនស្មើគ្នាដូចជាសាងមនុស្សមិនឱ្យស្មើគ្នា ទុកដាក់ឱ្យសត្វធំៗមានសិទ្ធិស៊ីសត្វតូចៗ បំណងរបស់ព្រះជាម្ចាស់ក្នុងរឿងនេះ មិនមានអ្នកណាអាចដឹងបាន ត្រូវនឹងពាក្យដែលអាចារ្យ **ប៉ូឡូ** បាននិយាយថា ***"អ្នកណានឹងស្គាល់ទឹកព្រះទ័យរបស់ព្រះជាម្ចាស់ដើម្បីនឹងបង្រៀនព្រះអង្គ"*** ។

ដោយសេចក្តីដៅយ៉ាងជ្រៅល្អិតនោះ យើងនឹងឃើញថាអំពីរឿងវិញ្ញាណក្នុងពុទ្ធសាសនានិងគ្រីស្តសាសនាមិនដូចគ្នាទាល់តែសោះ ។ ពិសេសជាងនេះទៅទៀត ក្នុងគ្រីស្តសាសនាគេមានជំនឿថា នៅក្នុងដើមឈើនិងសត្វមិនមានវិញ្ញាណ (មើលទៅខាងមុខ) ចំណែកពុទ្ធសាសានាមានជំនឿថា នៅក្នុងជីវិតរាល់យ៉ាងសុទ្ធតែមានវិញ្ញាណ ។ ក្នុងដើមឈើឬក្នុងពីជៈ (ពូជ) ផ្សេងៗក៏មានវិញ្ញាណ ។ តែបើក្នុងសភាពនៃធម្មជាតិមានជីវិតខុសគ្នា សភាពនៃវិញ្ញាណក៏រមែងខុសគ្នា ។

★ ★ ★

# សេចក្តីវិនិច្ឆ័យ

## អំពីដើមឈើមានវិញ្ញាណ

ក្នុងពុទ្ធសាសនា មានពុទ្ធសាសនិកខ្លះមានជំនឿថា ដើមឈើមិនមានវិញ្ញាណ ព្រោះដើមឈើជាអនុបាទិន្នកសង្ខារ ប្រែថាសង្ខារមិនមានចិត្តគ្រងរក្សា។ ការពិតរឿងនេះ កើតឡើងព្រោះសេចក្តីចូលចិត្តខុសអំពីពាក្យថា អនុបាទិន្នកៈ។ ពាក្យថា "**អនុបាទិន្នកៈ**" តាមស័ព្ទប្រែថាគឺកម្មមិនចូលទៅជិតកាន់យក (**តំ កម្មេន ឧបាទិន្នត្តា ឧបាទិន្នំ សេសំ តតោ វិបរិតត្តា អនុបាទិន្នំ**) ពាក្យទាំងនេះជាពាក្យបច្ចេកទេសក្នុងអភិធម្មជាពាក្យមានសេចក្តីដៅច្រើនជាន់ ឬមានន័យច្រើនស្រទាប់ មិនមែនដៅសេចក្តីថា មានវិញ្ញាណឬមិនមានវិញ្ញាណទេ។ ឧបាទិន្នកៈ ក៏គឺកម្មជរូប កម្មជរូបមាន ៩យ៉ាង ដូចដែលបានអប្បាយមកហើយ។ ចំពោះរឿងនេះបើចង់ដឹងសេចក្តីពិស្តារ គប្បីមើលក្នុងអភិធម្មសង្គណី ក្នុងនោះមានបែងចែកប្រភេទរបស់រូបយ៉ាងល្អិត បើមិនពិនិត្យឱ្យដិតដល់ នឹងចាប់យកសេចក្តីពុំបានឡើយ។ ដើម្បីឱ្យអ្នកអានបានដឹងជាបន្ទាន់ សូមឱ្យតួយ៉ាងខ្លះដូចមានតទៅនេះ :

ឧបាទិន្នករូបគឺ : ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយៈ ឥត្ថីភាព បុរិសភាព ជីវិតឬរូបណាៗ ទាំងអស់ដែលកើតអំពីកម្ម បានដល់រូប ក្លិន រស ផោដ្ឋព្វៈ អាកាសធាតុ អាបោធាតុ ភាពកើតរបស់រូប សន្តតិរបស់រូបអាហារ រូបទាំងអស់នេះ ហៅថា "**ឧបាទិន្នករូប**" ។

អនុបាទិន្នរូបគឺ : សំឡេង ចលនានៃកាយ ចលនានៃវាចា សេចក្តីស្រាលរបស់រូប សេចក្តីទន់របស់រូប សេចក្តីសមសួននៃការងាររបស់រូប សេចក្តីចាស់របស់រូប សេចក្តីបែកធ្លាយរបស់រូបឬរូបណាៗទាំងអស់ដែលមិនមែនកើតមកអំពីកម្ម បានដល់រូប ក្លិន រស ផោដ្ឋព្វៈ អាកាសធាតុ អាបោធាតុ សេចក្តីកើតរបស់រូប សេចក្តីតភ្ជាប់របស់រូប អាហាររូប ទាំងអស់នេះ ហៅថា "**អនុបាទិន្នករូប**" ។

**-ធម្មសង្គណី-**

អ្នកអានបានឃើញត្រួយ៉ាងត្រឹមប៉ុណ្ណេះ ក៏ល្មមពិចារណាឃើញថារឿងនេះមានសេចក្តីល្អិតណាស់ ប្រសិនបើយើងមិនសូវប្រសប់គិតនឹងវិលខួរជាមិនខាន ។ ដូច្នេះទើបមានអ្នកប្រាជ្ញរូបខ្លះ លោកនិយាយថាគម្ពីរអភិធម្មទាំងអស់ ដូចជាមិនមែនព្រះពុទ្ធសម្តែងមកទេ ព្រោះរបៀបសម្តែងនេះមិនមែនជាលក្ខណៈរបស់ព្រះពុទ្ធ។ ព្រះពុទ្ធអង្គមានប្រក្រតីធ្លាប់ធ្វើរបស់ក្រឱ្យកើតជារបស់ងាយ មិនធ្លាប់ធ្វើរបស់ងាយឱ្យទៅជាក្រទេ ។ ចំពោះរឿងនេះទោះព្រះពុទ្ធទ្រង់សម្តែងក្តី មិនសម្តែងក្តីសូមឱ្យរឿងនេះទៅជារឿងសម្រាប់ជជែកគ្នារវាងអ្នកប្រាជ្ញនិងអ្នកប្រាជ្ញចុះ។ ក្នុងទីនេះខ្ញុំមានមុខងារត្រឹមតែស្រង់យកមកនិយាយឱ្យបានជាត្រួយ៉ាងប៉ុណ្ណោះ។ តែរឿងដែលអ្នកប្រាជ្ញបានទទួលស្គាល់ថាជាពុទ្ធភាសិតពិតៗ នោះក៏គឺទាំងមហាភូតរូប ទាំងឧបាទាយរូបមានវិញ្ញាណថាបច្ច័យ ហើយវិញ្ញាណដែលមានមុខងារធ្វើជាបច្ច័យបាន ក៏ព្រោះតែវិញ្ញាណប្រកបដោយសង្ខារ គឺកម្ម។ បើតាមន័យនេះ របស់ផ្សេងៗ ក៏កើតមកអំពីកម្មទាំងអស់។ រឿងនេះគេអាចពិសោធបានចាកសេចក្តីពិតផ្សេងៗ ដូចបានអធិប្បាយមកហើយ។ តែក្នុងគម្ពីរធម្មសង្គណី ដែលលោកអធិប្បាយយ៉ាងល្អិតសក់មួយជ្រៀកជា ១០ ចំរៀកនោះ ប្រសិនបើយើង ចង់សិក្សាឱ្យចូលចិត្ត ត្រូវធ្វើចិត្តឱ្យត្រជាក់ៗហើយរកពេលឱ្យបានច្រើនៗ រៀបចំខួរក្បាលឱ្យបានល្អ ទន្ទេញមេរៀនឱ្យបានចាំពិតប្រាកដ ព្រោះរឿងនេះមានព្រំដែននៃសេចក្តីជាប់នៅជិតគ្នាណាស់... ប្រយ័ត្នតែចាំមិនល្អនឹងវាលចូលគ្នាប្រើការពុំបានឡើយ។ តែយ៉ាងណាក៏ដោយអនុបាទិន្នកសង្ខារ ដែលធ្លាប់ប្រែថា សង្ខារមិនមានចិត្តគ្រងរក្សានោះ មិនត្រូវសេចក្តីក្នុងរឿងនេះទេប៉ុន្តែកំហុសនេះមិនមែនជាកំហុសរបស់មនុស្សសម័យនេះ គឺជាកំហុសមានយូរណាស់មកហើយ គឺតាំងពី ព.ស. កន្លងទៅបានជាង ៩០០ឆ្នាំអ្នកដែលអធិប្បាយរឿងនេះខុសតាំងពីកាលនោះមក។ តាមអ្នកប្រាជ្ញខ្លះលោកថា គឺព្រះអត្ថកថាចារ្យ ដែលតែងគម្ពីរ អត្ថកថាធម្មសង្គណី ។ សម្រាប់ខ្លួនខ្ញុំ ខ្ញុំនឹកថា កំហុសនេះប្រហែលថាកើតមកអំពីអ្នកចម្លងតៗមកពុំមែនមកអំពីអ្នកតែងទេ ព្រោះខ្ញុំសង្កេតឃើញមានគម្ពីរនិងសាស្ត្រាជាច្រើន ដែលមានសេចក្តីខុសមកអំពីអ្នកចម្លង ។ តែរឿងខុសក្នុងគម្ពីរវិសេសខ្ពង់ខ្ពស់នោះ មានត្រឹមបន្តិចបន្តួចទេ ដែលខ្ញុំខំប្រឹងលើកយកមកនិយាយក្នុងទីនេះ ក៏ព្រោះមកអំពីខ្លាចថា ប្រសិនបើមានជំនឿថា ក្នុងដើមឈើមិនមានវិញ្ញាណនោះ ជំនឿនេះនឹងស្របទៅ

នឹងជំនឿដែលមាននៅក្នុងសាសនាជេនរបស់លោកមហាវីរៈ ដែលជាគូប្រជែងនៃពុទ្ធសាសនាក្នុងសម័យនោះ ។ ម្យ៉ាងទៀត ព្រោះក្នុងពុទ្ធកាលមានវិជ្ជាខាងជីវសាស្រ្តមិនទាន់រីកចម្រើនដូចសម័យបច្ចុប្បន្នបានជាព្រះពុទ្ធឃោសាចារ្យមិនបានអធិប្បាយ អំពីសេចក្តីសំខាន់របស់ខួរក្បាល ។ ចំណែកពាក្យថា "**ហទយវត្ថុ**" លោកមិនបានដៅយកខួរក្បាលទេ លោកដៅយកអវយវៈដែលជាចំណែកនៃបេះដូងវិញ។ ចំពោះរឿងនេះមិនថារូបអ្នកណាជារូបអ្នកណាទេ ជាលោកមហាវីរៈក្តី ជាព្រះពុទ្ធឃោសាចារ្យក្តី មិនមែនជាមនុស្សអន់ទេ តែដែលទៅជាមានអន់ដោយអន្លើខ្លះនោះ ក៏ព្រោះតែលោកកើតក្នុងពិភពលោកខុសសម័យប៉ុណ្ណោះ ។ ដូច្នេះយើងត្រូវតែអរគុណលោកបើកុំតែបានលោកនិយាយមានប៉ុណ្ណេះ យើងទាំងអស់គ្នានឹងងងឹតរកទ្វារចេញពុំឃើញ ហើយគំនិតនឹងពាក្យនិយាយរបស់លោកក៏ល្មមប្រើការបានតាមសម័យ មិនមែនជាការឥតប្រយោជន៍ទេ ។

ចំណែកសេចក្តីដែលព្រះពុទ្ធឃោសាចារ្យ បាននិយាយមិនចំនោះយើងគប្បីពិចារណាមើលក្នុងគម្ពីរបដ្ឋានត្រង់ចំណុចថា ***"ប្រសាទទាំង ៥ ជានិស្ស័យបច្ច័យរបស់វិញ្ញាណ ៥ មនោធាតុនឹងមនោវិញ្ញាណធាតុ គឺសេចក្តីនឹកនិងសេចក្តីដឹងអាស្រ័យនូវរូបណាហើយប្រព្រឹត្តទៅរូបនោះបានឈ្មោះថា ជានិស្ស័យបច្ច័យរបស់មនោធាតុនិងមនោវិញ្ញាណធាតុ"*** តាមសេចក្តីអធិប្បាយនេះ យើងរឹតតែឃើញថា រូបដ៏ជាបច្ច័យរបស់មនោធាតុនិងមនោវិញ្ញាណធាតុនេះ នឹងដៅយកបេះដូងពុំបានឡើយ តែទោះជាដូច្នេះក្តី ពាក្យថារូបណាក្នុងទីនេះព្រះពុទ្ធឃោសាចារ្យគង់ដៅយកបេះដូងដែលជាដុំសាច់នៅក្នុងដើមទ្រូងផ្នែកខាងឆ្វេងនុ៎ះឯង ។

បុគ្គលខ្លះមានជំនឿថា ដើមឈើមិនមានវិញ្ញាណក៏ព្រោះគេសង្កេតឃើញថាដើមឈើមិនមានមនោសញ្ចេតនា មិនមានសេចក្តីគិតដូចមនុស្សឬសត្វគ្រប់ប្រភេទ។ មិនចេះឈឺចាប់ក្នុងពេលដែលគេកាប់ មិនដឹងសេចក្តីសុខទុក្ខដែលមនុស្សនឹងសត្វគេតែងដឹងដូច្នេះជាដើម។ ជំនឿនេះខ្ញុំមិនបដិសេធទេ តែប្រសិនបើចង់ធ្វើខ្លួន ឱ្យជឿឡើងវិញ គប្បីពិចារណាថា មនុស្សយើងកាលទើបនឹងចាប់កំណើតថ្មីៗ សូម្បីក្នុងគម្ពីរក៏និយាយថា នៅក្នុងបឋមកំណើតនៃមនុស្ស មានកាយប្រសាទនិងខួរក្បាល ដែលគេពុំទាន់មើលឃើញនៅឡើយ តែវិញ្ញាណនេះនៅពុំទាន់ចេះគិតគូរ ពុំទាន់ចេះដឹងឈឺ

ចាប់ និងពុំទាន់មានមនោសញ្ចេតនា ដូចដើមឈើដែរ។ សេចក្តីដឹងឬសេចក្តីគិតនឹក ជាធម្មធាតុដែលត្រូវមានការទាក់ទងជាមួយរបបប្រសាទ ជាមួយនឹងខួរក្បាល ។ ដើមឈើបានជាពុំមានមនោសញ្ចេតនា ពុំមានសេចក្តីដឹងនិងមានសេចក្តីនឹកគិតក៏ព្រោះដើមឈើមិនមានរបបប្រសាទ មិនមានខួរក្បាល ។

មនុស្សយើងកាលទើបនឹងកើតថ្មីៗ ក៏ពុំទាន់មានមនោសញ្ចេតពុំទាន់មានសេចក្តីដឹង ព្រោះរបបប្រសាទរបស់យើងនៅពុំទាន់ចម្រើនពេញបរិបូណ៌ ។ ម្យ៉ាងទៀតសូម្បីយើងកើតធំខ្លួន មានវ័យចម្រើនហើយមានរបបប្រសាទគ្រប់គ្រាន់ មានខួរក្បាលល្អ តែខាងក្រោយមកខួរក្បាលត្រូវបានទទួលគ្រោះថ្នាក់ យើងក៏អស់សេចក្តីដឹងទៅវិញ នេះគឺជាសេចក្តីពិតរបស់ធម្មជាតិ ដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ការដឹងឬមនោសញ្ចេតនារបស់យើងនឹងប្រព្រឹត្តទៅបាននោះ ត្រូវទាក់ទងជាមួយខួរក្បាល ឬនឹងនិយាយថា ការទាក់ទងជាមួយមនោសម្ផស្សនិងមនោសម្ផស្ស ត្រូវអាស្រ័យខួរក្បាល ដូច្នេះវិញក៏បាន ។

អ្នកជីវសាស្រ្ត គេមិនមានសេចក្តីសង្ស័យទេ កាលណាគេបានដឹងថា ពុទ្ធសាសនាបានទទួលព្រមថាជីវិតមនុស្ស កាលទើបនឹងកើតថ្មីៗបានមានវិញ្ញាណចូលមកនៅអាស្រ័យហើយ ព្រោះអ្វី? ព្រោះមនុស្សឬសត្វឬពីជៈ រូបធាតុទាំងអស់នេះសុទ្ធតែកើតមកអំពីសេលល៍[7] ព្រឹត្តិកម្មរបស់សេលល៍ ក៏មានដូចៗគ្នា ក្នុងកាលណាគេដឹងថា អំណាចដែលធ្វើឱ្យឈាមក្លាយទៅជាអវយវៈផ្សេងៗ របស់មនុស្សឬសត្វគឺវិញ្ញាណនោះគេក៏រមែងចូលចិត្តថា អំណាចដែលធ្វើឱ្យដីក្លាយទៅជាចំណែកផ្សេងៗរបស់ដើមឈើ ក៏គឺវិញ្ញាណនុ៎ះឯងដែរ ។

អ្នកដែលយល់ថា ដើមឈើមិនមានវិញ្ញាណ កាលណាត្រូវគេសួរថា ប្រសិនបើដូច្នោះមែន តើជីវិតដើមឈើកើតមកអំពីអ្វី? គេនឹងឆ្លើយថាដើមឈើមានជីវិតកើតមកអំពីឧតុ (**រដូវ**) រីកចម្រើនឡើងអំពីឧតុ ។ ឧតុគេសំដៅយកសីតឧតុ រដូវត្រជាក់ និងឧណ្ហឧតុ រដូវក្តៅ ។ ឧតុ តាមសព្ទប្រែថា សម័យ គ្រា រដូវ កាល។ មានឧតុខ្លះ គេសំដៅយករដូវប្រចាំខែរបស់ស្រ្តី ។ តែក្នុងទីនេះ ពាក្យថា ស័តឧតុ និងឧណ្ហឧតុក៏គឺសីតុណ្ហភូមិនុ៎ះឯង ។ កំដៅមិនមានអ្នកណាអាចបដិសេធថា មិនមែនជារបស់មាន

[7] អ Cell ប Cellole = កោសិកា ឬ ទសកៈ (អង្គភពនៃវិញ្ញាណ)

ចំណែកសំខាន់ក្នុងការញ៉ាំងជីវិតឱ្យកើត តែបើមានត្រឹមតែរដូវមួយមុខ តើជីវិតអាចកើតបានឬទេ? មនុស្សយើងកើតមកអំពីរដូវ មិនមានរដូវកើតពុំបាន តែរដូវមួយមុខមិនមានធម្មជាតិដទៃប្រកបចូលផង ក៏ពុំអាចញ៉ាំងមនុស្សឱ្យកើតឡើងបានទេ។ ដូច្នេះ ឃើញថា អ្នកដែលមានជំនឿថា ដើមឈើមិនមានវិញ្ញាណ តែព្រមទទួលស្គាល់ថាមានជីវិតដោយជឿថា ជីវិតរបស់ដើមឈើកើតមកអំពីរដូវនោះ ជំនឿនេះ មានហេតុផលមិនគ្រប់គ្រាន់ទេ ។

សូមពិចារណាឱ្យល្អិតថា រូបធាតុដែលមានជីវិតមិនថាជាមនុស្សឬជាសត្វ ឬជាពីជៈ(រុក្ខជាតិ) រមែងត្រូវអាស្រ័យ សីតុណ្ហភូមិ សមគួរដល់សភាពនៃជីវិតរបស់ខ្លួន ។ សីតុណ្ហភូមិក្នុងរូបធាតុមានជីវិត កើតមកអំពីរំលាយអាហារ លទ្ធផលនៃអាហារដែលត្រូវបានរំលាយហើយ កើតបានជាថាមពល សម្រាប់ទ្រទ្រង់ជីវិត។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងថា **"វិញ្ញាណជាបច្ច័យឱ្យកើតធាតុ៤"** ក្នុងធាតុទាំង៤នេះ តេជោធាតុដែលប្រែថា ធាតុភ្លើង ក៏គឺសីតុណ្ហភូមិ។ កាលណាយើងដឹងថា អំណាចឃុំគ្រងការផ្លាស់ប្ដូររបបនៃសេលល៍ គឺវិញ្ញាណយើងគង់នឹងចូលចិត្តបានដោយងាយថា សីតុណ្ហភូមិក្នុងរាងកាយរបស់មនុស្ស ជាវត្ថុធាតុជាប់ទាក់ទងជាមួយវិញ្ញាណយ៉ាងម្ដេចឬមានវិញ្ញាណជាបច្ច័យយ៉ាងណា តួយ៉ាងដែលអាចឱ្យយើងសង្កេតបានងាយបំផុតនោះ ក៏គឺក្នុងពេលណាមួយ ដែលយើងត្រូវគេបំភ័យមិនឱ្យដឹងខ្លួនឬយើងមានគ្រោះថ្នាក់កើតឡើងដោយចៃដន្យ ក្នុងពេលនោះ យើងដឹងថា នៅក្នុងខ្លួនរបស់យើងមានកំដៅខុសប្រក្រតីកើតឡើងភ្លាម ហើយកំដៅនេះអាចធ្វើឱ្យយើងមានញើសហូរចេញក៏មាន សឹងសម្ដែងឱ្យឃើញថា សីតុណ្ហភូមិក្នុងរូបកាយជាប់ទាក់ទងជាមួយវិញ្ញាណយ៉ាងជិតស្និទ្ធជាទីបំផុត ។ មនុស្សស្លាប់ហើយ រាងកាយត្រូវត្រជាក់បន្តិចម្ដងៗ តាមលំដាប់ កំដៅខាងក្រៅមិនអាចបង្កើតសីតុណ្ហភូមិក្នុងរាងកាយនៃមនុស្សបានឡើយ ក្នុងកាលណាវិញ្ញាណមិនមាន ។ ដូច្នេះទើបមិនគួរចូលចិត្តថា ជីវិតរបស់ដើមឈើកើតឡើង ដោយអាស្រ័យត្រឹមតែសីតុណ្ហភូមិប៉ុណ្ណោះទេ គឺត្រូវអាស្រ័យវិញ្ញាណផង ។ ដើម្បីឱ្យបានភ្លឺក្នុងរឿងនេះ ខ្ញុំសូមឱ្យអ្នកអានរឭកដល់ពុទ្ធភាសិតថា :

**"អាយុ ឧស្មាច វិញ្ញាណំ យទា កាយំ ច ហន្តិ មំ អបវិជ្ឈោ តទា សេតិ និរត្ថំ វកលិង្គរំ"**

ប្រែថា “**អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី បានលះបង់នូវកាយនេះក្នុងកាលណា កាយនេះ ក៏មិនមានប្រយោជន៍អ្វី ដូចកំណាត់ឈើស្ងួតក្នុងកាលនោះ**” ពុទ្ធភាសិតនេះ បានបំភ្លឺយើងថា ក្នុងរូបធាតុមានជីវិតទាំងអស់ តែកាលណាធម្មជាតិទាំង៣នេះគឺ : អាយុ១ ភ្លើងធាតុ១ វិញ្ញាណ១ មិនមានជីវិតក៏មិនមាន ។ អាយុក្នុងទីនេះ សំដៅយកជីវិត ភ្លើងធាតុក្នុងទីនេះសំដៅធាតុឧស្ម័ន (ធាតុកំដៅ) វិញ្ញាណក្នុងទីនេះ សំដៅយកវិញ្ញាណដដែលឬសំដៅយកចិត្ត ។ មានបញ្ហាមួយទៀតដែលជាប់ជាមួយបញ្ហាខាងលើនេះ គឺធាតុ ៦ ប្រការដែលមាននិយាយក្នុងពុទ្ធសាសនាបានដល់ធាតុដី ទឹក ភ្លើង ខ្យល់ វិញ្ញាណនឹងអាកាស ។ ពុទ្ធសាសនាបានយល់ថា រូបធាតុមានជីវិតទាំងអស់ត្រូវអាស្រ័យធាតុ ៦ ប្រការនេះខ្វះណាមួយពុំបានឡើយ។ ដូច្នេះរូបធាតុមានជីវិតទាំងឡាយ ទោះជាមនុស្សក្តី ទោះជាសត្វក្តី ទោះជារុក្ខជាតិក្តី បើមិនមានធាតុ៦នេះឬមានដែរតែមិនគ្រប់គ្រាន់ក៏ពុំអាចនឹងរស់នៅបានទេ ។ កាលណាយើងបានពិចារណាបញ្ហានេះដោយជ្រៅជ្រះ ហើយបានយល់បញ្ហានេះច្បាស់លាស់យើងនឹងបដិសេធថា ដើមឈើមិនមានវិញ្ញាណក៏ពុំបាន ព្រោះអ្វី? ព្រោះរូបធាតុមានជីវិត ត្រូវអាស្រ័យវិញ្ញាណ បើវិញ្ញាណមិនមាន ជីវិតក៏មិនមាន។ ដោយមានបញ្ហានេះ ទើបកើតមានបញ្ហាមួយទៀត ដែលតែងតែលេចឮក្នុងចំណោមអ្នកសាសនាឬអ្នកគិតគូរថា នៅក្នុងពិភពលោកយើងនេះមានមនុស្សកើតអំពីផ្កា សត្វកើតអំពីដើមឈើ ឬស្លឹកឈើ ឬត្រួយឈើ ឬឫសឈើ ។ល។ ចំពោះបញ្ហានេះ បើអ្នកអានបានយល់នូវសេចក្តីអធិប្បាយរបស់ខ្ញុំ ដែលបាននិយាយមកហើយថា វិញ្ញាណត្រូវកើតបានតែក្នុងរូបធាតុមានជីវិតនោះ អ្នកអានគង់យល់បញ្ហានេះបានហើយ ព្រោះរូបធាតុមានជីវិតរមែងត្រូវមានវិញ្ញាណ ។ កាលណាដើមឈើមានវិញ្ញាណហើយ វិញ្ញាណខាងក្រៅ ឬវិញ្ញាណដទៃ ឬវិញ្ញាណថ្មីអាចមកបដិសន្ធិក្នុងដើមឈើ ត្រង់ចំណែកណាមួយក៏បាន ឬវិញ្ញាណក្នុងដើមឈើនោះអាចនឹងតាក់តែងរូបជីវិតដើមឈើរបស់ខ្លួន ឱ្យកើតទៅជារូបជីវិតមួយថ្មីទៀតមានលក្ខណៈផ្សេងអំពីរូបជីវិតដើម ដូចជាដើមត្រស់ទៅជាសត្វអន្ទង់ ផ្កាត្បែងកើតបានជាសត្វចាប ត្រួយម្ទិះកើតបានជាសត្វកណ្តូប សាច់ខាងក្នុងនៃផ្លែល្វា កើតបានជាសត្វមង់។ល។ អ្នកអានគប្បីដឹងថា វិញ្ញាណតាមពុទ្ធសាសនាលោកថាមានគុណភាពមិន

ស្មើគ្នាទេ វិញ្ញាណមានគុណ[8] ភាពច្រើនទៅបដិសន្ធិក្នុងភពល្អឬអាចនឹងតាក់តែងរូបជីវិតរបស់ខ្លួនឱ្យបានល្អ វិញ្ញាណមានគុណភាពតិចមក[9] វិញ្ញាណនោះអាចនឹងទៅបដិសន្ធិក្នុងភពអន់ឬអាចនឹងតាក់តែងរូបជីវិតរបស់ខ្លួនឱ្យបានល្អតិចចុះមកតាម លំដាប់ ។ ចំណែកខាងវិញ្ញាណដែលមិនមានគុណភាព ឬមានគុណភាពមិនល្អក៏ត្រូវទៅបដិសន្ធិក្នុងរូបជីវិតដែលអន់ៗ មានដើមឈើជាដើម ឬក្នុងភពដែលពុំប្រកបដោយសេចក្ដីសុខសេចក្ដីចម្រើន ។

ដើមឈើគ្រប់បែប បើវាពុំបានទទួលធាតុត្រជាក់ ឬធាតុក្ដៅឱ្យបានគ្រប់គ្រាន់ដល់សេចក្ដីត្រូវការរបស់វា វាក៏ពុំអាចនឹងរស់នៅបានទេ ដូចដើមឈើដែលធ្លាប់រស់នៅក្នុងប្រទេសត្រជាក់ ដល់គេយកវាមកដាំក្នុងប្រទេសក្ដៅ ក៏វារស់នៅពុំបាន ព្រោះអាកាស ទឹក ដី មិនសមល្មមដល់សេចក្ដីត្រូវការរបស់វា ដោយអាស្រ័យហេតុនេះទេដឹង? ទើបមានគេយល់ថាដើមឈើកើតមកអំពីធាតុត្រជាក់ ក្ដៅ គឺគេលើកយកសីតុណ្ហភូមិថា ជាធំរបស់កំណើតនៃដើមឈើ គេបានភ្លេចអស់រលីង នូវល័ខនៃបដិច្ចសមុប្បាទត្រង់ចំណុចថា សីតុណ្ហភូមិ ក្នុងរូបធាតុមានជីវិតកើតអំពីវិញ្ញាណបើមិនមានវិញ្ញាណ សីតុណ្ហភូមិក្នុងរូបជីវិតរមែងមានពុំបានឡើយ ។

អ្នកអានប្រសិនបើនៅមានសេចក្ដីសង្ស័យ អំពីដើមឈើមានវិញ្ញាណឬរូបជីវិតមានវិញ្ញាណនោះ គប្បីពិចារណាមើលចលនាអាការៈនិងមុខងាររបស់វា ដូចការរៀបចំតាក់តែងដើម ការរចនាស្លឹក ការវិចិត្រផ្កា ការបរិភោគអាហារ ការដកដង្ហើម ការលូន ការវារ ការតោង ការចាប់ ការញោច ការកម្រើក ការភ្ញាក់ ការដេក ការគេច ការឱន ការទំលុះ។ល។ គឺវាធ្វើឱ្យដើមវាបានធំមាំខ្ពស់វែង វាខំប្រឹងចាក់ឫសឱ្យបានជ្រៅឆ្ងាយនៅជុំវិញដើម វាពាសដោយសំបក បំបែកដោយមែក គឺមានន័យថា វាចង់រស់នៅយូរព្រោះឈើវាបរិភោគអាហារតាមឫស មែក ស្លឹក ផ្កា ផ្លែរបស់វា តាំងនៅបានដោយសារឫស ។ វាតាក់តែងស្លឹកវាឱ្យមានសម្បុរល្អ មានទ្រនុង មានផ្ទៃស្តើងៗនិងមានក្បាច់ក្បូរច្រើនបែបច្រើនយ៉ាងទៀត ព្រោះវាដកដង្ហើមតាមស្លឹកហើយវាប្រកួតលំអជាមួយគ្នាវាក៏ដោយស្លឹក...។ វាខំប្រឹងវិចិត្រផ្ការបស់វាឱ្យបានល្អដោយទំហំ ដោយជម្រៅ

---

[8] គុណភាពច្រើន សំដៅយកវិញ្ញាណរបស់មនុស្សដែលបានសាងបុណ្យច្រើន

[9] វិញ្ញាណមានគុណភាពតិច សំដៅយកវិញ្ញាណរបស់មនុស្សដែលបានសាងបុណ្យតិច ឬមិនមានសាងបុណ្យ ។

ដោយមណ្ឌលទ្រង់ទ្រាយ ដោយស្រទាប់ ដោយសម្បុរ ដោយកំរាស់ ដោយក្បាច់ ដោយក្លិននិងដោយលំអង ព្រោះវាមានបំណងដល់ការថែរក្សាពូជ និងការប្រកួតលំអ ក្នុងចំណោមឈើគ្នាវា ។ល។ ដើមវល្លិវាខំលូនកាត់ព្រៃធំៗ ដើម្បីរកអាកាសដកដង្ហើម ឱ្យបានគ្រប់គ្រាន់ ។ ដើមត្រសក់ សណ្តែក ឪឡឹក ត្រឡាច ឃ្លោក វាខំប្រឹងវារតោង ទ្រើង ឬដើមឈើធំៗកាលណាឡើងបានវាយកខ្សែដែលដុះជាប់នៅទងរបស់វាចង ភ្ជាប់ដៃវាជាមួយនឹងទ្រើងឬមែកឈើ ដើម្បីប្រយ័ត្នកុំឱ្យធ្លាក់ចុះមកវិញ ហើយវាឡើង តទៅទៀត ដៃវាចេះតែលូតចាប់ទ្រើងហើយចងខ្សែរហូតដល់ទីបំផុតទ្រើងទើបវាឈប់ នៅត្រឹមប៉ុណ្ណោះតែម្តង ។ រុក្ខជាតិខ្លះវាដុះគេចចេញអំពីរុក្ខជាតិដទៃ ឬវត្ថុអ្វីមួយដែល គ្របបាំងមកលើវា ដើម្បីស្វែងរកអាកាសសម្រាប់ដកដង្ហើម ។ រុក្ខជាតិខ្លះវាដុះអ៊ែន ញោច ដើម្បីបំផុតអំពីរបស់ដែលនៅគាបវា វេលាណាផុតពីគំនាបរបស់គេហើយ ទើប វាដុះត្រង់ឡើងវិញ។ រុក្ខជាតិវាចេះភ្ញាក់ ឬកម្រើកដើមស្លឹកមែន ក្នុងពេលដែលគេត្រូវ បេះគេចាប់ ។ល។ គឺចលនាអាការៈ និងមុខងារទាំងអស់នេះហើយ ដែលនាំឱ្យយើង យកហេតុបច្ច័យទាំងអស់ដែលបាននិយាយមកក្នុងខាងដើមអំពីរូបជីវិតមាន វិញ្ញាណ មកដាក់ចូលជាមួយសេចក្តីសង្កេតដែលទើបនឹងនិយាយមកហើយ នេះយើងមុខជាពុំ ខានជឿថា រុក្ខជាតិមានវិញ្ញាណទេ ព្រោះអ្វី? ព្រោះមនុស្សយើងរស់នៅក្នុងរបបណា រុក្ខជាតិក៏រស់នៅក្នុងរបបនោះដែរ គឺយើងរស់នៅដោយបរិភោគអាហារ រុក្ខជាតិក៏រស់ នៅដោយបរិភោគអាហារដែរ យើងត្រូវការអាកាសដកដង្ហើម រុក្ខជាតិក៏ត្រូវការអាកា-សដកដង្ហើមដែរ យើងចង់ល្អ រុក្ខជាតិក៏ចង់ល្អដែរ ។ល។ ដែលខុសគ្នាអំពីមនុស្ស ចំពោះតែអវយវៈចំណែកខ្លះ ឬរូបចំណែកខ្លះ ដែលមនុស្សយើងមានហើយរុក្ខជាតិមិន មានដូចមនុស្សយើងមានប្រសាទរូប ភ្នែក ត្រចៀក ច្រមុះ ។ល។ រុក្ខជាតិមិនមាន ប្រសាទរូបនេះទេ មនុស្សយើងមានខួរក្បាលរុក្ខជាតិមិនមានខួរក្បាលទេ មនុស្សយើង មានដៃជើងពេញលក្ខណៈ រុក្ខជាតិមិនមានដៃជើងពេញលក្ខណៈទេ ។ល។ ព្រោះតែ រុក្ខជាតិមានចិត្តក៏មិនគ្រប់មានរូបក៏មិនគ្រប់ មានចេតសិកមិនបរិបូណ៌ ដូចមនុស្ស យើងឬដូចសត្វប្រភេទខ្លះ ដូច្នេះទើបពុទ្ធសាសនា មិនសង្គ្រោះរុក្ខជាតិចូលក្នុងពួក មនុស្សនិងពួកសត្វតិរច្ឆាន ហើយមិនមានហាមអ្នករក្សាសីល អំពីការកាប់គាស់ដើម ឈើទេ វៀរលែងតែសិក្ខាបទខ្លះក្នុងបាដិមោក្ខ ដែលទ្រង់ហាមចំពោះតែភិក្ខុប៉ុណ្ណោះ

ហើយហាមនេះទៀត ក៏មិនមែនប្រារព្ធមកអំពីវិញ្ញាណនៃដើមឈើទេ គឺប្រារព្ធមកអំពីហេតុផ្សេងក្រៅអំពីនេះទៅវិញ ចំណែកខាងការផ្សំពន្ធ៍ ទាំងមនុស្ស ទាំងសត្វគ្រប់ប្រភេទ ទាំងពីជៈគ្រប់បែប សុទ្ធតែមានដូចគ្នា[10] ខុសគ្នាតែត្រង់របៀបដែលប្រព្រឹត្តប៉ុណ្ណោះ ។

★ ★ ★

[10] "ផ្សំពន្ធ៍" ការបង្កើតកូន ការបង្កាត់ពូជ ពាក្យធម្មតា ហៅសេពកាម ។

# វិញ្ញាណ

## គឺជាធម្មជាតិស្ថាបនានូវជីវិត

គេអាចដឹងបានយ៉ាងណាថា វិញ្ញាណជារបស់ស្ថាបនានូវជីវិត ? ប្រស្នានេះគេចូលចិត្តបានងាយ ក្នុងកាលណាដែលគេបានវែកញែករបស់ពិតនៃជីវិតចេញ ដោយឡែកដើម្បីពិចារណា ហើយផ្ទៀបមើលជាមួយន័យរបស់វិញ្ញាណក្នុងពុទ្ធសាសនា ដោយប្រើបញ្ញាឱ្យជ្រៅជាងធម្មតានោះគេនិងចូលចិត្តយ៉ាងច្បាស់ថា អំណាចមួយដែលគ្រងរក្សាការផ្លាស់ប្តូរនឹងការរីកចម្រើនរបស់ជីវិត ដែលយើងធ្លាប់ហៅថាធម្មជាតិនោះ ក៏គឺវិញ្ញាណនេះឯង ។

វិញ្ញាណជាធម្មជាតិមានបំណង ព្រោះវិញ្ញាណដែលជាបច្ច័យឱ្យកើតនាមរូបបាននោះ ត្រូវជាវិញ្ញាណដែលប្រកបដោយចេតនា បើចេតនាមិនមានវិញ្ញាណក៏មិនមានតាមសូត្រក្នុងបដិច្ចសមុប្បាទថា :

***"សង្ខារជាបច្ច័យឱ្យកើតវិញ្ញាណ***

***បើសង្ខារមិនមានវិញ្ញាណរមែងមិនកើត"***

សង្ខារក្នុងទីនេះ មិនមែនសំដៅយករូបកាយទេ គឺសំដៅយកចេតនាដែលប្រែថា ចំណង់ បំណង ការផ្តួចផ្តើម សេចក្តីតាំងចិត្ត សេចក្តីគូសដៅ...... វិញ្ញាណជាធម្មជាតិមានអំណាចប្រកបដោយសេចក្តីគូសដៅប្រកបដោយបំណង...... ដូចនេះទើបចំណែកផ្សេងរបស់ជីវិត នឹងព្រឹត្តិកម្មនានារបស់ជីវិត ជាធម្មធាតុកើតឡើងយ៉ាងមានន័យដូចគ្នាទាំងអស់ ។

វិញ្ញាណដូចបាននិយាយតាំងអំពីដើមមក ធម្មធាតុនេះមានច្រើនណាស់ តែពេលដែលត្រូវយកវិញ្ញាណនេះមកនិយាយ ឃើញមានច្រើនក៏មានតិចក៏មាន ស្រេចហើយតែអំពីផ្ទេររឿង ។ វិញ្ញាណមាននៅក្នុងរាល់ៗ កោសិការបស់ជីវិត តែបើកាលណានិយាយឱ្យខ្លីក៏មានត្រឹមតែប្រាំមួយប្រភេទប៉ុណ្ណោះ គឺជាចក្ខុវិញ្ញាណ សោតវិញ្ញា-ណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ នឹងមនោវិញ្ញាណ ។ វិញ្ញាណទាំងប្រាំមួយនេះ អ្នកអានគួរសិក្សាឱ្យច្រើនអំពីកាយវិញ្ញាណនឹងមនោវិញ្ញាណ ព្រោះវិញ្ញាណទាំងពីរនេះត្រូវបាននិយាយដល់ច្រើនជាងគេក្នុងរឿងសាងជីវិត ។

តាមធម្មតា កាលណានិយាយដល់កាយវិញ្ញាណ មនុស្សទូទៅដែលធ្លាប់រៀនអភិធម្មមកហើយ តែរៀនមិនទាន់ជ្រៅជ្រះច្រើនតែចូលចិត្តថាកាយវិញ្ញាណ ក៏គឺសេចក្ដីដឹង ក្ដៅ ត្រជាក់ ល្អិត គ្រាត ទន់ រឹង ឬសេចក្ដីដឹងផ្សេងៗទៀត ដែលកើតឡើងតាមស្បែកកាយប៉ុណ្ណោះ ។ ការណ៍ពិត កាយវិញ្ញាណមានន័យទូលំទូលាយជាងនេះឆ្ងាយណាស់ សូមត្រឡប់វិលទៅពិចារណាដល់ពាក្យថា **"កម្មជរូបកើតព្រមជាមួយបដិសន្ធិវិញ្ញាណ"** កម្មជរូបមួយក្នុងបណ្ដាកម្មជរូប ៣០ ដែលកើតព្រមគ្នាជាមួយបដិសន្ធិវិញ្ញាណនោះ ក៏គឺកាយប្រសាទ កាយប្រសាទជាទីតាំងរបស់កាយវិញ្ញាណ។ ជីវិតកើតថ្មីៗ នៅជាកលលៈនៅឡើយ គម្ពីរពុទ្ធសាសនាថា មានកាយប្រសាទនឹងកាយវិញ្ញាណកើតឡើងហើយ។ កាយវិញ្ញាណក្នុងខណៈនោះមានសកម្មភាពដោយជីវិតនោះមិនមានដឹងខ្លួនឡើយ គឺគ្រាន់តែដឹងក្នុងដឹង (ដឹងក្នុងខ្លួន) មិនដឹងជាអារម្មណ៍ គឺមិនដឹងក្ដៅ មិនដឹងត្រជាក់ មិនដឹងរឹងមិនដឹងទន់..... ទោះណាជាដឹងត្រឹមតែប៉ុណ្ណោះក៏ដោយព្រះអរហន្តសម្មាសម្ពុទ្ធក៏ព្រះអង្គទ្រង់ហៅថាវិញ្ញាណ មានឈ្មោះដោយចំពោះថា **"កាយវិញ្ញាណ"** ។

**"កាយវិញ្ញាណ"** មានន័យជ្រាលជ្រៅដូចពោលមកនេះ ។ ឯប្រសាទក្នុងខណៈនោះ ក៏សង្កេតមិនទាន់ឃើញថាជាអ្វីឡើយ សូម្បីប្រើគ្រឿងបុល្លទោរទស្សន៍យ៉ាងពិសេសឆ្លុះមើលក៏ឃើញមិនច្បាស់ ។ ទោះជាដូច្នោះ ក៏គម្ពីរពុទ្ធសាសនាប្រាប់ថាមានកាយប្រសាទកើតហើយ ។ កាលណាយើងមានជំនឿថា ក្នុងជីវិតមានខ្នាត់ដ៏តូចបំផុតនេះមានកាយប្រសាទ មានកាយវិញ្ញាណ ។ យើងក៏ត្រូវតែមានជំនឿថា ក្នុងជីវិតនេះមានផោដ្ឋព្វៈផងដែរ ផោដ្ឋព្វៈប្រែថា របស់ដែលប៉ះពាល់ដល់កាយ ដែលធ្វើឱ្យកាយប្រសាទកើតសេចក្ដីដឹងជាត្រជាក់ ក្ដៅ ទន់ រឹង ល្អិត គ្រាត ឬអ្វីៗ ទៀតដែលត្រូវដឹងតាមផ្លូវកាយ ហៅថា **"កាយសម្ផស្ស"** ផោដ្ឋព្វៈក្នុងខណៈនោះគឺអ្វី? គឺរបស់ដែលមាននៅជុំវិញជីវិត ដែលមកសម្ផស្សជាមួយជីវិតក្នុងខណៈនោះសឹងអាចជាលោហិតដែលជីវិតនោះបឺតចូលទៅឬអ្វីក៏ដោយដែលជារបស់សម្រាប់ធ្វើឱ្យជីវិតនោះ មានប្រតិកិរិយាកើតឡើង ។

ជាងនេះតទៅទៀត នៅខាងក្នុងកលលៈនេះ គម្ពីរពុទ្ធសាសនាក៏មានប្រាប់ថាមានមនោវិញ្ញាណ មានខួរក្បាលដ៏ជាទីតាំងនៅរបស់មនោវិញ្ញាណកើតឡើងផង

ដែរ ។ មនោវិញ្ញាណ គឺវិញ្ញាណដែលមកបដិសន្ធិដែលគេដឹងបានថាក្នុងខណៈនោះ ជីវិតមិនទាន់មានសេចក្តីនឹកគិតអ្វីឡើយ តែបើពិចារណាអំពីរឿងជីវិតចាកព្រឹត្តិកម្ម នានារបស់ជីវិតដែលកើតឡើងថ្មីៗ នោះវិញ្ញាណបានបំពេញមុខងារគិតនឹកត្រិះរិះ បញ្ញាការ ឃុំគ្រងការរបស់ខ្លួនប្រកបដោយរបៀបល្អយ៉ាងក្រៃលែង។ ប៉ុន្តែសកម្មភាព ទាំងអស់របស់វិញ្ញាណក្នុងពេលនោះ បានប្រព្រឹត្តទៅក្នុងដំណើរដូចសេចក្តីយល់សប្តិ ដ៏ជ្រាលជ្រៅសឹងខ្លួនឯងក៏ពុំបានដឹងខ្លួនឡើយ ។

***"សភាពរបស់ជីវិតក្នុងបឋមកំណើត បានមានទាំងកាយវិញ្ញាណនឹងមនោវិញ្ញា-ណា"*** ដូចនេះ សូមអ្នកអានល្បងយកទៅប្រៀបធៀបជាមួយសភាពរបស់ជីវិតសត្វនឹង ដើមឈើមើល ។ បើក្នុងកលលៈមិនមានវិញ្ញាណកលលៈនោះក៏មិនអាចនឹងរីក ចម្រើនឡើងបាន កលលៈរីកចម្រើនបានដោយអាស្រ័យអាហារគឺលោហិត។ អំណាច ណាដែលបានធ្វើការឃុំគ្រងនូវការវិវឌ្ឍន៍ការផ្លាស់ប្តូរ ឱ្យលោហិតក្លាយទៅជាចំណែក ផ្សេងៗរបស់រូបកាយគឺជាសាច់ ស្បែក សរសៃ ឆ្អឹង សក់ រោម ធ្មេញ ក្រចក... អំណាចនេះឯងហើយ ដែលពុទ្ធសាសនាថា **"វិញ្ញាណ"** បើវិញ្ញាណមានន័យដូចនេះ យើងក៏អាចយកន័យ នៃវិញ្ញាណរបស់មនុស្សនេះទៅធៀបជាមួយនិងសេចក្តីប្រព្រឹត្តិ ទៅរបស់ពីជៈនឹងសត្វក៏ឃើញថា គង់មានអំណាចសម្រាប់សាង សម្រាប់ឃុំគ្រងរក្សា ដូចមនុស្សដែរ ព្រោះអ្វី? ព្រោះអំណាចដែលធ្វើឱ្យអាហារដែលពីជៈ ឬសត្វទាំងឡាយ បឺតលេបចូលទៅហើយក្លាយទៅជាចំណែកផ្សេងៗ របស់ពីជៈនឹងសត្វគឺជាដើម ស្លឹក ផ្លែ ផ្កា...... សាច់ ស្បែក ឆ្អឹង សរសៃ...... ក៏មានលក្ខណៈដូចគ្នានឹងសេចក្តីប្រព្រឹត្តិ ទៅ (សេចក្តីវិវឌ្ឍន៍) របស់មនុស្សយើងដែរ ។

ជីវិតគ្រប់បែប ជាសត្វ ជាពីជៈ ជាមនុស្សសុទ្ធតែប្រកបឡើងចាកកោសិកា កោសិកាជាអនុភាគឬជាថ្នែងនៃជីវិតដ៏តូចជាទីបំផុត ។ សត្វល្អិតៗ ជាអតិបាណភិជាតិ ឬអតិសុខុមប្រាណផ្សេងៗ ជាសត្វមានកោសិកាតែមួយ ពីជៈតូចៗក្នុងពីជៈ មួយៗ មានកោសិកាមួយៗ។ ព្រឹត្តិកម្មរបស់វា គឺការស៊ី ការរំលាយអាហារ ការបន្ទោបង់ ការដកដង្ហើម ការផ្សំព័ន្ធ... ព្រឹត្តិកម្មអស់ទាំងនេះ ជាលក្ខណៈនៃរបស់ដែលមាន ជីវិតទូទៅ។ ព្រឹត្តិកម្មទាំងឡាយនេះ ពុទ្ធសាសនាថាកើតចាកវិញ្ញាណមានវិញ្ញាណជា បច្ច័យ របស់ដែលខាងជីវសាស្ត្រ ហៅថា **"សេលល៍"** គឺជាអនុភាគឬថ្នែងនៃជីវិត ដ៏តូច

បំផុតនោះពុទ្ធសាសនាហៅថា "**ទសកៈ**" ដូចបាននិយាយមកហើយ។ វិញ្ញាណកើតឡើងបាន ត្រូវអាស្រ័យសង្ខារគឺចេតនា វិញ្ញាណជាបច្ច័យឱ្យកើតនាមរូបបានត្រូវអាស្រ័យសង្ខារជាបច្ច័យ វិញ្ញាណជាអំណាចសាងជីវិតដ៏មានន័យ មានសេចក្ដីដៅ។ ព្រឹត្តិកម្មរបស់កោសិកាឬទសកៈទាំងឡាយនោះ ក្នុងមួយៗ ក៏កើតឡើងយ៉ាងមានន័យ មានសេចក្ដីដៅ ។ ដោយអាស្រ័យហេតុនេះ ទើបយើងអាចនិយាយបានថា : ក្នុងជីវិតរាល់ៗ ទសកៈឬកោសិកាសុទ្ធតែមានវិញ្ញាណ វិញ្ញាណនេះឯងគឺជាធម្មជាតិសាងជីវិត ។

## ជីវិតដែលគេចេះដឹងតាមជីវសាស្ត្រមានដូចនេះ

១- ចំណែកផ្សេងៗរបស់ជីវិតនឹងព្រឹត្តិកម្មរបស់ជីវិត ក្នុងរបស់មួយៗសុទ្ធតែកើតឡើងយ៉ាងមានន័យ បញ្ជាក់ឱ្យឃើញថា ធម្មជាតិសាងជីវិតនេះមានន័យពិតប្រាកដ ។

២- ធម្មជាតិសាងជីវិតនោះ គេមើលមិនឃើញសម្ផស្សមិនបាន បញ្ជាក់ឱ្យឃើញថាធម្មជាតិសាងជីវិតនោះជានាមធម៌ ។

៣- សេចក្ដីប្រព្រឹត្តទៅ (ការវិវឌ្ឍន៍) នៃជីវិត ជារបស់មានបែបមានរបៀបមានច្បាប់គ្រងរក្សាយ៉ាងម៉ត់ចត់ បញ្ជាក់ឱ្យឃើញថាធម្មជាតិនោះ ត្រូវជារបស់ប្រព្រឹត្តទៅយ៉ាងមានរបៀប មានច្បាប់ឃុំគ្រង ប្រកបដោយរបៀបបែបផែនយ៉ាងវិសេស ។

៤- ជីវិតមានការប្រែប្រួលផ្លាស់ប្ដូររឿយៗ នៅក្នុងរបបនៃកោសិកាទាំងឡាយ តែទោះជាដូច្នេះ ក៏ជីវិតមិនរីកសាយភាយខុសប្រក្រតីទៅប៉ុន្មាន ជីវិតនៅតែរក្សាលក្ខណៈបែបបទនៃបុព្វបុរសរបស់ខ្លួនអស់កាលជានិច្ច ព្រឹត្តិការណ៍អស់ទាំងនេះ សម្ដែងឱ្យឃើញថាធម្មជាតិសាងជីវិតនេះ មានការប្រែប្រួលផ្លាស់ប្ដូរ មានការតភ្ជាប់ប្រទាក់ប្រទង នឹងមានការប្រកាន់យកយ៉ាងមាំមួនក្នុងសភាពរបស់ជីវិតយ៉ាងក្រៃលែង ។

៥- គំរោងសំណង់នៃជីវិតមានរបៀបល្អិត ប្រកបដោយថ្នាក់ជាន់ច្រើន មានគុណភាពយ៉ាងប្រណីតពន់ពេកណាស់ សូម្បីតែជើងសត្វកណ្ដូបមួយ ក៏រៀបចំសាងឡើងប្រកបដោយប្លង់ក៏មានបច្ចេកទេសយ៉ាងចំឡែកអស្ចារ្យ មានរបៀបយ៉ាងប្រណីត

ជាងគ្រឿងចក្រទាំងឡាយ ដែលសាងឡើងដោយមនុស្សយើងទៅទៀត លក្ខណៈទាំងអស់នេះ សម្ដែងឱ្យឃើញថាធម្មជាតិដែលសាងជីវិតជាស្ថាប័ត្យករមានសេចក្ដីចេះដឹងមានសេចក្ដីជំនាញការប្រកបដោយបច្ចេកទេសយ៉ាងខ្ពស់បំផុត ។

## វិញ្ញាណដែលមាននិយាយក្នុងពុទ្ធសាសនាមានលក្ខណៈដូចនេះ

១- វិញ្ញាណជាធម្មជាតិមានន័យ ព្រោះវិញ្ញាណប្រកបដោយសង្ខារគឺចេតនា។

២- វិញ្ញាណជានាមធម៌ ព្រោះវិញ្ញាណជាថាមពល ហៅថានាមពលមិនមែនរូបថាមពលទេ ។

៣- ការកើត ការរីកចម្រើន ការរលត់ ការតភ្ជាប់នៃវិញ្ញាណជារបស់ប្រព្រឹត្តទៅនៅក្នុងរបៀបអស់កាលជានិច្ច ព្រោះមានច្បាប់សម្រាប់ឃុំគ្រង ច្បាប់នេះជាច្បាប់នៃធម្មជាតិជាច្បាប់សាកលនៃចក្រវាល គឺជាច្បាប់នៃបដិច្ចសមុប្បាទនោះឯង ។

៤- កាលអំពីមិនទាន់អាស្រ័យជាមួយរូបកាយណាមួយ សេចក្ដីប្រព្រឹត្តិទៅរបស់វិញ្ញាណលឿនរហ័សជាអតិបរមា ប្រៀបបាននឹងរលកនៃវិទ្យុ នឹងកម្លាំងស្ទុះនៃនៃចរន្តអគ្គិសនី ។

៥- វិញ្ញាណមានសេចក្ដីវិចិត្រយ៉ាងប្រណិតក្រៃលែង លុះត្រាតែព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ថ្លែងថា :

***"ភិក្ខុទាំងឡាយ! យើងពិចារណាមិនឃើញសោះឡើយថា : ក្នុងបណ្ដារបស់វិចិត្រទាំងឡាយ មានអ្វីមួយវិចិត្រក្រៃលែងជាងចិត្ត ភិក្ខុទាំងឡាយ! សេចក្ដីវិចិត្ររបស់វិចិត្រកម្មក្ដី របស់សត្វទាំងឡាយណាៗក្ដី ចិត្តដែលមានសេចក្ដីវិចិត្រពិស្ដារក្រៃលែងនេះហើយ ដែលជាស្ថាបត្យកររបស់សំណង់ទាំងឡាយ"*** ក្នុងព្រះសូត្រនេះ ព្រះអង្គទ្រង់ប្រើពាក្យថា **ចិត្ត**!! ពុំបានទ្រង់ប្រើពាក្យថា **"វិញ្ញាណ"** អ្នកអានខ្លះគង់ចូលចិត្តថាពាក្យទាំងពីរនេះមានន័យខុសគ្នា សេចក្ដីពិត ពាក្យទាំងពីរនេះមានន័យត្រូវគ្នាព្រោះក្នុងគម្ពីរអភិធម្មបានបញ្ជាក់អំពីពាក្យដែលមានន័យដូចគ្នាមាន ៩ ពាក្យដូចនេះ :

**"យំ ចិត្តំ មនោ មានស ហទយំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណខន្ធោ តជ្ជា ឥនំចិត្តំ"**

ពាក្យទាំងអស់នេះ មានន័យត្រូវគ្នា ចង់ប្រើពាក្យណាក៏បាន ។ ក្នុងព្រះសូត្រមួយទៀត ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់សម្តែងថា :

***"ភិក្ខុទាំងឡាយ! របស់ដែលហៅថាចិត្តក្តី មនោក្តី វិញ្ញាណក្តី របស់ទាំងអស់នេះ មានការកើតរលត់រាល់ៗ ខណៈទាំងពេលយប់ ទាំងពេលថ្ងៃ កាលណាដួងមួយកើត ដួងមួយទៀតក៏រលត់ទៅ"*** អ្នកអានចូរគិតថា កាលណាយើងនឹកដល់អក្សរមួយតួដំបូង ខណៈចិត្តកើតឡើងមួយ លុះដល់យើងនឹកដល់អក្សរកតួទី២ ខណៈចិត្តកើតឡើងមួយទៀតតែខណៈចិត្តបានរលត់ចាកតួអក្សរកជាដំបូងនោះហើយ......។

ចាកលក្ខណៈរបស់វិញ្ញាណទាំង៥ ដូចបាននិយាយមកនេះ ឃើញថាធម្មជាតិសាងជីវិត បើពោលតាមយោបល់នៃពុទ្ធសាសនា ក៏មិនឃើញមានអ្វីក្រៅអំពីវិញ្ញាណឡើយ ។

## ការខ្វែងយោបល់របស់អ្នកវិទ្យាសាស្រ្តជាមួយពុទ្ធសាសនា ២

អ្នកវិទ្យាសាស្រ្តខ្លះ យល់ថាវិញ្ញាណជាផលរបស់ធម្មជាតិច្រើនជាង ជាតួធម្មជាតិ គឺយល់ច្រើនទៅខាងថា វិញ្ញាណកើតមកអំពីធម្មជាតិ ព្រោះគេឃើញថា ក្នុងរបស់ទាំងឡាយដែលមិនមានជីវិត ដូចផែនដី ទន្លេ ស្ទឹង ភ្នំ ឬ ពិភពលោកដែលយើងនៅសព្វថ្ងៃនេះ ក៏កើតឡើងបានដោយមិនចាំបាច់ត្រូវមានវិញ្ញាណ តែកើតឡើងចាករបស់ធម្មតាច្រើនយ៉ាងជារូបធាតុខ្លះ ជាថាមពលខ្លះ ដែលគេបានរៀនចេះដឹងតាមផ្លូវវិទ្យាសាស្រ្ត សឹងប្រកបដោយមេរៀនខាងគំនិតថា ទឹកភ្លៀងដូចម្តេចទើបធ្លាក់ចុះមក? ក្នុងព្រះអាទិត្យដូចម្តេចបានជាមានកំដៅ? ខ្យល់ដូចម្តេចទើបត្រូវបក់ត្រូវស្ងប់? ដើមឈើទាំងឡាយហេតុអ្វីទើបត្រូវអាស្រ័យទឹកនឹងពន្លឺប្រកបដោយកំដៅ? ពិភពលោកហេតុយ៉ាងណាទើបកើតមក? របស់មានជីវិតទាំងអស់លើពិភពលោកកើតបានដោយសារអ្វី? រឿងអស់ទាំងនេះ អ្នកវិទ្យាសាស្រ្តបានអធិប្បាយទៅលើការផ្សំនៃរូបធាតុថាមពល......មិនបាននិយាយដល់អរូបធាតុ ឬនាមធាតុឡើយ ។

★ ★ ★

# កំណើតនៃវិញ្ញាណ

មនុស្សយើងចូលចិត្តថា វិញ្ញាណកើតឡើងព្រោះអាស្រ័យជីវិតដោយសង្កេតឃើញថា កាលបើជីវិតរលត់ (ស្លាប់) វិញ្ញាណក៏រលត់ ដូចជាគេបាញ់មនុស្សចំខួរក្បាលឬចំបេះដូង មនុស្សដែលគេបាញ់ ក៏ផុតរលត់មិនមានដឹងអ្វីទាំងអស់ ព្រោះខ្លួនគេដល់នូវសេចក្ដីស្លាប់ ។

ដូចនេះបើវិញ្ញាណក្នុងពុទ្ធសាសនាដៅយកសេចក្ដីដឹង មិនមានសំដៅដល់អំណាចដ៏មានអាថ៌កំបាំងអ្វីដទៃ ដែលគេចូលចិត្តមិនបានទេនោះនឹងឃើញថា វិញ្ញាណកើតឡើងព្រោះអាស្រ័យជីវិតជាពិតប្រាកដដូចជាអណ្ដាតភ្លើងដែល កើតមានឡើងព្រោះអាស្រ័យជីវិតជាពិតប្រាកដដូចជាអណ្ដាតភ្លើងដែលកើតមាន ឡើងព្រោះអាស្រ័យគ្រឿងឆេះទាំងឡាយមានចង្កៀងនឹងការដុតជាដើម បើចង្កៀងមិនមានប្រេងឆេះមិនមាន ប្រេងមិនមាន ឬរបស់ទាំងអស់នេះមានគ្រប់អស់ហើយតែខ្វះការដុតការអុជ អណ្ដាតភ្លើងក៏មិនអាចកើតឡើងបានឡើយ ។ កណ្ដាតភ្លើងនឹងកើតឡើងឬមិនកើតឡើងស្រេចហើយតែបច្ច័យទាំងឡាយដែលបាននិយាយមកវិញ្ញាណកើត នឹងមិនកើត ក៏ស្រេចនៅលើបច្ច័យផ្សេងៗ របស់ជីវិត ។ ប្រសិនបើបច្ច័យនៃជីវិតមានមុនគ្រប់គ្រាន់នោះក្នុងពេលណាជីវិតរលត់ វិញ្ញាណក៏រលត់ទៅជាមួយផង ។ វិញ្ញាណបដិសន្ធិបានតែតាមផ្លូវមួយ គឺការផ្សំព័ន្ធប៉ុណ្ណោះឯង ។ ការផ្សំព័ន្ធប្រៀបបានទៅនឹងការដុតឬការអុជភ្លើងដរាបណាមានការដុតនឹងមានបច្ច័យសម្រាប់ឱ្យភ្លើងឆេះ ដរាបនោះភ្លើងក៏ឆេះ ។ វិញ្ញាណក៏ដូចគ្នាដែរ ដារាបណាមានបច្ច័យជីវិតគ្រប់គ្រាន់បរិបូណ៌នឹងមានការផ្សំព័ន្ធត្រឹមត្រូវ ដរាបនោះជីវិតក៏រមែងមានការតភ្ជាប់ហើយវិញ្ញាណក៏អាស្រ័យនូវជីវិតនោះកើតឡើង ។ យោបល់នេះហើយដែលនាំឱ្យគេចូលចិត្តថា *"វិញ្ញាណមិនមែនជាតួធម្មជាតិ តែជាផលរបស់ធម្មជាតិ"* តាមសេចក្ដីយល់ឃើញរបស់អ្នកធម្មជាតិសាស្ត្រ ឬធម្មជាតិវិជ្ជា ។

# ពុទ្ធសាសនាថាវិញ្ញាណនឹងកើតបានត្រូវអាស្រ័យជីវិត

មតិនេះធ្លាប់មានមកហើយក្នុងពុទ្ធសាសនា ព្រោះពុទ្ធសាសនាបាននិយាយថាៈ **"វិញ្ញាណជាបច្ច័យឱ្យកើតនាមរូប នាមរូបក៏ជាបច្ច័យឱ្យកើតវិញ្ញាណ"**

នាមរូបក្នុងទីនេះសំដៅយកជីវិត។ ជីវិតបានឈ្មោះថានាមរូប ក៏ព្រោះរបស់ដែលមានជីវិតត្រូវមានទាំងនាមទាំងរូប ប្រកបដោយនាមនឹងរូប ។ ជីវិតត្រូវបានចែកចេញជានាមមួយចំណែក ជារូបមួយចំណែកសរុបសេចក្តីថា : វិញ្ញាណជាបច្ច័យឱ្យកើតជីវិត ជីវិតជាបច្ច័យឱ្យកើតវិញ្ញាណ។ សម្រាប់មនុស្ស សត្វ ដើមឈើទាំងឡាយដែលយើងធ្លាប់ស្គាល់មកទាំងប៉ុន្មាន យើងសង្កេតឃើញថា បើវិញ្ញាណមិនមាន ជីវិតក៏មិនមាន ឬជីវិតមិនមាន វិញ្ញាណក៏មិនមាន ។ វិញ្ញាណមាននៅក្នុងទីណា ជីវិតក៏មានក្នុងទីនោះ ឬជីវិតមាននៅក្នុងទីណាវិញ្ញាណក៏មាននៅក្នុងទីនោះ នេះជាសេចក្តីចូលចិត្តរបស់ពុទ្ធសាសនាដែលយើងធ្លាប់ មានជំនឿអស់កាលជាយូរអង្វែងមកហើយ ។

## កំណើតនៃវិញ្ញាណ
## តាមជីវសាស្ត្ររបស់ពុទ្ធសាសនាយើង

នាមជាបច្ច័យឱ្យកើតវិញ្ញាណ សំដៅសេចក្តីថា វេទនា សញ្ញា សង្ខារ តណ្ហា ឧបាទានជាដើមជាបច្ច័យឱ្យកើតវិញ្ញាណ ។ រូបជាបច្ច័យឱ្យកើតវិញ្ញាណ សំដៅសេចក្តីថា មហាភូតរូបនឹងឧបាទាយរូបជាបច្ច័យឱ្យកើតវិញ្ញាណ។ មហាភូតរូបគឺធាតុ ៤ ឧបាទាយរូប គឺរូបដែលកើតឡើងព្រោះអាស្រ័យធាតុ ៤ ។

មហាភូតរូបជាបច្ច័យឱ្យកើតវិញ្ញាណ។ គួរចូលចិត្តថាបើកំដៅក្នុងរូបកាយមិនមាន ខ្លួនមនុស្សយើងក៏ត្រជាក់ វិញ្ញាណរមែងមាននៅមិនបានឬបើខ្យល់ដង្ហើមមុនមាន ទឹកក្នុងរូបកាយមិនមាន មនុស្សយើងក៏ត្រូវស្លាប់ កាលណាស្លាប់វិញ្ញាណក៏រលត់ ។ នេះគឺជាការពិសោធន៍ងាយៗ ដែលស្វែងឱ្យឃើញថា ធាតុភ្លើង ធាតុទឹក ធាតុខ្យល់ជាបច្ច័យឱ្យកើតវិញ្ញាណ ចំណែកខាងធាតុដីជាបច្ច័យឱ្យកើតវិញ្ញាណនោះ លំបាកចូលចិត្តបន្តិច តែបើយើងចូលចិត្តថា ធាតុដីគឺអវយវៈចំណែកណាដែលមិនមែនទឹក

មិនមែនខ្យល់ មិនមែនភ្លើង ។ យើងក៏នឹងចូលចិត្តបានយ៉ាងច្បាស់លាស់ថា ធាតុដីក៏ជាបច្ច័យឱ្យកើតវិញ្ញាណបានដូចគ្នា ព្រោះធាតុដីតាមដែលព្រះអរហន្តសម្មាសម្ពុទ្ធឱ្យតួយ៉ាងទុកមក ក៏គឺខួរក្បាល បេះដូង សួត ថ្លើម ក្រពះ ពោះវៀន។ល។ ដូចនេះពាក្យថា ធាតុដីជាបច្ច័យឱ្យកើតវិញ្ញាណ មានន័យថា អវយវៈអស់ទាំងនេះជាបច្ច័យឱ្យកើតជីវិត ឱ្យជីវិតតាំងនៅបាន ។ កាលណាជីវិតតាំងនៅបាន វិញ្ញាណក៏រមែងតាំងនៅបាន ។

ឧបាទាយរូប ជាបច្ច័យឱ្យកើតវិញ្ញាណ ។ ដូចបានអធិប្បាយមកហើយក្នុងខាងដើមថា ឧបាទាយរូបបានដល់ព្រឹត្តកម្មផ្សេងៗ របស់រូបកាយ ដូចជាការស៊ី ការរំលាយអាហារ ការបន្ទោរបង់ ការដកដង្ហើម ការកិនកំទេចអាហារឱ្យបានជាថាមពល ។ល។ ធរណីផ្សេងៗរបស់អវយវៈទាំងអស់នេះ ហៅថាឧបាទាយរូប។ តាមន័យនេះនាំឱ្យយើងឃើញកាន់តែច្បាស់ថា ឧបាទាយរូបជាបច្ច័យឱ្យកើតវិញ្ញាណ បើឧបាទាយរូបមិនមាន វិញ្ញាណរមែងមានមិនបាន ។ សេចក្តីអធិប្បាយនេះ អ្នកជីវសាស្រ្តចូលចិត្តងាយ តែអ្នកបាលីពុំសូវចូលចិត្តទេ ។ ដូច្នេះសូមលើកយកយោបល់ពុទ្ធសាសនាដែលស្របជាមួយជីវសាស្រ្តដូចមានក្នុងមេរៀននៃបដិច្ចសមុប្បាទថា :

***"វិញ្ញាណជាបច្ច័យឱ្យកើតលក្ខណៈរូប៤ លក្ខណៈរូប៤ ក៏ជាបច្ច័យឱ្យកើតវិញ្ញាណ"***

លក្ខណរូប៤គឺ ឧច្ចយៈ សន្តតិ, ជរតា, អនិច្ចតា ។

ឧច្ចយៈ ប្រែថា ការកើត ឬការរីកចម្រើន,

សន្តតិ ការតភ្ជាប់ ឬតំណ,

ជរតា ជរា ឬចាស់ ពាក្យនេះប្រែថារំលាយក៏បាន,

អនិច្ចតា ការបែកធ្លាយ ឬការផ្លាស់ប្តូរសភាព ។

លក្ខណៈរូប ក៏គឺលក្ខនៈផ្សេងៗ ដែលមាននៅក្នុងកោសិកា ឬទសកៈ កាលណាកោសិកាបឺតអាហារចូលទៅ កោសិកាដែលអាស្រ័យអាហារនោះក៏សន្សឹមៗ ធំរីកចម្រើនឡើងបន្តិចម្តងៗ នេះគឺជាឧច្ចយៈ។ ការតភ្ជាប់គ្នានៃសេចក្តីរីកចម្រើនរឿយៗទៅនេះគឺជាសន្តតិ។ អាហារដែលបឺតចូលទៅរំលាយ ត្រូវដុតកម្ទេចឱ្យកើតបានជាកម្លាំងនៃថាមពល សម្រាប់ធ្វើឱ្យសភាពរបស់កោសិកានោះមានចំណាស់ ហើយផ្លាស់

ប្តូរលំនាំអំពីសភាពដើមអស់ទៅ កើតបានជាកោសិកាថ្មីទៀត នេះគឺជា ជរតា នឹង អនិច្ចតា ។ វិញ្ញាណជាបច្ច័យឱ្យកើតលក្ខណៈរូបទាំងអស់នេះតាំងអំពីចាប់ផ្តើមមានបដិសន្ធិ ព្រោះបើលក្ខណរូបទាំងនេះមិនមាន រូបកាយក៏មិនអាចនឹងរីកចម្រើនឡើងបានដោយដាច់ខាត ។ សូមកុំភ្លេចថាអំណាចដែលឃុំគ្រងការផ្លាស់ប្តូររបស់កោសិកាគឺវិញ្ញាណនេះឯង ។

## វិញ្ញាណកើតអំពីវិញ្ញាណ

រឿងនេះខាងជីវសាស្ត្រ មិនមាននិយាយដល់ទេ។ វិញ្ញាណកើតចាកជីវិតបាននិយាយមកហើយ ។ តទៅនេះនឹងអធិប្បាយឱ្យឃើញថា វិញ្ញាណកើតចាកវិញ្ញាណ។ តាមធម្មតា នាមធម៌ត្រូវកើតចាកនាមធម៌ រូបធម៌ត្រូវកើតចាករូបធម៌ មុននឹងចូលចិត្តអំពីរឿងនេះ យើងត្រូវចូលចិត្តរឿងនេះសិនថា :

១- ពាក្យថាវិញ្ញាណកើតនឹងរលត់មានន័យទៅដល់ណា?

២- អ្វីជារបស់ដែលមាននៅយ៉ាងពិតប្រាកដ? ឬ អ្វីជាសេចក្តីពិតរបស់វត្ថុធាតុទាំងពួងដែលប្រាកដមានមកក្នុងពិភពលោកនេះ ជារូបធាតុនឹងថាមពល ឬជាចិត្ត ឬទាំងពីរយ៉ាង?

## វិញ្ញាណមាន២ប្រភេទ

១- វិញ្ញាណដែលមានដំណើរប្រព្រឹត្តិទៅដោយជីវិតមិនបានដឹងខ្លួនដូចសេចក្តីដឹងរបស់ដើមឈើនឹងរបស់សត្វល្អិត ឬសត្វជាន់ទាប ដំណឹងនៃសត្វនៃដើមឈើទាំងឡាយនេះ គេសង្កេតឃើញហើយដឹងបានដោយប្រតិកិរិយារបស់វា ដូចដើមឈើទាំងឡាយហេតុដូចម្តេចទើបវាចេះងាករេរកពន្លឺដ៏លាយឡំដោយកំដៅ។ ដើមប្រក្លូបហេតុដូចម្តេចទើបវាក្តោបស្លឹកក្នុងពេលដែលគេលូកដៃទៅចាប់ ដើមឈើខ្លះមានផ្កាដែលវាតាក់តែងឱ្យមានជាស្រទាប់ៗ កាលណាបើមានសត្វល្អិតទាំងឡាយមានឃ្មុំជាដើមចូលទៅក្នុងស្រទាប់ផ្ការបស់វា វាក្តោបកៀបជាប់ភ្លាម ។ មានដើមឈើខ្លះក្នុងទ្វីបអាហ្វ្រិក មានឫសសំយុងចុះចាកមែកស្រដៀងដើមជ្រៃក្នុងប្រទេសយើង កាលណាមានសត្វអ្វីៗរកមកប៉ះឫសរបស់វា វាទាក់យកសត្វនោះបានដូចជាពស់ថ្លាន់រឹបមនុស្ស

ប្រតិកិរិយាទាំងអស់នេះ ស្តែងឱ្យឃើញថា វាមានសេចក្តីដឹងចំពោះរបស់ជុំវិញទាំងអស់។ សត្វល្អិតឬសត្វជាន់ទាបដែលគេពិសោធមើលដោយគ្រឿងឆ្លុះ កាលណាគេបន្តក់ទឹកថ្នាំអ្វីដែលបណ្តាលឱ្យមានគ្រោះថ្នាក់ទៅលើវា វាចេះគេចខ្លួនឱ្យផុតអន្តរាយ កាលណាអស់វត្ថុដែលជាអាហាររបស់វា វាចេះស្វែងរកលុះត្រាតែបាន ។ ពួកសត្វអភិបាណកជាតិឬអភិសុខុមប្រាណ ពួកខ្លះវាមានកោសិកាតែមួយប្រតិកិរិយារបស់សត្វពួកនេះ បញ្ជាក់ឱ្យដឹងថា វាមានសេចក្តីដឹងចំពោះវត្ថុដែលនៅជុំវិញខ្លួនរបស់វា តែដំណឹងអស់ទាំងនេះបានប្រព្រឹត្តទៅដោយដែលវាមិនមានដឹងខ្លួនឡើយ ដូចជាសេចក្តីដឹងរបស់កោសិកានៃសក់ នៃរោម នៃប្រចកជាដើម ដូចនេះព្រោះអ្វី? ព្រោះវាមិនមានប្រសាទសម្រាប់បង្កើតមនោសម្ផស្ស ។

យើងកាត់សក់ រោម ក្រចក មិនដឹងឈឺយ៉ាងណា យើងកាប់ដើមឈើឬសម្លាប់សត្វដែលមិនមានប្រសាទវាក៏មិនដឹងឈឺចាប់យ៉ាងនោះដែរ ។ ចំណែកសេចក្តីដឹងរបស់មនុស្សយើងដែលកើតមានឡើងដោយមិនដឹងខ្លួននោះ ឧទាហរណ៍ដូចក្នុងពេលសន្លប់ឬក្នុងពេលដេកលក់យ៉ាងស៊ប់។ ការមិនដឹងខ្លួនក្នុងពេលនោះ បើនិយាយតាមពុទ្ធសាសនា ក៏សំដៅសេចក្តីថា : ក្នុងខណៈនោះមិនមានមនោសម្ផស្សដែលបណ្តាលមកអំពីហេតុច្រើនប្រការ ។ ក្នុងខណៈមនុស្សយើងដេកលក់ស៊ប់នោះ បើមនោសម្ផស្សក្នុងវិថីចិត្តមិនមានទេ មនុស្សដេកលក់ស៊ប់នោះក៏ដូចជាមនុស្សស្លាប់ ឥតមានការយល់សម្តីអ្វីឡើយ តែបានជាមនុស្សនោះនៅមិនទាន់ស្លាប់ ព្រោះបេះដូងរបស់គេនៅធ្វើការជាធម្មតា។ នេះសម្តែងឱ្យឃើញថា មនុស្សនោះមានសេចក្តីដឹងនៅខាងក្នុងដែលពុទ្ធសាសនាហៅថា នៅក្នុងភវង្គ សេចក្តីដឹងប្រព្រឹត្តទៅដោយមិនដឹងខ្លួនដូចនេះហៅថាភវង្គចិត្តឬ ភវង្គវិញ្ញាណ ។

វិញ្ញាណដែលប្រព្រឹត្តទៅដោយដឹងខ្លួន វិញ្ញាណបែបនេះហៅថាវិថីចិត្ត បែកចេញជាវិញ្ញាណ ២ មានចក្ខុវិញ្ញាណជាដើម ។

ពាក្យថា វិញ្ញាណកើត សំដៅយកការកើតរបស់ភវង្គចិត្តនឹងវិថីចិត្ត។ បើកាលណាភវង្គចិត្តកើត តែមិនមានសេចក្តីដឹងខ្លួននោះ គេអាចសង្កេតបានចាកលក្ខណៈទាំងអស់នេះ គឺរបស់ណាបើមានភវង្គចិត្តកំពុងកើតនៅក្នុងនោះ របស់នោះត្រូវមានជីវិត អំណាចដែលឃុំគ្រង ការផ្លាស់ប្តូរខាងក្នុងរបបរបស់កោសិកា ឃុំគ្រងអវយវៈ

ផ្សេងៗ ឱ្យធ្វើការតាមនាទី អំណាចអស់ទាំងនេះ គឺជាសញ្ញលក្សណ៍របស់ភវង្គចិត្ត ព្រោះជារបស់កើតឡើងចាកភវង្គចិត្ត ។ បើភវង្គចិត្តមាន អំណាចទាំងអស់នេះក៏ប្រាកដឡើង បើរលត់អំណាចទាំងឡាយក៏អស់មានក្នុងរបស់អស់នោះៗ ។ សូមកុំភ្លេចថាព្រឹត្តិកម្មរបស់ជីវិតជាបច្ច័យមួយយ៉ាងសំខាន់ក្នុងកំណើតនៃភវង្គចិត្ត។

ពាក្យថាវិថីចិត្តកើត សំដៅយកកើតការឃើញ ការឮ ការដឹងក្លិន ការស្គាល់រសទាំងអស់នេះហៅថាវិថីចិត្ត វិថីចិត្ត ក៏គឺភវង្គចិត្តចំណែកមួយ ដែលប្រាកដតួចេញមកទាក់ទងជាមួយពិភពលោកខាងក្រៅហើយត្រឡប់ចូលកាន់ភវង្គចិត្តតាមប្រក្រតី ដើមវិញ ។ ពាក្យថាវិថីចិត្តរលត់ គឺអស់សេចក្តីដឹងតាមទ្វារទាំងឡាយមានចក្ខុទ្វារជាដើម។

សូមសង្កេតថា ចិត្តកើតចិត្តរលត់ ដែលយើងបានឮរឿយៗនោះច្រើនសំដៅយកការកើតរលត់របស់វិថីចិត្ត ដូចនិយាយថាព្រះអរហន្តចូលនិរោធ ចិត្តរលត់ឬមិនមានចិត្ត នេះក៏សំដៅយកត្រឹមតែវិថីចិត្តរលត់ឬមិនមានវិថីចិត្តប៉ុណ្ណោះឯង ព្រោះថាបើសំដៅដល់ភវង្គចិត្តផងនោះ ក៏ប្រែថាស្លាប់ស្រេចតែម្តង។ ដើមឈើមិនមានវិញ្ញាណក៏មានសេចក្តីដៅត្រឹមតែមិនមានវិថីចិត្តប៉ុណ្ណោះ ព្រោះដើមឈើមិនមានប្រសាទ មិនមានខួរក្បាលមិនមានអាយតនៈខាងក្នុង ដូចនេះវិថីចិត្តកើតឡើងពុំបានឡើយ ។

វិញ្ញាណដែលខ្ញុំបាននិយាយមកហើយដោយសង្ខេបនេះ ខ្ញុំដឹងថាអ្នកអានខ្លះមុខជាមិនទាន់ស្គាល់វិញ្ញាណដោយច្បាស់លាស់ទេ ប៉ុន្តែធ្វើម៉េចបើខ្ញុំមិនចង់ឱ្យសៀវភៅនេះមានទំព័រច្រើនពេក ។ ដូចនេះអ្នកអានសូមមេត្តាឱ្យខ្ញុំបញ្ចប់រឿងវិញ្ញាណនេះប៉ុណ្ណេះចុះ។ តទៅនេះ ខ្ញុំសូមតភ្ជាប់រឿងរបស់វិញ្ញាណតទៅនឹងរឿងរបស់និព្វាន ។ ចំពោះបញ្ហានិព្វាននេះ ពុទ្ធសាសនិកទាំងឡាយបានលើកយកមកដោះស្រាយជាមួយគ្នារឿយៗ តែរកផ្លូវចេញមិនរួចសោះខ្លះយល់ដូចនេះ ខ្លះយល់ដូចនោះ សឹងមិនមានឯកភាពសោះ ។ ដើម្បីឱ្យមានគំនិតស្របគ្នាឬឱ្យមានឯកភាពក្នុងរឿងនិព្វាននេះ ខ្ញុំសូមទាញស្មារតីពុទ្ធសាសនិកឱ្យចាប់អារម្មណ៍ទៅលើវិញ្ញាណ ឱ្យខំសិក្សា ខំអានសៀវភៅដែលមាននិយាយអំពីវិញ្ញាណឱ្យច្រើន ជាពិសេសឱ្យខំព្យាយាមគិតជាថ្មីឡើងវិញថា អ្វីទាំងអស់ដែលយើងធ្វើកើតព្រោះតែមានវិញ្ញាណ វិញ្ញាណជាធំជាប្រធានលើកិច្ចការទាំងអស់។ វិញ្ញាណសម្តែងតួជាអ្នកធ្វើការផង ជាអ្នកទទួលនូវផលរបស់ការផង ជារបស់កើតរលត់តៗគ្នានៅក្នុងសាកលពិភព ជាមនុស្ស ជាសត្វ ជា

ទេវតា ជាព្រហ្ម ជាអរូបព្រហ្ម។ ដូចនេះឃើញថា វិញ្ញាណជាធាតុមួយមានសកម្មភាព មានចលនាអស្ចារ្យសម្បើមណាស់ប្រសិនបើដល់ទីបំផុតទៅវិញ្ញាណដែលមាន ទាក់ទងដល់វិញ្ញាណ មានពុទ្ធភាសិតថា **មនោបុព្វង្គមាធម្មា** ។ល។ ជាដើមសោះឡើយ អាស្រ័យហេតុនេះ សូមពុទ្ធសាសនិកទាំងអស់គ្នា ពិនិត្យជាថ្មីឡើងវិញនូវសំនួរនឹងចម្លើយ របស់អជិតមាណព នឹងព្រះអរហន្តសម្មាសម្ពុទ្ធដូចមានតទៅនេះ ÷

*"បញ្ញានឹងសតិ នាមនឹងរូប របស់ទាំងអស់នេះនឹងត្រូវរលត់ដោយមិនមានសេសសល់ក្នុងទីណា"* អជិតមាណពទូលសួរ ។

*"ក្នុងទីណា! នាមនឹងរូបត្រូវបានរលត់ដោយមិនមានសេសសល់ក្នុងទីនោះឯង! សតិនឹងបញ្ញា ក៏រមែងត្រូវរលត់ដោយមិនមានសេសសល់ព្រោះវិញ្ញាណត្រូវរលត់"* ព្រះសម្ពុទ្ធទ្រង់ឆ្លើយ ។

ពាក្យថា **"ក្នុងទីណា"** ក្នុងទីនេះសំដៅដល់ព្រះនិព្វាន គឺមានន័យថា ក្នុងកាលណាវិញ្ញាណបានចូលទៅដល់អនុបានិសេសនិព្វានហើយវិញ្ញាណ ដែលជាតួធម្មជាតិសាងជីវិត វិញ្ញាណដែលធ្លាប់មានអវិជ្ជាមកអំពីមុន ក៏ដល់នូវសេចក្តីរលត់រលាយអស់ព្រមគ្នាជាមួយនឹងរបស់គ្រប់បែបគ្រប់យ៉ាង ដែលជាប់ទាក់ទងជាមួយវិញ្ញាណនោះ ក៏ត្រូវបានទទួលនូវសេចក្តីរលត់រលាយស្លាយសូន្យទៅ ត្រូវបានជួបជាមួយនឹងវិញ្ញាណថ្មី គឺវិញ្ញាណដែលជាអនន្តជីព វិញ្ញាណដែលមានឡើង ព្រោះសេចក្តីល្អរបស់វិញ្ញាណដែលរលត់រលាយសោះសូន្យទៅ។ វិញ្ញាណនេះមានសេចក្តីភ្លឺស្វាងរុងរឿងអស់កាលជានិច្ច ប៉ុន្តែសេចក្តីភ្លឺស្វាងរុងរឿងឬលក្ខណៈណាៗទាំងអស់របស់វិញ្ញាណនិព្វាននេះនឹងលើកយកមកប្រៀបប្រដូចជាមួយអ្វីៗ ដែលមាននៅក្នុងលោកនេះពុំបានឡើយ ព្រោះរបស់ទាំងអស់មិនមានរបស់ណាមានលក្ខណៈសម្បូរណ៍គ្រប់គ្រាន់ ដែលអាចលើកយកមកប្រៀបប្រដូចឱ្យល្អមស្តាប់ចូលចិត្តបាន ឬឱ្យស្តាប់យល់ដោយមិនមានការភាន់ច្រឡំ សម្រាប់មនុស្សដែលមិនទាន់សម្រេចនិព្វានដោយផ្ទាល់ខ្លួនឯង។ ទោះណាជានិព្វានហៅថា **"វិញ្ញាណ"**(11) ក៏កុំគប្បីចូលចិត្តជាដាច់ខាតថា វិញ្ញាណនោះដូចគ្នានិងវិញ្ញាណដែលយើងស្គាល់គ្រប់គ្នា ឬវិញ្ញាណធម្មតាសព្វថ្ងៃនេះឡើយ។ ចំពោះ

[11] ពាក្យថាវិញ្ញាណហៅថានិព្វាន ជាគូនឹងពាក្យមួយទៀតដែលថាវិញ្ញាណមាននៅក្នុងនិព្វាន ។

វិញ្ញាណជាអនន្តជីពឬវិញ្ញាណដ៏មានសេចក្តីភ្លឺស្វាងរុងរឿងជាអនន្តកាលឬ ជាវិញ្ញាណអនិទស្សនៈនេះមាននិយាយច្បាស់លាស់ ក្នុងសៀវភៅនិព្វានទស្សនៈត្រង់កេវដ្តសូត្រសព្វគ្រប់ហើយ។ អ្នកអានសូមត្រឡប់ទៅពិនិត្យមើលជាថ្មីទៀត ដើម្បីធ្វើនូវសេចក្តីសង្ស័យរបស់ខ្លួនឱ្យអស់ទៅផងចុះ ។

## ការរលត់នៃវិញ្ញាណ

ពុទ្ធសាសនិកខ្លះ ចូលចិត្តថាពុទ្ធសាសនាពិតប្រាកដនោះបង្រៀនថាមនុស្សយើងស្លាប់ហើយវិញ្ញាណរលត់មិនមានវិញ្ញាណទៅកើតទៀតទេ ព្រោះវិញ្ញាណនឹងកើតអាស្រ័យមានផស្សៈ ផស្សៈមាន អាស្រ័យមានជីវិត មានអាយតនៈគ្រប់បរិបូណ៌ ។ បើប្រកាន់ថាមានវិញ្ញាណចាស់ទៅកើតថ្មីទៀតក៏ត្រូវប្រកាន់ថា មានអត្តាដូចសេចក្តីចូលចិត្តរបស់ព្រាហ្មណ៍នោះដែរព្រោះអ្វី? ព្រោះព្រះអរហន្តសម្មាសម្ពុទ្ធរបស់យើងទ្រង់បង្រៀនថា មិនមានអត្តាទេ អ្វីៗទាំងអស់សុទ្ធតែជារបស់អនត្តា ។

(សេចក្តីចូលចិត្តនេះ) ត្រូវតាមមហាតណ្ហាសង្ខយសូត្រ តែមិនត្រូវតាមសូត្រទូទៅ ។ សេចក្តីពិតជាទូទៅ ពុទ្ធសាសនាថា មនុស្សយើងរមែងទៅកើតជាថ្មី មើលរឿងមហានាមនឹងរឿងសាតិភិក្ខុក្នុងសៀវភៅនិព្វានទស្សនៈ នឹងសៀវភៅបញ្ហាអនាគត) ។ ពុទ្ធសាសនាថា ដរាបណានៅមានបច្ច័យគ្រប់គ្រាន់ ដរាបនោះវិញ្ញាណត្រូវកើតថ្មី ។ ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ត្រាស់បញ្ជាក់ថា :

*"ម្នាលភិក្ខុទាំងឡាយ! វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យអ្វី វិញ្ញាណក៏មានឈ្មោះហៅថា តាមបច្ច័យនោះៗ វិញ្ញាណកើតព្រោះអាស្រ័យចក្ខុនឹងរូប ឈ្មោះថាចក្ខុវិញ្ញាណ វិញ្ញាណកើតព្រោះអាស្រ័យសំឡេង ឈ្មោះសោតវិញ្ញាណ។ល។ វិញ្ញាណកើតព្រោះអាស្រ័យមនោនឹងធម្មារម្មណ៍ ក៏មានឈ្មោះថាមនោវិញ្ញាណ"*

ភិក្ខុទាំងឡាយ! ប្រៀបដូចអណ្តាតភ្លើងឆេះឡើងដោយអាស្រ័យវត្ថុធាតុអ្វីៗ ក៏មានឈ្មោះហៅតាមវត្ថុធាតុនោះៗ ជាភ្លើងព្រៃ ជាភ្លើងឧស ភ្លើងប្រេង ភ្លើងទៀន ភ្លើងចង្កៀង ។ល។ ភិក្ខុទាំងឡាយ ! វិញ្ញាណក៏ដូច្នោះដែរ ។

# វិញ្ញាណ (កោសិកា)

## តាមនិយមរបស់ពួកព្រាហ្មណ៍

គប្បីចូលចិត្តថា វិញ្ញាណដែលគេស្គាល់ទាំងអស់គ្នាក្នុងសម័យនោះមានន័យផ្សេងៗគ្នា ស្រេចតែជំនឿនៃលទ្ធិមួយៗ ។ ពុទ្ធសាសនាប្រកាន់ថាមានវិញ្ញាណ មានជំនឿថាស្លាប់ហើយ វិញ្ញាណរបស់មនុស្សទៅបដិសន្ធិជាថ្មីទៀត ក្នុងកាលណាវិញ្ញាណនោះនៅមានកិលេសជាបច្ច័យតាក់តែងឱ្យកើត នឹងមានជំនឿថា វិញ្ញាណជាអនត្តា មិនមែនជាអត្តាដូចពួកព្រាហ្មណ៍ចូលចិត្តឡើយ ។ វិញ្ញាណក្នុងពុទ្ធសាសនាថារបស់កើតមកអំពីបច្ច័យច្រើនយ៉ាង កាលណាអស់បច្ច័យវិញ្ញាណក៏រលត់ ។ ចំណែកវិញ្ញាណក្នុងលទ្ធិរបស់ព្រាហ្មណ៍ គេប្រកាន់ថា មិនចាំបាច់ត្រូវអាស្រ័យបច្ច័យអ្វីទេជារបស់មានឯង កើតឡើងឯង មានលក្ខណៈដូចព្រះអាទិទេព ។

★ ★ ★

# ការតភ្ជាប់របស់វិញ្ញាណ

ពុទ្ធសាសនាមានជំនឿស្របជាមួយជីវសាស្ត្រត្រង់ចំណុចថា : **“ជីវិតរមែងជាបច្ច័យសំខាន់ក្នុងការកើតរបស់វិញ្ញាណ ព្រោះបើមិនមានជីវិតវិញ្ញាណរមែងមានមិនបាន”** ចំពោះរឿងនេះគេពិសោធឃើញងាយ ដូចយកកាំភ្លើងបាញ់មនុស្សចំខួរក្បាល ឬចំបេះដូង មនុស្សនោះត្រូវស្លាប់ភ្លាមព្រមជាមួយគ្នានេះ វិញ្ញាណក៏រលត់ចាករូបកាយ អស់ដឹងអ្វីទាំងអស់បន្ទាប់មករូបកាយសន្សឹមៗ ត្រជាក់ម្តងបន្តិចៗ មិនយូរពេលប៉ុន្មាន ការស្អុយ ការហើម ការរលួយ ក៏កើតមានបន្តបន្ទាប់គ្នា នេះស្តែងឱ្យឃើញថា ជីវិតជាបច្ច័យឱ្យកើតវិញ្ញាណ។ ចំណែកខាងជំនឿថា វិញ្ញាណជាបច្ច័យឱ្យកើតជីវិតនោះ ព្រោះសង្កេតសេចក្តីបានថា វិញ្ញាណឃុំគ្រងកិច្ចការផ្សេងៗរបស់រូបកាយឱ្យប្រព្រឹត្តទៅរឿយៗ ។ តែមានហេតុផលជាច្រើនដែលមានទំនងគួរឱ្យជឿថា វិញ្ញាណនោះត្រូវជាប់ទាក់ទងមកអំពីឪពុកម្តាយ ប្រសិនបើជឿថា ព្រឹត្តិកម្មរបស់ជីវិតជាហេតុឱ្យកើតវិញ្ញាណ នឹងវិញ្ញាណនោះត្រូវពង្រីកតួបានតាមការពង្រីកតួរបស់ជីវិត ហើយជីវិតនេះទៀតសោត បើតាមការពិសោធន៍របស់យើងក៏ឃើញថាជាប់ទាក់ទងមកអំពីឪពុកម្តាយ។ ដូចនេះវិញ្ញាណគួរតែជាប់ទាក់ទងមកអំពីឪពុកម្តាយ។ នេះជាសេចក្តីចូលចិត្តនៃជនទូទៅមានទាំងអ្នករៀនតិច មានទាំងអ្នករៀនច្រើន។ ចំពោះរឿងនេះ អ្នករៀនសូមវិលត្រឡប់ទៅ អានរឿងដើមដែលខ្ញុំបានសរសេររួចមកហើយក៏អាចយល់បានហើយ ។

*“វិញ្ញាណជាឫសគល់នៃរបស់ទាំងពួង... របស់ទាំងពួងរមែងប្រព្រឹត្តទៅតាមអំណាចនៃរបស់មួយពោលគឺវិញ្ញាណ”* ក្នុងរូបធាតុគ្រប់យ៉ាងមានវិញ្ញាណ តែវិញ្ញាណដែលមាននៅក្នុងរូបនោះជាវិញ្ញាណលក់គឺជាវិញ្ញាណដែលមិនមានលក្ខណៈ ប្រាកដចេញមកជាសេចក្តីដឹង មិនមែនជាអំណាចឃុំគ្រង់ជីវិត។ វិញ្ញាណដែលមាននៅក្នុងរបស់ មិនមានជីវិតនោះក៏មិនមានលក្ខណៈខុសគ្នាអំពីធាតុក្តៅត្រជាក់ដែលផ្សាយជ្រាបទៅពេញអាកាស ពេញដី ពេញទឹកទាំងអស់ឡើយ ។ ក្នុងអាកាសទូទៅក៏មានវិញ្ញាណ ព្រោះវិញ្ញាណជាធាតុមួយផ្សេងក្រៅអំពីធាតុទាំង ៥ ដូចបាននិយាយក្នុងខាងដើមម្តងហើយ ។

វិញ្ញាណធាតុនេះអាចចូលទៅក្នុងធាតុដទៃៗ បានព្រោះធាតុនេះមានកម្លាំងមានថាមពល ដូចជាមេដែកដែលរត់ឆ្លងអំពីទីមួយទៅកាន់ទីមួយដោយអំណាចកម្លាំងស្រូប។ ក្នុងពិភពលោកនៃវិញ្ញាណក៏មានការរត់ឆ្លងការជ្រៀតជ្រែក ការតភ្ជាប់អំពីកន្លែងមួយទៅកន្លែងមួយ មានលក្ខណៈដូចជារលកនៃធាតុអាកាស ព្រោះធាតុអាកាសនឹងធាតុវិញ្ញាណមានលក្ខណៈប្រហែលៗគ្នា ។

ដើម្បីងាយចូលចិត្តក្នុងរឿងនេះ សូមមេត្តានឹកដល់ពុទ្ធភាសិត ដែលមានក្នុងអរូបឈានថា :

"**អនន្តោ អាកាសោ** អាកាសជាអនន្តៈ

**អនន្តំ វិញ្ញាណំ** វិញ្ញាណជាអនន្តៈ"

ដែលមានក្នុងកេវដ្តសូត្រថា ÷

**"វិញ្ញាណំ អនិទស្សនំ អនន្តំ សព្វតោបភំ"**

និព្វានគឺវិញ្ញាណដែលមើលមិនឃើញដោយភ្នែក ដែលប្រៀបទៅនឹងអ្វីក៏ពុំបានជាអនន្តៈ មានផ្លូវចូលទៅដល់បាន តាមសមថកម្មដ្ឋាននឹងវិបស្សនាកម្មដ្ឋាន មានរស្មីភ្លឺស្វាងរុងរឿងត្រចះត្រចង់មិនមានទីបំផុត មិនមានពេលអស់ទៅវិញ។

អាកាស យើងចូលចិត្តថា មាននៅក្នុងនោះជាបរមាណូ ចន្លោះវាលធេងដែលធ្វើឱ្យអ៊ីឡេកត្រូនវិលបានជានិច្ចនោះ ក៏គឺជាអាកាសធាតុយើងមើលទៅខាងណាយើងនឹកដល់អ្វីក៏ជួបតែអាកាសធាតុមិនមានទីបំផុត។ យើងពុំអាចដឹងថា អាកាសមានដើមនៅត្រង់ណា មានទីបំផុតនៅត្រង់ណាកើតមានឡើងអំពីកាលណា រលត់រលាយទៅវិញក្នុងពេលណា មិនមាននរណាដឹងឡើយ ។ អាកាសជាអនន្តៈមិនមានទីបំផុត មានន័យដូចពោលមកនេះ ។

ចំណែកពាក្យថា វិញ្ញាណជាអនន្តៈមានន័យយ៉ាងណា? ក្នុងគម្ពីរវិសុទ្ធិមគ្គមាននិយាយថា : វិញ្ញាណជាអនន្តៈនោះមានន័យថាមនសិការៈរបស់វិញ្ញាណ ដែលនឹកដល់អាកាសជាអារម្មណ៍ជា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុតយ៉ាងណា មនសិការរបស់វិញ្ញាណដែលផ្សាយចេញទៅថា **អនន្តំ វិញ្ញាណំ** ក៏មិនមានទីបំផុតយ៉ាងនេះដែរ ។ សេចក្ដីនេះទោះណាជាយើងខំប្រឹងគិតដូចម្ដេចក៏មិនងាយនឹងយល់ដែរ តែប្រសិនបើយើងគិតតាមមេសូត្រនៃបដិច្ចសមុប្បាទជាបដិលោមថា : ជរា កើត

អំពីជាតិ ជាតិកើតអំពីភព ភពកើតអំពីឧបាទាន ឧបាទានកើតអំពីតណ្ហា តណ្ហាកើតអំពីវេទនា វេទនាកើតអំពីផស្សៈ ផស្សៈកើតអំពីអាយតនៈ អាយតនៈកើតអំពីនាមរូប នាមរូបកើតអំពីវិញ្ញាណ វិញ្ញាណកើតអំពីសង្ខារ សង្ខារកើតអំពីអវិជ្ជា ។ តាមន័យនេះ ឃើញថា សង្ខារជាបច្ច័យរបស់វិញ្ញាណឬតួវិញ្ញាណតែម្ដងកើតមកអំពីអវិជ្ជា គឺកើតមកអំពីមិនដឹង គឺមិនដឹងថាវិញ្ញាណនេះមានដើមកំណើតមកអំពីកាលណា មានចុងបំផុតនៅត្រង់ណា ដូចជាអាកាសដែលគេមិនអាចដឹងដើមដឹងចុងនោះដែរ ។ ប៉ុន្តែកុំច្រឡំថា វិញ្ញាណនៅក្រៅច្បាប់ធម្មជាតិ គឺអនិច្ចំ ទុក្ខំ អនត្តាឡើយ ។

វិញ្ញាណដែលខ្ញុំបាននិយាយមកនេះមានសេចក្ដីខ្លីពេកណាស់ អ្នកអានសូមរៀនរឿងវិញ្ញាណចាកសៀវភៅទាំងឡាយដែលមានស្ដីអំពីវិញ្ញាណឱ្យបានច្រើន ទៅទៀតព្រោះអ្វី? ព្រោះថាបើយើងស្គាល់វិញ្ញាណច្បាស់លាស់ យើងអាចនឹងមិនសូវមានសេចក្ដីសង្ស័យអំពីរឿងនិព្វានប៉ុន្មានទេ ។ ខ្ញុំសូមបំភ្លឺគំនិតអ្នកអានម្ដងទៀតថា ដើម្បីការពារនូវសេចក្ដីគិតខុស និព្វានមិនមែនជារបស់សោះសូន្យមិនមានអ្វីនោះទេ ប្រសិនបើថានិព្វានសូន្យនោះ គឺមិនមែនសូន្យដំណឹងដែលហៅថាវិញ្ញាណទេ គឺសូន្យកិលេស សូន្យបុណ្យ សូន្យបាប សូន្យបច្ច័យទាំងឡាយរបស់បដិច្ចសមុប្បាទ។ ចំណែកខាងវិញ្ញាណត្រូវនៅមានសម្រាប់ទទួលនូវបរមសុខ ប៉ុន្តែមិនមែនជាវិញ្ញាណធម្មតានេះទេ វិញ្ញាណនេះត្រូវរលត់រលាយទៅជាមួយបុណ្យបាបនឹងបច្ច័យទាំងឡាយអស់រលីងហើយ វិញ្ញាណនិព្វាននោះគឺវិញ្ញាណដែលមានបុណ្យបាបនឹងបច្ច័យផ្សេងៗអស់ហើយជាវិញ្ញាណចម្លែកអស្ចារ្យមួយដែលដើរតួក្នុងនិព្វានហៅថា **"វិញ្ញាណអនិទស្សនៈ"** ដូចបាននិយាយមកហើយ ។ ក្នុងគម្ពីរពុទ្ធសាសនាខ្លះ នឹងអ្នកប្រាជ្ញពុទ្ធសាសនាខ្លះលោកឱ្យឈ្មោះថា **"ផលញ្ញាណ"** ។ មគ្គ ៨ ឬសីល សមាធិ បញ្ញា ដែលវិញ្ញាណនៃមនុស្សយើងខំប្រឹងដើរតាមប្រតិបត្តិតាមនោះ ទីបំផុតទៅត្រូវបានសម្រេចផលដូចពោលមកនេះ ។

★ ★ ★

# វិញ្ញាណទស្សនាវសាន

សៀវភៅនេះ ខ្ញុំមានបំណងចង់ឱ្យចប់ត្រឹមការតភ្ជាប់របស់វិញ្ញាណតាមចំនួនទំព័រ ដែលគណៈធម្មទានត្រូវការ នឹងពេលដែលខ្ញុំត្រូវបរិច្ចាគ។ តែមានការមួយដែលខ្ញុំយល់ឃើញថាជារបស់សំខាន់ នៃបុគ្គលអ្នកចង់ដឹងអំពីរឿងនិព្វាននឹងវិញ្ញាណ ដែលខ្ញុំពុំទាន់បានដាក់ចូល គឺការប្រមូលអត្ថបទទាំងអស់មកធ្វើជាសំនួរ ដើម្បីឱ្យបេក្ខបុគ្គល (អ្នកសម្លឹងយកនូវនិព្វាន) បានភ្លឺក្នុងការប្រព្រឹត្តធម៌ក្នុងបំណងដឹងនាំខ្លួនឱ្យបានសម្រេចនូវនិព្វាន ក្នុងអនាគតកាល។ ដោយអាស្រ័យការណ៍នេះ ទើបខ្ញុំបង្កើតឱ្យមានវត្ថុនាមមួយទៀតហៅថា **"វិញ្ញាណទស្សនាវសាន"** ជាធម្មតាមនុស្សយើងសឹងតែមិនមានបុគ្គលណាម្នាក់ មិនចង់ស្គាល់នូវសំណង់សម្រេចរូបទេ ឧទាហរណ៍ គ្រឿងផ្ទះមានគ្រឿងអស់ហើយ តែជាងមិនទាន់ចាប់សង់នៅឡើយ ទស្សនិកជនទាំងឡាយក៏មិនអាចដឹងបានថាអនាគតនៃគេហដ្ឋាននោះមានទ្រង់ទ្រាយដូចម្ដេចដែរ ។ **"និព្វានទស្សនៈ វិញ្ញាណទស្សនៈ"** មានអត្ថបទគ្រប់បរិបូណ៌ជាមធ្យមដែរ តែអ្នកនិពន្ធមិនបានតាងសំនួរចម្លើយ អ្នកអានក៏មិនអាចដឹងបានថា **"និព្វានទស្សនៈ វិញ្ញាណទស្សនៈ"** មានបំណងយ៉ាងណាឡើយ ។ ដូច្នេះ យើងត្រូវសាកល្បងធ្វើសំនួរចម្លើយរួមគ្នាចំពោះតែបញ្ហាធំៗ ខ្លះក្នុងរឿងនិព្វាននឹងវិញ្ញាណ តែកុំទាន់អាលសម្រេចយកជាបានការ ។ យើងត្រូវយកសំនួរចម្លើយនេះទៅគិនលម្អិតដោយវិចារណាញ្ញាណរបស់យើងប្រកបដោយ ស្មារតីប្រុងប្រយ័ត្នជាទីបំផុត។ បើយល់ឃើញថាមានហេតុផលល្មមជឿ យើងត្រូវចាប់អនុវត្តភ្លាម តែបើមានហេតុផលមិនគ្រប់គ្រាន់ យើងត្រូវផ្អាកការអនុវត្តន៍ ហើយត្រូវសិក្សាទៅទៀត លុះត្រាតែយល់ច្បាស់ថា ត្រូវចោលឬត្រូវទុកស្រេចហើយលើការគិតអានរបស់យើងព្រោះខ្លួនយើងម្នាក់ៗ ក៏មានសេរីភាពពេញទីក្នុងការដាក់ចូលនូវជំនឿនឹងដកចោលនូវជំនឿ ។ ដើម្បីធ្វើពាក្យសន្ទនាឱ្យស្ដាប់បានងាយខ្ញុំសូមដាក់ឈ្មោះអ្នកធ្វើសំនួរថាធនបាល ឬចៅធនបាល អ្នកធ្វើចម្លើយថា និព្វានបាលត្ថេរៈ ឬភិក្ខុនិព្វានបាល ។

អក្សរកាត់ និព្វានបាលប្រើអក្សរនិចុចមុខ (និ.) ធមបាលប្រើអក្សរ ធចុចមុខ (ធ.) ។

**ចៅធនបាល** = លោកនិព្វានបាលក្នុងវត្តនាមមួយដែលមាននិយាយថា សេចក្ដីចូលចិត្តខុសក្នុងរឿងទាក់ទងជាមួយនិព្វាន តើលោកចង់និយាយថាម៉េច ក្នុងរឿងនេះ?

**ភិក្ខុនិព្វានបាល** = ខ្ញុំចង់និយាយថា និព្វានមិនមែនជារបស់សម្រាប់វ័យ, ពេស, ជាតិសាសន៍... នៃសត្វទាំងឡាយក្នុងសកលពិភពទេ គឺជារបស់សម្រាប់ទាំងអស់គ្នា ព្រោះអ្វី? ព្រោះខ្ញុំសម្អាងលើពុទ្ធភាសិតថា **ឥទំខោបន ភិក្ខវេ ទុក្ខំ អរិយសច្ចំ**... ពុទ្ធភាសិតនេះបញ្ជាក់ឱ្យដឹងថា អ្វីៗ ទាំងអស់ពិតជារបស់មានទុក្ខ កាលណាព្រះអង្គទ្រង់សម្ដែងអំពីរឿងលោកថា ទុក្ខសច្ចៈហើយព្រះអង្គនឹងមិនទ្រង់សម្ដែងអំពីរឿងលោកថា សុខសច្ចៈឡើយ ។ ដូច្នេះ អ្នកដែលត្រូវការសេចក្ដីសុខត្រូវទាក់ទងជាមួយនិព្វាន ព្រោះមានតែនិព្វានមួយប៉ុណ្ណោះទេ ដែលព្រះអរហន្តសម្មាសម្ពុទ្ធឱ្យឈ្មោះថា សុខសច្ចៈ ឬ និរោធសច្ចៈ ។

**ធ** = និព្វានបាលមានអាយុ ចម្លើយរបស់ព្រះគុណក្នុងរឿងនេះនាំឱ្យខ្ញុំព្រះករុណារឹតតែឆ្ងល់ខ្លាំងឡើងទៀត ។ ដូចនេះ សូមមេត្តាឆ្លើយឱ្យបានច្បាស់លាស់ ព្រមទាំងសេចក្ដីបញ្ជាក់ ឬពាក្យឧបមាក្នុងរឿងទាក់ទងជាមួយនិព្វាន និព្វានមិនមែនជារបស់សម្រាប់តែមនុស្សចាស់ និព្វានជាធម្មជាតុមួយដែលមនុស្សគ្រប់វ័យ... ត្រូវតែស្គាល់ ត្រូវតែយកចិត្តទុកដាក់ត្រូវតែប្រាថ្នា ។ តើមនុស្សលោកទាំងអស់ ជាពិសេសគឺយុវជនយុវនារី... ដែលគេចូលចិត្តថា ប្រភពនៃសេចក្ដីសុខនោះ មិនមានរបស់អ្វីក្រៅអំពីរូប សំឡេង ក្លិន រស សម្ផស្សនោះ វាមិនខុសអស់ទៅហើយឬ ?

**និ** = វាមិនខុសទេ ។

**ធ** = បើវាមិនខុស មានតែរូប សំឡេង ក្លិន រស សម្ផស្សរបស់បុរសវាជាតួនិព្វានរបស់ស្ត្រី ឯរូប សំឡេង... នៃស្ត្រីវាជាតួនិព្វានរបស់បុរសទៅហើយឬ?

**និ** = មិនមែនដូចនេះទេ ចៅធនបាល !

យោបល់ថារូប... ជានិព្វាននៃបុរសស្ត្រីនោះត្រូវហើយតែគំហើញនេះនៅខ្វះធម្មជាតុដែលជាគ្រឿងប្រកប គឺមានតែតួរូប... សំឡេង... ប៉ុណ្ណោះ មិនមានធម្មជាតុដទៃប្រកបចូលក្នុងរូប សំឡេង...... នោះទេរបស់ទាំងអស់នេះ ក៏មិនមែនថាតួនិព្វានរបស់មនុស្សលោកឡើយ ។

**ធ** = អ្វីជាគ្រឿងប្រកប ?

**និ** = ធម៌ជាគ្រឿងប្រកប ?

**ធ** = អ្វីជាធម៌ ?

**និ** = ច្បាប់ដែលតាក់តែងឡើងដោយមនុស្សមានចិត្តល្អ មនុស្សអស់មានសេចក្តីខុស មនុស្សអស់មានបញ្ហាអ្វីៗ ចោទមកលើខ្លួនទាំងផ្លូវសង្គមទាំងផ្លូវសីលធម៌ ។

**ធ** = បើដូច្នេះ មិនគឺព្រះនោះហើយឬ?

**ន** = ហ្នឹងហើយ! តែមិនមែនព្រះទាំងឡាយទេ គឺព្រះមានតែមួយ រីឯមនុស្សយើងទាំងអស់គ្នា នរណាដើរផ្លូវជាមួយព្រះ ក៏បានឈ្មោះថា "**មនុស្ស ដើម្បីព្រះ**" គឺខ្លួនគេនឹងបានទៅជាព្រះក្នុងអនាគតកាល ។

**ធ** = សាធុ! ស្តាប់បានហើយ បើដូច្នេះ មានតែយើងត្រូវកាន់ច្បាប់ព្រះទាំងអស់គ្នាទើបធ្វើជាស្វាមីភរិយាផងគ្នា ប្រកបដោយសេចក្តីសុខមែនទេ ! និព្វានបាល! លោកចេះនិយាយមែនហើយ សូមលោកមេត្តាជួយសង្គ្រោះនិយាយឱ្យខ្ញុំបានភ្លឺជាងនេះបន្តិចទៅទៀត បើរឿងនេះពិបាកស្តាប់ សូមធ្វើឧបមាដូចខ្ញុំបានសំណូមពរទុកក្នុងប្រស្នាមុនមកហើយ តើបានឬទេ ?

**និ** = បាន! មនុស្សទាំងឡាយក្នុងបច្ចុប្បន្នកាលនេះក្តី ក្នុងអតីតកាលក្តី ឃើញថា សេចក្តីសុខរបស់គេមានតែមួយគឺ សេចក្តីស្នេហារវាងបុរសស្ត្រី គំនិតនេះត្រូវណាស់ទៅហើយ មិនមាននរណាបដិសេធបានទេ តែគេមិនមានគំហើញឬមិនមានគំនិតថាសេចក្តីទុក្ខរបស់មនុស្សក៏មាន តែមួយគឺសេចក្តីស្នេហារវាងបុរសស្ត្រី។ ចំណែកព្រះវិញព្រះអង្គទ្រង់យល់ឃើញថា សេចក្តីសុខដែលកើតមានឡើងព្រោះសេចក្តីស្នេហានោះ ជាសេចក្តីសុខបោកប្រាស ជាសេចក្តីសុខបន្លំទេ។ ដូច្នេះហើយបានជាព្រះនឹងមនុស្ស ដើម្បីព្រះ លោកបានណែនាំឱ្យគូស្នេហា សាងសេចក្តីស្មោះត្រង់ឬសេចក្តីស្នេហាបរិសុទ្ធិឱ្យគ្នាទៅវិញទៅមក នោះទើបបានសេចក្តីសុខដូចប្រាថ្នា ។ ឧបមាដូចមនុស្សយើងប្រកបអាជីវកម្មអ្វីមួយ ជាកសិកម្មក្តី ឧស្សាហកម្មក្តី ពាណិជ្ជកម្មក្តី ត្រូវមានបំណងល្អក្នុងការងាររបស់ខ្លួនរៀបចំផែនការ កំណត់ចំនួនសាហ៊ុយដែលត្រូវចាយ មានចិត្តស្មោះត្រង់ចំពោះការងារ មានការបោសសម្អាតឧបសគ្គនានា

ជាពិសេសគឺមានចិត្តយុត្តិធម៌ក្នុងនាទីរបស់ខ្លួន ។ល។ ដូច្នេះ ទើបបានសម្រេចនូវសេចក្តីសុខ គឺបានចម្រើនផលសមតាមប្រាថ្នា ។

**ធ** = បើដូច្នេះ មានតែសេចក្តីសុខនោះគឺជាផលនៃចិត្តស្មោះត្រង់ក្នុងការងារ ក្នុងចរិយាថ្លៃថ្នូរ ក្នុងច្បាប់អ្វីៗ ទៅទៀត ក្រៅអំពីដុំសាច់ដុំ សំឡេងដុំក្លិន... នោះទៅវិញហើយមែនទេ ?

**និ** = មែនអ៊ីចឹងហើយ! តែមិនទាំងអស់ទេ ព្រោះវត្ថុធាតុទាំងឡាយមានដុំសាច់ជាដើមនោះក៏ជាបច្ច័យជួយផ្តល់នូវសេចក្តីសុខខ្លះដែរ ប្រសិនបើគេចេះចាត់តែងរៀបចំឱ្យទាំងនោះមានច្បាប់របស់ព្រះ ។

**ធ** = ខ្ញុំស្តាប់បានហើយ អំពីរឿងនិព្វានជារឿងរបស់មនុស្ស ជារឿងដែលត្រូវគិត ត្រូវរៀន ត្រូវចង់បាន ព្រោះនិព្វានផ្តល់ឱ្យនូវសេចក្តីសុខយ៉ាងស្ងប់ តែខ្ញុំពុំទាន់យល់បំណងពុទ្ធសាសនាដែលឱ្យមេរៀន ឱ្យសេចក្តីណែនាំ ជាពិសេសគឺឱ្យមនុស្សរាប់អាននិព្វាន ។ ដូចនេះសូមលោកនិព្វានបាលមេត្តាសម្តែងរឿងនេះឱ្យបានពិស្តារ ដើម្បីជាវិភាគទានដល់ខ្ញុំដែលជួញចិត្តគិតគូរយូរណាស់មកហើយៗ ពុំទាន់បានយល់ដោយជ្រៅជ្រះសោះ តើបានឬទេ ?

**និ** = បាន! មិនលំបាកប៉ុន្មានទេ សូមចៅធនបាលរៀនឡើងវិញនូវពុទ្ធជីវប្រវត្តិនូវប្រតិសាស្រ្តប្រទេសឥណ្ឌាក្នុងសម័យមុនពុទ្ធកាលនឹងសម័យពុទ្ធកាល។ ជួនកាលការសិក្សានេះនាំឱ្យស្គាល់គំនិតពុទ្ធសាសនាស្រេចតែម្តង ធនបាល! មិនឱ្យពុទ្ធសាសនាបង្រៀនអំពីរឿងនិព្វានឯណាបាន បើជនក្នុងវណ្ណៈខ្ពស់ម្នាក់ៗមានទ្រព្យសម្បត្តិចាក់គរដូចភ្នំ មានទាសៈរាប់មិនអស់ មានប្រពន្ធរកដាក់តាមចំនួនលេខមិនកើត ប៉ុណ្ណោះហើយក៏នៅតែពួកអស់ទាំងនេះមិនស្កប់ស្កល់ក្នុងទ្រព្យសម្បត្តិ ក្នុងប្រពន្ធទាំងឡាយរបស់ខ្លួនក្នុងពិភពនៃមនុស្សទេ ពួកនេះបន់ឱ្យខ្លួនដាច់ខ្យល់ទៅ បានទៅកើតក្នុងស្ថានទេវតា មានទ្រព្យសម្បត្តិ មានប្រពន្ធសុទ្ធតែច្រើន សុទ្ធតែទិព្វប្រសើរវិសេសជាស្ថានមនុស្សយ៉ាងផុតវិស័យប្រៀបធៀបបាន។ មនុស្សក្នុងវណ្ណៈពួកខ្ពស់នេះមិនទទួលស្គាល់សេចក្តីទុក្ខព្រួយរបស់អ្នកក្រទេ មិនទទួលដឹងនូវសេចក្តីឈឺចាប់ក្តៅក្រហាយរបស់ស្ត្រីទាំងឡាយ ដែលខ្លួនដាក់គុកគ្នាបង្អត់កាមនោះទេ ។ មនុស្សទាំងឡាយក្នុងវណ្ណៈខ្ពស់មិនត្រឹមតែធ្វើបាបអ្នកក្រធ្វើបាបស្រីៗ ប៉ុណ្ណោះទេ គេទាំងឡាយដដែលនេះ

នាំគ្នាបង្កើតចម្បាំងទាំងឡាយមានចម្បាំងដណ្តើមស្ត្រីនឹងចម្បាំងអាណានិគម ជាដើមទៀតផង ។ តាមប្រវត្តិសាស្ត្រខាងផ្លូវសាសនាថា : ចម្បាំងដណ្តើមស្ត្រីនេះ មានតាំងពីស្ថានមនុស្សរហូតដល់ស្ថានទេវតា (មើលរឿងចម្បាំងរវាងឥន្ទនឹងអសុរ)។ ជនក្នុងវណ្ណៈ ខ្ពស់ដោយខ្លួនចូលចិត្តមានប្រពន្ធច្រើន ម្ល៉ោះហើយចេះតែនឹកក្រែងព្រះទ័យរបស់ព្រះអាទិទេពនៃខ្លួន (ព្រះព្រហ្ម) សេចក្តីក្រែងខ្លាចនេះបានទៅជាបុព្វហេតុមួយឱ្យពួកគេបង្កើតព្រះតៗមកទៀត មានព្រះនារាយណ៍នឹងព្រះឥសូរជាដើម គ្រប់តែព្រះដែលគេបង្កើតនោះ គេឱ្យព្រះអង្គមានប្រពន្ធផងដែរ ដើម្បីកុំឱ្យច្រណែនកូនសិស្ស។ ធនបាល! ដោយអាស្រ័យនិទាននេះ ទើបព្រះអរហន្តសម្មាសម្ពុទ្ធរបស់យើងទ្រង់បង្រៀនអំពីនិព្វាន ណែនាំមនុស្សឱ្យរាប់អាននិព្វានព្រោះអ្វី? ព្រោះព្រះអង្គចង់ឱ្យមនុស្សស្គាល់គ្នាជាមនុស្សជាសត្វមានធាតុប៉ុន្មាន មានអ្វីប៉ុន្មានក៏មានដូចគ្នា សឹងមានចែងច្បាស់ក្នុងបរមត្ថធម៌ ចិត្ត ចេតសិក រូប និព្វាននោះស្រាប់ហើយ ។ ការបង្រៀននេះ មិនមែនមានអានិសង្សត្រឹមតែធ្វើមនុស្សឱ្យចេះស្គាល់គ្នា ចេះអាណិតគ្នា ចេះមិនជិះជាន់គ្នា ចេះជួយគ្នាប៉ុណ្ណោះទេ គឺធ្វើឱ្យមនុស្សអស់ជាតិ អស់វណ្ណៈ អស់ពណ៌សម្បុរ អស់ទេព អស់ឥន្ទ...... សល់នៅតែមនុស្សមួយពួក សត្វមួយពួកប៉ុណ្ណោះដើម្បីឱ្យត្រូវតាមបំណងធម្មជាតិ ព្រោះធម្មជាតិឬវិញ្ញាណដែលបង្កើតមនុស្សសត្វឡើងក៏ពុំបានវាយត្រាឬដាក់សញ្ញាអ្វីសម្រាប់សំគាល់ថាអ្នកនេះជាអ្នកនោះ អ្នកនោះជានេះទេ ។ អ្វីៗទាំងអស់សុទ្ធតែកើតក្រោយដោយសារមនុស្សរៀបចំឱ្យមានឡើង ប្រសិនបើការរៀបចំឱ្យមានស្តេច ស្តេចលោកទ្រង់ច្បាប់ លោកទុកដាក់ព្រះអង្គជាអ្នកបម្រើប្រជាជាតិនោះជាការប្រពៃ តែបើលោកមិនទ្រង់ច្បាប់ លោកជិះជាន់ប្រជាជាតិទៅវិញក៏អស់ផ្លូវស្រេច។ ដូច្នេះ ឃើញថាបំណងនឹងឧត្តមគតិរបស់ពុទ្ធសាសនាក្នុងរឿងនិព្វាននោះ ជារឿងបំផុតដែលគួរតែយើងរៀនទាំងអស់គ្នា គិតគូរទាំងអស់គ្នា ។

**ធ** = និព្វានបាល! លោកសម្តែងយោបល់មកនេះខ្ញុំពីរោះសែនពីរោះ ព្រមជាមួយគ្នានេះ ខ្ញុំនឹកអាណិតពេក ឥន្ទ, ព្រហ្ម, ដែលលោកតានិព្វានបាល មិនបានដាក់ចូលក្នុងមេរៀននៃពុទ្ធសាសនា មិនមានសេចក្តីណែនាំឱ្យមនុស្សប្រាថ្នា តើរឿងនេះយ៉ាងណាទៅវិញ សូមមេត្តាអធិប្បាយព្រមមួយអន្លើដោយសេចក្តីបញ្ជាក់មកផង តើមានសេចក្តីដូចម្តេចទៅវិញ ?

**និ** = ចៅធនបាល! ចំពោះរឿងនេះមិនជាលំបាកយល់ទេ ចូរគិតថា អាយុកាលនៃការត្រាស់ដឹងរបស់ព្រះពុទ្ធជាបរមគ្រូនៃយើង មានចំនួនត្រឹមតែ ៤៥ឆ្នាំ រយៈកាលប៉ុណ្ណេះមិនធួនល្មមឱ្យព្រះអង្គធ្វើការទេសនា បង្រៀន អធិប្បាយ អំពីរឿងស្ថានសួគ៌ស្ថាននរកដ៏វែងអន្លាយនេះបានទេ ។ ដូច្នេះ រឿងសួគ៌នរកវាជារឿងដែលគេធ្លាប់ចេះចាំជាហូរហែតាំងអំពីបូរាណកាលមកស្រាប់។ សាសនាទាំងអស់ក៏មានរឿងនេះ ជំនឿទាំងអស់នៃមនុស្សក៏មានក្នុងរឿងនេះ ។ ព្រះពុទ្ធបរមគ្រូរបស់យើងក្រោយអំពីកាលត្រាស់ដឹងហើយ ព្រះអង្គបានឆ្លើយនូវសំនួរខ្លះ អំពីរឿងសួគ៌នរក ដែលត្រូវចោទឡើងដោយពួកមនុស្សក្នុងសម័យនោះដែរ តែព្រះអង្គពុំសូវយកព្រះទ័យទុកដាក់ខំប្រឹងដោះស្រាយប៉ុន្មានទេ ព្រះអង្គទ្រង់គ្រាន់តែប្រាប់ថា នៅក្នុងពិភពលោកយើងនេះ ក៏មានសួគ៌មាននរកដែរ **(មនុស្សនរក មនុស្សប្រេត មនុស្សតិរច្ឆាន មនុស្សអសុរកាយ មនុស្សទេព)** ព្រះអង្គទ្រង់បញ្ជាក់ថា មនុស្សនរកនៅក្នុងលោកនេះ ស្លាប់ទៅកើតក្នុងលោកខាងមុខជានរកទៀត...... មនុស្សទេពក្នុងលោកនេះស្លាប់ទៅកើតក្នុងលោកខាងមុខជាទេពទៀត។ ក្នុងកថា ៥ **(ទាន សីល សគ្គ អាទីនព នេក្ខកម្ម)** ព្រះអង្គទ្រង់បដិសេធចោលនូវឋានសួគ៌ថា ឋានសួគ៌ជាឋានក្រខ្វក់ប្រកបដោយមន្ទិលសៅហ្មងច្រើន។ នៅក្នុងត្រៃលក្ខណៈ ព្រះអង្គទ្រង់ទាត់ចោលនូវឋានទាំងអស់នឹងអ្វីៗទាំងអស់ថាជារបស់ប្រកបដោយអនិច្ចំ ទុក្ខំ អនត្តា ដោយព្រះពុទ្ធភាសិតថា :

**"ន គាមធម្មោ និគមស្ស ធម្មោ នចាបិយំ ឯកកុសលស្ស ធម្មោ សព្វស្ស លោកស្ស សទេវកស្ស ឯសេវ ធម្មោ យទិទំ អនិច្ចតា យទិទញ្ច ទុក្ខតា យទិទំ អនត្តតា"**

មិនមានប្រែ

ចៅធនបាល! ចូរអ្នកគិតថា មុខងាររបស់ព្រះពុទ្ធបរមគ្រូនៃយើងជាអ្នកទេសន៍ អ្នកបង្រៀន អ្នកឆ្លើយបញ្ហា... មែនពិត តែព្រះអង្គពុំសូវបានទេសន៍... អំពីស្ថានសួគ៌នរកទេ ព្រះអង្គទេសន៍តែអំពីរឿងនិព្វាន ព្រោះអង្គត្រូវការចម្លងសត្វទៅនិព្វាន មិនមែនទៅស្ថានសួគ៌ទេ។ ដូច្នេះហើយបានជាព្រះអង្គទ្រង់បញ្ចប់ធម៌ទេសនារាល់ៗកន្លែងដោយអរិយសច្ចៈឬដោយត្រៃលក្ខណៈ ។

**ធ** = និព្វានបាល! ខ្ញុំស្តាប់បានហើយ តែខ្ញុំចង់ឱ្យព្រះគុណនិយាយបញ្ជាក់ជាថ្មី

ម្តងទៀត ព្រោះរឿងនេះពុទ្ធសាសនិកទាំងឡាយរបស់យើងនៅមានសេចក្តីច្រឡំច្រើនណាស់ ខ្លះយល់ថាសួគ៌នរកព្រះលោកបង្កើតឡើង ខ្លះយល់ថាសួគ៌នរកដែលយើងចេះដឹងគ្រប់គ្នានេះ ព្រះលោកសម្តែងទុកមក ខ្លះយល់ថាសួគ៌នរកមាននៅក្នុងលោកនេះ ក្នុងលោកដទៃមិនមានទេ ខ្លះយល់ថាសួគ៌នរកមានក្នុងលោកដទៃ ក្នុងលោកនេះមិនមានទេ ខ្លះយល់ថាសួគ៌នរកមាននៅក្នុងលោកនេះផងមាននៅក្នុងលោកដទៃផង ខ្លះយល់ថាឋានសួគ៌នៅលើមេឃ ឋាននរកនៅក្រោមដី តើរឿងអស់ទាំងនេះ បើតាមសេចក្តីពិតវានឹងជាយ៉ាងណាទៅវិញ ?

**ន** = ធនបាល! រឿងទាំងអស់នេះវាងាយយល់ទេ ប្រសិនយើងបានស្គាល់បំណងនឹងឧត្តមគតិរបស់ពុទ្ធសាសនាជាមួយនឹងរឿងទាំងឡាយ មានរឿងរស់នៅរបស់មនុស្ស ក្នុងសម័យបុរាណជាដើម។ ដើម្បីឱ្យចៅឆាប់យល់ លោកតាសូមនិយាយទាំងអស់ឡើងវិញថា : របស់ដែលព្រះអរហន្តសម្មាសម្ពុទ្ធនៃយើងទ្រង់រកឃើញដោយផ្ទាល់ខ្លួន របស់ព្រះអង្គមានតែមួយគឺ សច្ចៈ៤ប្រការ (**ទុក្ខៈ សមុទយៈ និរោធៈ មគ្គៈ**) ការរកឃើញសច្ចៈ៤ នេះរបស់ព្រះអង្គមិនមែនមានន័យថាព្រះអង្គអន់ទេ គឺមានន័យថាព្រះអង្គពូកែខ្លាំងណាស់ ព្រោះអ្វីទាំងអស់ក្នុងលោក ជាមនុស្ស ជាសត្វ ជាទេព ជាព្រហ្ម ជានរក ជាប្រេត។ល។ គេរកឃើញ គេរៀនចេះ គេសរសេរចងជារឿងបាន គេទេសន៍បាន គេឆ្លើយរួច ។ល។ តែចំពោះរឿងសច្ចៈឬនិព្វានមិនមាននរណាម្នាក់រកឃើញទេ ដូច្នេះនិព្វានទើបជាធម្មធាតុមួយមានគុណវិសេសមានអាថ៌កំបាំងយ៉ាងចម្លែកអស្ចារ្យ ស្ថិតនៅក្នុងពុទ្ធវិស័យមួយប៉ុណ្ណោះ អ្វីៗទាំងអស់ក្នុងសកលពិភព រួមទាំងឋានសួគ៌ឋាននរកផង ព្រះពុទ្ធមិនបង្កើតទេ របស់ទាំងអស់នេះកើតមានឯងតាមធម្មតាសង្ខារធម៌ ព្រោះការបង្កើតសកលពិភពឬមាននរកសួគ៌នោះ របស់អស់ទាំងនេះបានផុតវិស័យរបស់ព្រះអង្គហើយ តែប្រសិនណាបើព្រះអង្គមានសមត្ថភាពអាចបង្កើតនូវអ្វីៗបានទាំងអស់នោះ ព្រះអង្គទ្រង់មិនបង្កើតឋាននរកទេ ព្រះអង្គនឹងបង្កើតតែឋានសួគ៌មួយប៉ុណ្ណោះ ព្រោះថាអរហន្តសម្មាសម្ពុទ្ធរបស់យើងទ្រង់មានព្រះទ័យអាណិតមនុស្សស្មើគ្នា សូម្បីតែឋាននរកមានស្រាប់ ក៏ព្រះអង្គមិនទ្រង់ដែលដាក់ទណ្ឌកម្មដល់មនុស្សណាម្នាក់ឱ្យចុះនរកឡើយ ។ មនុស្សចុះនរកឡើងសួគ៌ទាំងអស់គ្នា សម្រេចទៅតាមកម្លាំងរុញច្រាននៃបុណ្យបាបរបស់ខ្លួន។ ឋានសួគ៌ឋាននរកសព្វ

ថ្ងៃនេះព្រះអង្គទ្រង់សម្តែងខ្លះ មិនទ្រង់សម្តែងខ្លះទ្រង់សម្តែងតាមគេខ្លះ ទ្រង់សម្តែងតាមព្រះចិន្តារបស់ព្រះអង្គខ្លះ។ ដែលទ្រង់សម្តែងតាមគេ ព្រោះក្នុងសម័យនោះ គេមានជំនឿក្នុងរឿងនរកសួគ៌ត្រូវគ្នាទាំងអស់ ប្រសិនបើព្រះអង្គមិនទ្រង់ថាតាមគេខ្លះ គេក៏មិនព្រមថាតាមព្រះអង្គដែរ ឧទានហរណ៍ :

ព្រះអង្គទ្រង់ថាត្រៃលក្ខណៈមានពីរ **(អនិច្ចំ ទុក្ខំ)** តាមដែលគេរកឃើញមុនការត្រាស់ដឹងរបស់ព្រះអង្គ ។ លុះក្រោយមក ព្រះអង្គទ្រង់ថាត្រៃលក្ខណៈមាន ៣ **(អនិច្ចំ ទុក្ខំ អនត្តា)** តាមដែលព្រះអង្គទើបនឹងរកឃើញមួយទៀត។ ដូចគ្នានឹងអ្នកសរសេរឬអ្នកនិពន្ធក្នុងបច្ចុប្បន្នកាលដែលត្រូវសរសេរតាមគំនិតរបស់ អ្នកនិពន្ធក្នុងអតីតកាលនោះដែរ ព្រោះអ្វី? ព្រោះថាបើមិនធ្វើតាមគេ ក៏មិនដឹងបានអីធ្វើ ដោយមកពីក្នុងពិភពលោកយើងនេះ មិនមានការអ្វីដែលគេមិនទាន់ធ្វើទេ។ ខុសគ្នាតែត្រង់របៀបធ្វើ អ្នកខ្លះធ្វើរបៀបនេះ អ្នកខ្លះធ្វើរបៀបនោះប៉ុណ្ណោះ ។

ចំពោះរឿងដែលថាព្រះអង្គទ្រង់ថាតាមគេនោះ មិនមែនមានន័យថា ព្រះអង្គល្ងង់ឬព្រះអង្គឆ្លាតចង់បោកបំភាន់គេយកលោភសក្ការៈនោះទេ គឺមានន័យថាព្រះអង្គបណ្តោយតាមគេទៅសិន ហើយទ្រង់ទាញគេឱ្យត្រឡប់មកមានជំនឿក្នុងរឿងរបស់ព្រះអង្គជាខាងក្រោយវិញ ។ អ្នកដែលយល់ថានរកសួគ៌មានតែក្នុងលោកនេះ លោកដទៃមិនមាននោះ ជាសេចក្តីយល់តូចពេកណាស់ ឬម្យ៉ាងទៀតអាចនឹងថាជាសេចក្តីយល់ឃើញតែមួយចំហៀង គឺឃើញតែខាងរូបធម៌ មិនឃើញខាងនាមធម៌ បានសេចក្តីថា ឃើញមនុស្សដែលមានទ្រព្យសម្បត្តិស៊ីចាយមិនអស់សម្បូណ៌សប្បាយមានផ្ទះថ្មប្រាសាទ វិមាន... នៅយ៉ាងហ៊ឹហា ថាជាទេវតា។ ឃើញអ្នកក្រអត់ឃ្លានរហេមរហាមឬអ្នកទោសត្រូវទណ្ឌកម្មជាប់គុកច្រវាក់ថាជាសត្វនរក ។ អ្នកដែលយល់ថា នរកសួគ៌មានតែក្នុងលោកដទៃលោកនេះមិនមាននោះ គឺជាសេចក្តីយល់រឹតតែតូចណាស់ទៅទៀត វាដែលមានដែរ មានពិភពលោកហើយ ទៅជាមិនមានទេពមិនមាននរកនោះ ព្រោះហេតុថា ពាក្យទេព ពាក្យនរក គ្រាន់តែជាពាក្យគុណសម្រាប់សម្តែងសេចក្តីសុខទុក្ខឬសេចក្តីអាក្រក់ល្អរបស់មនុស្សប៉ុណ្ណោះ មិនមែនជាពាក្យបរមត្ថទេ។ ពាក្យបរមត្ថសុទ្ធ មានតែចិត្ត ចេតសិក រូប និព្វាន ពាក្យបរមត្ថបរិយាយមានតែ **"សត្វ"** សត្វជាពាក្យនាម កាលណាយកពាក្យគុណមកភ្ជាប់ក៏កើតបានជាសត្វមនុស្ស សត្វតិរច្ឆាន

សត្វនរក សត្វទេព សត្វឥន្ទ សត្វព្រហ្ម សត្វអរូបព្រហ្ម។ល។ អ្នកទាំងពីរពួកបែកមតិគ្នា ព្រោះតែខ្លួនបកស្រាយពុទ្ធបំណងអំពីរឿងសួគ៌នរកមិនទាន់ត្រូវចំ។

ធនបាលថៅ! អ្នកណាដែលយល់ថាសួគ៌នរកមាននៅគ្រប់ពិភពលោក អ្នកនោះប្រាកដជាពុទ្ធសាវ័កហើយ ព្រោះគេបកស្រាយរឿងនរកសួគ៌ត្រូវតាមពុទ្ធបំណង! ធនបាលថៅ! អំពីរឿងនរកសួគ៌ ដែលអ្នកខ្លះយល់ថា នៅលើមេឃ នៅក្នុងដីនោះ សេចក្ដីយល់ឃើញរបស់អ្នកទាំងឡាយនោះមិនត្រូវទេ ព្រោះអ្វី? ព្រោះពាក្យថាលើមេឃ នឹងពាក្យថាក្រោមដី ពាក្យទាំងពីរនេះ ជាពាក្យមិនមានន័យទេ ។ មេឃមិនមានលើដោយហេតុថា ធម្មធាតុមួយដែលយើងស្គាល់ថាជាមេឃនោះ ធម្មជាតិនេះវាមិនមានរូបទេ គឺវាជាអរូបធម៌ ជាឈ្មោះនៃអាកាសទៅវិញទេ ផែនដីគឺពិភពលោកយើងនេះ មិនមានក្រោមទេ ដោយហេតុថាលោកធាតុនេះ មានទ្រង់ទ្រាយជារាងមូល ធំកណ្ដាល តូចសង្ខាង អណ្ដែតនៅក្នុងអាកាសធាតុប្រកបដោយចលនាវិលជាប់ជានិច្ច។ ដូច្នេះ បើយើងសន្និដ្ឋានថាឋានសួគ៌នៅលើមេឃ ក៏មិនដឹងជាលើនោះ នៅត្រង់ណា ព្រោះមេឃជាអរូបធាតុ ថាឋាននរកនៅក្រោមដីក៏មិនដឹងជាក្រោមដីនោះ នៅត្រង់ណាព្រោះដីជាលោកធាតុមួយអណ្ដែតក្នុងអាកាសមិនមានក្រោមមិនមានលើ ។ តែបើយើងសន្និដ្ឋានថាឋានសួគ៌នៅក្នុងពិភពលោកមួយដទៃ ក្រៅអំពីពិភពលោករបស់យើង ឋាននរកនៅក្នុងផ្ទៃដីនៃពិភពលោករបស់យើងនោះ សេចក្ដីសន្និដ្ឋានឬសេចក្ដីចូលចិត្ត នេះនាំឱ្យយើងបានរៀនជាមួយគ្នាអំពី រឿងឋានសួគ៌ឋាននរកទៅលុះត្រាតែចប់ចុងចប់ដើម ។ ការរៀនអំពីរឿងឋានសួគ៌ យើងត្រូវរៀនអំពីធាតុអាកាសដ៏ធំទូលាយមិនមានទីបំផុត នៅក្នុងអាកាសធាតុនេះ តាមគម្ពីរពុទ្ធសាសនាខ្លះក្ដី តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញភូមិសាស្ត្រក្ដី របស់អ្នកប្រាជ្ញអវកាសក្ដី បាននិយាយត្រូវគ្នាថា នៅក្នុងអាកាសធាតុមានចក្រវាឡច្រើន មានពិភពលោកច្រើន។ បើពិភពលោកមានច្រើនដូចថាមកនេះមែន ប្រាកដជាមានពិភពលោកល្អ ពិភពលោកអាក្រក់ ពិភពលោកមានសុខ ពិភពលោកមានទុក្ខ ពិភពលោករីកចម្រើន ពិភពលោកមិនទាន់រីកចម្រើន ដែលហៅថា ឋានសួគ៌ឋាននរក ដូចយើងធ្លាប់ចេះមក។ ធនបាលថៅ! ចំពោះឋាននរកត្រង់ នេះវិញដែលជនពួកមួយចូលចិត្តថា នៅក្រោមដីនោះមិនមែនទេ ព្រោះដីពោលគឺពិភពលោកយើងនេះមិនមានលើក្រោមទេ ដូចលោកតាបានពន្យល់មកហើយ

តែបើគេថានរកនៅក្នុងដីវិញនោះ ។ ពាក្យនេះមានន័យគួរឱ្យបកស្រាយទៅជាពីរយ៉ាង : ម្យ៉ាងដីគឺពិភពលោកយើង (ដីខាងក្រៅ) ម្យ៉ាងដីគឺរូបកាយរបស់មនុស្សយើង (ដីខាងក្នុង) ។

ចៅធនបាល! អ្នកចូរស្គាល់ដីគឺពិភពនៃមនុស្សយើង តាមសេចក្ដីសន្និដ្ឋាននៃអ្នកប្រាជ្ញភូមិសាស្ត្រក្នុងសម័យបុរាណសិន អ្នកប្រាជ្ញភូមិសាស្ត្របុរាណ ចូលចិត្តថាដីសព្វថ្ងៃនេះ កាលអំពីដើមឡើយ គឺជាចំណែកមួយរបស់ពិភពអាទិត្យ លោកថាដីគឺពិភពយើងនេះ បានរបេះចេញចាកដួងអាទិត្យមក ថាដួងអាទិត្យវិលញាប់ណាស់កម្លាំងវិលញាប់នៃដួងអាទិត្យនេះហើយ ដែលទាក់ច្រានបំណែកពោលគឺពិភពលោកយើងនេះ ឱ្យខ្ទាតចេញឆ្ងាយ អស់មានពេលវិលទៅជួបគ្នាបាន។ ពិភពលោកនេះកាលទើបនឹងបែបចេញមកមានធាតុលក្ខណ ជាដុំភ្លើង ក្រោយមកដុំភ្លើងនេះសន្សឹមរលត់សន្សឹម ត្រជាក់បន្តិចម្ដងៗ កើតបានជាផែនដីរបស់យើងទៅ។ អ្នកប្រាជ្ញភូមិសាស្ត្របច្ចុប្បន្នបានសន្និដ្ឋានតមកទៀតថា ពិភពលោកយើងពិតមែនតែបានរលត់ភ្លើងរលត់កំដៅ តែរលត់ត្រឹមសំបកក្រៅទេ ខាងក្នុងនៅមានភ្លើងមានកំដៅនៅឡើយ។ ធនបាល! ចំពោះការវិវត្តន៍នៃពិភពលោកនេះ ខ្ញុំចូលចិត្តថា អ្នកប្រាជ្ញទាំងឡាយនោះមានសេចក្ដីសន្និដ្ឋានត្រូវ ។ លោកតាសូមធ្វើសេចក្ដីសន្និដ្ឋានតមកទៀតថាភ្លើងក្នុងពិភពលោកមិនរលត់ទេ ប្រសិនបើរលត់ពិភពលោកក៏ត្រូវរលាយឬត្រូវស្លាប់ជាពិតប្រាកដមិនខានឡើយ ព្រោះអ្វី? ព្រោះវត្ថុធាតុទាំងឡាយទាំងមានជីវិតទាំងឥតជីវិត សុទ្ធតែត្រូវអាស្រ័យធាតុភ្លើងទាំងអស់។ ធនបាល! ដោយយោងមកអំពីគម្ពីរទាំងឡាយ ដែលមាននិយាយអំពីរណ្ដៅនរកទាំងឡាយ មាននរកឈ្មោះអវិចីជាដើមនោះខ្ញុំយល់ថានរកបើវានៅក្នុងដី ហើយជាដីខាងក្រៅ មានតែដីក្នុងផ្ទៃនៃពិភពនេះឯង ពីព្រោះនៅក្នុងនោះមានកំដៅភ្លើងយ៉ាងខ្លាំង។ កំដៅនេះ មិនដឹងកាលណានឹងរលត់ទេ ពិភពមនុស្សយើងតាមសេចក្ដីដៅស្មានរបស់អ្នកប្រាជ្ញថា មានអាយុជាងពីរពាន់លានឆ្នាំមកហើយ ក៏នៅតែមានផ្ទុះភ្នំភ្លើងរឿងៗ វេលាផ្ទុះម្ដងៗ មានគ្រោះភ័យដល់មនុស្សសត្វ នឹងទ្រព្យសម្បត្តិយ៉ាងច្រើនដែលអ្នកវិទ្យាសាស្ត្រគួរតែរកមធ្យោបាយការពារគ្រោះកាចនេះឱ្យបានពូកែសក្តិសិទ្ធិ តែរកពុំទាន់ឃើញនៅឡើយ ប្រហែលជាដូចនេះទេដឹង! ដែលហៅរណ្ដៅនរកអវីចី តាមដែលយើងចេះគ្រប់គ្នា ព្រោះអវីចីប្រែ

ថានរកអណ្ដាតភ្លើងស្រាប់ ។ ធនបាល! ចំពោះរឿងនេះ បើអ្នកជឿក្ដីមិនជឿក្ដី ចូរអ្នកកុំសួរខ្ញុំថា សត្វនរកនោះម៉េចក៏មិនស្លាប់? ឬស្លាប់ហើយម៉េចក៏កើតវិញ ឬសត្វនរកនោះបានអ្វីជាអាហារ? បញ្ហានេះខ្ញុំមិនឆ្លើយទេ ដែលខ្ញុំមិនឆ្លើយនេះ មិនមែនមានន័យថា ខ្ញុំមិនចេះគម្ពីរទេ ខ្ញុំចេះតែខ្ញុំមិនយល់បំណងមិនយល់ន័យរបស់លោក មិនដឹងជាលោកចង់និយាយថាម៉េចអំពីរឿងនេះ។ ធនបាល! បើអ្នកមិនធុញស្ដាប់ទេ ចូរអ្នកស្ដាប់អំពីរឿងនរកនឹងសួគ៌មួយបែបទៀត ដែលមាននៅក្នុងខ្លួនរបស់មនុស្សយើង នរកសួគ៌នេះ ព្រះពុទ្ធបរមគ្រូរបស់យើងទ្រង់ទេសនាដោយត្រង់ៗផង ដោយបរិយាយផង ដោយត្រង់ៗថា :

ភិក្ខុទាំងឡាយ! វាជាសំណាងរបស់អ្នកទាំងឡាយហើយ អ្នកទាំងឡាយបានល្អហើយ ដែលបានមានឱកាសប្រព្រឹត្តព្រហ្មចរិយធម៌ យើងបានឃើញហើយភិក្ខុទាំងឡាយ! នរកនឹងសួគ៌មាននៅក្នុងអាយតនៈ ៦ ដែលជាអណ្ដូងជាទីកើតឡើងនៃផស្សៈនេះឯង សេចក្ដីនេះយ៉ាងណា? គឺក្នុងខណៈណាអាយតនៈខាងក្នុង ៦ បានជួបប្រទះរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ មិនជាទីប្រាថ្នា មិនជាទីពេញចិត្ត ក្នុងខណៈនោះចិត្តក៏សោយអារម្មណ៍ជានរក។ ក្នុងខណៈណាអាយតនៈ ៦ បានជួបប្រទះ រូប សំឡេង... ជាទីប្រាថ្នាជាទីពេញចិត្ត ក្នុងខណៈនោះ ចិត្តក៏រសាយអារម្មណ៍ជាសួគ៌។

## ដោយបរិយាយថា

ភិក្ខុទាំងឡាយ! ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ត្រូវភ្លើងដុតកំដៅរឿយៗ អ្វីជាភ្លើង? រាគៈ ទោសៈ មោហៈ យើងពោលថាជាភ្លើង ជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ក៏យើងពោលថាជាភ្លើង ភិក្ខុទាំងឡាយមិនមានកំដៅភ្លើងឯណា ក្នុងលោកនេះក្ដៅស្មើនឹងភ្លើងអស់ទាំងនេះទេ ។

ធនបាល! នេះហើយជានរកនៅក្នុងដី ពោលគឺក្នុងរូបកាយយើងទាំងអស់គ្នា ព្រោះរូបកាយយើងក៏ជាដីមួយដែរ ដែលបរមត្ថហៅថា មហាភូតរូប៤ នោះឯង។ ពុទ្ធភាសិតនេះឆ្ងាញ់ណាស់ ស្ដាប់ហើយមានសេចក្ដីតក់ស្លុតភ្លាម មានសេចក្ដីរីករាយភ្លាម ព្រោះពុទ្ធភាសិតនេះ បានចង្អុលបង្ហាញនរកសួគ៌ក្នុងបច្ចុប្បន្នយ៉ាងច្បាស់ក្រឡែត ដោយមិនចាំបាច់ប្រើគំនិតនាំឱ្យខាតពេល ។ ក្នុងឋានៈនៃព្រះអង្គជាមនុស្សម្នាក់ដែល

គេទទួលស្គាល់ថាជាព្រះរបស់គេគ្រប់គ្នា ព្រះអង្គមិនទ្រង់លាក់ឋានសួគ៌ឋាននរកទេ ព្រះអង្គតែងប្រាប់ថា នរកសួគ៌មាននៅក្នុងលោកនេះផងមាននៅក្នុងលោកដទៃផង ពិសេសជាងនេះទៅទៀត ព្រះអង្គមិនទ្រង់បន្លាចមនុស្សដោយឋាននរកនឹងមិនទ្រង់ព្រលោមមនុស្សឱ្យសប្បាយដោយឋានសួគ៌ទេ។ ព្រោះអ្វី? ព្រោះសេចក្ដីទុក្ខក្នុងនរកនោះ(នរកក្រៅខ្លួន) ជាសេចក្ដីទុក្ខតូចតាចទេ ព្រោះសេចក្ដីសប្បាយក្នុងឋានសួគ៌ក៏ជាសេចក្ដីសប្បាយតូចតាចដូចគ្នាដែរ ។ ដើម្បីឱ្យរឿងនេះ បានជារឿងមានប្រសិទ្ធិភាពសម្រាប់ពុទ្ធសាសនារបស់យើង ពុទ្ធសាសនាទាំងឡាយគប្បីអានឡើងវិញនូវសច្ចៈទី១ ដែលសម្ដែងដោយព្រះពុទ្ធបរមគ្រូថា :

"ភិក្ខុទាំងឡាយ! របស់អ្វីខ្លះដែលពិតជាបច្ច័យនៃសេចក្ដីទុក្ខព្រួយ? ភិក្ខុទាំងឡាយ! របស់ទាំងឡាយនេះ ជាបច្ច័យនៃសេចក្ដីទុក្ខព្រួយគឺ : ជាតិ ជរា ព្យាធិ មរណៈ **អប្បិយេហិសម្បយោគៈ : បិយេហិវិប្បយោគៈ យម្បិច្ឆំនលភតិ សង្ខិត្តេន បញ្ចក្ខន្ធៈ** : ភិក្ខុទាំងឡាយ! របស់ទាំងឡាយនេះហើយដែលធ្វើឱ្យអ្នករាល់គ្នាមានទុក្ខធំ ទុក្ខយូរ ភិក្ខុទាំងឡាយ អ្នកត្រូវនាំគ្នាគិតគូរធ្វើយ៉ាងណាឱ្យអស់នូវរបស់ទាំងឡាយនេះទៅ ទើបអស់សេចក្ដីទុក្ខគ្រប់យ៉ាងដែលអ្នកទាំងឡាយមិនត្រូវការ" ។

ពុទ្ធភាសិតនេះ បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា មិនមានទុក្ខឯណាធំជាង យូរជាងទុក្ខទាំងឡាយនេះឡើយ ហើយក៏មិនមានទុក្ខទាំងឡាយណាដទៃទៀត មុខគួរឱ្យខ្លាចឱ្យធុញទ្រាន់ ជាងទុក្ខទាំងឡាយដែលមានមកក្នុងពុទ្ធភាសិតនេះទេ ព្រោះទុក្ខទាំងអស់នេះ មាននៅគ្រប់ភូមិគ្រប់ភពដែលមានសត្វកើត សត្វនៅតែម្ដង ។

**ធ** = សាធុ! ឆ្លើយមកនេះខ្ញុំព្រះករុណាស្ដាប់យល់គ្រប់ចំណុចនៃសំនួររបស់ខ្ញុំព្រះករុណាហើយ ប្រសិនបើលោកតាមិនទាន់មានសេចក្ដីធុញទ្រាន់ទេ ។ ខ្ញុំព្រះករុ-ណាសូមនិមន្តលោកតាសម្ដែងអំពីភូមិដែលសត្វកើត បដិសន្ធិដែលសត្វមាន កម្មដែលសត្វសាង សេចក្ដីស្លាប់ដែលសត្វទទួល ព្រោះរឿងនេះជាប់ទាក់ទងមកអំពីរឿងមុនដែលខ្ញុំព្រះករុណាភ្លេចពុំទាន់បានសួរ តើរបស់ទាំងអស់នេះ មានប៉ុន្មានយ៉ាងទៅដែរ? ក្នុងយ៉ាងមួយៗ ចែកចេញជាប៉ុន្មានទៅទៀត ? ។

**និ** = ភូមិដែលសត្វកើតមាន ៤ គឺ :

១- អបាយភូមិ ៤

២- កាមសុគតិភូមិ ៧

៣- រូបាវចរភូមិ ១៦

៤- អរូបាវចរភូមិ ៤

**អបាយភូមិ ៤**

ក- នរក

ខ- ប្រេត

គ- តិរច្ឆាន

ឃ- អសុរកាយ

**កាមសុគតិភូមិ ៧**

ក- មនុស្ស

ខ- ចាតុ

គ- តាវតឹង្ស

ឃ- យាមា

ង- តុសិត

ច- បរនិម្មិត

ឆ- បរនិម្មិតវសវតី

**រូបាវចរភូមិ ១៧**

ព្រហ្មបារិសជ្ជា ។ល។ អកនិដ្ឋកា ។

**អរូបាវចរភូមិ ៤**

ក- អាកាសានញ្ចាយតនៈ

ខ- វិញ្ញាណញ្ចាយតនៈ

គ- អាកិញ្ចញ្ញាយតនៈ

ឃ- នេវសញ្ញានាសញ្ញាយតនៈ

**បដិសន្ធិមាន ៤ គឺ :**

១- អបាយបដិសន្ធិ

២- កាមសុគតិបដិសន្ធិ

៣- រូបាវចរបដិសន្ធិ

៤- អរូបាវចរបដិសន្ធិ

**អបាយបដិសន្ធិ ៤ :**

ក- និរយបដិសន្ធិ

ខ- បេតបដិសន្ធិ

គ- តិរច្ឆានបដិសន្ធិ

ឃ- អសុរកាយបដិសន្ធិ

**កម្ម ៤ គឺ :**

១- ជនកកម្ម

២- ឧបត្ថម្ភកកម្ម

៣- ឧបបិទ្បិកកម្ម

៤- ឧបឃាតកកម្ម

**មរណៈ ៤ គឺ :**

១- អាយុខយៈ

២- កម្មខយៈ

៣- ឧភយខយៈ

៤- ឧបច្ឆេទកៈ ។

**ធ** = ខ្ញុំស្តាប់បានហើយលោកតា តែខ្ញុំនៅឆ្ងល់ថា ហេតុដូចម្តេចទើបព្រះពុទ្ធបរមគ្រូរបស់យើង ទ្រង់សង្គ្រោះអបាយភូមិ ៤ ចូលមកក្នុងភូមិរបស់មនុស្សគឺនៅក្នុងពិភពនៃមនុស្ស ? ហេតុយ៉ាងណាបានជាព្រះអង្គទ្រង់ចាត់ទុកឋានមនុស្សជាសុគតិភូមិ គឺជាឋានសួគ៌ដែរ? តើលោកតានិព្វានបាលអាចនឹងបកស្រាយបំណងរបស់ព្រះអង្គក្នុងរឿងនេះបានឬទេ?

**និ** = ចៅធនបាល! ដូចលោកតាបាននិយាយមកហើយថា នរកសួគ៌មាននៅក្នុងលោកនេះផង ក្នុងលោកដទៃផងម៉េចក៏ចៅនៅតែមិនចូលចិត្ត ឬមួយចៅអស់ជំនឿក្នុងព្រះសទ្ធម្មនៃព្រះអរហន្តសម្មាសម្ពុទ្ធហើយ។

**ធ** = មិនដូច្នោះទេ លោកតា! ចៅនៅតែជឿ ហើយរិតតែជឿច្រើនឡើងទៀត

ផង ក្នុងពេលដែលចៅបានមកសន្ទនាធម៌ជាមួយលោកតា។ ដើម្បីសង្គ្រោះខ្ញុំព្រះករុណាឱ្យបានជាពុទ្ធសាសនិកម្នាក់ មានជំនឿក្នុងធម៌អស់សេចក្ដីសង្ស័យនោះ សូមលោកតាមេត្តាឆ្លើយពន្យល់ម្ដងទៀត ព្រមទាំងអាងគម្ពីរផង តើរឿងឋានសួគ៌នរក... មកនៅជាមួយឋានមនុស្សយើងនេះមានភស្ដុតាងប្រាកដយ៉ាងណា ?

**និ** = ចៅធនបាលមិនអន់ទេណា៎ ចេះដេញដោលរកគម្ពីរដីការផងតើ! មិនអីទេ! លោកតាមិនភ័យមិនស្លន់ទេ ចូរទៅផ្ទៀងស្ដាប់ដោយយកចិត្តទុកដាក់ចុះ អាត្មានឹងឱ្យពាក្យអធិប្បាយពន្យល់នឹងគម្ពីរដូចមានតទៅនេះ ÷

ពាក្យពន្យល់ : មិនមាននរណាម្នាក់អាចដកនរកសួគ៌ព្រហ្មចេញអំពីឋានមនុស្សបានទេ ព្រោះពាក្យថា នរក សួគ៌ ព្រហ្ម វាគ្រាន់តែជាពាក្យគុណ សម្ដែងលក្ខណៈនៃមនុស្សយើងឱ្យដឹងថា នរណាអាក្រក់ នរណាល្អ នរណាសុខ នរណាទុក្ខ ។ល។ ឧទាហរណ៍ មនុស្សនរក មនុស្សមិនល្អ ឬមនុស្សមានសេចក្ដីទុក្ខ មនុស្សទេព មនុស្សល្អឬមនុស្សមានសេចក្ដីសុខ មនុស្សព្រហ្ម មនុស្សប្រសើរឬមនុស្សបរិសុទ្ធ។ ធនបាលចៅ! ចូរអ្នកកុំភ្លេចថាមនុស្សនរកក្នុងលោកនេះ ស្លាប់ទៅកើតជាសត្វនរកក្នុងលោកដទៃទៀត មនុស្សនរកក្នុងលោកដទៃ ស្លាប់មកកើតជាសត្វនរកក្នុងលោកយើងនេះផ្លាស់ប្ដូរគ្នាទៅវិញទៅមក ។

ចំណែកទេវតានឹងព្រហ្មក៏មានការផ្លាស់ប្ដូរកំណើតចុះឡើងដូចជានរកដែរ ។ ដើម្បីឱ្យចៅកាន់តែបានយល់ច្រើនជាងនេះទៅទៀត អាត្មាសូមបញ្ជាក់ថា មនុស្សក្នុងសម័យបូរាណ គេនាំគ្នាបង្កើតឱ្យមានព្រះ ឱ្យមានទេព ឱ្យមានឥន្ទ ឱ្យមានព្រហ្ម... តើគេបង្កើតធ្វើអ្វី មិនមែនព្រោះចង់បានសេចក្ដីល្អនោះទេឬ? មនុស្សដូចគ្នាធ្វើបាបគ្នា គេឱ្យឈ្មោះមនុស្សនរក មនុស្សដូចគ្នាទំនុកបម្រុងគ្នា គេឱ្យឈ្មោះថាមនុស្សទេព មនុស្សដូចគ្នាលែងប្រកាន់ទោសគ្នា គេឱ្យឈ្មោះថាមនុស្សព្រហ្ម ។ គេនឹកឃើញវែងឆ្ងាយថា នៅក្នុងមេឃមានទេព មានឥន្ទ មានព្រហ្ម ជាសត្វល្អប្រសើរ ចាំជួយសង្គ្រោះមនុស្សឱ្យអស់ទុក្ខ។ ដូចនេះហើយបានជាគេឃើញមនុស្សណាល្អ គេហៅថាមនុស្សទេព មនុស្សឥន្ទ មនុស្សព្រហ្ម ។ ដោយអាស្រ័យហេតុដូចបាននិយាយមកនេះទើបពុទ្ធសាសនាបាន យកឈ្មោះទេពមកភ្ជាប់នឹងឈ្មោះមនុស្សដែលបានធ្វើការបម្រើមនុស្សលោកដោយសុចរិតយុត្តិធម៌ កើតបានជាបុព្វទេព វិសុទ្ធិទេព សម្មតិទេព

ឧប្បត្តិទេព ។ បុព្វទេពបានដល់មាតាបិតានិងអាណាព្យាបាល វិសុទ្ធិទេពបានដល់អង្គព្រះអរហន្តសម្មាសម្ពុទ្ធជាមួយសាវ័កទាំងឡាយ សម្មតិទេពបានដល់អ្នកបម្រើប្រជាជាតិក្នុងប្រទេសឱ្យបានប្រកបដោយសេចក្ដីសុខ មានគតិយុត្តិធម៌បរិបូណ៌ មានព្រះរាជានឹងអាមាត្យទាំងឡាយជាដើម ឧប្បត្តិទេព បានដល់ទេវតាក្នុងលោកដទៃឬទេវតាដែលកើតតាមលក្ខណៈចិត្តប្រព្រឹត្តទៅ គឺមនុស្សយើងនេះឯងកាលណាចិត្តល្អកើតឡើង ក៏កើតបានជាទេវតា កាលណាចិត្តល្អរលត់ទៅ ក៏អស់ភាពជាទេវតាទៅវិញ។

ចៅធនបាល! ប្រសិនណាហើយបើយើងដក **"គុណស័ព្ទ"** ពួកនេះគឺនិរិយ តិរច្ឆាន បេត អសុរ ទេព ព្រហ្ម ។ល។ ចេញទៅនោះប្រាកដជាមនុស្សយើងមិនខានច្រឡំគ្នាទេ ព្រោះខ្វះគុណលក្ខណៈសម្រាប់សំគាល់ សម្រាប់ចំណាំឱ្យដឹងថា មនុស្សណាជាមនុស្សអាក្រក់ មនុស្សណាជាមនុស្សល្អ ។ល។ ព្រោះតែដូច្នេះហើយ បានជាព្រះសម្ពុទ្ធទ្រង់លើកពាក្យបរមត្ថធម៌ទី ២ គឺរូបបន្ទាប់អំពីចិត្តនោះមកឱ្យឈ្មោះថា **"សត្វ"** ហើយទ្រង់យកពាក្យ **"សត្វ"** នោះភ្ជាប់ទៅជាមួយមនុស្ស ទេព ឥន្ទ ព្រហ្ម... កើតបានជាសត្វមនុស្ស សត្វទេព សត្វឥន្ទ សត្វព្រហ្ម សត្វតិរច្ឆាន... ហៅថាពាក្យបញ្ញត្ត ឬ ពាក្យព្រះសូត្រ សម្រាប់តែនិយាយគ្នាឱ្យស្ដាប់បាន ។ រីឯពាក្យឯកភាពឬពាក្យបរមត្ថនោះមានតែមួយគឺមហាភូតរូប ៤ ប្រសាទរូប ៥ វិស័យរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប១ អាហាររូបប៉ុណ្ណោះ ។

## ពាក្យគម្ពីរបាលីធម្មបទ

**"មនោ បុព្វង្គមា ធម្មា មនោ សេដ្ឋា មនោ មយា មនសា ចេ បសន្នេន ភាសតិវា ករោតិ វា តតានំ សុខមន្វេតិ ឆាយា វ អនុបាយិនី"**

**"មនោបុព្វង្គមា ធម្មា មនោ សេដ្ឋា មនោ មយា មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា តតោនំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ"**

"ភិក្ខុទាំងឡាយ! ធម៌ទាំងឡាយ មានចិត្តជាធម្មធាតុផ្ដើមបង្កើតមានចិត្តជាធាតុធ្វើឱ្យល្អវិសេស មានចិត្តជាធម្មធាតុធ្វើឱ្យសម្រេច បើបុគ្គលមានចិត្តស្អាតស្អាន ទំហើដែលធ្វើក៏ស្អាតស្អាន ក្នុងលំដាប់តមកសេចក្ដីសុខក៏ជាប់តាមទៅជាមួយបុគ្គលនោះដូចជាស្រមោលជាប់តាមប្រាណនៃមនុស្ស"

"ភិក្ខុទាំងឡាយ! ធម៌ទាំងឡាយមានចិត្តជាធម្មធាតុផ្ដើមបង្កើតមានចិត្តជាធម្មធាតុធ្វើឱ្យវិសេស មានចិត្តជាធម្មធាតុធ្វើឱ្យសម្រេច បើបុគ្គលមានចិត្តអាក្រក់ សម្ដីដែលនិយាយក៏អាក្រក់ ទំហើដែលធ្វើក៏អាក្រក់ក្នុងលំដាប់តមក សេចក្ដីទុក្ខក៏ជាប់តាមទៅជាមួយបុគ្គលនោះ ដូចកង់រទេះវិលតាមជើងគោ"

ពុទ្ធភាសិតនេះ បញ្ជាក់ថាសេចក្ដីសុខទុក្ខជាប់តាមបុគ្គលអ្នកធ្វើបុណ្យបាបចាប់តាំងអំពីពេលដែលខ្លួនបានប្រព្រឹត្ត។ ន័យរបស់ភាសិតនេះយើងត្រូវបកស្រាយថា មនុស្សយើងត្រូវបានធ្លាក់នរកនឹងត្រូវបានឡើងឋានសួគ៌ក្នុងបច្ចុប្បន្ននេះហើយ ព្រោះអ្វី? ព្រោះសេចក្ដីទុក្ខជាឈ្មោះរបស់នរក សេចក្ដីសុខជាឈ្មោះរបស់សួគ៌ ។ លុះដល់ថ្ងៃស្លាប់ បុគ្គលនោះក៏ចុះនរកនឹងឡើងសួគ៌មួយក្នុងជីវិតថ្មីទៀត ។

## ពាក្យគម្ពីរបាលីអភិធម្ម

**"ចតស្សោ ភូមិយោ ចតុព្វិធាបដិសន្ធិ ចត្តារិកម្មានិ ចតុធាមរណុប្បត្តិ ចេតិ វិថិមុត្តសង្គហេ ចត្តារិ ចតុក្កានិ វេទិតព្វានិ"**

"អ្នកប្រាជ្ញទាំងឡាយគប្បីដឹងថា ចតុក្កទាំងឡាយ ៤ មានមកក្នុងវិថីមុត្តសង្គហ គឺភូមិចតុក្កៈ១ បដិសន្ធិចតុក្កៈ១, កម្មចតុក្កៈ ១ មរណចតុក្កៈ១។ បួនៗដងដូចនិយាយមកខាងដើមហើយ ។ ដោយមានពុទ្ធភាសិតនេះ ជាសម្អាងទើបខ្ញុំសម្រេចថា ស្រុកមនុស្សយើងក៏ជាស្ថានសួគ៌មួយដែរ ព្រោះស្រុកមនុស្សលោកចាត់ចូលក្នុងសុគតិភូមិ។ ប៉ុន្ដែស្រុកមនុស្សក៏ជាឋាននរកមួយដែរ ព្រោះស្រុកមនុស្សលោកចាត់ចូលក្នុងអបាយភូមិមួយទៀត ។ ដូច្នេះ នរកនឹងសួគ៌ដែលយើងត្រូវស្គាល់ជាបឋមនោះ គឺនរកនឹងសួគ៌ក្នុងខ្លួនរបស់យើងឬក្នុងខួរក្បាលរបស់យើង ព្រោះពុទ្ធសាសនាបានសម្រេចថា មានតែចិត្តទេដែលជាធម្មធាតុធំក្នុងការធ្វើបុណ្យបាប ក្នុងការទទួលនូវផលនៃបុណ្យបាប គឺមានតែចិត្តទេដែលត្រូវធ្លាក់នរកត្រូវឡើងសួគ៌ ។ ចំណែករូបកាយត្រូវគេដុតចោលអសារឥតការមិនមានទៅណាមកណាបានទៀតទេ ។

**ធ** = សេចក្ដីពន្យល់នឹងសេចក្ដីសម្អាង របស់លោកតានិព្វានបាលស្ដាប់បានច្រើនយល់បានច្រើន តែចៅសូមអភ័យទោសទៅចុះ ខ្ញុំព្រះករុណាមិនទាន់អស់សេចក្ដីសង្ស័យទេ ក្នុងរឿងនរកសួគ៌នេះ ព្រោះមានគម្ពីរខ្លះដែលចៅបានមើលបាន

អាន មានទេវទូតសូត្រជាដើម នឹងពាក្យនិយាយខ្លះដែលចៅបានឮគេនិយាយរឿយៗ ថា ក្នុងឋាននរកនោះមានគ្រឿងសស្ត្រាវុធ សម្រាប់ប្រហារ មានភ្លើងសម្រាប់ដុត មានទឹកក្តៅសម្រាប់ស្រោច ។ល។ មានយមបាលចាប់ចងបណ្តើរ ឬគ្រវែង មានយមរាជពិភាក្សាសួរចម្លើយសត្វនរក តើរឿងនេះវាយ៉ាងម៉េចទៅវិញសូមលោកតាបំភ្លឺខ្ញុំព្រះករុណាបន្តិចមកទៀតដោយសេចក្តីអនុគ្រោះទៅចុះ ។

**និ** = វាមិនមែនយ៉ាងដូច្នេះទាំងអស់ទេ ធនបាលចៅ ។

**ធ** = បើមិនមែន មានតែគម្ពីរនោះខុសឬ អ្នកនិយាយមកនោះខុសឬ យ៉ាងណាទៅវិញលោកតា ?

**និ** = គម្ពីរមិនមែនសុទ្ធតែត្រូវទេ គង់មានខុសខ្លះជាមិនខាន បើមិនច្រើនក៏តិច។ ចំពោះរឿងនេះ មនុស្សលោកគេមិនសូវឆ្ងល់ប៉ុន្មានទេចៅ! ព្រោះខុសនឹងត្រូវវាជាគូនឹងគ្នា វាធ្លាប់មានហូរហែរមកហើយ ។ ដោយរឿងខុសនេះជៀសមិនរួច ការពារមិនឈ្នះនោះហើយ បានជាព្រះសម្ពុទ្ធរបស់យើងទ្រង់ដាស់ទឿនស្មារតីនៃអ្នកគម្ពីរ ក្នុងកាលាមសូត្រថា ÷ "**នបិដក សម្បនានេន**" ថាកុំជឿតែតាមគម្ពីរពេក ។ នេះបញ្ជាក់ឱ្យយើងដឹងថា ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់មិនទុកព្រះទ័យលើគម្ពីរទាំងនោះទាំងអស់ទេ ទើបទ្រង់ត្រាស់រំលឹកមកយ៉ាងនេះ ។ សម្រាប់ខ្លួនលោកតា យល់ថាគម្ពីរទេវទូតសូត្រទាំងអស់ដែរ ព្រោះក្នុងសម័យនោះ ជំនឿនៃមនុស្សយើងមានឯកភាពណាស់ លទ្ធិណា សាសនាណាក៏មាននរកបែបគ្នានេះទាំងអស់ លុះមកដល់សម័យវិទ្យាសាស្ត្រចម្រើនយ៉ាងខ្លាំងនេះជំនឿនៃមនុស្សមិនមានឯកភាពទេ ដែលខូចឯកភាពនៃជំនឿនេះមិនមានអ្នកឯណាធ្វើទេ គឺពួកទស្សនវិទូគ្រប់សង្គមជាតិ សង្គមសាសនា ខំប្រឹងត្រដររកផ្លូវរត់មុខវិទ្យាសាស្ត្រ ក៏ចេះតែសម្តែងយោបល់ថ្មីៗ ឬកែប្រែយោបល់ចាស់ខ្លះដើម្បីទប់ទល់កុំឱ្យវិទ្យាសាស្ត្រទាត់ចោលនូវជំនឿរបស់ខ្លួន។ ព្រឹត្តិការណ៍ដូចនេះ ធ្វើឱ្យពួកទស្សនវិទូ ទាំងផ្លូវសង្គមទាំងផ្លូវសាសនាបដិសេធគម្ពីរក្បួនតម្រាថាខុសយ៉ាងនេះខុសយ៉ាងនោះទៅ ។

**ធ** = ស្តាប់បានដែរតែមិនទាន់ច្បាស់សោះ លោកតាថាអ្នកប្រាជ្ញទាំងឡាយសម័យនេះ គេបដិសេធថាគម្ពីរនេះត្រូវគម្ពីរនេះខុស ចុះខ្លួនលោកតាចំពោះទេវទូតសូត្រនេះលោកតាថាខុសឬត្រូវ ឬយ៉ាងម៉េចទៅវិញ?

**និ** = លោកតា មិនមានសម្ដីពីរទេ ក្នុងសៀវភៅមួយរបស់អាត្មាដែលនិយាយអំពីឋាននរកតាមទេវទូតសូត្រនោះ ខ្ញុំបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ចំពោះរឿងនរកក្នុងទេវទូតសូត្រ បើអ្នកអានទាំងឡាយមានជំនឿ ក៏មានគម្ពីរនោះជាសម្អាងស្រាប់ តែបើមិនមានជំនឿ កុំគប្បីបដិសេធគម្ពីរនោះចោល ត្រូវទុកជាឯកសារខាងវណ្ណកម្មនៃព្រះពុទ្ធសាសនារបស់យើង ព្រោះធម្មៈក្នុងពុទ្ធសាសនាទាំងមូល លោកចែកទៅជាពិធីកម្ម ជានិទាន ជាទស្សនវិជ្ជា ។ ពិធីកម្មបានដល់ការធ្វើសក្ការ បូជា ។ និទានបានដល់រឿងផ្សេងៗ ប្រមូលមកហៅថា **"វណ្ណកម្ម"** ។ ទស្សនវិជ្ជា បានដល់សច្ចធម៌៤ ប្រការ ឬធម៌ណាៗដែលសង្គ្រោះចូលក្នុងសច្ចធម៌ ។

**ធ** = សាធុ ច្បាស់ហើយ! អស់សង្ស័យហើយ តែខ្ញុំព្រះករុណាចង់ឱ្យលោកតាមកស្រាយបំណងនៃទេវទូតសូត្រ ដោយបញ្ញារបស់លោកតាដើម្បីទាញសូត្រនោះចូលក្នុងទស្សនវិជ្ជាទៅវិញ តើកើតឬទេ ?

**និ** = មិនទាស់អីចៅ! លោកតាចេះតែទទួលបម្រើចៅបានទាំងអស់ ឱ្យតែចៅចង់ស្ដាប់ចង់ចេះ ប៉ុន្តែការបកស្រាយរបស់លោកតា ត្រូវចិត្តចៅឬមិនត្រូវចិត្តនោះ វាជាបញ្ហាដែលលោកតាមិនហ៊ានធានាទេ។ សូត្រនេះគ្រាន់តែឮឈ្មោះក៏ហាក់ដូចជានឹកឃើញថា មិនមែនជាសូត្ររបស់ពុទ្ធសាសនាសុទ្ធៗទេ ព្រោះសម័យនោះពុទ្ធសាសនាមិនរាប់អានទេវតាសោះ ។ ទេវទូតនេះគឺជាឈ្មោះនៃទេវតាដែលបម្រើព្រះអាទិទេពក្នុងសាសនាព្រាហ្មណ៍គឺព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ឯណោះទេ ដូចម្ដេចទើបមកជាឈ្មោះសូត្រក្នុងពុទ្ធសាសនាទៅវិញ ពុទ្ធសាសនាបង្រៀនថា មនុស្សត្រូវគិតគូរដោះស្រាយនូវគ្រប់បញ្ហាទាំងអស់ផ្អែកលើខ្លួនឯង សម្រេចលើខ្លួនឯង មនុស្សមិនមានអ្នកណាជាគំរូរបស់ខ្លួនទេមានតែព្រះ ចុះហេតុដូចម្ដេចទើបទេវតានេះចូលមកជ្រៀតជ្រែកទទឹងមេឃទទឹងដីដូច្នេះទៅវិញ ។ សេចក្ដីឆ្ងល់របស់ខ្ញុំបានកើតមានឡើងយ៉ាងនេះ ខ្ញុំក៏ចាប់ពិនិត្យមើលទេវទូតសូត្រនោះតាំងអំពីដើមរហូតដល់ចប់ ស្រាប់តែស្មារតីខ្ញុំ ភ្ញាក់ព្រើតឃើញថាម៉ែឪខ្ញុំអើយ! ពុទ្ធសាសនាទាញយកមនុស្សអំពីសាសនាព្រាហ្មណ៍ ដោយទេវទូតសូត្រនេះទេតើ! ធនបាល! គឺទេវទូតសូត្រនេះហើយដែលបានធ្វើឱ្យសាសនាព្រាហ្មណ៍គ្នាបាក់កម្លាំងយ៉ាងខ្លាំង ព្រោះអីសាសនាព្រាហ្មណ៍គេបានបន្លាចមនុស្សលោកដោយនរកនេះបានផលល្អណាស់។ មនុស្សក្នុងសម័យនោះបើមិនមាន

បន្លាច វាមិនឈប់ធ្វើបាបទេ វាខុសគ្នាស្រឡះអំពីមនុស្សក្នុងសម័យនេះ មនុស្សក្នុងសម័យនេះបើបន្លាចបែបទេវទូតសូត្រនេះ វាលែងខ្លាចស្រេចតែម្តង ។ ធនបាលចៅ! ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គចេះណាស់វៃណាស់ ការប្រោសសត្វរបស់ព្រះអង្គបើមានការចាំបាច់តម្រូវឱ្យបោកបញ្ឆោត ព្រះអង្គក៏បញ្ឆោតដូចជាទ្រង់បញ្ឆោតភិក្ខុឈ្មោះនន្ទៈ ដែលរឿងនេះចៅក៏ដឹងដែរហើយ ។ ទេវទូតសូត្រនិយាយត្រង់ៗ តាមរឿងគឺព្រះអង្គទ្រង់លើកយកនរកដែលគេធ្លាប់ស្គាល់ក្នុងលទ្ធិសាសនាទាំងឡាយ មានសាសនាព្រាហ្មណ៍ជាដើមមកសម្តែងដើម្បីបញ្ឆោតបំភ័យ លុះដោយឆោតដោយភ័យហើយទើបព្រះអង្គប្រាប់សច្ចធម៌ជាខាងក្រោយ កាលណាគេបានសម្រេចអរិយមគ្គអរិយផលហើយគេក៏ដឹងខ្លួនថា ឧបាយស្រោចស្រង់សត្វរបស់ព្រះសម្មាសម្ពុទ្ធខ្ពស់ពន់ពេកណាស់រកគួរប្រៀបពុំបានទេ ។ ធនបាល! ក្នុងសម័យនេះ មនុស្សយើងលែងខ្លាចនរក ក្នុងទេវទូតសូត្រហើយ ដូចនេះលោកតាសូមបកស្រាយឱ្យចៅស្តាប់ថា : រឿងនរកក្នុងទេវទូតសូត្រទាំងមូលនោះ បើកាលណាយើងចង់យកមកដាក់ចូលក្នុងរឿងពិត (**សច្ចធម៌**) ទៅវិញនោះ យើងត្រូវដាក់នៅក្នុងបរមត្ថអភិធម្ម ដែលចែងអំពីមនោគតិនៃមនុស្សដែលទៀបនឹងដល់មរណកាល ។ មនុស្សពួកនេះតែងឃើញនូវនិមិត្ត៣ គឺកម្ម, កម្មនិមិត្ត, គតិនិមិត្ត។ កម្មឃើញដូចខ្លួនកំពុងធ្វើបុណ្យឬធ្វើបាប កម្មនិមិត្តឃើញប្រដាប់ប្រដាធ្វើបុណ្យ មានបាត្រចីវរ មុង កន្ទេល ខ្នើយ ជាដើម ឃើញប្រដាប់ធ្វើបាបមានកាំភ្លើង ធ្នូ ស្នា ដាវ លំពែង សំណាញ់ មុងជាដើម គតិនិមិត្ត ឃើញដំណើរដែលខ្លួនទៅកើត ខាងបុណ្យឃើញប្រាសាទវិមាស វិហារ ចេតិយ៍ ឋានសួគ៌ជាដើម ខាងបាប ឃើញភ្លើងនរក រណ្តៅនរក មានដុំលាមក បន្លា ពួរដែក ទឹកពុះ ទឹកទង់ដែង ដាវ លំងពែង ច្បូក ស្នរជាដើម រហូតដល់ឃើញយមបាលចាប់ចង ឃើញយមរាជពិភាក្សាសួរយកចម្លើយ ។ល។ ធនបាលចៅ! នេះហើយជាចម្លើយនឹងសេចក្តីបកស្រាយរបស់លោកតាអំពីរឿងនរកក្នុងទេវទូតសូត្រ ចូរចៅយកទៅសិក្សារៀនសូត្រចុះ បើឆ្ងល់ត្រង់ណា ចាំសួរលោកតាថ្ងៃមុខថ្ងៃក្រោយទៀតចុះ ។

**ធ** = អរគុណលោកតាហើយ! ខ្ញុំព្រះករុណាស្តាប់បានច្រើនណាស់ បើយ៉ាងនេះទេវទូតសូត្រអាច ទុកជាវណ្ណកម្មរបស់ព្រះពុទ្ធសាសនាក៏បានអាចទុកជាមនោគមវិជ្ជាខាងមនោគតិនៃពុទ្ធសាសនា ផ្នែកអភិធម្មត្រង់ចំណុចនៃនិមិត្ត៣ ក៏បាន មែនអ៊ីចឹង

ទេ លោកតា ?

**និ** = មែនហើយចៅ! តែលោកតាសូមតឿនស្មារតីចៅម្ដងទៀតថា រឿងនរករក ក្នុងទេវទូតសូត្រជារឿងបានការណាស់ក្នុងសម័យនោះ លុះមកដល់សម័យនៃលោក វិទ្យាសាស្ត្រចម្រើន រឿងនេះអស់ឥទ្ធិពលលើប្រជាសត្វហើយ តែក៏បានជាឯកសារ យ៉ាងសំខាន់របស់ពុទ្ធសាសនា ព្រោះគ្រប់តែសាសនាក្នុងពិភពលោក តែងតែមាន ទ្រឹស្ដីរកសួគ៌។ ដូច្នេះ ក្នុងអនាគតកាល ប្រសិនបើមានការប្រកួតខាងទ្រឹស្ដីនៃនរក សួគ៌ជាមួយសាសនាទាំងឡាយ អាត្មាដៅស្មានថា ពុទ្ធសាសនាយើងមុខជាមិនចាញ់ គេទេ។ ដើម្បីឱ្យរឿងនរកក្នុងទេវទូតសូត្រមានឥទ្ធិពលលើមនុស្សទាំងអស់ទៅវិញ នោះ ចៅត្រូវកុំភ្លេចប្រើទេវទូតសូត្រឱ្យស៊ីនឹងនិស្ស័យវាសនារបស់មនុស្ស គឺមនុស្ស ធម្មតាត្រូវប្រើទេវទូតសូត្រជាវណ្ណកម្ម មនុស្សវិទ្យាសាស្ត្រត្រូវប្រើទេវទូតសូត្របក ស្រាយ ។

**ធ** = លោកតា! ចំពោះទេវទូតសូត្រតែម្ដងនោះ លោកបានប្រាប់អំពីលំនៅរបស់ នរកទាំងឡាយនោះថានៅត្រង់ណាច្បាស់លាស់ឬទេ? បើនៅក្នុងដីតើនៅក្នុងប្រទេស ណា? ក្រោមដីកុំនិយាយចុះ ព្រោះលោកតាថាដីអីពិភពនេះមានទ្រង់ទ្រាយមូល អណ្ដែតក្នុងអាកាសធាតុ រកកំណត់ថាត្រង់ណាលើត្រង់ណាក្រោមមិនកើតទៅ ហើយ?

**និ** = ចៅធនបាលសួរនេះ ឱ្យលោកតានៅតែម្ដងឬ?

**ធ** = ម៉េចអីចឹងលោកតា ខ្ញុំព្រះករុណាសួរនេះ មិនមែនចង់ឱ្យទាល់ទេ គឺចង់ដឹង ប៉ុណ្ណោះ ព្រោះខ្ញុំព្រះករុណារកមនុស្ស គួសន្ទាឱ្យមានចិត្តមេត្តាសន្ដោសដូចលោកតា មិនបានសោះ ដូចនេះសូមមេត្តាឆ្លើយឱ្យទាន ?

**និ** = ក្នុងទេវទូតសូត្រ លោកនិយាយមិនសូវច្បាស់លាសទេ រឿងលំនៅរបស់ នរក តែតាមផ្ទៃរឿងយើងអាចសន្និដ្ឋានបានថានរកនៅក្នុងដីព្រោះលោកចេញឈ្មោះ ថារណ្ដៅ តែរណ្ដៅនោះនៅក្នុងស្រុកណា ឬព្រៃណាឬភ្នំណា លោកមិនមានប្រាប់ឱ្យ ច្បាស់លាស់ទេ ប៉ុន្តែប្រាកដជានៅក្នុងប្រទេសឥណ្ឌាហ្នឹងឯង ព្រោះមានថ្ងៃមួយព្រះ រាជាបសេនទិ ដែលមានព្រះរាជវាំងនៅក្នុងក្រុងសាវត្ថី ព្រះអង្គទ្រង់មិនស្រួលព្រះទ័យ ទ្រង់ផ្ទំមិនលក់ ព្រះអង្គទ្រង់ឮសំឡេងស្រែកថា ទុ-ស-ន-សោ តែមិនដឹងជាសំឡេងអ្វី

ដោយអាស្រ័យ ព្រះប្រាជ្ញាញ្ញាណនៃព្រះអរហន្តសម្មាសម្ពុទ្ធក្រោយមកទើបទ្រង់ដឹងថា សំឡេងនោះជាសំឡេងសត្វនរកក្នុងរណ្តៅមួយឈ្មោះលោហគម្ភីរ បើតាមរឿងនេះលំនៅនៃនរកទាំងឡាយ នៅក្បែរៗក្រុងសាវត្ថីនោះឯង ។

**ធ** = ចុះរឿងហ្នឹង ព្រះពុទ្ធបរមគ្រូរបស់យើង ទ្រង់បានធ្វើសេចក្តីបញ្ជាក់ថារណ្តៅនរកលោកហគម្ភីរនៅក្នុងដីត្រង់កន្លែងនោះឬទេ?

**និ** = ទ្រង់បញ្ជាក់នឹងទ្រង់មិនបញ្ជាក់អាត្មាច្រឡំទៅដែរ តែទោះជាថាព្រះអង្គទ្រង់បញ្ជាក់ ក៏ជាការឥតប្រយោជន៍ទេ ព្រោះព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គជាទស្សនវិទូខ្ពស់ណាស់ កាលណាព្រះអង្គថានៅក្នុងដី ក៏យើងមិនអាចដឹងថាដីនៅទីណា ព្រោះដីមាន២គឺដីខាងក្នុង (**រូបកាយ**) នៃមនុស្សយើងដីខាងក្រៅ (**ដីស្រែចំការ**) ទូទៅគឺថាបើទ្រង់និយាយក្នុងឋានៈនៃព្រះអង្គជាព្រះពុទ្ធថាប្រមុខនៃសាសនាមួយ ក្នុងលោកនេះ នោះមុខជាទ្រង់ថានរកមានរណ្តៅនៅក្នុងដីខាងក្រៅហើយព្រោះប្រមុខនៃសាសនាដទៃៗ នឹងជំនឿនៃមនុស្សក្នុងសម័យនោះគេថានរកនៅក្នុងដីខាងក្រៅអស់ទៅហើយ ប៉ុន្តែបើទ្រង់និយាយក្នុងឋានៈនៃព្រះអង្គជាអ្នកទស្សនវិទូនោះមុខជាទ្រង់ថារណ្តៅនរកនៅក្នុងដីក្នុងរូបកាយរបស់មនុស្សយើងហើយ ។

**ធ** = ចូលចិត្តហើយលោកតា! ចុះឋានសួគ៌នោះយ៉ាងណាទៅវិញដែរ?

**និ** = ដូចគ្នាទេចៅ! តែសូមចៅប្រុងប្រយ័ត្នស្មារតីឱ្យមែនទែន តែមិនប្រុងអ្នកមុខជាយល់ថាគ្មានឋានសួគ៌ឋាននរកហើយ ខ្លួនអ្នកនឹងធ្លាក់ចុះទៅក្នុងអន្លង់មិច្ឆាទិដ្ឋិអស់មានពេលកែខ្លួនបានហើយ ។

**ធ** = លោកតា! ខ្ញុំព្រះករុណាខ្លាចមិច្ឆាទិដ្ឋិណាស់ បើយ៉ាងនេះខ្ញុំព្រះករុណាចង់និយាយថារណ្តៅនរកនៅក្នុងដីក្រោមក្រុងសាវត្ថី ចំណែកឋានសួគ៌នៅលើដីគឺតួក្រុងសាវត្ថីតែម្តងទៅ តើបានឬទេ ដើម្បីកុំឱ្យធ្លាក់ខ្លួនទៅជាមិច្ឆាទិដ្ឋិ ?

**និ** = វារិតតែមិច្ឆាទិដ្ឋិទៅទៀតហើយចៅ ។

**ធ** = ម៉េចយ៉ាងចឹងលោកតាធ្វើដូចម្តេចទៅវិញទើបជៀសមិច្ឆាទិដ្ឋិរួច?

**និ** = មិនអីទេចៅ! កុំអាល់ស្លន់ លោកតានៅមានផ្លូវនិយាយឱ្យចៅចូលចិត្តតទៅទៀត ប៉ុន្តែបើនិយាយជាសរសេរនេះមិនកើតទេ ព្រោះទំព័រនៃសៀវភៅនេះកាន់តែច្រើនណាស់ហើយ ដូចនេះចាំយើងនិយាយគ្នាដោយមិនមានសរសេរទៅវិញ។ លោក

តា សូមបញ្ជាក់យ៉ាងខ្លីថាបើយើងចង់និយាយថានរកនៅក្នុងដី ក្នុងនរកដែលថៅថានោះ ចំណង់នេះបង្អង់សិនទៅ ព្រោះពិភពលោកបច្ចុប្បន្ន មានសេចក្តីចម្រើនខាងការស្រាវជ្រាវណាស់ថ្មីៗនេះពួកអ្នកអវកាសនៃប្រទេសខ្លះ គេបានទៅដល់លោកព្រះចន្ទហើយ គេនៅតែមិនទាន់ចុះលើពិភពព្រះចន្ទប៉ុណ្ណោះ ព្រោះគេធ្វើយានអាវកាសសម្រាប់ដឹកមនុស្សទៅឋានព្រះចន្ទមិនទាន់បាននៅឡើយ តែគេកំពុងធ្វើសព្វថ្ងៃនេះហើយ។ ដូចនេះប្រសិនបើយើងនិយាយអំពីនរកសួគ៌ងាយៗ ដូចថៅថានោះ យើងមុខជានឹងត្រូវខូចកេរ្តិ៍ឈ្មោះធំហើយ ប្រសិនបើពួកអ្នកស្រាវជ្រាវទាំងនោះ គេទៅរកតាមដែលយើងថាមិនឃើញ។ ធនបាល! ពួកយើងអ្នកសាសនាមានទ្វារចេញតែមួយគឺដើរតាមព្រះពុទ្ធក្នុងឋានៈនៃព្រះអង្គជាទស្សនវិទូ ។

**ធ** = ស្តាប់បានហើយលោកតា ខ្ញុំព្រះករុណាព្រមតាមហើយ តែខ្ញុំព្រះករុណាចង់បញ្ជាក់លោកតាបន្តិចទៀតថា ព្រះពុទ្ធបរមគ្រូរបស់យើងព្រះអង្គទ្រង់និយាយនូវរឿងអ្វីៗ ទាំងអស់តាមគំនិតរបស់ព្រះអង្គទាំងអស់ឬតាមគំនិតរបស់អ្នកដទៃផងដែរ?

**និ** = តាមគំនិតរបស់ព្រះអង្គខ្លះ តាមគំនិតរបស់អ្នកដទៃខ្លះ ។

**ធ** = តើរឿងណាតាមគំនិតព្រះអង្គ រឿងណាតាមគំនិតរបស់អ្នកដទៃ សូមលោកតា មេត្តាឆ្លើយអធិប្បាយ ហើយប្រសិនបើអាចឱ្យឧទាហរណ៍បាន សូមឱ្យមកផង ?

**និ** = រឿងណាដែលព្រះអង្គបានរៀន បានស្តាប់អំពីដទៃជាស្រេចហើយ លុះគ្រាក្រោយមកមានការចាំបាច់ត្រូវប្រើ ព្រះអង្គទ្រង់លើកយករឿងនោះមកប្រើ រឿងដូចនេះឈ្មោះថារឿងព្រះអង្គតាមគេ ឧទាហរណ៍ ត្រៃលក្ខណៈបី (ទុក្ខំ អនិច្ចំ អនត្តា) ព្រះអង្គទ្រង់បានរៀនចេះដឹងអំពីគេពីរ! អនិច្ចំ! ទុក្ខំ! ឬថាទ្រឹស្តីទ្វិលក្ខណៈនេះ គេបានចងជាក្បួនតម្រាទុកស្រេចតាំងអំពីដើមមកហើយព្រះអង្គក៏ប្រើជាមួយគេទៅ ព្រោះព្រះអង្គជាសិស្សម្នាក់ ដែលមិនចេះភ្លេចគុណគ្រូ មិនចេះភ្លេចនូវគុណឧបការៈដែលអ្នកណាៗបានធ្វើឱ្យពិភពលោក ។ នរកសួគ៌ខាងក្រៅដែលមនុស្សលោកបានបង្កើតបាននិយាយ បានជឿជាយូរណាស់មកហើយព្រះអង្គក៏ទ្រង់និយាយតាម បង្រៀនតាមគឺថាតាមគ្រូរបស់ព្រះអង្គមានអាឡារៈនឹងឧទកៈជាដើម ថាតាមអ្នកសាសនានឹងទស្សនវិទូទាំងឡាយជាពិសេសថាតាមក្បួនបូរាណដែលគេបានរៀបចំទុកមក។ ធន-

បាលចៅ! ចូរអ្នកចាំជាប់ជានិច្ចថា ព្រះពុទ្ធបរមគ្រូនៃយើងមានព្រះបញ្ញាខ្ពស់ណាស់ មានសេចក្ដីវៃឆ្លាតជ្រាលជ្រៅណាស់ មានចិត្តដឹងគុណអ្នកដទៃណាស់ មានការសម្របសម្រួលជាមួយអ្នកដទៃណាស់ ។ ដោយអាស្រ័យទឹកព្រះទ័យរបស់ព្រះអង្គមានគុណសម្បត្តិដូចនេះហើយ បានជាមានមនុស្សជាច្រើនណាស់បានលះបង់ចោលនូវជំនឿខុសរបស់ខ្លួនត្រឡប់មករកជំនឿត្រូវតាមព្រះអង្គវិញ ។

**ធ** = ខ្ញុំព្រះករុណាស្ដាប់បានហើយលោកតា! បើយ៉ាងដូច្នេះសូមលោកតាបញ្ជាក់យ៉ាងខ្លី ក្នុងចំណុចមួយត្រង់ថា ព្រះអង្គជាព្រះមួយថាតាមគេ ជឿតាមគេ ហើយលោកតាបានសរសើរថាព្រះអង្គជាព្រះមួយមានបញ្ញាច្រើនមានព្រះទ័យ ល្អមិនចេះប្រឆាំងជាមួយអ្នកណា ខ្ញុំយល់ថាព្រះអង្គធ្វើយ៉ាងនេះខូចសេចក្ដីពិតអស់ហើយ ដូចម្ដេចក៏លោកតាថាព្រះអង្គវៃឆ្លាតទៅវិញ រឿងនេះខ្ញុំព្រះករុណាជឿលោកតាមិនបានទេ?

**និ** = ធនបាល! អ្នកកុំអាលទាន់តម្លើងសម្លេងខ្លាំងៗ ពេក អាត្មាមិនមែនជាមនុស្សខ្លាចស្លាប់ព្រោះតែចៅមិនឡើងចុះរាប់អានទេ អាត្មាធ្លាប់គោរពរាប់អានព្រះពុទ្ធទីពឹងព្រះពុទ្ធដូចមនុស្សទាំងឡាយដទៃដែរ តែឧត្ដមគតិរបស់អាត្មាខុសអំពីគេច្រើន។ ដូច្នេះចៅចាំស្ដាប់អាត្មាសិនកុំអាលច្រឡោត យើងត្រូវនិយាយគ្នាជាបណ្ឌិតវាទ កុំនិយាយគ្នាជាពាលវាទឬរាជវាទឡើយ ។ ឯចំណែកចំណុចមួយត្រង់ថាព្រះរបស់យើងចេះតែតាមគេនោះ មិនមែនព្រះអង្គតាមព្រោះខ្លាចគេមិនរាប់អាននោះទេ គឺតាមព្រោះតែទាញយកវិញឱ្យបាននោះឯង បានសេចក្ដីថា ព្រះអង្គតាមគេមែន តែព្រះអង្គទ្រង់មិនលះបង់នូវឧត្ដមគតិរបស់ព្រះអង្គទេ ព្រះអង្គតាមព្រោះហេតុការណ៍តម្រូវឱ្យតាមប៉ុណ្ណោះ ។ ធនបាលចៅ! អាត្មានិយាយមកប៉ុណ្ណោះចៅប្រហែលស្ដាប់បានហើយ។

**ធ** = ស្ដាប់បានហើយ តែក្នុងរឿងនេះ ប្រសិនបើលោកតា មេត្តាបន្ថែមសេចក្ដីឱ្យបានច្បាស់លាស់ជាងនេះបន្តិចទៀត ខ្ញុំព្រះករុណាមានចិត្តត្រេកអរណាស់អម្បាញ់មិញខ្ញុំព្រះករុណាបានពោលពាក្យធំៗ បន្តិច សូមមេត្តាអភ័យទោសចុះ ធ្វើម៉េចបញ្ញារបស់ចៅវាតិចពេកណាស់ មិនងាយនឹងតាមលោកតាទាន់ទេ ។ ចំពោះបញ្ហាដដែលនេះ ប្រសិនលោកតាមិនយល់ទាស់ទេ ខ្ញុំព្រះករុណាសូមថា ឱ្យលោកតានិយាយឱ្យចំ ចំណុចសំខាន់ត្រង់ថា ព្រះអង្គទៅជាមួយនឹងគេសិន ខុសក៏ដោយត្រូវក៏

ដោយហើយសឹមទាញមក ឬសឹមកែប្រែ ឬបដិសេធជាក្រោយនោះ តើយ៉ាងណា?

**និ** = មិនលំបាកទេចៅ! ឋានសួគ៌ព្រះអង្គទ្រង់ដើរទៅជាមួយនឹងគេក្នុងគ្រាដំបូង លុះ ក្រោយមកព្រះអង្គទ្រង់បដិសេធឋានសួគ៌ចោលដោយយកនិព្វានមកជំនួសវិញ ដូចនិយាយមកហើយក្នុងកថា ៥ (**ទាន សីល សគ្គ អាទីនវៈ នេក្ខម្មៈ**) ។ ឋាននរក ខាងក្រៅព្រះអង្គទ្រង់ដើរជាមួយនឹងគេ លុះកាលជាខាងក្រោយមក ព្រះអង្គទ្រង់យក នរកខាងក្នុង (**អាយតនៈ ៦**) ភ្លើង ៣ (រាគគ្គិ ទោសគ្គិ មោហគ្គិ នឹង ទុក្ខ ១៣ កងក្នុង ទុក្ខសច្ចៈ ដូចនិយាយម្តងហើយមកបដិសេធ) ។ រួមសេចក្តីថា ក្នុងខាងដើមព្រះអង្គ ទ្រង់ដើរជាមួយជឿជាមួយ ដើម្បីយកជាសិស្សលុះក្រោយមកសិស្សទោះមានគំនិត បញ្ញាល្មមស្តាប់សេចក្តីពិតបានហើយ ព្រះអង្គក៏ទ្រង់លើកយកសេចក្តីពិតមកបដិសេធ សេចក្តីមិនពិតនោះចោលទៅ ។

**ធ** = ចូរចិត្តអស់ហើយលោកតា! តអំពីនេះទៅខ្ញុំព្រះករុណាសូមបញ្ជាក់ក្នុង ចំណុចថា និព្វានជារបស់សម្រាប់មនុស្សទាំងអស់ មិនមានគិតគូរដល់វ័យចាស់ក្មេង ពេលប្រុសស្រី...... ឡើយ ចំពោះចំណុចនេះលោកតាក៏បាននិយាយមកម្តងហើយ ដែរ ខ្ញុំព្រះករុណាក៏ស្តាប់បានបន្តិចបន្តួចដែរ ដើម្បីឱ្យរឿងនេះមានប្រយោជន៍ដល់ មនុស្សទូទៅ ខ្ញុំព្រះករុណាចង់ឱ្យលោកតាឆ្លើយអធិប្បាយម្តងទៀត ព្រោះមនុស្សសព្វ ថ្ងៃនេះគេមិនចង់បាននិព្វានទេ គេចង់បានតែឋានសួគ៌ ឋានសុខនៅក្នុងសកលពិភព តើលោកតាអាចពន្យល់ឱ្យគេភ្លឺ ឱ្យគេចាប់អារម្មណ៍មកលើនិព្វានវិញបានដែរឬទេ?

**និ** = អាត្មាមិនហ៊ានធានាទេ តែអាត្មាគ្រាន់តែជួយផ្តល់យោបល់តាមដែលមាន ខ្លះ ដូចមានតទៅនេះ ÷

១- ឋានសួគ៌មិនមានសេចក្តីសុខពិតទេ

២- ឋានសួគ៌មិនមែនជាសម្បត្តិនៃជនអ្នកបង់អស់ទុក្ខទេ

៣- ឋានសួគ៌មិនមែនជារបស់នៃពុទ្ធសាសនារបស់យើងទេ គឺជារបស់នៃសាក-លសាសនា

៤- ឋានសួគ៌ជាឋានត្រូវបដិសេធដោយព្រះអរហន្តសម្មាសម្ពុទ្ធនៃយើង ។

ចម្បាំងទាំងឡាយ ជម្លោះទាំងឡាយ ការដណ្តើមប្រជែងទាំងឡាយ សេចក្តី ច្រណែនទាំងឡាយ ការរកកេរ្តិ៍ឈ្មោះទាំងឡាយ ល្មោភទាំងឡាយ កំហឹងទាំងឡាយ

សម្លាញ់ទាំងឡាយ សម្អប់ទាំងឡាយ សេចក្តីជិះជាន់ទាំងឡាយ សេចក្តីបៀតបៀនទាំងឡាយ បន្លំទាំងឡាយ បំបាត់ទាំងឡាយ សំណូកទាំងឡាយ សំណៅនទាំងឡាយ ។ល។ កើតមកតែអំពីរឿងឋានសួគ៌ មានឋានសួគ៌ជាហេតុជបច្ច័យ។ ដូច្នេះ ឋានសួគ៌មិនមែនជាបច្ច័យនៃសេចក្តីសុខមែនទែនទេ គឺជាបច្ច័យនៃសេចក្តីសុខបន្លំប៉ុណ្ណោះ។ បើយ៉ាងហ្នឹងតើយើងទាំងអស់គ្នា ដែលត្រូវការបង់បាននូវសេចក្តីសុខពិតប្រាកដ នៅតែត្រូវការឋានសួគ៌ធ្វើអ្វីទៀត បើឋានសួគ៌សម្រាប់តែធ្វើឱ្យមនុស្សយើងស្រវឹងភ្លេចគ្នីគ្នារបស់ខ្លួនសោះនឹងថា មកមិនរួចក៏មិនមែន ព្រោះទេវតាពូកែខ្លាំងណាស់ ។

ម្យ៉ាងទៀត ឋានសួគ៌នេះ ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គមិនត្រឹមតែបដិសេធចោលទេ គឺព្រះអង្គបានទាំងតាំងខ្លួនធ្វើជាសំពៅនាំសត្វឆ្លងចាកអន្លង់គឺឋានសួគ៌នេះទៅនិព្វានផង។ ធនបាលថៅ! ចម្លើយនឹងសេចក្តីអធិប្បាយរបស់អាត្មានេះ ចូរថៅកុំខានគិតពិចារណា ប្រកបដោយចិត្តជាកុសល ដើម្បីជួយតឿនស្មារតីមនុស្សលោកទាំងអស់គ្នាឱ្យចាប់អារម្មណ៍លើនិព្វាន ដែលជាវត្ថុបំណងនឹងឧត្តមគតិនៃពុទ្ធសាសនារបស់យើង ។

**ធ** = ខ្ញុំព្រះករុណាស្តាប់បានហើយលោកតា! តែខ្ញុំព្រះករុណាចង់ដឹងថានិព្វាននោះ មានប៉ុន្មានយ៉ាងទៅ? និព្វាននៅទីកន្លែងណាទៅ? យើងទាំងឡាយត្រូវធ្វើនូវអ្វីខ្លះ ទើបបានសម្រេចនូវនិព្វានឬដល់និព្វាន?

**និ** = និព្វានដោយសង្ខេបមានពីរប្រភេទគឺ សឧបាទិសេសនិព្វាន១ អនុប្បាទិសេសនិព្វាន១ ។ សឧបាទិសេសនិព្វាន ជានិព្វាននៅក្នុងសកលពិភពឬត្រៃភព អនុប្បាទិសេសនិព្វាន ជានិព្វានមាននៅក្រៅសកលពិភពឬទីបំផុតនៃត្រៃភព។ ការបានសម្រេចនិព្វាន បើនិយាយអំពីទំហើ[12] ដែលធ្វើបានដល់បារមីធំ១០ **(ទាន សីល នេក្ខម្មៈ បញ្ញា វិរិយៈ ខន្តី សច្ចៈ អធិដ្ឋាន មេត្តា ឧបេក្ខា)**។

បើនិយាយដោយផ្លូវដែលត្រូវដើរបានដល់មគ្គ៨ប្រការ **(សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ)** បើនិយាយដោយកិច្ចប្រតិបត្តិទូទៅបានដល់**សីល សមាធិ បញ្ញា**ឬសមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋាន វិបស្សនា វិសុទ្ធិ... ដូចមានមកក្នុងសៀវភៅទាំងឡាយ ដែលលោកអ្នក

---

[12] "ទំហើយ" ប្រើតាមទម្លាប់ថា "អំពើ" ប្រើតាមវេយ្យាករណ៍ថា "ទំហើ" មកអំពីកិរិយាស័ព្ទថា "ធើឬធ្វើ" ។

ប្រាជ្ញទាំងឡាយក្នុងប្រទេសយើងនឹងប្រទេសទាំងឡាយដទៃ បាននិពន្ធទុកមកគ្រប់សព្វអស់ហើយ ។

**ធ** = បើដូច្នេះ ឃើញថា : នរកមានពីរ : គឺនរកក្នុងខ្លួនមនុស្សបច្ចុប្បន្ន១ នរកក្នុងខ្លួនមនុស្សខាងបរលោក១។ ឋានសួគ៌មានពីរគឺ : ឋានសួគ៌ក្នុងខ្លួនមនុស្សបច្ចុប្បន្ន១ ឋានសួគ៌ក្នុងខ្លួនមនុស្សខាងបរលោក១។ និព្វានមានពីរគឺ : និព្វានក្នុងខ្លួនមនុស្សបច្ចុប្បន្ន១ និព្វាននៃវិញ្ញាណរបស់មនុស្សក្នុងទីបំផុតនៃសកលពិភពលោក១។ ក្នុងរឿងនេះស៊ីគ្នាងាយយល់ ងាយរៀនមែនលោកតា បើនរណាចង់ចេះដឹងអំពីរឿងនរក សួគ៌ និព្វាន នេះ ត្រូវរៀនត្រូវស្គាល់របស់អស់ទាំងនេះក្នុងបច្ចុប្បន្នមុនព្រោះឋាននរកបច្ចុប្បន្នជាបច្ច័យនៃឋាននរកបរលោក ឋានសួគ៌បច្ចុប្បន្នជាបច្ច័យនៃឋានសួគ៌បរលោ-ក និព្វានក្នុងលោកជាបច្ច័យនៃនិព្វានក្នុងអលោក។ តែខ្ញុំព្រះករុណាសូមសេចក្ដីអនុគ្រោះអំពីលោកតា សូមអាណិតពន្យល់អំពីរឿងនិព្វានបច្ចុប្បន្នបន្តិចទៀត ព្រោះខ្ញុំព្រះករុណាយល់មិនទាន់អស់ ។ ធម៌ដែលត្រូវគោរពប្រតិបត្តិដើម្បីសម្រេចនូវនិព្វាននោះ ខ្ញុំព្រះករុណាស្ដាប់បានហើយ យល់អស់ហើយ ។ ចំណែកធម៌ដែលនិព្វាន បុគ្គលត្រូវកម្ចាត់បង់ឬធ្វើឱ្យអស់ទៅនោះឈ្មោះធម៌អី មានប៉ុន្មានយ៉ាងទៅដែរ អ្វីខ្លះ?

**និ** = ឈ្មោះសំយោជនធម៌មាន១០ យ៉ាងគឺ : សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតប-រាមាស កាមរាគៈ បដិឃៈ រូបរាគៈ អរូបរាគ មានះ ឧទ្ធច្ចៈ អវិជ្ជា ។

**ធ** = ខ្ញុំព្រះករុណាស្ដាប់បានចូលចិត្តហើយ តែដើម្បីនឹងទាញអារម្មណ៍អ្នកឋានសួគ៌មកភ្ជាប់នឹងនិព្វានវិញនោះ សូមឱ្យលោកតានិព្វានបាលធ្វើអត្ថាធិប្បាយបន្តិចទៀត ដើម្បីឱ្យមនុស្សលោកបានភ្លឺក្នុងរឿងនេះ ឱ្យកាន់តែច្រើនឡើងទៀត តើបានឬទេ ?

**និ** = បានចៅ! តែវែងពេកមិនបានទេព្រោះពេលរបស់អាត្មាជិតអស់ហើយ ។ ចំពោះរឿងនេះ ចូរចៅដឹងថា និព្វានថារបស់មួយដែលព្រះពុទ្ធបរមគ្រូរបស់យើង ទើបតែនឹងរកឃើញក្រោយឋានសួគ៌។ និព្វានមិនមាននរណាម្នាក់រកឃើញទេ គេទាំងឡាយរកឃើញតែឋានសួគ៌។ ហេតុដែលនាំឱ្យព្រះអង្គខំស្វះស្វែងរុករកនិព្វាននោះ មិនមានអ្វីក្រៅអំពីមិនពេញព្រះទ័យនឹងឋានសួគ៌ ព្រោះសួគ៌ដឹកនាំឱ្យមនុស្សទាំងឡាយធ្លាក់ចុះក្នុងរណ្ដៅកាមគុណ កាលណាខ្លួនគេម្នាក់ៗ ធ្លាក់ចុះក្នុងរណ្ដៅកាម

គុណហើយ គេក៏បានភ្លេចអស់រលីងនូវទុក្ខ នូវហេតុនៃទុក្ខ នូវនិរោធ នូវមគ្គៈ។ កាមគុណនៃមនុស្សវាបានសាងនូវសេចក្តីទុក្ខព្រួយ ឱ្យអ្នកបរិភោគឬ ប្រើប្រាស់សម្បើមណាស់ តែអ្នកស្រវឹងកាមគុណ មិនមានដឹងខ្លួនថា ទុក្ខព្រួយទាំងអស់កើតអំពីកាមគុណទេ ។ ធនបាល! ចូរចៅសង្កេតមើលបាលីពុទ្ធភាសិតមិនមានប្រែដូចតទៅនេះ ÷

**“បិយតោ ជាយតេ សោកោ បិយតោ ជាយតេ ភយំ បិយតោ វិបមុត្តស្ស នត្ថិសោកោ កុតោ ភយំ”**

**“បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ បេមតោ វិបមុត្តស្ស នតិ សោកោ កតោ ភយំ”**

**“រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ រតិយា វិមុត្តស្ស នត្ថិ សោកោ កុតោ ភយំ”**

**“តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ, តណ្ហាយ វិបមុត្តស្ស នត្ថិ សោកោ កុតោ ភយំ”**

**“កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ កាមតោ វិបមុត្តស្ស នត្ថិ សោតោ កុតោ ភយំ”**

ពុទ្ធភាសិតនេះ បញ្ជាក់ថា សេចក្តីទុក្ខសោករោគភ័យ កើតមកអំពីស្លាញ់[13] គាប់រីករាយ ចង់បាន ប្រាថ្នា ។

**ធ** = ខ្ញុំមានសេចក្តីភ័យតក់ស្លុតហើយលោកតា! បើតាមន័យនេះឋានសួគ៌មិនទៅជាប្រភពនៃទុក្ខនៃសេចក្តីជិះជាន់ទៅហើយឬ?

**និ** = មែនអ៊ីចឹងហើយចៅ! អ្នកសួគ៌ទាំងអស់ ឬ ភាគច្រើនរមែងតែងសោយទុក្ខរមែងតែងជិះជាន់គ្នា ធ្វើបាបអ្នកមិនបានសួគ៌ដូចខ្លួន...ពិភពលោកមានចម្បាំង មកតែអំពីអ្នកសួគ៌បង្កើតឡើង ក្នុងបំណងសង្កត់សង្កិនគេយកប្រយោជន៍ខ្លួន ។ អ្នកសួគ៌ធ្វើបុណ្យទានអ្វីៗ សុទ្ធតែធ្វើឡើងក្នុងបំណងចង់មានទ្រព្យសម្បត្តិច្រើន ចង់បានសក្តិយសធំ ចង់បានកេរ្តិ៍ឈ្មោះ ចង់អួតបុណ្យ អួតសេចក្តីល្អ ។ល។ របស់ខ្លួន។ ដោយ

[13] “ស្លាញ់” ប្រើតាមទម្លាប់ថា “ស្រឡាញ់” ប្រើតាមវេយ្យាករណ៍ថា “ស្លាញ់” ជាពាក្យកិរិយា ពាក្យនាមថា “សម្លាញ់” ។

អាស្រ័យហេតុនេះហើយ បានជាគេតែងបានជួបបានឃើញអ្នកស្នូគ៌ឈ្លោះគ្នាក្នុងគ្រប់រឿងទាំងអស់ សូម្បីតែរឿងធ្វើបុណ្យក៏ឈ្លោះគ្នាដណ្តើមមុខដណ្តើមមាត់ ដណ្តើមឈ្មោះសំឡេង ដណ្តើមអ្វីៗ ទៀតរាប់មិនអស់ សរុបសេចក្តីទៅឃើញថាអ្នកស្នូគ៌ទាំងអស់បានភ្លេចនូវវត្ថុបំណង នឹងឧត្តមគតិនៃពុទ្ធសាសនារបស់ខ្លួន ដែលមានចែងយ៉ាងច្បាស់ថា ជាមនុស្សត្រូវតែធ្វើម៉េចឱ្យខ្លួនបានសម្រេចនូវសេចក្តីល្អបរិសុទ្ធ ជាមនុស្សត្រូវតែបម្រើមនុស្សដទៃ ឱ្យបានសម្រេចនូវសេចក្តីសុខចម្រើនដូចគ្នានឹងខ្លួន ។ នេះមិនដូច្នោះទេ គេធ្វើបុណ្យម្តងៗ គេអួតបុណ្យ គេចង់ឱ្យអ្នកផងអួតថាគេពូកែធ្វើបុណ្យ ។ រីឯផលបុណ្យទាំងអស់របស់គេ គេមិនមានប្រាថ្នាអ្វីក្រៅអំពីឱ្យខ្លួនគេបានទៅជាទេវតាធំៗ ដើម្បីជិះជាន់ទេវតាតូចៗ ឬអ្នកដទៃទៀត អ្នកស្នូគ៌បានធំក្នុងលោកនេះចង់ទៅធំក្នុងលោកដទៃទៀត ឮថាក្នុងឋានព្រះឥន្ទ មានប្រាសាទប្រាក់ មាស កែវ អ្នកស្នូគ៌ចង់ទៅកើតនៅប្រាសាទវិមានសបែបនោះទៀត ឮថាឋានព្រះឥន្ទមានប្រពន្ធច្រើនៗ អ្នកស្នូគ៌យើងក៏រិតតែញ័រសាច់ឆ្អឹងខ្នងច្រើនឡើងទៀត។ អ្នកស្នូគ៌គេធ្វើបុណ្យគេប្រាស្រ័យទាក់ទងការងារតែក្នុងសង្គមអ្នកស្នូគ៌ដូចគ្នា ឧទាហរណ៍ក្នុងពិធីបុណ្យសពអ្នកក្រខ្សត់ក្តី ក្នុងពិធីអាពាហ៍ពិពាហ៍អ្នកតូចទាបក្តី គេមិនដែលឃើញអ្នកស្នូគ៌អ្នកធំ អ្នកមាន ចូលទៅក្នុងពិធីកម្មនោះៗទេ ។ ធនបាលថៅ! ព្រិត្តិកម្មនេះហើយដែលអាចនឹងធ្វើឱ្យពុទ្ធសាសនាក្លាយទៅជាសាសនារបស់អ្នកស្នូគ៌ របស់នាយទុនមិនមែនជាសាសនាសម្រាប់រំដោះទុក្ខមនុស្សក្រខ្សត់អត់ឃ្លានឡើយ ។

**ធ** = បើដូច្នេះ មានតែយើងលះបង់ភាពអ្នកស្នូគ៌មកជាភាពអ្នកនិព្វានវិញមែនទេលោកតា ?

**និ** = មែនហើយថៅធនបាល ! ប្រសិនបើយើងអាចធ្វើបាននោះយើងក៏បានឡើងឋានៈជាបេក្ខបុគ្គលរបស់និព្វាន ទាំងលោក(14) និព្វានទាំងអលោក(ii) និព្វាន។ ពិភពនៃមនុស្ស ជាពិសេសប្រទេសខ្មែរយើង ក៏ត្រូវបានសម្រេចនូវសេចក្តីសុខចម្រើនខាងសេដ្ឋកិច្ចខាងវប្បធម៌ ។ល។ ព្រោះជាតិយើងទាំងអស់គ្នាសុទ្ធតែជាបេក្ខជននៃនិព្វាន គេធ្វើនូវអ្វីទាំងអស់ដើម្បីនិព្វាន ឧទាហរណ៍ ឪពុកដើម្បីនិព្វាន ម្តាយដើម្បីនិព្វាន កូនដើម្បីនិព្វាន ស្វាមីដើម្បីនិព្វាន ភរិយាដើម្បីនិព្វាន គ្រូដើម្បីនិព្វាន សិស្ស

[14] "លោកនិព្វាន" និព្វាននៅក្នុងត្រៃលោក។ (ii) "អលោកនិព្វាន" និព្វាននៅក្នុងទីបំផុតនៃត្រៃលោក។

ដើម្បីនិព្វាន អ្នកគ្រប់គ្រងឬអ្នកនឹកនាំដើម្បីនិព្វាន អ្នកតាមឬអ្នកនៅក្រោមការដឹកនាំដើម្បីនិព្វាន ។ល។ កាលបើដូច្នេះ ប្រទេសយើងក៏អស់មនុស្សជិះជាន់មនុស្ស នៅមានតែមនុស្សជួយទំនុកបម្រុងមនុស្ស ព្រោះទាន សីល ភាវនារបស់គេ ជាទានសីលដើម្បីនិព្វានមិនមែនជាទានសីល ភាវនា ដើម្បីសួគ៌។ មានតែនិព្វានមួយទេដែលជាគុណធម៌ធ្វើឱ្យមនុស្សយើងបានសម្រេចនូវសេចក្តីសុខយ៉ាងស្ងប់។ ដោយសេចក្តីសុខនោះមិនបានស្ថិតនៅលើរូប សំឡេង ក្លិន រស... ធម្មតាដែលជាហេតុនៃទុក្ខដូចបានពោលមកហើយ ។

**ធ** = ល្អមែនលោកតា! ប្រសិនបើគេព្រមធ្វើនូវអ្វីៗទាំងអស់ដើម្បីនិព្វាន ដូចនេះ សូមលោកតាពន្យល់ឱ្យបានច្បាស់លាស់ជាងនេះបន្តិចទៅទៀត តើនិព្វានក្នុងលោកនេះ ត្រូវបានសម្រេចតែព្រះអរហន្តឬមនុស្សទូទៅអាចប្រតិបត្តិធម៌ហើយបានសម្រេចនូវព្រះនិព្វាននេះដែរ ?

**និ** = ធនបាលចៅ! និព្វានមិនមែនជារបស់សម្រាប់តែបុគ្គលម្នាក់ៗទេ គឺសម្រាប់អ្នកណាដែលធ្វើទាន សីល ភាវនាក្នុងបំណងឱ្យកើតសុខដល់អ្នកដទៃ មិនមែនត្រូវការអ្វីក្រៅអំពីនេះ អ្នកនោះក៏បានសម្រេចនូវនិព្វានមួយ ហៅថា **"និព្វានដើមឬី"** សោតាបន្នបុគ្គល នឹងសកទាមិបុគ្គល លោកបានសម្រេចនូវនិព្វានមួយ ហៅថា **"និព្វានដើមផ្លូវ"** អនាគាមិបុគ្គលនឹងអរហត្តមគ្គបុគ្គលលោកបានសម្រេចនូវនិព្វានមួយហៅថា **"និព្វានកណ្តាលផ្លូវ"** អរហត្តផលបុគ្គលឬព្រះអរហន្ត លោកបានសម្រេចនូវនិព្វានមួយហៅថា **"និព្វានចុងផ្លូវ"** ឬ **"និព្វានទីបំផុត"** និព្វានទាំងឡាយបួននេះគម្ពីរពុទ្ធសាសនាលោកពុំបាននិយាយទេ តែលោកតាត្រូវការឱ្យចៅស្តាប់បាននូវវត្ថុបំណងនឹងឧត្តមគតិនៃពុទ្ធសាសនា ទើបសម្តែងឡើងក្នុងបំណងឱ្យតែចៅស្តាប់បានចៅយល់បានប៉ុណ្ណោះទេ។ និព្វានប្រសិនបើមិនបង្កើតឱ្យមានឈ្មោះថា **"ដើមឬី"** **"ដើមផ្លូវ"** **"កណ្តាលផ្លូវ"** **"ចុងផ្លូវ"** ដូចបានពោលមកនេះទេ ក៏មិនងាយនឹងយល់បាន បើយល់មិនបានក៏មិនត្រូវការ។ ការឱ្យឈ្មោះនេះ អាត្មាយល់ថាមិនមានទាស់នឹងពុទ្ធបំណងទេ ព្រោះព្រះអរហន្តសម្មាសម្ពុទ្ធនៃយើង ក៏ព្រះអង្គទ្រង់ត្រាស់រឿយៗថា អ្នកមានប្រាថ្នាចង់អស់ទុក្ខ ត្រូវតែធ្វើខ្លួនជាបេក្ខជននិព្វាន ឬរៀបចំខ្លួនឱ្យមានបេក្ខភាពក្នុងនិព្វាន ពាក្យប្រើជំនួសបេក្ខជននិព្វានឬបេក្ខាភាពនៃនិព្វាន ក៏គឺពាក្យថា **"ពោធិសត្វ"**

ដែលយើងធ្លាប់ចេះចាំមកគ្រប់គ្នា ។ ដូច្នេះ ពុទ្ធសាសនិកម្នាក់ៗប្រសិនបើចង់បាន សុខស្ងប់ក្នុងជីវិតរបស់ខ្លួននោះ គប្បីតម្កល់ខ្លួនក្នុងបេក្ខភាពនៃនិព្វាន ឬធ្វើជាបេក្ខជននិព្វាន មិនគប្បីតម្កល់ខ្លួនក្នុងបេក្ខភាពនៃសួគ៌ ឬធ្វើជាបេក្ខជននៃសួគ៌ឡើយ ។

**ធ** = សាធុ លោកតា! ខ្ញុំព្រះករុណាយល់ហើយ តែមិនទាន់អស់សង្ស័យក្នុងចំណុចថា បើអ្នកណាសម្លឹងយកនូវនិព្វាន អ្នកនោះត្រូវបានឈ្មោះថា បេក្ខជននិព្វាន ឬពោធិសត្វ បើដូច្នេះ ពោធិសត្វមិនសម្បូរណ៍ណាស់ទៅហើយឬ?

**និ** = មិនសម្បូរណ៍ប៉ុន្មានទេចៅ! ចំពោះពោធិសត្វពិតៗគឺពោធិសត្វដែលឃើញសច្ចៈធម៌ពិតប្រាកដ ។ ចំណែកពោធិសត្វបន្លំឬពោធិសត្វលេងៗនោះមានច្រើនរាប់មិនអស់ទេ ។

**ធ** = "**និព្វានដើម្បី**" "**និព្វានដើមផ្លូវ**" "**និព្វានកណ្តាលផ្លូវ**" និង "**និព្វានចុងផ្លូវ**" និព្វានទាំងអស់នេះ បើឱ្យឈ្មោះរួមគ្នា ហៅថា និព្វានអ្វី? ហេតុដូចម្តេចទើបមានឈ្មោះដូចនេះ? និព្វានណាសម្រាប់បុគ្គលពួកណា?

**និ** = ឈ្មោះរួមគ្នាហៅថា "**និព្វានបរិយាយ**" ឬ "**និព្វានវោហារ**" ។ "**និព្វានដើម្បី**" សម្រាប់មនុស្សបុថុជ្ជន និព្វានក្រៅអំពីនេះសម្រាប់អរិយមនុស្សទាំងឡាយមានសោតាបន្នបុគ្គលជាដើម ។

**ធ** = ព្រោះហេតុដូចម្តេចនិព្វាននេះ ទើបមានឈ្មោះថា "**និព្វានបរិយាយ ឬ និព្វានវោហារ**" ។

**និ** = ព្រោះហេតុនិព្វាននេះមិនមែនជានិព្វានប្បភេទ គឺគ្រាន់តែជានិព្វានដែលត្រូវបានបំបែកចេញមកអំពីនិព្វានប្បភេទ ដើម្បីឱ្យងាយស្គាល់ងាយយល់ប៉ុណ្ណោះ។

**ធ** = បេក្ខជននិព្វាន នឹងបេក្ខជនសួគ៌ ក្នុងវេលាធ្វើទាន សីល ភាវនា មានគំនិតខុសគ្នាយ៉ាងណា?

**និ** = បេក្ខជននិព្វាន វេលាធ្វើទាន សីល ភាវនា មានគំនិតថាឱ្យមនុស្សទាំងឡាយ សត្វទាំងឡាយអស់ទុក្ខ ។ ចំណែកបេក្ខជនសួគ៌វេលាធ្វើទាន សីល ភាវនា មានគំនិតថា ឱ្យខ្លួនបានជាធំ ឱ្យអ្នកដទៃបម្រើខ្លួនឬឱ្យអាត្មាខ្លួនឯងបានសុខចម្រើន រីឯអ្នកដទៃតាមតែម៉េចក៏ដោយចុះ ។

**ធ** = "**និព្វានដើម្បី**" មានលក្ខណៈខុសអំពីនិព្វានដទៃណា?

**និ** = "**និព្វានដើម្បី**" គឺមិនមែនជាតួសឧបាទិសេសនិព្វាន អនុបាទិសេសនិព្វាន ដែលយកមកឱ្យឈ្មោះថា "**ដើមផ្លូវ**" "**កណ្ដាលផ្លូវ**" "**ចុងផ្លូវ**" នោះទេ គឺ "**និព្វានដើម្បី**" នេះជាឈ្មោះនៃ "**ដើម្បី**" នោះតែម្ដង ។

**ធ** = ជាឈ្មោះនៃ "**ដើម្បី**" ដូចម្ដេចទៅ?

**និ** = ជាឈ្មោះនៃ "**ដើម្បី**" នោះគឺអ្នកធ្វើៗនូវទំហើការងារបុណ្យណា កុសលណា។ល។ គេធ្វើដើម្បីនិព្វានទាំង "**អស់**" ដូច្នេះទើបត្រូវឱ្យឈ្មោះថា "**និព្វានដើម្បី**" គឺបេក្ខភាពនៃជននោះ មិនទាន់សម្រេចនូវនិព្វានណាមួយនៅឡើយទេ ប៉ុន្តែគេកំពុងធ្វើដំណើរទៅកាន់និព្វាននោះហើយ ។

**ធ** = ខ្ញុំព្រះករុណាមិនទាន់អស់ចិត្តទេ សូមលោកតានិព្វានបាលមេត្តាឱ្យឧទាហរណ៍បាន ២-៣ មកមើល ?

**និ** = គេធ្វើបុណ្យទានដើម្បីនិព្វាន គេមិនមានបំណងយកកេរ្តិ៍ឈ្មោះយសសក្តិ រិទ្ធិអំណាចសួគ៌ព្រហ្ម ។ល។ អ្វីឡើយ គេប្រកបអាជីវកម្មគ្រប់យ៉ាងដើម្បីនិព្វាន គឺគេធ្វើខ្លួនគេឱ្យជាមនុស្សមានទ្រព្យសម្បត្តិស្តុកស្តម្ភមាំមួន ដើម្បីបំពេញបារមីធម៌ឬបំពេញមុខការជាមនុស្ស ដើម្បីអនាគតនិព្វាន ។

គេមានស្វាមីភរិយាដើម្បីនិព្វាន គឺគេមិនមែនចេះតែសប្បាយរីករាយជាមួយកាម តាមតែកិលេសតណ្ហាដឹកនាំទេ គេចេះសន្តោសក្នុងកាម គេចេះវៀរចាកកាម គេព្យាយាមបន្ថយកាមគ្រប់យ៉ាងបន្តិចម្តងៗ តាមដែលគេអាចលៃលកធ្វើបាន ។ ទំហើទាំងអស់របស់គេនេះហើយ ដែលធ្វើឱ្យខ្លួនគេបានសម្រេចនូវ "**និព្វានដើម្បី**" ។ បុគ្គលអ្នកសម្រេចនូវ "**និព្វានដើម្បី**" នេះឯងហើយ ដែលជាបុគ្គលឱ្យប្រទេសជាតិរបស់ខ្លួនមានសេចក្តីសុខចម្រុងចម្រើន មានសីលធម៌ខ្ពង់ខ្ពស់ ព្រោះឧត្តមគតិរបស់គេនៅខាងផ្នែកបម្រើសេចក្តីសប្បាយរបស់អ្នកដទៃ មិនបម្រើសេចក្តីសប្បាយរបស់ខ្លួន គេខំប្រឹងប្រែងធ្វើកិច្ចការរបស់មនុស្សលុះត្រាតែចប់ ក្នុងទីបំផុតកិច្ចការរបស់គេនោះ ក៏បានលើកឋានៈរបស់គេអំពីមនុស្សធម្មតាឱ្យបានជាអរិយមនុស្ស ហើយក៏បានសម្រេចនូវនិព្វានជាទីបំផុតនោះទៅ ។

**ធ** = ខ្ញុំព្រះករុណានៅមិនទាន់យល់ក្នុងចំណុចថា "**វិញ្ញាណំអនិទស្សនំ**"

វិញ្ញាណដែលរកប្រៀបទៅនឹងអ្វីមិនបាន ឬដែលសម្តែងចេញមិនបាននោះ បានមាននៅក្នុងនិព្វាន តើរឿងនេះលោកតានិព្វានបាល អាចនឹងពន្យល់បានខ្លះឬទេ?

**និ** = ធនបាល! ចំពោះរឿងនិព្វានក្នុងចំណុចថា **វិញ្ញាណំអនិទស្សនំ** នេះក្នុងគម្ពីរពុទ្ធសាសនាមានតែ**កេវដ្តសូត្រ**មួយទេ គម្ពីរក្រៅពីនេះលោកពុំបាននិយាយថានៅក្នុងនិព្វាននោះមានវិញ្ញាណអនិទស្សនៈនៅក្នុងនោះទេ លោកច្រើននិយាយថាមានផលញ្ញាណនៅក្នុងនោះទៅវិញ។ ដូច្នេះឃើញថានិព្វានជាធម្មជាតុមួយល្អិតណាស់ជ្រាលជ្រៅណាស់រសេមរសាមណាស់ សូម្បីតែគម្ពីរពុទ្ធសាសនាក៏និយាយមិនត្រូវគ្នាផង ។ ចៅធនបាល! ប្រសិនបើចៅមិនយល់ទាស់ មិនធុញទ្រាន់ទេ ចូរចៅប្រកាន់យក**កេវដ្តសូត្រ**នោះទុកជាពន្លឺនៃគំនិតរបស់ចៅចុះ ព្រោះវិញ្ញាណបានសម្តែងតួជាអ្នកដឹងនាំធម្មធាតុដទៃៗ ឱ្យធ្វើការគ្រប់យ៉ាង ។ ក្នុងកាលណាវិញ្ញាណចាស់ផុតរលត់ទៅ វិញ្ញាណចាស់នេះ ក៏បានជាបច្ច័យឱ្យកើតវិញ្ញាណថ្មីតៗគ្នា រាប់ជាតិមិនអស់ ។

វិញ្ញាណដើរតួជាមនុស្ស ជាសត្វ ជាទេព ជាឥន្ទ ជាព្រហ្ម ជាអរូបព្រហ្ម ។ល។ ក្នុងទីបំផុតវិញ្ញាណនេះ ក៏បានផ្លាស់ភាពរបស់ខ្លួនទាំងអស់ សម្រេចបានជាភាពនៃវិញ្ញាណថ្មីមួយដែលមានគុណភាពខ្ពង់ខ្ពស់បំផុត ដែលមិនអាចនឹងរកគុណភាពអ្វីមកប្រៀបផ្ទឹមឱ្យស្មើបាន ដែលមិនមែនជាវិញ្ញាណដែលធ្លាប់ដើរតួក្នុងកំណើតទាំងឡាយក្នុងសាកលពិភព ដូចដែលយើងបានដឹងមកនោះឡើយ ។

**ធ** = ខ្ញុំព្រះករុណាយល់ខ្លះដែរ ប៉ុន្តែនៅមិនទាន់ស្អាតក្នុងគំនិតទេព្រោះមិនទាន់ថាលោកតាចង់និយាយថាម៉េច គឺមិនដឹងជាចង់ថា វិញ្ញាណតួសព្វថ្ងៃនេះ ក្រោយអំពីបានធ្វើការបុណ្យកុសល ឬបំពេញនាទីនៃខ្លួនចប់អស់ហើយ ក៏បានទៅនៅក្នុងនិព្វាន ឬយ៉ាងម៉េចទេ ។ ដូច្នេះ សូមមេត្តាប្រាប់ឱ្យច្បាស់មក តើវិញ្ញាណក្នុងនិព្វាននោះ ជាវិញ្ញាណតួសព្វថ្ងៃឬតួណា?

**និ** = ជាវិញ្ញាណតួសព្វថ្ងៃហ្នឹងឯង ។

**ធ** = បើដូច្នេះ ពុទ្ធភាសិតដែលថាចិត្តជាអនត្តា វិញ្ញាណជាអនត្តានោះ វាទៅយ៉ាងម៉េចទៅវិញ? វាមិនទៅជាស្របគ្នានឹងសាសនាព្រាហ្មណ៍ដែលគេនិយាយថាក្នុងសាកលពិភពមានអត្តានោះទៅហើយឬ ? ឬមួយក៏ពុទ្ធសាសនាមាននិយាយអំពី

អត្តាដូចព្រាហ្មណ៍ក្នុងកន្លែងណាដែរ ?

**និ** = វាគ្មានទៅជាអ្វីទេ ! វាដូចជាយើងនិយាយគ្នាថា មនុស្សស្លាប់ទៅវិញ្ញាណទៅតជាតិក្នុងភពថ្មីទៀត ឬវិញ្ញាណកើតទៀត ពាក្យនេះមានន័យថា វិញ្ញាណតួសព្វថ្ងៃនេះទៅកើតទៀត ។ ពាក្យនេះសម្រាប់តែប្រើនិយាយគ្នាឱ្យឆាប់ចប់ឆាប់ស្ដាប់បានប៉ុណ្ណោះ ព្រោះពុទ្ធសាសនាយើងក៏មាននិយាយអំពីអត្តាត្រូវគ្នានឹងព្រាហ្មណ៍ ឬតាមព្រាហ្មណ៍ដូចជារឿងនៃនរកសួគ៌នោះដែរ តែពុទ្ធសាសនាមិននិយាយដូចនេះ រហូតចប់ចុងចប់ដើមទេ គឺនិយាយដើម្បីប្រមូលមនុស្ស ឬនិយាយដើម្បីឱ្យមនុស្សចូលចិត្តជាដំបូងសិន ក្រោយមកពុទ្ធសាសនាក៏បដិសេធអត្តានោះចោលទៅ របស់ទាំងអស់ក៏នៅជាអនត្តាដដែល តាមត្រៃលក្ខណៈទី៣ ដែលពួកព្រាហ្មណ៍រកមិនឃើញ ហើយព្រះអរហន្តសម្មាសម្ពុទ្ធរបស់យើងទ្រង់រកឃើញនោះឯង ។ ធានបាលចៅ! លោកតាចង់និយាយថា វិញ្ញាណក្នុងឋានសួគ៌ក្ដី ក្នុងឋាននរកក្ដី ក្នុងឋាននិព្វានក្ដី ។ល។ គឺវិញ្ញាណសព្វថ្ងៃនេះឯង ព្រោះវិញ្ញាណនេះបានបំពេញមុខងារសម្រាប់មនុស្ស សម្រាប់ទេវតា សំរាប់ព្រហ្ម សម្រាប់អរូបព្រហ្មចប់អស់ហើយ ។ វិញ្ញាណនេះត្រូវតែបានសម្រេចនូវនិព្វាន ដោយកម្លាំងបុណ្យកុសលដែលខ្លួនបានកសាងអស់រយៈកាលនៃកំណើតរាប់មិនអស់មកហើយ ។ ធានបាលចៅ! ប្រសិនបើលោកតាមិននិយាយយ៉ាងនេះ ក៏មិនឃើញមានផ្លូវឯណាដទៃ សម្រាប់និយាយឱ្យចៅចូលចិត្តបានឡើយ ។

**ធ** = ខ្ញុំព្រះករុណាស្ដាប់ទាន់ហើយលោកតា តែខ្ញុំព្រះករុណាយល់ថា ចម្លើយនឹងសេចក្ដីអធិប្បាយរបស់លោកតាក្នុងរឿងនេះ គឺក្នុងរឿងថាវិញ្ញាណហ្នឹងហើយ ត្រូវមាននៅក្នុងនិព្វាននោះ ជាចម្លើយមិនត្រឹមត្រូវតាមពុទ្ធបំណងទាំងអស់ទេ ព្រោះអ្វី? ព្រោះថាក្នុងលទ្ធិសាសនាដទៃៗ គេក៏បាននិយាយថា វិញ្ញាណរបស់មនុស្សទាំងអស់ក្រោយអំពីបានគោរពជឿស្ដាប់ព្រះអាទិទេពរបស់ខ្លួនហើយ ក៏បានទៅនៅរួមជាមួយវិញ្ញាណធំនៃអាទិទេពគ្រប់ៗ វិញ្ញាណដែលគេកត់សម្គាល់នៅទីនោះថាជានិព្វានឬជាឋានសួគ៌ដ៏ទៀងទាត់របស់គេ ។ គំនិតលោកតាចង់និយាយឱ្យមនុស្សទាំងឡាយស្ដាប់បាន ប៉ុន្តែវាមិនមែនបានមកជាសេចក្ដីពិតតាមបំណងនៃពុទ្ធសាសនារបស់យើង វា មិនមែនធ្វើឱ្យពុទ្ធសាសនារបស់យើងបានស្ថិតនៅជាសាសនាមួយដាច់ដោយឡែកអំពីគេ គឺវាបានទៅជាសាសនារួមចូលជាមួយសាសនាឥស្លាម សាសនាគ្រិស្ត

សាសនាព្រាហ្មណ៍ ឬសាសនាណាៗ ទៅទៀតដែលមាននៅក្នុងសកលលោកទៅវិញ វាមិនមែនជាពុទ្ធសាសនាយើងទៀយ ។ ដូច្នេះ សូមលោកតាមេត្តាឆ្លើយម្តងទៀត ដើម្បីឱ្យខ្ញុំព្រះករុណាអស់សង្ស័យ តើវាពិតជាវិញ្ញាណតួហ្នឹងដដែលឬមានវិញ្ញាណតួថ្មីទៀតមកជំនួស ?

**និ** = ធនបាលចៅ! អាត្មានឹកស្មានថាចៅមិនមានគំនិតជ្រៅជ្រះប៉ុន្មានឥឡូវនេះការស្មានរបស់លោកតាខុសហើយ ចៅប្រាកដជាក្មេងវ័យទេ តែចេះដឹងល្អិតល្អន់ណាស់ ។

ធនបាលចៅ! ចម្លើយនឹងសេចក្តីអធិប្បាយរបស់អាត្មាថា វិញ្ញាណតួហ្នឹងហើយនោះ គឺគ្រាន់តែសាកល្បងគំនិតចៅប៉ុណ្ណោះទេ ។ រីឯសេចក្តីពិតរបស់ពុទ្ធសាសនានោះព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់សម្តែងថា វិញ្ញាណជាធាតុកើតរលត់រាល់ៗ ខណៈវិញ្ញាណចាស់រលត់ទៅកើតមានវិញ្ញាណថ្មីទៀត ។ ចលនានៃវិញ្ញាណមានការកើតរលត់រឿយៗ ប្រៀបបាននឹងរលកទឹក រលកតួមួយរលាយបាត់ទៅ កើតតួរលកមួយថ្មីមកជំនួស ។ រលកទឹកឈប់កើតឈប់មាន លុះត្រាតែអស់ខ្យល់ឬខ្យល់ស្ងប់ សេចក្តីនេះមានឧបមាយ៉ាងណាមិញ វិញ្ញាណនៃដើមឈើ នៃសត្វ នៃមនុស្ស នៃទេពនៃព្រហ្មក្នុងសកលពិភព ក៏មានការកើតរលត់តៗគ្នា មានឧបមេយ្យយ៉ាងនោះឯង ព្រោះវិញ្ញា-ណនៅមានបច្ច័យសម្រាប់រចនាតាក់តែង ។ ពេលណាវិញ្ញាណអស់បច្ច័យតាក់តែងហើយ វិញ្ញាណក៏រលត់មិនមានចាប់កើតទៀត ឬមិនមានវិញ្ញាណថ្មីមកជំនួសទៀតឡើយ ។ ធនបាលចៅ! ចូរអ្នកដឹងថា វិញ្ញាណដំបូងនោះក៏បានជាអនន្តរបច្ច័យរបស់វិញ្ញាណដែលត្រូវមានតទៅ វិញ្ញាណចាស់តួនេះបានជាអនន្តរបច្ច័យរបស់វិញ្ញាណក្នុងខណៈកើតមានតទៀត **(គឺជាបច្ច័យឱ្យមានវិញ្ញាណថ្មីនោះឯង)** ។ ធនបាលចៅ! ចំណែកវិញ្ញាណដែលមានក្នុងនិព្វាននោះ ក៏មិនមែនជាវិញ្ញាណតួចាស់នោះទេ គឺវិញ្ញាណតួថ្មីទៀត ប៉ុន្តែបើមិនមានវិញ្ញាណតួចាស់ ក៏មិនមានវិញ្ញាណតួថ្មីក្នុងនិព្វាននោះដែរ ដូចជាធាតុម្សៅ បើមិនមានដីស្រែមិនមានដើមស្រូវមិនមានគ្រាប់ស្រូវមិនមានគ្រាប់អង្ករ មិនមានគ្រឿងប្រដាប់សម្រាប់បុកសម្រាប់កិន ឬ មានគ្រប់សព្វអស់ហើយ តែមិនមានមនុស្សស្ទូង ច្រូត កាត់ បុក កិន អុំ ស្ងៃ ក៏មិនកើតជាធាតុម្សៅឡើយ សេចក្តីនេះមានឧបមាយ៉ាងណា វិញ្ញាណតួថ្មីក្នុងឋានសួគ៌ ឋាននរក ឋាននិព្វាននោះ

ក៏មានឡើងព្រោះតែមានវិញ្ញាណតួចាស់ ។ ធនបាលចៅចំពោះវិញ្ញាណក្នុងនិព្វាន ដែលព្រះសម្មាសម្ពុទ្ធទ្រង់ឱ្យឈ្មោះថាវិញ្ញាណ**អនិទស្សនៈ**នោះ ក៏ព្រោះតែវិញ្ញាណនោះអស់គ្រឿងប្រដូចអស់ឧទាហរណ៍អស់បច្ច័យតាក់តែង គឺអស់មានបដិសន្ធិថ្មីទៀត ដូចធាតុម្សៅដែលមិនត្រូវដុះពន្លកជាដើមស្រូវតទៅទៀត ព្រោះពីជះឬតួកំណើតនៃស្រូវនោះត្រូវគេបុកកំទេចអស់ហើយ ។ ធនបាលចៅ! ដែលអាត្មាថាវិញ្ញាណតួហ្នឹងឯងមាននៅក្នុងសួគ៌ក្នុងនិព្វាន ។ល។ នោះគឺអាត្មានិយាយឱ្យតែអ្នកស្តាប់បានយល់សិនប៉ុណ្ណោះទេ ឥឡូវនេះចៅបានយល់ហើយ ពាក្យថាវិញ្ញាណតួហ្នឹងឯង ទៅកើតក្នុងឋានសួគ៌ក្នុងឋាននិព្វាន ក៏អស់មានបញ្ហាចោទទៀតហើយ ។

**ធ** = ខ្ញុំព្រះករុណាចូលចិត្តហើយ អំពីរឿងវិញ្ញាណក្នុងឋាននិព្វានតែខ្ញុំព្រះករុណាមិនទាន់ដឹងថា ឋាននិព្វាននៅក្នុងទីណា សូមលោកតានិព្វានបាលមេត្តាប្រាប់កន្លែងនិព្វាន តើនៅក្នុងទីណា ?

**និ** = **សឧបាទិសេសនិព្វាន**នៅគ្រប់លោកគ្រប់ភពទាំងអស់គឺស្រេច ហើយតែព្រះអរិយបុគ្គលទាំងឡាយលោកបានសម្រេច លោកសម្រេចនិព្វាននៅក្នុងលោកណា ភពណា ឋាននិព្វានក៏នៅក្នុងលោកនោះភពនោះ ចំណែកខាងអនុប្បាទិសេសនិព្វានជាឋាននិព្វាននៅក្នុងទីបំផុតលោកឬក្នុងទីក្រៅលោកទាំងអស់ ។

**ធ** = បើមនុស្សទាំងឡាយគេចង់បានសម្រេចនូវ "**និព្វានដើម្បី**" តើគេត្រូវប្រព្រឹត្តធម៌ណាខ្លះ ?

**និ** = គេត្រូវប្រព្រឹត្តធម៌តាមភេទ គឺបើខ្លួនគេជាគ្រហស្ថ គេត្រូវធ្វើទាន សីល ភាវនា បើខ្លួនគេជាបព្វជិតគេត្រូវធ្វើសីល សមាធិ បញ្ញា ។

**ធ** = សព្វថ្ងៃនេះគេធ្វើទាន សីល ភាវនា ស្ទើរតែគ្រប់គ្នាអស់ទៅហើយ ។ ដូច្នេះគេទាំងឡាយនោះឈ្មោះថាជាអ្នកបានសម្រេចនូវ "**និព្វានដើម្បី**" ហើយឬ?

**និ** = ការបានសម្រេចនឹងមិនបានសម្រេចនោះស្រេចនៅលើខ្លួនអ្នកកសាង គឺបើគេធ្វើទាន សីល ភាវនា ដើម្បីរំដោះទុក្ខសត្វទាំងឡាយ ក្នុងលោកនោះឈ្មោះថាគេបានសម្រេច "**និព្វានដើម្បី**" ហើយ តែបើគេធ្វើដើម្បីមុខមាត់កេរ្តិ៍ឈ្មោះយសសក្តិគេក៏ពុំទាន់បានសម្រេចនូវ "**និព្វានដើម្បី**" នេះទេ គឺគេបានសម្រេចតែត្រឹមមុខមាត់កេរ្តិ៍ឈ្មោះយសសក្តិប៉ុណ្ណោះ ។

**ធ** = ដែលថាស្វាមីដើម្បីនិព្វាននោះ គឺស្វាមីមានកិរិយាប្រព្រឹត្តយ៉ាងណា?

**និ** = គេរាប់អានលើកតម្កើងភរិយារបស់គេទុកជាស្ត្រីគូជីវិតពិតៗ គេមិនប្រមាថមើលងាយភរិយារបស់គេដូចសត្វតិរច្ឆាន គេមិនប្រព្រឹត្តក្បត់ចិត្តភរិយារបស់គេរហូតអស់កាលមួយជីវិត គេប្រគល់ឱ្យនូវសិទ្ធិជាមេផ្ទះដល់ភរិយារបស់គេ គេគិតគូរឱ្យភរិយារបស់គេមានគ្រឿងតាក់តែងកាយតាមសមគួរ ។

**ធ** = តែប៉ុណ្ណឹងទេ ឬមានធម៌អ្វីទៅទៀតដែរ ?

**និ** = ស្រេចហើយតែពេលដែលខ្លួនកើត បើពេលនោះមិនមានធម៌អាថ៌អ្វីទេ តែប៉ុណ្ណឹងក៏បានហើយ ព្រោះព្រះពោធិសត្វនៃយើងដែលជាបេក្ខជននៃនិព្វាននោះ មានពេលខ្លះក៏ព្រះអង្គមិនមានធម៌អ្វីច្រើនទេ ព្រះអង្គប្រព្រឹត្តតែមនុស្សធម៌ក្នុងគ្រួសារប៉ុណ្ណោះ ។

**ធ** = ឧបាសក ឧបាសិកា ធ្វើសីល សមាធិ បញ្ញាបានឬទេ ?

**និ** = បាន ប្រសិនបើគេលះបង់នូវសេចក្តីកង្វល់ក្នុងគ្រួសារ គឺគេមិនអាស្រ័យនៅក្នុងគ្រួសារតាមប្រពៃណីលោក ។

**ធ** = អ្នកមានតែសីល មិនមានសមាធិ បញ្ញាទៅនិព្វានបានឬទេ?

**និ** = មិនបានទេ ! ព្រោះមានពុទ្ធភាសិតថា : បុគ្គលដែលនឹងបានដល់នូវនិព្វានជាឋានដ៏ឧត្តមនោះ គប្បីទៅតាមសីល សមាធិ បញ្ញា ព្រោះសីលជាគុណធម៌សម្រាប់កម្ចាត់នូវកិលេសធុនគ្រោតគ្រាត សមាធិជាគុណធម៌សម្រាប់កម្ចាត់បង់នូវកិលេសធុនមធ្យម បញ្ញាជាគុណធម៌សម្រាប់កម្ចាត់បង់នូវកិលេសធុនល្អិតឬអនុសយកិលេស ។

**ពុទ្ធភាសិតជាបាលីថា :**

**"សីលេន វីតិក្កមម្ពន្តំ, បរិយុដ្ឋំ សមាធិនា, បញ្ញាយ អនុសយំ ឆិន្ទំ គច្ឆេ និព្វានមុត្តមំ"**

**ធ** = សីល, សមាធិ, បញ្ញា មានអានិសង្សដូចម្តេច ?

**និ** = សីលបរិសុទ្ធមានអានិសង្សឱ្យបានសម្រេចនូវសមាធិ សមាធិបរិសុទ្ធមានអានិសង្សឱ្យបានសម្រេចនូវបញ្ញា បញ្ញាបរិសុទ្ធមានអានិសង្សឱ្យចិត្តផុតចាកអាសវកិលេសទាំងឡាយ គឺសម្រេចនូវនិព្វាន ។

**បាលីពុទ្ធភាសិតថា :**

**"សីល បរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ, សមាធិ បរិភាវិតាបញ្ញា មហប្ផលា ហោតិ មហានិសំសា, បញ្ញា បរិភាវិតំ ចិត្តំ អាសវេហិ វិមុច្ចតិ"**

**ធ** = បុគ្គលធ្វើបុណ្យទានប្រាថ្នាយកនិព្វានបានឈ្មោះថា មានតណ្ហាឬទេ? ព្រោះហេតុអ្វី ?

**និ** = បានឈ្មោះថា នៅមានតណ្ហានៅឡើយ ព្រោះតណ្ហារបស់មនុស្សត្រូវអស់ក្នុង ពេលដែលខ្លួនបានសម្រេចនូវនិព្វានដរាបណាមិនទាន់បានសម្រេចនិព្វានដរាបនោះមិនទាន់អស់តណ្ហាឡើយ សូម្បីបានសម្រេចនិព្វានហើយ និព្វានបុគ្គលនោះក៏នៅប្រាស្រ័យទាក់ទងជាមួយវត្ថុធាតុនៃតណ្ហានៅឡើយ ព្រោះបញ្ចក្ខន្ធមិនទាន់រលត់ ។

**ធ** = បើគ្រាន់តែបញ្ចក្ខន្ធមិនទាន់រលត់ប៉ុណ្ណោះដូចម្ដេចទើបនៅមានតណ្ហា ?

**និ** = ព្រោះតណ្ហាជាធម្មធាតុសម្រាប់បម្រើវេទនា បើវេទនានៅ តណ្ហាក៏អស់មិនទាន់កើត ។ ម្យ៉ាងទៀតតណ្ហាជាតួជាបដិច្ចសមុប្បាទធម៌មិនមែនជាចេតសិកធម៌ទេ ឬមិនមែនជាសំយោជនកិលេសឡើយ ។

**ធ** = អ្នកប្រាថ្នានិព្វាននៅមានតណ្ហាមានឧទាហរណ៍ដូចបុគ្គលណា ?

**និ** = ដូចព្រះពុទ្ធបរមគ្រូរបស់យើង កាលនៅជាពោធិសត្វឬបេក្ខជននិព្វាននៅឡើយ ព្រះអង្គរមែងនៅមានប្រពន្ធកូន រមែងនៅចង់បានជានេះជានោះតាមវិស័យនៃតណ្ហា លុះជាតិជាចុងក្រោយ បង្អស់នៃបេក្ខភាពនិព្វានរបស់ព្រះអង្គ ព្រះអង្គក៏បានសម្រេចត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ គឺបានត្រាស់ជាព្រះពុទ្ធក្នុងពេលនោះ ព្រះអង្គទ្រង់បានពន្លឺ[15] នូវពុទ្ធឧទានវាចាថា : ព្រះទ័យរបស់ព្រះអង្គបានឆ្លងផុតចាកតណ្ហាហើយ។ ធនបាលចៅ! ចូរពិនិត្យមើលបាលីពុទ្ធឧទានមិនមានសេចក្ដីប្រែដូចតទៅនេះ ÷

**"អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ គហករក ទិដ្ឋោសិ បុន គេហំ ន កាហសិ សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា"**

[15] "ពន្លឺ" ប្រើតាមទម្លាប់ថា "បន្លឺ" ប្រើតាមវេយ្យាករណ៍ថា "ពន្លឺ" មកពីកិរិយាស័ព្ទថា "លឺឬឮ" ។

ពុទ្ធឧទានមិនមានសេចក្ដីប្រែនេះ មានន័យថាព្រះទ័យរបស់ព្រះអង្គបានអស់តណ្ហាហើយ តណ្ហាមិនមានអំណាចអ្វីនឹងចាត់ចែងសាងផ្ទះ ពោលគឺរូបកាយរបស់ព្រះអង្គក្នុងអនាគតជាតិបានទៀតទេ ។

**ធ** = ពាក្យថា តណ្ហាបានសេចក្ដីថាម៉េច មានប៉ុន្មានយ៉ាង?

**និ** = តណ្ហា មានសេចក្ដីថាប្រាថ្នា ថាចង់បាន... ចែកចេញជា៣ យ៉ាងគឺ កាមតណ្ហាប្រាថ្នា កាម (**រូប សម្លេង ក្លិន រស សម្ផស្ស**) ភវតណ្ហា ប្រាថ្នាកេរ្តិ៍ឈ្មោះ ប្រាថ្នាសក្តិយសអំណាច... វិភវតណ្ហាប្រាថ្នាមិនចង់បានជានេះជានោះ គឺមិនចង់បាននូវអ្វីៗដែលមនុស្សលោកចង់បានចង់ជួប ។

**ធ** = ដែលថានិព្វានបុគ្គលនៅប្រាស្រ័យជាមួយវត្ថុធាតុ[16] នៃតណ្ហានៅឡើយនោះមានន័យយ៉ាងណា ?

**និ** = មានន័យថា និព្វានបុគ្គលលោកនៅមានរូប មានខន្ធដែលជាវត្ថុធាតុសម្រាប់មនុស្សលោកីយ៍លោកក៏ត្រូវទាក់ទងជាមួយបាយ ទឹក នំ ចំណី... រហូតដល់ថ្ងៃរំលាយខន្ធទើបលោកអស់ការទាក់ទងជាមួយវត្ថុធាតុធម្មតាក្នុងពេលនោះតែម្តង ។

**ធ** = បាយ ទឹក សំនី... ហ្នឹងឬជាតណ្ហា ?

**និ** = និមមែនទេ! ចំណង់លើបាយ ទឹក នំ សំនី នោះទេជាតណ្ហា ។

**ធ** = បើដូចនេះព្រះអរហន្តទាំងឡាយ លោកនៅមានចំណង់ឬ ?

**និ** = លោកនៅមាន បើមិនមានលោកមិនឆាន់ចង្ហាន់ទេ ។

**ធ** = ព្រះអរហន្តដូចម្តេច ទើបត្រូវអាស្រ័យវត្ថុធាតុនៃតណ្ហា ?

**និ** = ព្រោះលោកនៅប្រើរូបកាយបច្ចុប្បន្ន ។ រូបកាយនេះតម្រូវឱ្យលោកចិញ្ចឹមថែរក្សា បានជាលោកអាស្រ័យវត្ថុធាតុនៃតណ្ហាដោយនិមន្តទៅបិណ្ឌបាត ស្វែងរកអាហារភោជនមកឆាន់ ដើម្បីបំបាត់នូវទុក្ខវេទនាក្នុងខន្ធ ៥ បច្ចុប្បន្ន ។

**ធ** = បេក្ខជននិព្វានទាំងឡាយ សុទ្ធតែត្រូវអាស្រ័យតណ្ហាគ្រប់គ្នាឬ ?

**និ** = អាស្រ័យគ្រប់គ្នា ព្រោះថាបើមិនមានតណ្ហា ក៏មិនមានពាក្យថា "**និព្វាន**" នឹងមិនមានពាក្យថាបានសម្រេចនូវនិព្វាន គឺតណ្ហានៅក្នុងត្រើយម្ខាង (**ភព៣**) និព្វាននៅក្នុងត្រើយម្ខាងផុតភព ៣ ។ អ្នកទៅនិព្វាន ត្រូវយកតណ្ហាធ្វើជាទូកគ្រប់គ្នា ។

---

[16] **វត្ថុធាតុនៃតណ្ហា បានដល់គោចតណ្ហាទាំងឡាយនេះគឺ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ។**

**ធ** = បើដូច្នេះ និព្វានត្រូវបានសម្រេចដោយតណ្ហា មិនមែនបានដោយធម៌ទាំងឡាយ ដូចពោលហើយនោះទេឬ ?

**និ** = និព្វានត្រូវបានដោយកុសលទាំងឡាយ មានទាននឹងសីលជាដើម ប៉ុន្តែបើមនុស្សមិនមានចំណង់ក្នុងនិព្វានក៏មិនអាចធ្វើកុសលកើត ។

**ធ** = បើយ៉ាងនេះ យើងត្រូវនិយាយគ្នាថាម៉េចទើបត្រូវ ?

**និ** = យើងត្រូវនិយាយថា ត្រូវអាស្រ័យតណ្ហាហើយលះបង់តណ្ហាចោលទៅវិញ ដូចជាគេត្រូវអាស្រ័យទូកក្នុងដំណើរឆ្លងទឹកលុះផុតទឹកហើយ គេក៏លះបង់ទូកចោលទៅ។ ត្រង់នេះត្រូវនឹងពុទ្ធឧទានថា : តថាគតស្វែងរកជាងផ្ទះពោលគឺតណ្ហាអស់រយៈកាលមានជាតិរាប់មិនអស់ ឥឡូវនេះបានឃើញហើយ តណ្ហាអ្នកនឹងសាងផ្ទះគឺរូបកាយនៃតថាគតក្នុងអនាគតកាលអស់បានទៀតហើយ ។

**ធ** = តណ្ហា ប្រសិនបើថាទៅលើរាគៈ រូបរាគៈ អរូបរាគៈ ឬលោភៈ ក្នុងធម៌ទូទៅក្នុងសំយោជនៈ ក្នុងលោភមូលបានឬទេ ?

**និ** = មិនបានទេ! ព្រោះតណ្ហាជាពាក្យបច្ចេកទេស ប្រែថាម៉េចក្រៅអំពីប្រែថាចំណង់ ឬប្រាថ្នាពុំបានឡើយ តែប្រែខុសអំពីនេះ នឹងខុសន័យរបស់ពាក្យជាប្រាកដ។ ធនបាលចៅ! ចូរអ្នកចាំកុំភ្លេចថា តណ្ហាជាបដិច្ចសមុប្បាទ ជាធម្មធាតុសម្រាប់បម្រើវេទនា ដរាបណាវេទនាមាននៅដរាបនោះតណ្ហាក៏មាននៅដែរ ។

**ធ** = ខ្ញុំព្រះករុណាស្តាប់បានហើយអំពីរឿងនិព្វាន ចំណែកខាងរឿងវិញ្ញាណ ក៏ខ្ញុំព្រះករុណាយល់អស់ហើយដែរ តែខ្ញុំព្រះករុណានៅមិនទាន់អស់សង្ស័យក្នុងចំណុចមួយ គឺចំណុចថា ដើមឈើមានវិញ្ញាណតើលោកតានិព្វានបាលអាចបំភ្លឺបានឬទេ ?

**និ** = ដើម្បីឱ្យឆាប់យល់ក្នុងរឿងនេះ លោកតាសូមសួរចៅបន្តិចសិន តើចៅបានឮគេនិយាយថា ឈើរស់ ឈើងាប់ ស្មៅរស់ ស្មៅងាប់ដែរឬទេ?

**ធ** = ដែលឮដែរលោកតា ។

**និ** = បើដែលឮម៉េចក៏ចៅថាមិនយល់ ព្រោះពាក្យថា រស់មានន័យថាមានវិញ្ញាណ ពាក្យថា ងាប់បានន័យថា មិនមានវិញ្ញាណ ។

**ធ** = ខ្ញុំព្រះករុណាយល់ថា របស់ទាំងឡាយមានឈើជាដើមនោះ មិនមានវិញ្ញាណទេ ព្រោះវាគ្មានធ្វើការអ្វីសោះ វាគ្មានដឹងអ្វីបន្តិចបន្តួចសោះ ហេតុអ្វីបានជា

លោកតាថា វាមានវិញ្ញាណ ?

**និ** = ព្រោះវាចេះដុះ ចេះលូតចេះវារចេះឡើងទ្រើង ចេះយកទងឬដៃរបស់វាទៅចងភ្ជាប់ជាមួយទ្រើងឬដើមឈើ ដើម្បីកុំឱ្យខ្លួនវាធ្លាក់ចុះមកវិញ ។

**ធ** = ដែលវាលូតលាស់ឬវាវារតោងនេះតោងនោះ វាមិនមែនដឹងខ្លួនវាថា អញតោងអញចាប់អ្វីទេគឺជាធម្មតារបស់វាតែងតែប្រព្រឹត្តទៅយ៉ាងដូច្នេះឯង ។

**និ** = ចុះពួកឈើបន្លែខ្លះ មានដើមកញ្ឆែតជាដើម កាលណាអាកាសត្រជាក់វាចេះក្ដោបស្លឹកឡើង បើមានគេយកដៃទៅស្ទាប វាចេះក្ដោបស្លឹក ហាក់ដូចខ្លាចឈើ បើយ៉ាងនេះតើវាមានវិញ្ញាណឬទេ ព្រោះវិញ្ញាណប្រែថាដឹង?

**ធ** = ឈ្មោះថារុក្ខជាតិមិនមានវិញ្ញាណទេ ។

**និ** = ស៊ុតសត្វទាំងឡាយមានស៊ុតមាន់ទាជាដើម តើមានវិញ្ញាណនៅក្នុងនោះដែរឬទេ ?

**ធ** = ឈ្មោះថាស៊ុតទាំងឡាយសុទ្ធតែមានវិញ្ញាណទាំងអស់ ។

**និ** = បើមានវិញ្ញាណដូចម្ដេចទើបវាមិនចេះដើរមិនចេះស្រែកក្នុងពេល ដែលត្រូវគេស្ងោរ តើវាជាយ៉ាងម៉េចទៅ ?

**ធ** = ខ្ញុំព្រះករុណាមិនដឹងដែរលោកតា ។

**និ** = ធនបាលចៅ! ក្នុងដើមឈើនឹងស៊ុតសត្វមានវិញ្ញាណដូចគ្នា ។ វិញ្ញាណក្នុងដើមឈើមានលក្ខណៈ ដូចគ្នានឹងវិញ្ញាណក្នុងរូបទារកក្នុងផ្ទៃម្ដាយ គឺចេះលូតលាស់ចេះធំចេះរីកដូចគ្នា តែមិនមានដឹងខ្លួនទេ ព្រោះមិនទាន់មានប្រសាទឬអាយតនៈសម្រាប់ដឹង ដូចលោកតាបាននិយាយមកសព្វគ្រប់អស់ហើយ ។

ធនបាលចៅ! ចូរអ្នកចាំកុំភ្លេចថា វិញ្ញាណក្នុងខ្លួនទារកនឹងវិញ្ញាណក្នុងស៊ុតសត្វទាំងឡាយ ជាវិញ្ញាណមិនទាន់ដឹងអ្វីដូចវិញ្ញាណក្នុងដើមឈើដែរ តែប្រសាទសម្រាប់ដឹងរបស់វាចេះតែបានទទួលការរីកចម្រើនបន្តិចម្ដងៗ អនាគតកាលរបស់វាត្រូវបានទទួលដំណឹងពេញបរិបូរណ៍ ដូចនេះទើបព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ហាមមិនឱ្យអ្នករក្សាសីលសម្លាប់សត្វស្ងោរស៊ុតសត្វដោយប្រការដូច្នេះឯង ។

**ធ** = បើដូច្នេះ វិញ្ញាណដែលមិនទាន់ដឹងអ្វីនោះបានដល់វិញ្ញាណ ណាខ្លះទៅលោកតា ?

**និ** = បានដល់ភវង្គវិញ្ញាណ ចុតិវិញ្ញាណ បដិសន្ធិវិញ្ញាណ នឹងរុក្ខវិញ្ញាណ...។

**ធ** = ដែលថាបដិច្ចសមុប្បាទជាបច្ច័យតាក់តែងឱ្យមនុស្សសត្វ... កើតនោះ អង្គនៃធម៌បដិច្ចសមុប្បាទក្រៅអំពីអវិជ្ជា ខ្ញុំព្រះករុណាយល់បានខ្លះ តែចំពោះអវិជ្ជាមួយគិតមិនឃើញសោះ មិនដឹងអវិជ្ជានោះសំដៅយកអ្វី? ជារូបធម៌ឬជានាមធម៌ ឬជាព្រះអាទិទេព តើលោកតាអាចពន្យល់បានខ្លះឬទេ ?

**និ** = បានខ្លះ! តែទោះជាយ៉ាងណា ក៏ចៅមិនងាយយល់បានច្បាស់លាស់ទេ ព្រោះបញ្ហានេះព្រះពុទ្ធបរមគ្រូទ្រង់ទេសនាល្អិតជ្រាលជ្រៅណាស់។ បុគ្គលណាយល់ធម៌នេះហើយ បុគ្គលនោះក៏បានសម្រេចមគ្គផលជាទីបំផុត គឺបានជាព្រះអរហន្តស្រេចតែម្តង ។ ដូចនេះ ចូរចៅគិតជាមួយលោកតាថា ក្នុងសម័យមុនអំពីពុទ្ធកាលមនុស្សទាំងឡាយជជែកគ្នាមិនចេះដាច់ស្រេចនូវបញ្ហាថា តើអ្នកណាជាអ្នកបង្កើតនូវអ្វី? ទាំងអស់ក្នុងសកលពិភព។ ចំពោះបញ្ហានេះ អ្នកខ្លះថាធម្មជាតិ អ្នកខ្លះថា ព្រះអាទិទេព អ្នកខ្លះថាអ្វីៗ ទៅទៀតរាប់មិនអស់ទេ ។ ចំណែកព្រះអរហន្តសម្មាសម្ពុទ្ធនៃយើង បើមានគេលើកយករឿងនេះមកចោទសួរ ព្រះអង្គទ្រង់ឆ្លើយថា របស់ទាំងឡាយនេះកើតយូរណាស់មកហើយ មិនដឹងអ្នកណាបង្កើតទេលំបាកនឹងរកមុខអ្នកបង្កើតណាស់ ។ ព្រះអង្គទ្រង់បញ្ជាក់ថា ណ្ហើយកុំចង់ដឹងអ្នកបង្កើតនោះធ្វើអ្វី! គិតតែនាំគ្នាធ្វើឱ្យអស់ទុក្ខព្រួយទៅបានហើយ បើតាមព្រះតម្រាស់របស់ព្រះអង្គក្នុងរឿងនេះ ដូចជាព្រះអង្គចង់ប្រាប់ឱ្យ យើងគ្រប់គ្នាគិតតែធ្វើសេចក្តីល្អទៅព្រោះសេចក្តីល្អជាហេតុឱ្យអស់កើតដែលជាហេតុនៃទុក្ខកុំចង់ស្គាល់មុខមាត់អ្នកបង្កើតនោះធ្វើអ្វី ដោយអាស្រ័យនិទាននេះ ទើបខ្ញុំចាប់យកវិញ្ញាណមកនិយាយថាវិញ្ញាណជាបច្ច័យឱ្យកើតនាមរូប... ដោយខ្ញុំនឹកឃើញថារបស់ជាបច្ច័យនៅខាងដើមបំផុតនៃមេសូត្របដិច្ចសមុប្បាទ នោះគឺអវិជ្ជា អវិជ្ជាតាមន័យនៃពុទ្ធភាសិតនេះគឺមិនដឹងជាស្អីដែលធ្វើជាមេបង្កើតគេអំពីដំបូងឡើយ ។ អវិជ្ជា តាមសេចក្តីចេះដឹងនៃអ្នកប្រាជ្ញពុទ្ធសាសនាទាំងឡាយ ខ្លះថាជារូបធម៌ សំដៅយកដី ទឹក ភ្លើង ខ្យល់ ។ ខ្លះថាជានាមធម៌ សំដៅយកសេចក្តីមិនដឹងនៃចិត្តនៃវិញ្ញាណរបស់មនុស្សយើង ។ ធនបាលចៅ! ដោយអវិជ្ជានេះមានន័យលំបាកនឹងយល់ពេក បានជាសៀវភៅនេះ លោកតាមិនបាននិយាយអំពីវិញ្ញាណតែម្តង បានសេចក្តីថាវិញ្ញាណកើតមាន ព្រោះបច្ច័យនៃសង្ខារ សង្ខារកើតមានព្រោះបច្ច័យនៃអ្វី

ដែលយើងមិនដឹងឬអ្វីដែលយើងមិនចាំបាច់ត្រូវដឹងដែលហៅថាអវិជ្ជានោះឯង ។

**ធ** = អវិជ្ជាដែលប្រែថាមិនដឹងនោះមានគុណលក្ខណៈស្មើគ្នាឬយ៉ាងណា ?

**និ** = មិនស្មើគ្នាទេ អវិជ្ជាក្រាស់បានដល់អវិជ្ជារបស់ដី ទឹក ភ្លើង ខ្យល់ អវិជ្ជាមធ្យមបានដល់អវិជ្ជារបស់អាកាសធាតុ អវិជ្ជាស្ដើងបានដល់អវិជ្ជារបស់វិញ្ញាណធាតុ។

**ធ** = សាធុលោកតា! ខ្ញុំព្រះករុណាយល់បានខ្លះដែរ គឺយល់ថាអវិជ្ជាបើថាទៅលើរូបសំដៅ ដី ទឹក ភ្លើង ខ្យល់ បើថាទៅលើនាម សំដៅយកឈ្មោះនៃសេចក្ដីមិនដឹងរបស់រូបរបស់នាមនោះឯង ។ បើនិយាយតាមអង្គបដិច្ចសមុប្បាទធម៌ផ្នែកខាងអវិជ្ជាជារូបធម៌ បានសេចក្ដីថាដី ទឹក ភ្លើង ខ្យល់ ជាអវិជ្ជា ចលនាទាំងឡាយនៃដី ទឹក ភ្លើង ខ្យល់ មានការវិល ឡើង ស្រក ឆេះ រលត់ បក់ ស្ងប់ ក្ដៅ ត្រជាក់ ភ្លៀង រាំង យប់ ថ្ងៃ... "**សង្ខារ**" ព្រោះសង្ខារប្រែថារចនាតាក់តែងឬប្រែយ៉ាងខ្លីថា "**ធ្វើ**" តែប៉ុណ្ណេះក៏បាន ។ សេចក្ដីនេះខ្ញុំយល់ថាសកម្មភាពឬ ចលនានៃសេចក្ដីមិនដឹងនោះហើយ ដែលចេះតែប្រព្រឹត្តទៅមិនមានឈប់ឈរ ព្រោះមិនដឹងជាឈប់មិនដឹងជាមិនឈប់នោះផងទៀត ហើយការដែលប្រព្រឹត្តជាប់ជានិច្ចនៃធម្មធាតុនេះ ក៏កើតមានជាចំណងនៅក្នុងនោះចុងក្រោយបង្អស់មកបំណងឬចេតនានោះក៏ជាបច្ច័យឱ្យមានវិញ្ញាណឡើង ។ បើនិយាយតាមអង្គបដិច្ចសមុប្បាទធម៌ផ្នែកខាងអវិជ្ជាជានាមធម៌វិញនោះ ក៏បានសេចក្ដីថា មិនដឹងជាអ្វីទេដែលជាបច្ច័យនៃសង្ខារគឺបំណងឬចេតនានោះ នេះគឺសេចក្ដីយល់របស់ខ្ញុំព្រះករុណាតាមដែលធ្លាប់គិតអំពីពុទ្ធភាសិតរឿងបដិច្ចសមុប្បាទ ។

**និ** = ត្រូវហើយចៅ! លោកតាមិនបានស្មានថា ចៅមានបញ្ញាវាងវៃដល់ប៉ុណ្ណោះទេ ចូរចៅរស់នៅជាមួយពុទ្ធសាសនាឱ្យបានយូរ ។ ចៅមានសំណួរអ្វីទៀតដែរឬអស់ប៉ុណ្ណឹងហើយ ។

**ធ** = ខ្ញុំព្រះករុណានៅចង់ដឹងអំពីឧត្តមគតិរបស់អ្នកសួគ៌ (**សគ្គជន**) នឹងអ្នកនិព្វាន (**និព្វានជន**) តើផ្សេងគ្នាយ៉ាងណា?

**និ** = ផ្សេងគ្នាដូចនេះ គឺសគ្គជន គេធ្វើនូវបុណ្យអ្វីៗទាំងអស់ គេទាមទារយកកម្រៃអំពីបុណ្យជាកេរ្តិ៍ឈ្មោះ ជាសេចក្ដីកោតសរសើរ ជាសេចក្ដីរាប់អាន ជាសេចក្ដីគោរពប្រតិបត្តិ ជាសេចក្ដីគួរសម ជាទ្រព្យសម្បត្តិ ជាយសសក្ដិ ជាអំណាច ជាទេព ជាតន្ទ ។ល។ ចំណែកនិព្វានជន គេធ្វើនូវបុណ្យអ្វីៗទាំងអស់ គេមិនមានចង់បានអ្វីក្រៅ

អំពីឱ្យខ្លួនរបស់គេនឹងមនុស្សទាំងឡាយអស់ទុក្ខព្រួយ។ សគ្គជនជាអ្នកបម្រើសេចក្ដីសុខរបស់ខ្លួន រីឯនិព្វានជនជាអ្នកបម្រើសេចក្ដីសុខរបស់សត្វក្នុងសាកលពិភព ។ សគ្គជនគិតតែអំពីឱ្យខ្លួនបានសេចក្ដីសប្បាយ ចង់នរណាកើតទុក្ខយ៉ាងណាក៏មិនខ្វីវល់ ។ និព្វានជនគិតឱ្យមនុស្សសត្វទាំងឡាយបានសុខសប្បាយ ចំពោះខ្លួនឯងប្រសិនបើមានទុក្ខព្រួយក៏ស៊ូទ្រាំឥតមានសេចក្ដីតូចចិត្ត ។ល។ ធនបាលថៅ ! នេះហើយជាសេចក្ដីផ្សេងគ្នានៃឧត្តមគតិរបស់អ្នកសួគ៌នឹងអ្នកនិព្វាន ។

**ធ** = អ្នកនិព្វានអាចរៀបចំពិភពលោកឬប្រទេសជាតិឱ្យចម្រើនរុងរឿងបានឬទេ ?

**និ** = បាន! ការពិតនោះ គឺមានតែអ្នកនិព្វានទេដែលធ្វើឱ្យពិភពលោកបានចម្រើន ព្រោះបុគ្គលពួកនេះមានបំណងធំដើម្បីធ្វើខ្លួនឱ្យបានសម្រេចនូវនិព្វាន ។

**ធ** = បើមានបំណងចង់ទៅនិព្វានឯណោះទេ ហេតុអ្វីបានជាខំធ្វើឱ្យពិភពលោកចម្រើនទៅវិញ ។

**និ** = ព្រោះអ្នកនិព្វានត្រូវធ្វើការទាំងអស់សម្រាប់ពិភពលោក ឱ្យចប់សិនទើបអាចសម្រេចនិព្វាន ។

**ធ** = បើយ៉ាងដូចនេះ អ្នកនិព្វានមិនមែនសម្រេចនិព្វានបានដោយលះបង់ពិភពលោកនេះទេ គឺត្រូវធ្វើការបម្រើពិភពលោកឱ្យចប់យ៉ាងហ្នឹងឬ ?

**និ** = មែនយ៉ាងនេះឯង ។

**ធ** = ក្រែងមានបុគ្គលខ្លះ គេបានសម្រេចនូវនិព្វានដោយមិនមានធ្វើការបម្រើពិភពលោកដែរឬ ?

**និ** = មិនមានទេ! ព្រោះបារមីធម៌ ១០ ជាធម៌សម្រាប់បម្រើមនុស្សលោក អ្នកណាធ្វើធម៌នេះមិនទាន់គ្រប់គ្រាន់ អ្នកនោះគ្មានឧបនិស្ស័យនឹងបានសម្រេចនូវនិព្វានទេ ។

**ធ** = ក្នុងរឿងនេះ មានបុរសបុគ្គល ណាជាតួយ៉ាងដែរឬទេ ?

**និ** = មាន! ព្រះពុទ្ធបរមគ្រូយើង កាលនៅជាបេក្ខជននិព្វានដែលទាំងអស់គ្នាស្គាល់ព្រះអង្គថាជា "**ពោធិសត្វ**" នោះឯង ។

**ធ** = ដូច្នេះ យើងត្រូវបានសម្រេចនូវនិព្វាន ដោយលះបង់ឬដោយកសាង ?

**និ** = ដោយកសាងក្នុងខាងដើម ដោយលះបង់ក្នុងខាងក្រោយបំផុត ។

**ធ** = ដំណើរទៅនិព្វានមិនត្រូវប្រញាប់ពេកទេឬ ?

**និ** = មិនត្រូវស្រូតរូតពេកទេ គឺត្រូវធ្វើយ៉ាងណាឱ្យចប់កិច្ចការសម្រាប់មនុស្សលោកសិន ព្រោះលោកជាបច្ច័យឱ្យបាននិព្វាន ក្នុងកាលណាបានរៀបចំពិភពលោកឱ្យបានចម្រើន ឱ្យបានដល់នូវសេចក្តីល្អបរិសុទ្ធិក្នុងកាលនោះ និព្វានក៏ត្រូវបានសម្រេចឯងៗដោយស្វ័យប្រវត្តិ ។

**ធ** = បើមិនមានលោក ! តើមាននិព្វានឬទេ ?

**និ** = មិនមានទេ ព្រោះនិព្វានទៅអំពីលោក កាលណាមិនមានលោក និព្វានក៏មិនមានដែរ ។

**ធ** = មានតួយ៉ាងដូចបុគ្គលណាទៅ ?

**និ** = តួយ៉ាងដូចព្រះពុទ្ធបរមគ្រូរបស់យើងក្នុងពេលដែលព្រះអង្គបំពេញបារមីធម៌សម្រាប់លោកចប់ហើយ ព្រះអង្គក៏មានព្រះទ័យឆ្លងចាកលោកគឺតាមលោក រូបលោក អរូបលោក ឬឆ្លងចាកចិត្ត គឺចិត្តជាកាមាវចរ រូបាវចរ អរូបាវចរ គឺលោកុត្តរចិត្តនោះឯង ។

**ធ** = ខ្ញុំព្រះករុណានៅមិនទាន់អស់សេចក្តីសង្ស័យក្នុងចំណុចថាឋាននិព្វាននៅក្រៅលោកឬទីបំផុតលោក លោកៗ ហ្នឹងមានន័យដូចម្តេចបើតាមមតិពុទ្ធសាសនាយើង ?

**និ** = លោកៗមានន័យថា ចម្រើនរុងរឿងឡើង ហើយទ្រុឌទ្រោមស្រកចុះវិញ។

**ធ** = មានបាលីវិគ្រោះសព្ទដែរឬលោកតា ?

**និ** = មាន ! **លុជ្ជតិ បលុជ្ជតីតិ លោកោ** ។

**ធ** = ឋាននិព្វាន ប្រសិនបើយើងកុំនិយាយ ថានៅក្រៅលោក ឬទីបំផុតលោក តើយើងនឹងនិយាយថាម៉េចទៅវិញ ។

**និ** = ថាកំពូលលោក ។

**ធ** = បើកុំថាយ៉ាងនេះ ថាម៉េចទៅទៀត ?

**និ** = ថា ! “**អលោក**” ។

**ធ** = “**អលោក**” មានន័យថាម៉េច ?

**និ** = មានន័យថា លោកពិសេស មិនមែនជាកាមលោក រូបលោក អរូបលោក គឺជាលោកដែលបានដូរកាម ដូររូប ដូរអរូបអស់ហើយ លោកឱ្យឈ្មោះថា "**អលោក**" ដោយសេចក្តីថាមិនមែនជាលោក ព្រោះមិនមានបច្ច័យរចនាតាក់តែង ដូចលោកទាំងឡាយមានលោកយើងនេះជាដើម ។

**ធ** = ពិភពលោកចម្រើនរុងរឿងដោយសារអ្នកសួគ៌ ឬដោយសារអ្នកនិព្វាន ?

**និ** = ដោយសារអ្នកនិព្វាន ។

**ធ** = ព្រោះហេតុអ្វី ?

**និ** = ព្រោះហេតុថា អ្នកនិព្វានជាមនុស្សមានចិត្តសប្បុរស ឬមានចិត្តប្រកបដោយមេត្តាករុណា ខំប្រឹងប្រែងសាងលោកឱ្យចប់ ហើយលះបង់លោកនេះចូលនិព្វាន ។ ចំណែកអ្នកសួគ៌ ជាមនុស្សមានចិត្តចង់តែសប្បាយធ្វើការអ្វីៗ ចង់បានតែប្រយោជន៍ផ្ទាល់ខ្លួន គឺគិតយ៉ាងណាធ្វើយ៉ាងណាឱ្យតែខ្លួនអាត្មាបានសេចក្តីសុខចម្រើន មិនសូវខ្វីវល់អំពីសេចក្តីសុខចម្រើនរបស់អ្នកដទៃ របស់ប្រទេសជាតិនៃខ្លួនពិសេសរបស់ពិភពលោក ។

**ធ** = ចម្បាំងអ្នកណាបង្កើត ?

**និ** = អ្នកសួគ៌បង្កើត ។

**ធ** = ព្រោះអ្វីទើបអ្នកសួគ៌បង្កើតចម្បាំង ?

**និ** = ព្រោះអ្នកសួគ៌ជាមនុស្សបម្រើសេចក្តីសប្បាយរបស់ខ្លួន រមែងតែងតែដណ្តើមយកសេចក្តីសុខសប្បាយរបស់អ្នកដទៃដោយកម្លាំងចម្បាំង របស់ខ្លួននោះឯង ។

**ធ** = បើគេចង់បានសម្រេចនូវ "**និព្វានដើម្បី**" តើគេត្រូវដើរតាមផ្លូវណា?

**និ** = គេដើរតាមផ្លូវ ៨ ប្រការ ។

**ធ** = អ្វីខ្លះផ្លូវ ៨ ប្រការ ?

**និ** = ផ្លូវ ៨ ប្រការគឺ :

**ទី១-** ទស្សនៈត្រូវពិត (**សម្មាទិដ្ឋិ**) ។ ភាពសង្ស័យមានទស្សនៈខុសៗ ត្រឹមតែជាសេចក្តីគិតឃើញត្រូវទៅលើផ្លូវខុសមួយៗ ។ បុគ្គលគប្បីដឹងដល់សេចក្តីផ្លែកផ្សេងនៅចន្លោះនៃសេចក្តីស្ថិតស្ថេរនឹងសេចក្តីមិនស្ថិតស្ថេរ។ ត្រូវឃើញសេចក្តីពិតនៅលើ

របស់មិនពិត មុននឹងកាន់យកនូវជំនឿលើរបស់ណា ត្រូវរាវរកហេតុផលក្នុងរបស់នោះឱ្យគ្រប់គ្រាន់សិន ។

**ទី២**- សេចក្តីត្រិះរិះត្រូវ (**សម្មាសង្កប្បៈ**) ។ គឺសេចក្តីតាំងចិត្តក្នុងការពង្រីកជីវភាព ដោយមានមូលដ្ឋានចាកការចេះដឹងរបៀបគ្រប់គ្រងខ្លួន មើលឃើញវែងឆ្ងាយដឹងថាមានផ្លូវណាខ្លះ មានចំណេះវិជ្ជាណាខ្លះ អាចដឹកនាំខ្លួនទៅកាន់សេចក្តីចម្រើនរុងរឿងបាន ។

**ទី៣**- ការនិយាយត្រូវ (**សម្មាវាចា**) ។ នេះជាកាំជណ្តើរដំបូងសម្រាប់ឈានឡើងទៅកាន់ការប្រតិបត្តិដើម្បីគ្រប់គ្រងខ្លួនឯង ។ ការនិយាយដោយប្រាសចាកស្មារតីប្រុងប្រយ័ត្ន និន្ទាមើលងាយស្តីបង្អាប់ជេរប្រទេចផ្តាសា ស្វែងស្វាក់ចិត្តអ្នកដទៃ សម្តីទាំងអស់នេះត្រូវលះបង់ចោល។ ត្រូវនិយាយតែសម្តីប្រកបដោយមេត្តាករុណា បរិសុទ្ធ សុចរិតយុត្តិធម៌គ្រប់កាល ។

**ទី៤**- ទំហើត្រូវ (**សម្មាកម្មន្តៈ**) បានដល់ទំហើដែលមិនធ្វើឱ្យជនដទៃក្តៅក្រហាយទុក្ខលំបាក មានសេចក្តីសុចរិត មានសីលធម៌ ។ ទំហើរាល់ប្រការ ត្រូវឱ្យនៅក្នុងក្របខ័ណ្ឌនៃមនុស្សធម៌ប៉ុណ្ណោះ ។ ត្រូវលះបង់នូវទំហើទាំងអស់ណា ដែលបានប្រយោជន៍ខ្លួន ខូចប្រយោជន៍អ្នកដទៃ ក្នុងបច្ចុប្បន្នឬអនាគតកាល។ ការសងសឹកឬកែកំហឹងមិនត្រូវធ្វើឡើយ ត្រូវដឹកនាំទំហើរាល់ប្រការដោយសីលធម៌ មនុស្សធម៌។ ចូរប្រព្រឹត្តខ្លួនដោយអាស្រ័យធម្មៈ ៤ ប្រការ (**មេត្តា ករុណា មុទិតា នឹងឧបេក្ខា**) ។

**ទី៥**- ការរស់នៅត្រូវ (**សម្មាអាជីវៈ**) ។ គ្រប់តែរបរការងារចិញ្ចឹមជីវិតណាៗទាំងអស់ ត្រូវលះបង់កុំធ្វើនូវរបរណាដែលខ្លួនរស់ហើយគេស្លាប់ ខ្លួនបានប្រកបដោយសេចក្តីសុខ គេបានសេចក្តីទុក្ខ ខ្លួនមានទាន គរទឹកគរដី គេក្រលំបាក ។ល។ ត្រូវពង្រីកជីវភាពរបស់ខ្លួន នៅលើកម្លាំងនឹងសមត្ថភាពរបស់ខ្លួន ។ ឱ្យអ្នកដទៃដែលធ្វើការដើម្បីរស់នៅជាមួយខ្លួន មានតុល្យភាពក្នុងជីវិតរបស់គេ ដោយកាន់យកនូវធម្មៈជាគ្រឿងប្រស្រ័យទាក់ទងនៃការរស់នៅ។ អំពើជិះជាន់នូវជីវភាពរវាងគ្នានឹងគ្នានឹងមិនអាចកើតឡើងបានទេ ប្រសិនបើគេបានឈានជាន់ស៊ប់លើកាំទី ៣ នឹងទី៤ នៃមគ្គជាពិតប្រាកដហើយ ។

**ទី៦**- សេចក្តីព្យាយាមត្រូវ (**សម្មាវាយាម**) ។ ក្រោយអំពីកាលមានសេចក្តីមេត្តា

មានបញ្ញា បានទទួលសេចក្ដីភ្លឺស្វាងស្រឡះមុខមាត់ហើយ បុគ្គលអ្នកប្រកបសេចក្ដីព្យាយាមនឹង បានស្គាល់ច្បាស់នូវការលៃលកចែកកម្លាំងស្មារតីទាំងអស់របស់ខ្លួនទៅកាន់សភាពរឹងប៉ឹងមាំមួនវៃឆ្លាតជ្រៅជ្រះ ស្គាល់ការខុសត្រូវក្នុងទំហើររបស់ខ្លួននឹងចំណុចទីដៅចុងបំផុតនៃទំហើនោះៗ ។ ប្រតិបត្តិការរាល់យ៉ាងនៃបុគ្គលនេះទោះជាការស៊ីឬផឹកដេកឬភ្ញាក់ ធ្វើការឬសម្រាកក៏តាំងនៅលើធម្មៈនេះ ព្រោះខ្លួនគេជាបុគ្គលពេញប្រៀបទៅដោយគុណធម៌ល្អ គុណធម៌ល្អបានក្លាយទៅជាជីវិតរបស់គេ គេមិនមានការចាំបាច់ត្រូវលះបង់វេលាក្នុងការពិចារណាមើលទំហើណាៗ របស់ខ្លួន ក្នុងពេលប្រតិបត្តិការ ដូចបុគ្គលមានសុខភាពអនាម័យសម្បូណ៌មិនចាំបាច់ត្រូវប្រើឱសថជួយគាំទ្ររូបកាយដូច្នោះឯង ។

**ទី៧**- ស្មារតីត្រូវ (**សម្មាសតិ**) ។ សភាពចិត្តតម្កល់ត្រូវក្នុងការតាំងខ្ជាប់នៅក្នុងសន្តិ។ បុគ្គលដែលរស់ក្នុងសភាពចិត្តបែបនេះ គេនឹងគោរពចំពោះតែសភាវៈពិត គេអាចចូលចិត្តរបស់ផ្សេងៗ បានយ៉ាងច្បាស់លាស់ដោយបានទំលាយលាងភាពបោកបន្លំអស់ហើយ គេមានសេចក្ដីពិតនៅក្នុងទីចំពោះមុខគេ។ គេជាបុគ្គលដឹងច្បាស់នូវសេចក្ដីពិត ។ ពិសេសជាងនេះទៅទៀតគឺខ្លួនគេនុ៎ះឯងជាសេចក្ដីពិតតែម្ដង ។ បុគ្គលមានស្មារតីឈរនៅលើសេចក្ដីពិតដូចនេះ រមែងមិនមានវេលាដូរផ្លាស់នូវសកម្មភាពរបស់គេសោះឡើយ ។

**ទី៨**- សេចក្ដីសង្រួមចិត្តត្រូវ (**សម្មាសមាធិ**) ។ នេះគឺជាសភាពចិត្តតាំងខ្ជាប់ខ្ជួនក្នុងសន្តិ ។ ជាសន្តិពិតប្រាកដ ដោយប្រាសចាកទុក្ខណាៗទាំងអស់ ។ កាលណាបុគ្គលបានចូលដល់គុណធម៌ថ្នាក់នេះហើយខ្លួនគេនឹងមិនមានរបស់ណាៗ ទាំងអស់ទៀត អាចដឹកនាំឱ្យគេកើតសេចក្ដីសៅសោក មិនមានសភាពទាំងអស់ណាវៀរតែសភាពដែលនាំមកនូវសេចក្ដីសុខស្ងប់ ។ សេចក្ដីសង្ស័យនឹងសេចក្ដីស្លុតខ្លាច សេចក្ដីកង្វល់នឹងសេចក្ដីជំពាក់ស្មុកស្មាញ បានដល់នូវសេចក្ដីសោះសូន្យទៅ ។ ជំនឿក្នុងកម្មដែលមិនមានមូលដ្ឋាន សេចក្ដីសង្ស័យនឹងសេចក្ដីភ្ញាក់ផ្អើលខុស នឹងរលាយបាត់អស់ទៅ ការចូលដល់គុណធម៌ថ្នាក់នេះនឹងបានប្រសព្វ នូវសន្តិសុខយ៉ាងខ្ពស់បំផុត លើសវិស័យនឹងបរិយាយឱ្យចូលចិត្តបាន ។ បុគ្គលណាបានសម្រេច បុគ្គលនោះអស់មានវេលាប្រែត្រឡប់ដូរផ្លាស់ហើយ ។

**ធ** = បុគ្គលដើរតាមផ្លូវ ៨ ប្រការជាបុគ្គលបានសម្រេចនូវ "**និព្វានដើម្បី**" តែប៉ុណ្ណឹងឬបានសម្រេចនូវនិព្វានទីបំផុតដែរ ?

**និ** = ក្នុងខណៈកំពុងហាត់ដើរ គេបានសម្រេចនូវ និព្វានដើម្បី លុះដំណើរគេមានសេចក្ដីថ្មឹកស្ទាត់អស់មានភាន់ច្រឡំ គេក៏បានសម្រេចនូវនិព្វានទីបំផុត ។

**ធ** = ខ្ញុំព្រះករុណាចូលចិត្តហើយលោកតា ! អំពីរឿងផ្លូវ ៨ ប្រការតែនៅនឹកឆ្ងល់ថា មានអ្វីទៅជាហេតុឱ្យកើតទាំង ៨ នេះ ?

**និ** = ធនបាល ! សេចក្ដីពិត (**សច្ចៈ**)[17] ៤ប្រការជាហេតុឱ្យកើតផ្លូវ៨ នេះគឺ ÷

សេចក្ដីកើតជាហេតុនៃសេចក្ដីទុក្ខ ដោយមកអំពីជីវិតគឺជាទុក្ខ ដោយពានពារសេចក្ដីទុក្ខគ្រប់ជាន់ចាប់តាំងអំពីកើតរហូតដល់ស្លាប់ ។ នេះគឺជាសេចក្ដីពិតប្រការទី១ ។

ហេតុនៃការកើតជាប់ទាក់ទងមកអំពីសេចក្ដីស្រេកឃ្លានចង់រស់នៅ ចង់ពង្រីករស់របស់ខ្លួនឱ្យដល់ទីបំផុតនៃចំណង់ ជាសភាពនាំទៅកាន់ការ កើតហើយកើតទៀតទំនុកបម្រុងបណ្ដុះបណ្ដាលឱ្យចម្រើនឡើយដោយតណ្ហាផ្លូវកាយ តណ្ហាផ្លូវភ្នែក ។ល។ សេចក្ដីរីករាយភ្លើតភ្លើនចំពោះការតាំងនៅនៃជីវិត ចំពោះការរីកដុះដាលនៃជីវិត ។ នេះគឺជាសេចក្ដីពិតប្រការទី២ ។

វិធីបំបាត់នូវហេតុនៃសេចក្ដីកើត គឺរំលាយនូវសេចក្ដីស្រេកឃ្លានចង់ទ្រទ្រង់នូវសេចក្ដីរស់នៅ (**ជីវិត**) ចង់ពង្រីករស់នៅឱ្យធំទូលាយ ដោយរំលត់តណ្ហាខុសៗ ឱ្យសូន្យអស់ទៅមិនឱ្យមានសេសសល់ ដោយដកឫសគល់វាចេញ កុំឱ្យនៅមានសូម្បីត្រឹមតែបន្តិចបន្តួច ។ នេះគឺជាសេចក្ដីពិតប្រការទី ៣ ។

ចំណែកសេចក្ដីពិត ប្រការទី៤ គឺមគ្គប្រកបដោយអង្គ ៨ ប្រការដូចបានពោលមកហើយ ។ នេះគឺជាសេចក្ដីពិតប្រការទី ៤។

**ធ** = សគ្គជននឹងនិព្វានជន មានការគោរពប្រតិបត្តិធម្មៈនៃពុទ្ធសាសនាខុសគ្នាឬដូចគ្នា ?

**និ** = ខុសគ្នា ។

---

[17] "សច្ចៈ" សច្ចៈ ៤ ប្រការនេះ ទុក្ខសច្ចៈជាលោកិយផល សមុទយសច្ចៈជាលោកិយហេតុ និរោធសច្ចជាលោកុត្តរផល មគ្គសច្ចៈជាលោកុត្តរហេតុ ។

**ធ** = សគ្គជន មានគំនិតនឹងការប្រព្រឹត្តយ៉ាងណា !

**និ** = សគ្គជន ជាពុទ្ធសាសនិកយល់ច្រឡំនូវវត្ថុចំណងនឹងឧត្តមគតិនៃពុទ្ធសាសនា ដោយគំនិតថា ពុទ្ធសាសនាអាចជួយទំនុកបម្រុងខ្លួនឱ្យបរិសុទ្ធបាន សម្រេចនូវសេចក្តីសុខបាន កម្ចាត់បង់នូវសេចក្តីទុក្ខគ្រប់យ៉ាងបាន ដោយកម្មវិធីត្រឹមតែថ្វាយបង្គំបួងសួងបន់ស្រន់ ។ ពួកគេមិនខ្វីរវល់ក្នុងកិច្ចសិក្សា ក្នុងការប្រតិបត្តិ សីល សមាធិ បញ្ញា ឱ្យសមតាមឧត្តមគតិនឹងវត្ថុបំណងនៃពុទ្ធសាសនារបស់ខ្លួនឡើយ ។ ប្រាកដការណ៍នៃជនពួកនេះ គឺស្លៀកស្បង់ គ្រងចីពរ ស្លៀកស ពាក់សចូលវត្ត ចូលវិហារសូធ្យធម៌ថ្វាយបង្គំព្រះក្នុងរបៀបផ្គាប់ផ្គុនឱ្យ ព្រះប្រោសប្រាណឱ្យគេស្រឡាញ់រាប់អានខ្លួន ដើម្បីស៊ីពោះលោះកម្លាំងនៅក្រោមទង់នៃព្រះពុទ្ធសាសនាតែប៉ុណ្ណោះ ។

**ធ** = និព្វានជនមានគំនិតនឹងការប្រព្រឹត្តយ៉ាងណា?

**និ** = និព្វានជន ជាពុទ្ធសាសនិកយល់ស្គាល់នូវវត្ថុបំណងនៃពុទ្ធសាសនាការប្រព្រឹត្តិខ្លួនតាមដំបូន្មាន របស់ព្រះពុទ្ធបរមគ្រូគឺជាការដើរតាមឧត្តមគតិរបស់ព្រះអង្គនៃជនពួកនេះ ។ គេយល់ច្បាស់ថា ពុទ្ធសាសនាជាសាសនាមួយ បានដឹកនាំប្រជាសត្វដោយការងារ ពោលអំពីការងារ សម្អាងលើការងារ ការងារជាវត្ថុធាតុ ជាមតិក ជាកំណើត ជាមិត្ត ជាទីតាំងអាស្រ័យ ជាគ្រឿងលៃលកផ្សំផ្គុំរៀបចំឋានៈនៃមនុស្សលោក ។ ដោយអាស្រ័យគំនិតនេះ ទើបគេខំប្រឹងប្រែងធ្វើការទាំងផ្លូវបច្ចុប្បន្ន ផ្លូវបរលោក ផ្លូវនិព្វាន (**មើលសៀវភៅបញ្ហាជីវិត**) របស់ខ្ញុំ ។

**ធ** = ខ្ញុំព្រះករុណាស្តាប់បានច្រើនហើយប្រសិនបើលោកតានិព្វានបាល មិនទាន់ធុញទ្រាន់ទេ សូមមេត្តាបញ្ជាក់តែអំពីគំនិតសគ្គជន ឱ្យបានច្បាស់ជាងនេះបន្តិចទៀតតើបានឬទេ ?

**និ** = មិនអីទេធនបាល! សគ្គជនដែលអាត្មាបាននិយាយមកហើយអំពីចរិយាខ្លះរបស់គេនោះ ជនពួកនេះបានបន្លំយកឧត្តមគតិនឹងវត្ថុបំណងនៃពុទ្ធសាសនាទៅបម្រើឧត្តមគតិនឹងវត្ថុបំណងរបស់ខ្លួន ដោយខំប្រឹងបំពេញសកម្មភាពតាមពុទ្ធសាសនាទាំងផ្លូវទ្រឹស្តី ទាំងផ្លូវប្រតិបត្តិ ហើយបំបែរសកម្មភាពទាំងអស់នោះ ទៅរកសេចក្តីសប្បាយរីករាយតាមកិលេសតណ្ហារបស់ខ្លួន ។ គេយកពុទ្ធសាសនាទៅប្រើក្នុងផ្លូវពង្រីកកាមតណ្ហាបម្រើសេចក្តីសប្បាយរបស់គេ ក្នុងលោកបច្ចុប្បន្ន លោកអនាគត ។ គេឥតមាន

បម្រើឧត្តមគតិពុទ្ធសាសនាដល់បន្តិចបន្តួចសោះ **ទាន សីល ភាវនា** ដែលជនពួកនេះធ្វើ គេមានបំណងតែមួយ គឺឱ្យខ្លួនគេមានទ្រព្យច្រើន រូបល្អ អាយុវែង អំណាចតេជៈ ដើម្បីបម្រើសេចក្ដីសុខរបស់ខ្លួន ដើម្បីយកឈ្នះជនដទៃដោយទ្រព្យសម្បត្តិ រូបកាយ យសស័ក្តិរិទ្ធិអំណាច ។ ជាចុងក្រោយបង្អស់គេយកផលរបស់បុណ្យនេះ ទៅប្រើសង្កត់សង្កិនលើជីវភាពសុខសប្បាយរបស់ជនដទៃ ដោយមិនមានមេត្តាប្រណីអាណិតអាសូរ អ្នកក្រខ្សត់តូចទាបល្ងង់ខ្លៅដល់បន្តិចបន្តួចឡើយ ។ គេគិតដល់តែសេចក្ដីសប្បាយរបស់គេ គេពុំនឹកនាអើពើដល់សេចក្ដីទុក្ខលំបាករបស់សង្គមប្រជាជាតិសាសនាដែលខ្លួនគេបានរស់នៅជាមួយ ។ ឧត្តមគតិរបស់គេគឺឱ្យមនុស្សឥតបុណ្យបម្រើមនុស្សមានបុណ្យ ។ គេគិតថាឱ្យមនុស្សឥតបុណ្យសោយទុក្ខលំបាកចុះ ឱ្យតែអ្នកមានបុណ្យបានសប្បាយ គឺឱ្យមនុស្សមានបុណ្យសោយសុខនៅលើទុក្ខលំបាកនៃជនឥតបុណ្យ។ ធនបាលចៅ! ចំណែកឧត្តមគតិរបស់និព្វានជន គឺផ្ទុយអំពីនេះទាំងអស់ ដូចបាននិយាយខ្លះក្នុងខាងដើមហើយ ។

**ធ** = ខ្ញុំព្រះករុណាមិនទាន់យល់ច្បាស់នូវឧត្តមគតិនៃព្រះពុទ្ធបរមគ្រូរបស់យើងទេ តើមានដូចម្ដេច ?

**និ** = ខាងការរស់នៅក្នុងសង្គមមនុស្ស ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ណែនាំប្រជាពលលោកឱ្យតស៊ូជាមួយធម្មជាតិ ជាមួយហេតុការណ៍នៃជាមួយមនុស្សគ្នាឯងដោយយុត្តិធម៌ដើម្បីយកតំណែងនាទីមុខការ មុខរបរ ហើយយកលទ្ធផលដែលកើតអំពីការតស៊ូ ទៅបម្រើប្រទេសជាតិ បម្រើសង្គមមនុស្សជាតិពិសេសគឺឱ្យលះបង់នូវអ្វីៗទាំងអស់បូជាមនុស្សលោក ។

ខាងផ្លូវសន្តិភាព (**និព្វាន**) ព្រះអង្គទ្រង់ណែនាំប្រជាពលលោកឱ្យយកតំណែងនាទីយសស័ក្តិ អំណាចអធិប្បតេយ្យ ទ្រព្យសម្បត្តិ ។ល។ បូជាសន្តិភាព បម្រើសន្តិភាព ជាពិសេសឱ្យលះបង់នូវនិស្ស័យចិត្តថោកទាបដែលធ្លាប់បម្រើសុខ បម្រើតណ្ហារបស់ខ្លួន ដើម្បីសង្គមមនុស្សលោក ព្រះអង្គទ្រង់បញ្ជាក់ថា មានតែការលះបង់ឈប់បម្រើតណ្ហា បម្រើសុខផ្ទាល់ខ្លួនរបស់មនុស្សតែមួយប៉ុណ្ណោះទេ ដែលអាចធ្វើឱ្យពិភពលោកបានសន្តិភាព អស់ទុក្ខ អស់សង្គ្រាម ហើយបានសម្រេចនូវនិព្វានជាស្ថាពរក្នុងបច្ឆិមជាតិ ។

ព្រះពុទ្ធបរមគ្រូជាអ្នកតស៊ូយ៉ាងខ្ពស់ នៅគ្រប់តែកំណើត ព្រះអង្គទ្រង់តស៊ូមិនមានឈប់ឈរសោះ តស៊ូនឹងសេចក្ដីក្រខ្សត់ តស៊ូនឹងសេចក្ដីល្ងង់ខ្លៅ តស៊ូនឹងសេចក្ដីថោកទាប ។ល។ ក្នុងទីបំផុតនៃការតស៊ូនេះ ព្រះអង្គក៏បានឡើងកាន់ឋានៈខ្ពង់ខ្ពស់។ ព្រះអង្គឈ្នះសេចក្ដីសប្បាយផ្ទាល់ខ្លួន ទើបទ្រង់ឈ្នះទុក្ខគ្រប់ប្រការ។ ការឈ្នះរបស់ព្រះអង្គគឺជាការឈ្នះពិសេសមិនមានពេលត្រឡប់ចាញ់វិញ ជាការឈ្នះដ៏ប្រសើរ ដែលមនុស្សលោកគួរតែយកព្រះអង្គធ្វើជាគំរូ ។

**ធ** = ឧត្តមគតិរបស់ព្រះពុទ្ធបរមគ្រូ ខ្ញុំព្រះករុណាស្ដាប់បានហើយ ។ តែខ្ញុំព្រះករុណាចង់ដឹងថា ព្រះពុទ្ធរបស់យើងត្រូវបានមនុស្សលោកគេរាប់អាន គេទទួលស្គាល់ព្រះអង្គថាជាអ្វីទៅ ?

**និ** = ពុទ្ធសាសនិកមាន ៣ បែប ។ **បែបទី១** ទទួលស្គាល់ព្រះពុទ្ធជាអ្នកធ្វើការជាអ្នកសង្គម ជាអ្នកសីលធម៌ ជាអ្នកមនុស្សធម៌ ។ល។ បូជាព្រះពុទ្ធដោយការងារសីលធម៌ មនុស្សធម៌ ។ ដើរតាម ប្រព្រឹត្តតាម ស្របជាមួយឧត្តមគតិនឹងវត្ថុបំណងរបស់ព្រះអង្គ ទាំងផ្លូវបច្ចុប្បន្ន បរលោក និព្វាន ។ **បែបទី២** ស្គាល់ព្រះពុទ្ធជាអង្គអាទិ-ទេព ជាអ្នកសាងពិភពលោក ជាអ្នកគ្រប់គ្រងរក្សាពិភពលោក ជាអ្នកផ្ដន្ទាទោសមនុស្សលោក ។ល។ បូជាព្រះពុទ្ធដោយបន់ស្រន់បួងសួង ។ បែបទី៣ ស្គាល់ព្រះពុទ្ធជាអង្គចក្រព័ត្រ ជាអ្នកកាន់អំណាច ជាអ្នកសប្បាយ ។ល។ បូជាព្រះពុទ្ធដោយគ្រឿងប្រដាប់សម្រាប់អំណាច ដោយគ្រឿងសប្បាយផ្សេងៗ ។

ពុទ្ធសាសនិកទាំង ៣ ពួកនេះ **ពួកទី១** ត្រូវការរបស់នៅជាមួយពុទ្ធសាសនាគ្រប់លក្ខណៈធម៌ទាំងអស់ ដើម្បីដោះស្រាយបញ្ហាសន្តិភាពពិភពលោករួមគ្នា ដោយកាន់យកនូវឧត្តមគតិតែមួយគឺធ្វើការដើម្បីរស់នៅទាំងអស់គ្នា មិនជិះជាន់គ្នាដោយកម្លាំងទាំងឡាយមានកម្លាំងការងារជាដើម ។ **ពួកទី២** ត្រូវការរស់នៅជាមួយពុទ្ធសាសនា ដោយសុំជំនួយ ដោយមិនមានធ្វើការងារអ្វីៗទាំងអស់ ត្រូវការឱ្យព្រះពុទ្ធព្រះធម៌ ព្រះសង្ឃ ស្រោចស្រង់ខ្លួនឱ្យរួចចាកទុក្ខ ដោយកិច្ចត្រឹមតែលុតក្រាបក្នុងវិហារប៉ុណ្ណោះ ។ **ពួកទី ៣** ត្រូវការរស់នៅជាមួយពុទ្ធសាសនាតែខាងផ្លូវវត្ថុ គឺយកពុទ្ធសាសនាទៅប្រើជារបរកស៊ី ជាជម្រកសាងខ្លួនឱ្យមានឋានៈខ្ពង់ខ្ពស់សោយសុខយ៉ាងសប្បាយ មិនមានគិតគួរដល់សេចក្ដីទុក្ខព្រួយរបស់ប្រជាសត្វក្នុងពិភពលោក ព្រោះ

ជនពួកនេះមិនមានសេចក្តីអើពើដល់ការអប់រំចិត្តឱ្យបានល្អសោះឡើយ ។

**ធ** = សន្តិភាព បើកុំទាន់អាលនិយាយដល់និព្វានតើបានដល់អ្វីទៅ?

**និ** = បានដល់សេចក្តីមេត្រីរាប់រកគ្នា លះបង់នូវគតិ "**សង្គ្រាម**" កាន់យកនូវគតិ "**ធម៌**" របស់ប្រជាពលលោក ដោយការសាង **ទាន សីល ភាវនា** តាមផ្លូវសាកលនិយម ។

**ធ** = ទាន សីល ភាវនា ជាសាកលនិយមនោះតើយ៉ាងណា?

**និ** = ទាន សីល ភាវនា ជាសាកលនិយមនោះគឺ : ទាន សីល ភាវនា ដែលចេញផុតអំពីគតិធម៌ (**ឆន្ទា ទោសា ភយា មោហា**) ដែលអ្នកខ្លាំងបានធ្វើដល់អ្នកខ្សោយ ដោយសម្លឹងឃើញនូវឧត្តមប្រយោជន៍ដែលត្រូវយកមប្រើរួមគ្នាក្នុងជីវភាពបច្ចុប្បន្ននៃប្រជាពលលោក ហើយតម្កល់ខ្លួននៅក្នុងគតិសាកល ក្នុងសកម្មភាពរាល់យ៉ាង។

**ធ** = ព្រះពុទ្ធបរមគ្រូទ្រង់មើលឃើញនូវបំណងមនុស្សយ៉ាងណាទើបណែនាំឱ្យធ្វើទាន សីល ភាវនា ជាសាកលនិយម ?

**និ** = ព្រះអង្គទ្រង់ឃើញថា មនុស្សទាំងអស់ត្រូវការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ត្រូវការមិនឱ្យគេជិះជាន់នូវសេចក្តីរស់ នៅរបស់ខ្លួនជាពិសេសគឺត្រូវការរស់នៅជាមួយគ្នាយ៉ាងស្និទ្ធស្នាលប្រកបដោយភាតរភាព ។ល។ សេចក្តីត្រូវការនេះ កើតមកជាមួយធម្មជាតិ មិនមានអ្នកណាអាចរំលាយចោលបានឡើយ ។

**ធ** = ទាន សីល ភាវនា ជាសាកលនិយមនោះ ប្រសិនបើនិយាយឱ្យច្បាស់ជាងនេះទៅទៀត តើត្រូវនិយាយថាម៉េច ?

**និ** = ត្រូវនិយាយថា អ្នកមានទ្រព្យសម្បត្តិសល់ទុក សល់ដាក់ ត្រូវជួយទំនុកបម្រុងអ្នកទីទាល់ ដោយកុំគិតដល់ជាតិសាសន៍ វណ្ណៈ ត្រកូល គោត្ត។ល។ នេះឈ្មោះថាទានសាកល។ ប៉ុន្តែជីវភាពនេះនឹងត្រូវជិះជាន់ដោយប្រការដទៃទៀត ទើបដឹកនាំឱ្យមនុស្សធ្វើសីលគ្រប់គ្នា ដោយឱ្យយោបល់ថា សព្វសត្វទាំងអស់ត្រូវការសេចក្តីសុខសប្បាយ ត្រូវការសេរីភាព សទ្ធិភាព អធិប្បតេយ្យភាពត្រូវការរស់យឺនយូរ ត្រូវការជួបជុំស្វាមីភរិយា បុត្តធីតា មិនត្រូវការសេចក្តីស្លាប់ ។ល។ ដូច្នេះ មនុស្សដែលមានសេចក្តីត្រូវការដូចគ្នា មិនត្រូវបៀតបៀនគ្នាឡើយ ។ សេរីភាពរបស់មនុស្សរមែងកើតឡើងដោយសីលសាកល តែបើមនុស្សគ្រប់គ្នានៅតែប្រកាន់ជាតិសាសន៍ វណ្ណៈ

គោត្ត ត្រកូល ។ល។ ការរស់នៅរបស់មនុស្សក៏មិនបានជិតស្និទ្ធជាមួយគ្នាឡើយ ។ ដោយអាស្រ័យហេតុនេះ ពុទ្ធសាសនាទើបបង្រៀនមនុស្សឱ្យចម្រើនចិត្តជាសាកល **(*ភាវនាសាកល*)** គឺរាល់តែពេលដែលគិតនឹកដល់មនុស្សនោះ ត្រូវគិតត្រឹមតែមនុស្សៗ សត្វៗ កុំគប្បីគិតនឹកជាជាតិ វណ្ណៈ គោត្ត ត្រកូល ឋាន លទ្ធិ សាសនា និកាយ ។ល។ អ្វីៗ ឡើយ ត្រូវចម្រើនចិត្តថា "***សូមឱ្យមនុស្សសត្វទាំងឡាយរស់នៅជាសុខ ចូរកុំមានសេចក្ដីទុក្ខ ចូរកុំបៀតបៀនគ្នា ចូរចេះថែរក្សាគ្នាឱ្យបានសុខ ដែលមានទុក្ខ សូមឱ្យអស់ទុក្ខទៅ ដែលមានភ័យសូមឱ្យអស់ភ័យទៅ ដែលមានជម្ងឺសូមឱ្យអស់ជម្ងឺទៅ ។ល។***" កាលណាចិត្តសាកលនេះកើតឡើងហើយ មនុស្សយើងនឹងរស់នៅក្នុងសន្តិភាពជាមិនខាន ។

**ធ** = ជីវិតសន្តិភាពក្នុងលោកនេះ នឹងជាបច្ច័យឱ្យមានជីវិតសន្តិភាពក្នុងលោកដទៃទៀតបានឬទេ ?

**និ** = ជីវិតសន្តិភាព ព្រោះទាន សីល ភាវនា ក្នុងលោកនេះនឹងត្រូវបានជាបច្ច័យឱ្យមានជីវិតសន្តិភាព ក្នុងពិភពលោកទាំងឡាយរហូតដល់ព្រះនិព្វានជាទីបំផុត ។

**ធ** = វិញ្ញាណក្នុងជីវិតនៃមនុស្សម្នាក់ៗ ដែលបានបំពេញបារមីធម៌ជាទានក្ដី សីលក្ដី បញ្ញាក្ដី ។ល។ លុះដល់ពេលស្លាប់ថាត្រូវកើតជាថ្មីទៀត ប៉ុន្តែមិនមែនថាវិញ្ញាណតួសព្វថ្ងៃនេះទេ គឺវិញ្ញាណតួនេះគ្រាន់តែជាបច្ច័យនៃវិញ្ញាណតួថ្មីក្នុងជីវិតដទៃទៀត បើដូច្នេះ តើបុណ្យដែលវិញ្ញាណចាស់កសាងនោះត្រូវជាប់ទៅជាមួយវិញ្ញាណថ្មីដែរឬទេ ?

**និ** = ត្រូវជាប់ទៅជាមួយវិញ្ញាណថ្មីទៀតមិនបានរលាយបាត់បង់ទៅជាមួយវិញ្ញាណចាស់ទេ តែមិនមែនជាតួបុណ្យទេ គឺជាតួវិបាករបស់បុណ្យ ដែលគេធ្លាប់ហៅថា ផលឬអានិសង្ស ។

**ធ** = សូមមេត្តាអធិប្បាយអំពីលក្ខណៈនៃវិញ្ញាណថ្មីនឹងវិបាកនៃបុណ្យបាបដែលត្រូវមាននៅក្នុងវិញ្ញាណថ្មីឱ្យបានងាយស្ដាប់ងាយពិចារណា តើយ៉ាងណាទៅ ?

**និ** = ធនបាលចៅ! ចំពោះសំណួមនេះ អាត្មាអាចអធិប្បាយ អាចពន្យល់បានទាំងអស់ តែរឿងនេះមានសេចក្ដីល្អិតជ្រាលជ្រៅណាស់ កាលណាបើលើកយកបញ្ហាដ៏មានជម្រៅមានអាថ៌កំបាំងមកឆ្លុះបញ្ចាំងឱ្យស្ដាប់បានចប់ចុងចប់ដើមនោះឃើញថា

ទៅមិនរួចទេ ។

**ធ** = ហេតុដូចម្តេចទើបទៅមិនរួច ?

**និ** = ព្រោះហេតុពីរប្រការគឺ : (១) ពេលរបស់អាត្មាមានតិចពេក (២) សៀវភៅនេះត្រូវមានកំណត់ចំនួនទំព័រ ។

**ធ** = បើដូច្នេះ ធ្វើយ៉ាងណាទើបអាចប្រព្រឹត្តទៅបាន ?

**និ** = ធនបាលចៅ! ដើម្បីឱ្យបានយល់អំពីរឿងវិញ្ញាណថ្មីនឹងវិបាកនៃបុណ្យបាបដែលត្រូវអាស្រ័យជាមួយវិញ្ញាណថ្មីនោះ មធ្យោបាយមានត្រឹមតែពីរគឺ: (ក) ត្រូវមើលឡើងវិញនូវសៀវភៅឈ្មោះ "**បញ្ហាអនាគត**" របស់ភិក្ខុធម្មបាល (ខ) ត្រូវចូលទៅរកអ្នកជំនាញខាងបរមត្ថធម៌ឬខាងបដិច្ចសមុប្បាទ ដើម្បីពិគ្រោះអំពីរឿងនេះ ។

**ធ** = ខ្ញុំព្រះករុណាចង់ដឹងនូវកំពូលនៃសេចក្តីប្រាថ្នាឬត្រួយនៃសេចក្តីប្រាថ្នាឬសេចក្តីប្រាថ្នាជាទីបំផុតរបស់មនុស្ស តើនៅលើធម្មាធាតុអ្វី? ឬវត្ថុធាតុអ្វី?

**និ** = មុននឹងឆ្លើយនូវសំនួរនេះ អាត្មាសូមធ្វើអត្ថាធិប្បាយឱ្យឃើញនូវចំណង់របស់មនុស្សដែលធ្លាប់មានជាហូរហែមក។ បុគ្គលពួកខ្លះក្នុងលោកនេះ ឃើញថាប្រាក់មាសគឺ ជាកំពូលនៃចំណង់របស់មនុស្សព្រោះគេលើកតម្កើងប្រាក់មាសទុកដូចជាព្រះអាទិទេព... របស់គេ ទុក្ខធុរៈ ព្រួយលំបាកគ្រប់យ៉ាង គេត្រូវពឹងផ្អែកលើប្រាក់មាស ដើម្បីរំលាយទុក្ខទោសទាំងអស់នោះ ។ តែក្នុងរឿងដដែលនេះ មិនមែនមានមតិស្របគ្នាជាទូទៅទេ គង់មានមតិផ្ទុយគ្នាខ្លះ ព្រោះមាសប្រាក់ក៏មិនមែនជាចំណុចចុងចប់នៃសេចក្តីប្រាថ្នារបស់មនុស្សយើងទេ ។ ព្រោះអ្វី? ព្រោះមនុស្សមានលុះដល់ថ្នាក់ដែលគេហៅថា មហាសេដ្ឋីក៏នៅតែស្រវេស្រវាស្ទុះស្ទាខំរកនូវរបស់អ្វី? ទៀតដែលមិនអាចនឹងដាក់ឈ្មោះឱ្យ ចប់សព្វគ្រប់បានដើម្បីបំពេញនូវបំណង់របស់ខ្លួនក្នុងផ្លូវដទៃទៀត ប្រែថាសេចក្តីប្រាថ្នារបស់មនុស្សពុំបានចប់ត្រឹមលុយទេ គឺដំណាក់ចុងក្រោយនៃសេចក្តីប្រាថ្នានោះនឹងត្រូវមានអ្វីផ្សេងទៀតមិនមែនលុយទេ ។ នៅក្នុងរឿងនេះ អាត្មាកំពុងគិតគូររកពាក្យឆ្លើយតទៅទៀតដោយនឹកថាអ្វីទៅហ្ន៎ ! ដែលជាសេចក្តីប្រាថ្នាទីបំផុតនៃមនុស្សលោក ។ នឹកឃើញដល់លោកធម៌គឺ លាភៈ យសៈ បសំសៈ សុខៈថាជារបស់ដែលមនុស្សត្រូវការជាទីបំផុតឬជាកំពូលនៃសេចក្តីប្រាថ្នា ដែលគំនិតនេះ នឹងរាប់ថាត្រូវក៏ពុំបានព្រោះមនុស្សរិតតែមានទ្រព្យសម្បត្តិច្រើនក៏រិតតែចង់បាន

ច្រើនទៅទៀតរហូតលុះក្លាយទៅជាមនុស្សល្មោភយ៉ាងខ្លាំងក្លារកអ្វីប្រៀបពុំបាន ។ យសៈ ក៏មិនមែនជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្ស ព្រោះមនុស្សដែលមានយសសក្តិ ក៏មិនមាននមនោសញ្ចេតនា ឆ្អែតឆ្អន់ ដោយយសសក្តិរបស់ខ្លួនត្រឹមប៉ុណ្ណោះប៉ុណ្ណោះ គឺចេះតែចង់បានតទៅទៀត ។ សេចក្តីសរសើរ ក៏មិនមែនជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្សដែរ ព្រោះពាក្យសរសើរជាធម្មជាតុប្រៀបបាននឹងឱសថទំនុកបម្រុងបេះដូង ដែលជួយឱ្យប្រព្រឹត្តទៅបានស្រួលក្នុងមួយពេលប៉ុណ្ណោះ ។ មនុស្សលោកមានចំនួនតិចពេកណាស់ដែលឆ្អែតដោយការសរសើរ។ សុខៈ សេចក្តីសុខឬសេចក្តីសប្បាយ នេះគួររាប់ថា ជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្ស ព្រោះមនុស្សគ្រប់រូប ទោះជាប្រាថ្នាអ្វីក៏ដោយក៏រមែងទៅជួបចំណុចចុងក្រោយបង្អស់គឺសេចក្តីសុខ ឧទារហណ៍មនុស្សអង្គុយក៏មកអំពីចង់បានសុខ ឈរក៏ប្រាថ្នាឱ្យបានសុខ ដេកក៏ចង់ដេកឱ្យជាសុខ ស៊ីក៏ចង់ស៊ីឱ្យជាសុខ ។ល។ សូម្បីស្លាប់ក៏ស្លាប់យ៉ាងមានសេចក្តីសុខ ។

សេចក្តីសុខ ហាក់ដូចបានសម្រេចថា ជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្ស តែមនុស្សទាំងឡាយនៅក្នុងពិភពលោកនេះ មានចំនួនតិចពេកណាស់ ដែលបាននិយាយប្រាប់គេថា ខ្លួនបានសេចក្តីសុខ។ តាមធម្មតា មនុស្សដែលដេកនៅលើគំនរទ្រព្យសម្បត្តិ ក៏នៅតែនិយាយត្អូញត្អែរថាខ្លួនមានទុក្ខ មានសេចក្តីអផ្សុកធុញទ្រាន់អស់កាលជានិច្ច ។ មនុស្សខ្លះត្រូវរកឱសថមកព្យាបាលរោគ នឹងឱសថសម្រាប់ជួយឱ្យដេកលក់ដើម្បីលុបបំបាត់នូវសេចក្តីទុក្ខក៏មាន បញ្ហាទាំងអស់នេះនាំឱ្យមានសេចក្តីសង្ស័យថា តើសេចក្តីសុខដែលបាននិយាយមកហើយនោះ ពិតជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្សឬ? ឬមានធម្មធាតុណាមួយ ដែលធ្វើឱ្យមនុស្សយើងស្វែងរកសេចក្តីសុខខុសចាកសេចក្តីពិត ឬខុសចាកផ្លូវដែរ? ធនបាលចៅ! សេចក្តីសុខ ពុទ្ធសាសនាចែកតាមអាការៈដែលប្រាកដចេញមកជា ២យ៉ាងគឺ បើសេចក្តីសុខប្រាកដចេញមកតាមផ្លូវកាយ ដូចជាសេចក្តីសុខសប្បាយដែលកើតចាកឈាមខ្យល់ក្នុងខ្លួនប្រព្រឹត្តទៅជាប្រក្រតី មិនមានជម្ងឺអ្វីបៀតបៀន មានសម្បុរថ្លាស្អាត ហៅតាមបាលីថា "**កាយិកសុខ**" ឬ "**សុខតាមផ្លូវកាយ**" តែបើសេចក្តីសុខសនោះប្រាកដចេញមកតាមផ្លូវចិត្ត ដូចជាសេចក្តីជ្រះថ្លារីករាយ មិនមានអាការៈអផ្សុកធុញទ្រាន់ខាងផ្លូវចិត្ត រហូត

ដល់កើតចាកចិត្តថ្លាស្អាត មិនមានលោភៈ ទោសៈ មោហៈ ជាដើម ហៅតាមបាលីថា **"ចេតសិកសុខ"** ឬ **"សុខតាមផ្លូវចិត្ត"** ។ ធនបាលចៅ! ការស្គាល់លក្ខណៈនៃសេចក្តីសុខខាងពុទ្ធសាសនាត្រឹមប៉ុណ្ណេះ មិនទាន់ល្មមទេ ដូចនេះ ចូរចៅ ខំប្រឹងពិនិត្យផ្ទៀងស្ទាត់ចម្លើយរបស់អាត្មា បន្ទាប់អំពីពាក្យផ្តើមឆ្លើយនេះតទៅ ÷

លក្ខណៈនៃសេចក្តីសុខមាន ២ ប្រការទៀត ប្រការទី១ លោកហៅថា **"សាមិសសុខ"** សុខបន្លំ ឬសុខក្លែងក្លាយ។ ប្រការទី ២ លោកហៅថា **"និរាមិសសុខ"** សុខសុទ្ធ ឬ សុខមិនមានបន្លំ មិនមានក្លែងក្លាយ ។

សុខបន្លំ សំដៅយកសេចក្តីសុខដែលមិនសុទ្ធ ជាសេចក្តីសុខដែលផ្សំលាយដោយវត្ថុខ្លះ ទុក្ខខ្លះ ។ ពាក្យថាបន្លំ មានន័យថា មិនសុទ្ធមិនស្អាត ឧទាហរណ៍ មាសបន្លំគឺមាសដែលមានលាយធាតុស្ពាន់ ធាតុប្រាក់គេហៅថាមាសក្លែងក្លាយ។ ទឹកមិនស្អាត គឺទឹកដែលមានកករ នៅក្នុងនោះគេហៅថា ទឹកមិនបរិសុទ្ធ។ មាសបន្លំ កាលណាគេបានដុតរំលាយបំបែកយកវត្ថុដទៃចេញ មាសក៏បរិសុទ្ធ ទឹកមិនស្អាត កាលណាគេបានត្រងយកវត្ថុដទៃចេញ ទឹកក៏បរិសុទ្ធ។ សេចក្តីសុខបន្លំនោះ គឺមិនមែនសុខសុទ្ធ ជាសុខផ្សំលាយដោយវត្ថុ ដូចជាសេចក្តីសុខក្នុងភាពជាសេដ្ឋីជាសេចក្តីសុខកើតឡើងព្រោះវត្ថុគឺទ្រព្យសម្បត្តិ បើដកយកទ្រព្យសម្បត្តិចេញក៏មិនមានសុខ ។ សុខរបស់មនុស្សស្រឡាញ់សេចក្តីស្អាតសេចក្តីល្អ មិនមែនសុខបរិសុទ្ធ ជាសុខផ្សំលាយដោយអារម្មណ៍ដ៏ស្អាតដ៏ល្អ ។ សុខរបស់មនុស្សភាគច្រើននៅនាលោកិយនេះ ជាសេចក្តីសុខ មានរូប សំឡេង ក្លិន រស នឹងសម្ផស្ស ជាគ្រឿងប្រកប មិនមែនជាសុខសុទ្ធ ជាសុខអាស្រ័យវត្ថុគឺកាមគុណ បើញែកកាមគុណចេញក៏អស់សេចក្តីសុខ។ សុខរបស់បុគ្គលវង្វេងកាន់ច្រឡំក្នុងលោកធម៌ មិនមែនសុខសុទ្ធ គឺជាសុខផ្សំលាយដោយ លាភ យស បសំសៈ សុខៈ ។ សុខរបស់បុគ្គលដែលមានលោភៈ ទោសៈ មោហៈ ក៏មិនមែនជាសុខសុទ្ធ ជាសុខនៅក្រោមបញ្ជានៃកិលេស ។

សរុបសេចក្តីថា សុខទាំងឡាយណាមិនបានកើតឡើងដោយដាច់ឡែក នៅត្រូវអាស្រ័យវត្ថុ បុគ្គល អារម្មណ៍ កិលេស សុខនោះជាសាមិសសុខគឺ សុខបន្លំ ឬ សុខក្លែងក្លាយ ។

សុខសុទ្ធ គឺជាសុខបរិសុទ្ធ មិនមានអាស្រ័យវត្ថុ បុគ្គល អារម្មណ៍ នឹង កិលេស

ជាសេចក្ដីសុខស្ងាត់ចាកវត្ថុធាតុនឹងធាតុទាំងឡាយ ដូចជាសេចក្ដីសុខរបស់អ្នកបួសពិតៗ មែនៗ ។ លោកបានលះបង់អស់ហើយឬកំពុងតែព្យាយាមលះបង់នូវរូប សំឡេង ក្លិន រស សម្ផស្ស ។ កំពុងប្រតិបត្តិធម៌ កម្ចាត់សេចក្ដីលោភ សេចក្ដីវង្វេង។ កម្ចាត់បង់នូវសេចក្ដីកង្វល់បលិពោធខាងផ្លូវចិត្ត នឹងសេចក្ដីប្រពាក់ប្រពូនរបស់វិញ្ញា-ណគ្រប់ពេលវេលា។ ជីវិតនៃអ្នកបួសទាំងឡាយនោះ សូម្បីនៅប្រាសចាកវត្ថុធាតុជាគ្រឿងសប្បាយសម្រាប់មនុស្សលោកអស់ហើយ ក៏លោកនៅមានសែងស្វាងនៃសេច-ក្ដីសុខផ្ទះចាំងចូលមកក្នុងចិត្តរបស់លោកជានិច្ច។ សេចក្ដីសុខបែបនេះហៅថាសុខសុទ្ធ កើតអំពីភាវៈមិនមានអ្វីឡើយ ដូចជាព្រះអរិយទាំងឡាយដែលបានបង់នូវវត្ថុធាតុធម្មតាឥតមានសេសសល់ ក៏លោកនៅតែបានទទួលនូវសេចក្ដីសុខក៏ប្រណីត នេះគឺជានិរាមិសសុខ សុខសុទ្ធ សុខស្អាត ឬសុខស្ងប់នោះឯង ។

ធនបាលចៅ! កាលណាបើយើងនាំយកសុខសុទ្ធនឹងសុខបន្លំមកប្រៀបធៀបគ្នា យើងនឹងឃើញថា សេចក្ដីសុខបន្លំជាសេចក្ដីសុខនៅមានវត្ថុធាតុក្នុងលោកជ្រៀតជ្រែក តែសេចក្ដីសុខសុទ្ធជាសេចក្ដីសុខប្រាសចាកការជ្រៀតជ្រែកនៃវត្ថុធាតុក្នុងលោកហើយ។ មនុស្សទាំងឡាយ មើលឃើញសេចក្ដីសុខខុសៗគ្នា ស្រេចហើយទម្លាប់ដែលខ្លួនបានឆ្លងកាត់ អ្នកខ្លះឃើញតាមនិយម អ្នកខ្លះឃើញតាមចរិតរបស់ខ្លួន ។ ដូចអ្នកញៀនស្រា ញៀនល្បែងភ្នាល់ ញៀនដើរលេងយប់ ញៀនមើលល្ខោន ។ល។ គេថា សេចក្ដីសុខពិតប្រាកដ នៅលើការមើលល្ខោន ការផឹកស្រា។ល។ អ្នកញៀនសេចក្ដីក្រោធ ថ្ងៃណាមិនបានជេរអ្នកដទៃ គេថាមិនមានសេចក្ដីសុខ ។ បុគ្គលខ្លះប្រកបដោយរាគចរិត ស្វែងរកសេចក្ដីសុខ ដោយមើលរូប ស្ដាប់សំឡេង ថើបក្លិន ។ល។ បើស្វែងរករូប សំឡេង ក្លិន... មិនបាន គេថា មិនមានសេចក្ដីសុខ ។

បុគ្គលខ្លះ ប្រកបដោយវិតក្កចរិត ចូលចិត្តលើកយករឿងដែលកន្លងហួសទៅហើយ មកគិតគូរជាថ្មីទៀត ។ មនុស្សយើងចូលចិត្តលើកយកសេចក្ដីញៀនគ្រប់យ៉ាងមកធ្វើជាគ្រឿងវាស់ ឬជាគ្រឿងបង្កើតនូវសេចក្ដីសុខឱ្យខ្លួន ទើបបណ្ដាលឱ្យមនុស្សឃើញទុក្ខជាសុខ ឃើញសុខជាទុក្ខដូចមានរឿងដំណាលថា :

មានឥសីពីររូប បំពេញសមណៈធម៌នៅក្នុងព្រៃមួយ។ សេចក្ដីប្រតិបត្តិនៃឥសីទាំងពីរនោះខុសគ្នា គឺម្នាក់ប្រតិបត្តិត្រូវ ម្នាក់ទៀតប្រតិបត្តិខុស។ លុះអស់ជីវិតទៅ ក៏

ត្រូវបានទទួលផលនៃកម្មអាក្រក់ល្អរៀងៗខ្លួន។ ក្នុងជាតិជាទីបំផុតតសីម្នាក់បានមកកើតជាព្រហ្មរលឹកជាតិបានសព្វគ្រប់ ដឹងថាសម្លាញ់របស់ខ្លួន ទៅកើតជាដង្កូវនៅក្នុងគំនរលាមក ក៏កើតមានចិត្តអាណិត ចង់ជួយឱ្យផុតចាកទុក្ខក្នុងគំនរលាមក ទើបតំណែងជាមនុស្សទៅឈរនៅជិតទីនោះហើយនិយាយថា :

សម្លាញ់អើយ! អ្នកមកកើតនៅក្នុងទីនេះសែនលំបាកពន់ពេកណាស់ឡើងមកសម្លាញ់ ! ខ្ញុំនឹងនាំអ្នកទៅនៅព្រហ្មលោក ដើម្បីក្រេបផឹកនូវរសនៃអាហារទិព្វ។

សត្វដង្កូវសួរថា ***"អ្នកនឹងនាំខ្ញុំទៅព្រហ្មលោកនោះ ក្នុងព្រហ្មលោកមានអ្វីខ្លះ?"***

***"មានរបស់គ្រប់បែបគ្រប់យ៉ាង សុទ្ធតែជាទិព្វ"*** តសីឆ្លើយ។

***"លើព្រហ្មលោកមានឧច្ចារ ស៊ីឬទេ?"*** ដង្កូវសួរ

***"មិនមានទេ"*** តសីឆ្លើយ ។

***"បើនៅក្នុងព្រហ្មលោកមិនមានលាមកស៊ីទេ អញ្ជើញសម្លាញ់វិលទៅវិញចុះ ខ្ញុំមិនទៅផងទេ"*** ដង្កូវឆ្លើយហើយមុជចុះទៅក្នុងគំនរលាមកបាត់ទៅ ។

សេចក្តីនេះបញ្ជាក់ឱ្យឃើញថា ដង្កូវមិនយល់ឃើញថា មានអ្វីល្អជាងលាមកទៅទៀតទេ ព្រោះដង្កូវកើតមកក្នុងគំនរលាមក ញៀនក្លិន ញៀនរស របស់លាមកជាយូរមកហើយ ។ តែសេចក្តីសុខរបស់ព្រហ្មនឹងដង្កូវនោះផ្សេងគ្នាយ៉ាងណា យើងគិតទៅគង់យល់ហើយ។ មនុស្សយើងក៏ដូចគ្នា ខ្លះកើតមកក្នុងគំនរនៃវត្ថុ គឺប្រាក់ មាស កែវកង ។ល។ ខ្លះកើតមកនៅក្នុងកណ្តាលបញ្ចកាមគុណ ។ ខ្លះកើតមកនៅកណ្តាលលោកធម៌ នៅក្នុងកងកិលេស គឺលោភៈ ទោសៈ មោហៈ ។ល។ គេធ្លាប់ជ្រកជ្រែញធ្លាប់ស៊ីផឹក ធ្លាប់ញៀនញ៉ាមអស់ទៅហើយ ។ អ្នកណាទៅបបួលមនុស្សបែបនេះ ឱ្យទៅនៅក្នុងទីកន្លែងមិនមានរបស់អស់ទាំងនេះ គេមិនជឿមិនព្រមទៅឡើយ ។ បុគ្គលខ្លះនឹកសង្ស័យថានិព្វានជាសភាពដែលទំនេរដែលវាលធេង មិនមានរបស់សម្រាប់ស៊ីសម្រាប់ផឹក មិនមានអត្តាខ្លួនប្រាណសម្រាប់ស៊ីសម្រាប់ផឹកសោះទៅហើយ នឹងថាជាសុខបានយ៉ាងម៉េច? ព្រោះគេធ្លាប់ញៀនធ្លាប់ញ៉ាមចំពោះសេចក្តីសុខ ដែលមានខ្លួនប្រាណស៊ីសោយ ឬសេចក្តីសុខបន្លំនោះស្រេចទៅហើយ។ ធនបាលថៅ! កំពូលនៃសេចក្តីប្រាថ្នារបស់មនុស្សគឺសុខសុទ្ធឬសុខពិតប្រាកដ មិនមែនសុខបន្លំឬសុខក្លែងក្លាយទេ ។ របស់ដែលថាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្ស គឺនៅត្រង់ចំណុចរលត់

រលាយអស់នូវសេចក្តីប្រាថ្នា គឺកាលណាបើទៅដល់ត្រង់នោះ សេចក្តីប្រាថ្នាដែលធ្លាប់តែមានមកយូរហើយក៏ត្រូវបានរលត់ភ្លឹបបាត់ឈឹងភ្លាម ។ ធនបាលថៅ! ចូរអ្នកងាកមកមើលមនុស្សលោកដែលកំពុងព្យាយាមទៅឱ្យដល់នូវសេចក្តីសុខ ដែលអាស្រ័យមាសប្រាក់... ឬរូប សំឡេង... នឹងលោកធម៌ តែសេចក្តីប្រាថ្នារបស់គេពុំបានចប់ឬអស់ត្រឹមប៉ុណ្ណេះទេ គឺរិតតែចង់បានច្រើនឡើងទៀត ។ យើងងាកមកមើលជនមួយពួកទៀត គឺជនដែលលះបង់នូវវត្ថុគ្រប់បែបគ្រប់យ៉ាងដូចបាននិយាយមកហើយ។ លោកទាំងឡាយនោះបានសម្រេចនូវសេចក្តីសុខបែបមួយផ្សេងដោយឡែក លោកបានទៅដល់ចុងចប់នៃសេចក្តីប្រាថ្នាត្រឹមនោះ ។ សុខនោះគឺនិរាមិសសុខ ជាសុខដែលមិនមានលាយឡំដោយរបស់ណាៗទាំងអស់ គឺសេចក្តីសុខដែលលោកតាដៅយកថាជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្សក្នុងទីនេះ ។

ធនបាលថៅ! មនុស្សបុថុជ្ជនទាំងអស់គ្នា សុទ្ធតែចង់ទៅឱ្យដល់កំពូលនៃសេចក្តីប្រាថ្នានេះ តែមិនមានអ្នកណាម្នាក់ ធ្លាប់បានឃើញនូវកំពូលនៃសេចក្តីប្រាថ្នានេះឡើយ ពិសេសជាងនេះទៅទៀតគឺមិនមានអ្នកណាជឿថា របស់នេះជារបស់មានពិតប្រាកដ ទោះណាជាព្រះពុទ្ធអង្គនៃយើងទ្រង់ដឹកនាំសត្វនឹងទ្រង់ជាតួយ៉ាងមកហើយក៏ដោយ ។ គេទាំងឡាយប្រកាន់យកយ៉ាងធំថា កំពូលនៃសេចក្តីប្រាថ្នាឬបរមសុខរបស់គេនៅលើមាស ប្រាក់ លាភ យសនឹងបញ្ចកាមគុណនោះឯង ។ សេចក្តីយល់ឃើញនេះមិនអាចនឹងឱ្យគេដល់នូវទីបំផុតនៃទុក្ខបានឡើយ ដូចគ្នានឹងបុគ្គលចង់បានមាសសុទ្ធ ព្យាយាមស្វែងរកមាសសុទ្ធ តែខ្លួនមិនស្គាល់មាសសុទ្ធមួយរយភាគរយ ការមិនស្គាល់នេះជាបច្ច័យឱ្យគេរើសយកមាសមិនសុទ្ធដោយសម្គាល់ថា ជាមាសសុទ្ធ តើគេនឹងបានសោយនូវសេចក្តីពេញចិត្តក្នុងមាសដែរឬទេ? មិនបានទេធនបាល! គេត្រូវបានទទួលនូវសេចក្តីព្រួយលំបាករឿយៗ លុះត្រាតែបានមាសសុទ្ធ ទើបគេបានសោយតង្ហារម្មណ៍។ កាលណាសេចក្តីប្រាថ្នានៅពុំទាន់ដល់ទីបំផុតសេចក្តីទុក្ខក៏នៅពុំទាន់ចប់ ព្រោះសេចក្តីប្រាថ្នាឬចំណង់ជាមាតានៃទុក្ខ ។ ដូច្នេះ បើយើងដឹងថា ការនឿយហត់របស់យើងក្នុងការខំស្វែងរកនូវរបស់ដែលជាកំពូលនៃសេចក្តីប្រាថ្នា តែនៅពុំទាន់បានជួប ជួបតែរបស់ដែលជាអាមិសក្នុងលោកនេះ ក៏កុំទាន់អាលសម្រេចថាសុខដទៃក្រៅចាកអាមិលពុំមានឡើយ។ ធនបាលថៅ! ចូរអ្នកត្រឡប់វិលមករកសេច-

ក្តីសុខ ចាកភាពមិនមានរបស់អស់ទាំងនោះខ្លះ ជួនកាលសេចក្តីប្រាកដថាព្រះពុទ្ធអង្គក្តី សាវកទាំងឡាយរបស់ព្រះអង្គក្តី លោកបានបញ្ឈប់នូវសេចក្តីប្រាថ្នារបស់លោកនៅត្រង់សេចក្តីសុខដែលមិនមានចំណុះដល់វត្ថុឬមិនមានអាស្រ័យនូវអាមិស ។

**ធ** = ខ្ញុំព្រះករុណាស្តាប់បានហើយ តែខ្ញុំព្រះករុណាគិតថា លោកតានិព្វានបាល ហាក់ដូចជាចង់កេណ្ឌមនុស្សឱ្យទៅនិព្វានឱ្យអស់ពីពិភពលោកតែម្តងហើយ! តើលោកតាមានគំនិតដូច្នេះមែនឬទេ?

**និ** = មិនមែនទេ ! លោកតា មានគំនិតគិតដល់គតិត្រង់ចំណុចមួយថា "បើយើងនឹងបាញ់វង់ឯណានីមួយ យើងត្រូវសម្លឹងមើលវង់នោះឱ្យច្បាស់ ហើយយើងដាក់មុខព្រួញឱ្យខ្ពស់ជាងវងនោះបន្តិច ដើម្បីការពារនូវកម្លាំងឆក់ស្រូបនៃពិភពលោកដែលតែងតែទាញស្រូបនូវវត្ថុធាតុទាំងអស់ឱ្យទាបចុះមក។ គ្រាប់ព្រួញឬគ្រាប់កាំភ្លើងអាចធ្លាក់ចុះចំវង់ ដែលយើងបាញ់តម្រង់ តែបើយើងដាក់គ្រាប់ស្មើនឹងវង់ឬចំវង់តែម្តងគ្រាប់អាចរត់ខុសមិនត្រង់វង់ទេ យើងទាំងឡាយប្រាថ្នានូវរបស់ដែលជាកំពូលនៃសេចក្តីប្រាថ្នាដូចៗគ្នា តាមធម្មតា យើងគ្រប់គ្នាសម្លឹងមើលសូន្យទាបជាងចំណុចកំពូលនៃសេចក្តីប្រាថ្នាជាស្រេចទៅហើយ គឺយើងសម្លឹងមើលសេចក្តីសុខរបស់មនុស្សលោកដែលផ្សំលាយដោយ **លាភៈ យសៈ បសំសៈ សុខ** រហូតដល់សេចក្តីសុខដែលបានមកចាកកិលេសធម៌...... សេចក្តីឆក់ស្រូបរបស់លោកនេះមានកម្លាំងណាស់ ទើបវាអាចអូសទាញចិត្តរបស់មនុស្សយើងឱ្យធ្លាក់ទាបចុះជាងចំណុចកំពូលនៃសេចក្តីប្រាថ្នារបស់លោកយ៉ាងច្រើនទាបចុះមកលុះដល់ចំណុចនៃសេចក្តីទុក្ខ ដូចដែលយើងថ្ងូរផងគ្នារាល់ៗ ថ្ងៃនេះ ។

**ធ** = បើដូច្នេះ លោកតាមានបំណងយ៉ាងណាក្នុងរឿងនេះ ?

**និ** = ក្នុងឋានៈ ជាមិត្តរួមសុខទុក្ខផងគ្នា លោកតាសូមស្នើថា យើងទាំងអស់គ្នាគួរតែនាំគ្នាសម្លឹងមើលចំណុចទីដៅថ្មី គឺសម្លឹងមើលចុងផ្លូវរបស់យើង ដែលព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ស្វែងរកឃើញហើយថា : កំពូលនៃសេចក្តីប្រាថ្នារបស់យើងពុំបាននៅលើមាស ប្រាក់ ឬសម្បត្តិណាទាំងអស់ ពុំបាននៅលើបញ្ចកាមគុណ ពុំបាននៅលើលោកធម៌ ពុំបាននៅលើកិលេសធម៌ឬវត្ថុដែលជារបស់កិលេស ដូចក្នុងពេលមានកើតលោក ក៏ត្រូវស្វែងរកវត្ថុមកបម្រើលោក កើតក្រោធ ក៏ត្រូវសម្តែងបទបាទរបស់

មនុស្សក្រោធ ចេញមកខាងក្រៅជាដើម បើបានសុខព្រោះធម្មធាតុនោះជាសេចក្ដីសុខដែលនៅអាស្រ័យកិលេស មិនមែនសុខពិតប្រាកដ... កំពូលនៃសេចក្ដីប្រាថ្នារបស់មនុស្សនៅលើសេចក្ដីសុខសុទ្ធៗ មែនៗពិតៗ មិនមានចំណុះវត្ថុធាតុណាឬមិនមានទាក់ទងដល់អាមិសណាទាំងអស់ ជាសេចក្ដីសុខ កើតអំពីសន្តិស្ងប់ចាករបស់ទាំងឡាយ ដូចពោលមកហើយក្នុងខាងដើម នេះជានិរាមិសសុខ គឺសុខពិតប្រាកដនោះឯង ។

**ធ** = បើយើងតាំងសេចក្ដីប្រាថ្នាដូចនេះ តើយើងនឹងបានទទួលផលសុទ្ធតែល្អឬ?។

**និ** = មានតែល្អ មិនមានអាក្រក់ទេ គឺមានតែផ្លូវបាន មិនមានផ្លូវបង់ បានក៏បានដល់ខ្លួនឯង មិនមានអ្នកណាដទៃជាអ្នកបាន ។ កាលណាយើងតាំងចំណុចគូសដៅទុកថា កំពូលនៃសេចក្ដីប្រាថ្នារបស់យើង មិនបាននៅលើប្រាក់ មាស បញ្ចកាមគុណឬលោកធម៌ទាំងឡាយជាដើម។ កាលណារបស់ទាំងអស់នេះនៅក្រោមបង្គាប់របស់យើង វាមិនធ្វើឱ្យយើងស្ទុះស្ទាលោភលន់ស្លន់ស្លោ លុះត្រាភ្លេច ចាស់ ឈឺ ស្លាប់ យើងក៏អាចការពារនូវសេចក្ដីស្រវឹងប្រមាទក្នុងរបស់ទាំងឡាយនេះ ។ កាលណាមានទុកមានដាក់ហើយត្រូវអន្តរធានទៅវិញ យើងក៏មិនខូចចិត្តលុះដល់ថ្នាក់ស៊ីមិនបានដេកមិនបាន ព្រោះមានស្មារតីភ្ញាក់រលឹកជានិច្ចរបស់ដែលអន្តរាយទៅនោះ មិនមែនជាកំពូលនៃសេចក្ដីប្រាថ្នា បើរបស់ទាំងអស់នេះមិនមាន ក៏មិនខ្វល់ខ្វាយស្វែងរក លុះត្រាល្មើសសីលធម៌ដ៏ល្អប្រសើររបស់មនុស្ស ។ ផលដែលត្រូវបានខាងផ្លូវធម៌ គឺសេចក្ដីមិនជំពាក់ចិត្តក្នុងវត្ថុសក្ការៈ នឹងនាមធម៌ ដែលជាចំណុចគូសដៅរបស់ពុទ្ធសាសនា ។ របស់ដែលស្មើមកនេះលោកតាជឿថា ជាកំពូលនៃសេចក្ដីប្រាថ្នារបស់មនុស្សបច្ចុប្បន្នប្រសិនបើយើងមិនយកចិត្តទុកដាក់ យើងក៏មិនដឹងថាអ្វី គឺជារបស់ដែលជាកំពូលនៃសេចក្ដីប្រាថ្នា ។

★ ★ ★

# ចប់

# សៀវភៅសម្រាប់ជាធម្មតា

## ចម្លងជាថ្មីដោយខ្ញុំបាទ

ថៃ ប៊ុនឆាយ

ខ្ញុំព្រះករុណាខ្ញុំបាទសូមថ្វាយបង្គំប្រជុំបីនៃព្រះត្រៃរតន ដែលជារតនៈប្រសើរខ្ពស់ខ្ពស់បំផុតលើសលោក។ ដោយអំណាចនៃសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃនេះទើបធ្វើឲ្យខ្ញុំព្រះករុណាមានសេចក្តីព្យាយាមចម្លងសារជាថ្មីដោយគិតថាសៀវភៅនេះនិងបានជាប្រយោជន៏ដល់ជនច្រើន និងគិតថាសៀវភៅចាស់ហើយពិបាកមើលផង ដូច្នេះហើយទើបខ្ញុំព្រះករុណាចម្លងជាថ្មីជូនដល់ប្រជាជនខ្មែរយើងសិក្សា។ ដោយអំណាចនៃកុសលចេតនានេះ សូមជូនបុណ្យកុសលដែកើតមានពីការចម្លងនឹងបានពិនិត្យអានឡើងវិញនូវអក្ខរាវិរុទ្ធ ដោយសំអាងនឹងវចនានុក្រមខ្មែរ (សម្តេចព្រះសង្ឃរាជ ជួន ណាត) ក៏សូមជូនបុណ្យកុសលនេះដល់ (ភិក្ខុធម្មបាល ខៀវ ជុំ) ដែលអ្នកប្រាជ្ញបណ្ឌិត សូមលោករួចផុតចាកទុក្ខបានដល់ព្រះនិព្វាន កុំបីឃ្លាងឃ្លាតឡើយ និងសូមជូនបុណ្យលោកអ្នកមានគុណរបស់ខ្ញុំ និងបងប្អូនទាំងអស់បានរួចផុតចាកទុក្ខទាំងពួង សូមសត្វលោកទាំងអស់បានសេចក្តីសុខសព្វកាល។

ប្រគល់ជូនកេហ៍ទំព័រ ៥០០០ឆ្នាំ។

ភ្នំពេញថ្ងៃទី ១៩, សីហា, ព.ស ២៥៥៩។